សាកលវិទ្យាល័យភូមិន្ទកសិកម្ម
មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ

# សេដ្ឋកិច្ចអភិវឌ្ឍន៍

## Economics for Development

សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា
ជា សុភ:មករា

ឧបត្ថម្ភដោយ

២០២១

សាកលវិទ្យាល័យភូមិន្ទកសិកម្ម

មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ


# សេដ្ឋកិច្ចអភិវឌ្ឍន៍

# Economics for Development


សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គន្ធា

ជា សុភ:មករា


២០២១

# រក្សាសិទ្ធ

© ឆ្នាំ២០២១

**រក្សាសិទ្ធគ្រប់យ៉ាង**

គ្មានផ្នែកណាមួយនៃសៀវភៅនេះ អាចត្រូវបានថតចម្លង និងផលិតឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកនិពន្ធ និងសាកលវិទ្យាល័យភូមិន្ទកសិកម្មឡើយ។

បោះពុម្ពលើកទី១ ដោយមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍(ស.គ.ន)នៃក្រសួងអប់រំ យុវជន និងកីឡា នៅព្រះរាជាណាចក្រកម្ពុជា។

**ទំនាក់ទំនងព័ត៌មាន:**

អ្នកនិពន្ធ៖ សាស្រ្តាចារ្យរង បណ្ឌិត **ឆាយ គង្គា** និង **ជា សុភ:មករា**

ទូរស័ព្ទ៖ (+៨៥៥) ១២ ៦៨៤ ៨២៨ / ៩៨ ៦៨៤ ៨២៨

អ៊ីមែល៖ chhaykongkea@gmail.com

© 2021 by Assoc. Prof. CHHAY Kongkea, Ph.D. and Chea Sopheakmakara, All rights reserved. No part of this publication may be reproduced, stored in a retrieval system, or transmitted by any process without the prior written permission from the author and the Royal University of Agriculture.

First Edition

Printed by the Research Creativity and Innovation Fund (RCI Fund) of Ministry of Education, Youth and Sports, Kingdom of Cambodia

Enquiries about the book:

Author: Assoc. Prof. CHHAY Kongkea, Ph.D. and Chea Sopheakmakara
Mobile phone: (+855) 12 684 828 / 98 684 828
Email: chhaykongkea@gmail.com

# បុព្វកថា

ដំណើរអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងយុគសម័យទំនើបនេះ ជាមេរៀនដ៏ជោគជ័យបំផុតមួយ ដែលចាប់ឫសគល់ចេញពីការបញ្ចប់របបប្រល័យពូជសាសន៍ ការបញ្ចប់សង្គ្រាម ការផ្សះផ្សាជាតិ ការកសាងមូលដ្ឋានរឹងមាំនៃសន្តិភាពនិងស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច។ នៅក្រោយពេលដែលសន្តិភាពត្រូវបានកើតឡើងដោយបរិបូរណ៍នៅឆ្នាំ១៩៩៨ កម្ពុជាទទួលកំណើនសេដ្ឋកិច្ចខ្ពស់ គឺប្រមាណ៨% ក្នុងមួយឆ្នាំ។ លើសពីនេះទៀត អត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយពីប្រមាណ៥៣% នៅឆ្នាំ២០០៤ មកនៅទាបជាង១០% នៅឆ្នាំ២០១៩។ ដំណើរនៃការអភិវឌ្ឍជាតិជាសកម្មភាពដែលបន្តទៅមុខជាប់ជានិច្ច ហើយគោលនយោបាយថ្មីៗដែលមានលក្ខណៈអន្តរវិស័យគ្រប់ដណ្តប់ក៏កំពុងលេចរូបរាងឡើង ដើម្បីតម្រង់ទិសកម្ពុជាឆ្ពោះទៅកាន់ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានឡើងជាប្រទេសមានប្រាក់ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មពិភពលោកនិងតំបន់ រួមទាំងទំនាក់ទំនងភូមិសាស្ត្រនយោបាយ បានផ្តល់កាលានុវត្តភាពសម្រាប់ការអភិវឌ្ឍឧស្សាហកម្មនៅកម្ពុជា ដែលត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាមូលដ្ឋានគ្រឹះនៃកំណើនសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តពង្រឹងនិងអភិវឌ្ឍវិស័យអប់រំឆ្ពោះទៅរកការស្រាវជ្រាវនិងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញរបស់ធនធានមនុស្សនៅកម្ពុជា ឱ្យស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍ ជាពិសេសការពង្រឹងសហគ្រិនភាពក្នុងការរៀបចំម៉ូដែលធុរកិច្ចថ្មីៗ។ ដើម្បីចាប់យកកាលានុវត្តភាពពីបដិវត្តន៍ឧស្សាហកម្មទី៤ និងសេដ្ឋកិច្ចឌីជីថលដែលកំពុងផុសផុលឡើង ប្រព័ន្ធអេកូឡូហ្ស៊ីដែលបង្កលក្ខណៈអំណោយផលដល់ការបង្កើតថ្មី នវានុវត្តន៍ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ត្រូវតែមានការកែលម្អ។

បណ្តាប្រទេសនៅទ្វីបអាស៊ីកំពុងនាំមុខក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ដោយមានភាគហ៊ុនប្រមាណ៤៤% នៃការវិនិយោគទាំងមូលរបស់ពិភពលោក។ ប្រទេសចិនកំពុងបន្តកសាងហេដ្ឋារចនាសម្ព័ន្ធនៃការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ ក៏ដូចជាសមត្ថភាពមនុស្ស។ ផ្ទុយទៅវិញប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក កំពុងស្ថិតនៅឆ្ងាយពីការវិនិយោគនេះ ហើយជាលទ្ធផលប្រទេសទាំងនោះក៏ពុំមានកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់ដែរ។ ទុនវិនិយោគសរុបលើការស្រាវជ្រាវនិងអភិវឌ្ឍរបស់ប្រទេសនៅទ្វីបអាមេរិកខាងត្បូងនិងអាហ្វ្រិក មានប្រមាណ៥%នៃការវិនិយោគទាំងមូលរបស់ពិភពលោក ក្នុងពេលដែលតំបន់ទាំង២នេះមានប្រជាជនប្រមាណ២០%នៃប្រជាជនពិភពលោក។ ប្រទេសចំនួន៦ដែលមានលំដាប់ខ្ពស់ជាងគេនៅក្នុងការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍ រួមមានសហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ ឥណ្ឌា និងកូរ៉េខាងត្បូង ដែលស្មើនឹងប្រមាណ៧០%នៃទុនវិនិយោគសរុបរបស់ពិភពលោក។

តើចំណេះដឹង ផលិតផល និងសេវាកម្មថ្មីទាំងនេះកើតឡើងពីអ្វី? ហើយកើតឡើងដោយរបៀបណា? ព្រះរាជាណាចក្រកម្ពុជាកំពុងតែកសាងមូលដ្ឋានសម្រាប់ការត្រៀមខ្លួនទទួល និងប្រកួតប្រជែងក្នុងយុគសម័យបដិវត្តឧស្សាហកម្មទី៤ នៅក្នុងសេដ្ឋកិច្ចដែលផ្អែកលើពុទ្ធិ ហើយដែលប្រការនេះ

ចាំបាច់តម្រូវឱ្យពលរដ្ឋកម្ពុជា ត្រូវក្លាយខ្លួនជាពលរដ្ឋឌីជីថល ពលរដ្ឋសកល និងពលរដ្ឋដែលប្រកបដោយការទទួលខុសត្រូវ ដែលមានសមត្ថភាពក្នុងការផលិត ចែកចាយ និងប្រើប្រាស់ពុទ្ធិដើម្បីទទួលមនុញ្ញផល និងរួមចំណែកក្នុងកំណើន។ ធនាគារពិភពលោកបានធ្វើការកត់សម្គាល់តាំងពីឆ្នាំ ២០០២នូវបម្លាស់ប្តូរនៃមូលដ្ឋានសេដ្ឋកិច្ច ពីសេដ្ឋកិច្ចដែលពឹងផ្អែកលើកម្លាំងពលកម្ម និងធនធានអតិកម្ម (Labour and Resource Based Economy) ទៅកាន់សេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិ (Knowledge Based-Economy) ដែលក្នុងន័យនេះ ពុទ្ធិគឺជាគន្លឹះនៃការអភិវឌ្ឍ។ អាស្រ័យហេតុនេះ នៅលើគន្លងដែលកម្ពុជាកំពុងធ្វើដំណើរឆ្ពោះទៅកាន់សេដ្ឋកិច្ចឌីជីថល សង្គមកម្ពុជាត្រូវតែមានសមត្ថភាពក្នុងការផលិត ជ្រើសរើស បន្សាំ បង្កើតមុខរបរ និងប្រើប្រាស់ពុទ្ធិ ដើម្បីរក្សានិរន្តរភាពនៃកំណើន និងកែលម្អជីវភាពរស់នៅ។ សមត្ថភាពទាំងនេះ អាចកើតឡើងនៅពេលពលរដ្ឋកម្ពុជាមានឱកាសក្នុងការទទួលបានបទពិសោធន៍ពីការស្រាវជ្រាវ ការបណ្តុះគំនិតច្នៃប្រឌិត និងការស្វែងរកនវានុវត្តន៍។

កំណែទម្រង់វិស័យអប់រំ គឺជាការត្រួសត្រាយមាគ៌ាសម្រាប់ដំណើរឆ្ពោះទៅកាន់សង្គមប្រកបដោយពុទ្ធិ និងប្រជាពលរដ្ឋប្រកបដោយភាពរស់រវើក។ តាមរយៈមូលដ្ឋានអប់រំ សង្គមប្រកបដោយពុទ្ធិនឹងប្រមូលផ្តុំ បង្កើត និងចែករំលែក ទៅកាន់សមាជិកក្នុងសង្គមនូវសម្បទាអប់រំ ពិសេសគឺពុទ្ធិសម្បទាក្នុងបុព្វហេតុនៃមនុស្សជាតិនិងឧត្តមប្រយោជន៍នៃប្រទេស។ សង្គមប្រកបដោយពុទ្ធិ គឺពុំគ្រាន់តែជាសង្គមដែលសម្បូរព័ត៌មានប៉ុណ្ណោះទេ តែជាសង្គមដែលប្រជាពលរដ្ឋអាចធ្វើបរិវត្តកម្មពីព័ត៌មានទៅជាមូលធនប្រកបដោយប្រសិទ្ធភាព។ ការរីកចម្រើនទៅមុខជាលំដាប់នៃបច្ចេកវិទ្យានិងតំណភ្ជាប់ បានពង្រីកព្រំដែននៃការចូលទៅកាន់ និងការទទួលបានព័ត៌មានជាសកល ហើយដែលក្នុងន័យនេះ ការអប់រំនឹងបន្តវិវត្តទៅមុខនិងមានការផ្លាស់ប្តូរ។ សង្គមមួយដែលមានអំណាន និងរបាប់ជាបុរេលក្ខខណ្ឌនៃជីវភាពប្រចាំថ្ងៃនៃប្រជាពលរដ្ឋ ពេលនោះបំណិននៃអំណាន និពន្ធ និងការគណនាលេខនព្វន្ត គឺជាចលករនៃការរៀនរបស់សិស្ស។ ធាតុដ៏ចម្បងមួយដែលស្ថិតនៅក្នុងការកសាងសង្គមដែលប្រកបដោយពុទ្ធិគឺសៀវភៅសិក្សា ហើយការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សាជាប្រចាំ គឺជានវានុវត្តន៍នៃវិស័យអប់រំដែលនាំទៅរកការសិក្សាពេញមួយជីវិត ការអភិវឌ្ឍសម្បទាអប់រំ និងការចែករំលែកចំណេះដឹង។ មូលដ្ឋានអប់រំ ជាពិសេសគឺគ្រឹះស្ថានឧត្តមសិក្សាត្រូវមានតួនាទីដែលប្រកបដោយការឆ្លើយតប ចំពោះតម្រូវការខាងលើនេះ។ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំត្រូវបន្តសិក្សាជាប់ជានិច្ច តាមរយៈការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ហើយដែលសៀវភៅសិក្សាទាំងនេះនឹងក្លាយជាស្ពាននៃទំនាក់ទំនងរវាងនវានុវត្តន៍នៃបច្ចេកវិទ្យា និងការរៀននិងបង្រៀននៅក្នុងថ្នាក់រៀន។

សង្គមដែលប្រកបពុទ្ធិ ក៏ជាសង្គមដែលបណ្តុះឱ្យមានរចនាសម្ព័ន្ធទន់នៃសេដ្ឋកិច្ចដែលពឹងផ្អែកលើពុទ្ធិដែរ។ ឧទាហរណ៍ជាក់ស្តែងនៃបែបផែននេះរួមមាន Silicon Valley នៃសហរដ្ឋអាមេរិក សួនឧស្សាហកម្មវិស្វកម្មអាកាសយានយន្តនិងយានយន្តនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ តំបន់ជីវបច្ចេកវិទ្យានៅក្រុង Hyderabad ប្រទេសឥណ្ឌា តំបន់ផលិតគ្រឿងអេឡិចត្រូនិកនិងសារគមនាគមន៍ឌីជីថលនៅទីក្រុង Seoul ប្រទេសកូរេខាងត្បូង ក៏ដូចជាសួនឧស្សាហកម្មថាមពល និងឥន្ទនគីមីសាស្ត្រនៃប្រទេសប្រេស៊ីល ហើយក៏នៅមានទីក្រុងនៃប្រទេសជាច្រើនទៀតនៅលើពិភពលោក។ លក្ខណៈសម្បត្តិ

នៃទីក្រុងទាំងនេះគឺការប្រើប្រាស់និន្នាការនៃការអភិវឌ្ឍដែលជំរុញ និងតម្រង់ទិសដោយចំណេះដឹង ហើយដែលចំណេះដឹងទាំងនោះកើតចេញជាដំបូងពីការវិនិយោគទៅលើគ្រឹះស្ថានឧត្តមសិក្សា ស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឧត្តមភាពនៃជំនាញជាន់ខ្ពស់ ការប្រកួតប្រជែងដោយគុណាធិបតេយ្យ និងជាពិសេសគឺការបណ្តុះវប្បធម៌អំណាននិងនិពន្ធសៀវភៅ។ ល្បឿននៃការរីកចម្រើនផ្នែកពុទ្ធិ និងបច្ចេកវិទ្យាកំពុងមានសន្ទុះលឿនជាងអ្វីដែលសិស្ស និងនិស្សិតអាចទទួលបានពីគ្រូនៅគ្រឹះស្ថានសិក្សា ដែលធ្វើឱ្យគោលដៅនៃការអប់រំនៅពេលបច្ចុប្បន្ននេះ មានការប្រឈមខ្លាំងជាងពេលណាទាំងអស់។ ឧទាហរណ៍ក្នុងមួយឆ្នាំ មានសៀវភៅជាង២,២លានចំណងជើង ត្រូវបានសរសេរនិងបោះពុម្ព ដែលក្នុងនោះប្រទេសចិនមាន៤៤០ពាន់ ចំណែកឯសហរដ្ឋអាមេរិកមាន៣០៥ពាន់ និងប្រទេសរុស្ស៊ីមាន១២០ពាន់ចំណងជើង។

ខណៈពេលដែលបច្ចេកវិទ្យាកំពុងរីកចម្រើនជារៀងរាល់ថ្ងៃ មធ្យោបាយសម្រាប់អំណានក៏មានច្រើនជម្រើសសម្រាប់សិស្ស-និស្សិត និងសាធារណៈជន រួមមានការអានសៀវភៅ ការអានលើឧបករណ៍អេឡិចត្រូនិក ការអានដោយប្រើទូរសព្ទវៃឆ្លាត និងការអានលើកុំព្យូទ័រ ដែលសុទ្ធសឹងជាមធ្យោបាយសំខាន់ៗដែលនាំអ្នកអានទាំងឡាយឱ្យសម្រេចគោលបំណងអានរបស់ខ្លួន។ ម្យ៉ាងវិញទៀត អំណានដោយប្រើមធ្យោបាយបច្ចេកវិទ្យាទំនើប ចំណាយពេលតិច ងាយស្រួលអាន និងជួយដល់បរិស្ថានមួយកម្រិតទៀត។ នាពេលបច្ចុប្បន្ន សិស្ស-និស្សិត និងសាធារណៈជនកម្ពុជាដែលស្រឡាញ់អំណានកំពុងតែប្រើប្រាស់មធ្យោបាយអំណានទាំងនេះ។ បើយើងក្រឡេកមើលទៅប្រទេសជឿនលឿន ទោះបីជាបច្ចេកវិទ្យារីកចម្រើនខ្លាំងយ៉ាងណា អំណានតាមរយៈសៀវភៅនៅតែមានសន្ទុះដដែល។ ម្យ៉ាងវិញទៀត បច្ចេកវិទ្យាអានបែបទំនើបតាមរយៈឧបករណ៍ទំនើប អាស្រ័យលើលទ្ធភាពនៃធនធានអប់រំឌីជីថល និងមាតិកាឌីជីថលគ្រប់គ្រាន់ដែលបានផលិត និងបង្ហោះចែកចាយសម្រាប់អំណាន។

ក្នុងបរិបទកម្ពុជា ជាពិសេសក្នុងបរិការណ៍នៃការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានជំរុញឱ្យមានបរិវត្តកម្មឌីជីថលនៅក្នុងអេកូស៊ីស្តែមនៃការអប់រំ ជាពិសេសការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនិងការអប់រំពីចម្ងាយ ដើម្បីលើកកម្ពស់អំណាន តាមរយៈការផលិតមាតិកាឌីជីថលដែលមានភាពចំរុះ ការកសាងសមត្ថភាពផ្នែកតំណភ្ជាប់និងវេទិកាឌីជីថល ការពង្រីកវិសាលភាពនៃមជ្ឈមណ្ឌលទិន្នន័យ និងការលើកកម្ពស់គុណភាពនៃការផលិតធនធានអប់រំឌីជីថល គួបផ្សំជាមួយការចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅរៀននៅផ្ទះ និងការចុះទៅជួបជាមួយសិស្សជាបណ្តុំនៅតាមសហគមន៍។ ក្នុងន័យលើកកម្ពស់អំណាន និងភាពសម្បូរបែបនៃធនធានសៀវភៅសិក្សា ឱ្យកាន់តែមានប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងផ្តល់ឱកាសអំណានកាន់តែច្រើនថែមទៀតដល់សិស្សានុសិស្ស និស្សិត និងសាធារណៈជន ក្រសួងអប់រំ យុវជន និងកីឡាលើកទឹកចិត្តនូវចំណុចមួយចំនួនដូចខាងក្រោម៖

១. សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងបុគ្គលិកអប់រំ សូមបន្តនិងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាខេមរភាសា

២. គ្រឹះស្ថានឧត្តមសិក្សា សូមផ្តល់លទ្ធភាពគ្រប់បែបយ៉ាង ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ និងនិស្សិតគ្រប់កម្រិតសិក្សាអាចចូលរួមអាន និងសិក្សាស្រាវជ្រាវតាមគ្រប់លទ្ធភាពជាមួយធនធានអំណាន ជាពិសេសការរៀបចំឱ្យមានពេលវេលាសម្រាប់សហសិក្សា និងអំណានក្នុងបណ្ណាល័យ

៣. សាស្ត្រាចារ្យតាមមុខវិជ្ជា និងអ្នកស្រាវជ្រាវតាមជំនាញឬវិស័យ ត្រូវរៀបចំដំណើរការរៀនបង្រៀន និងស្រាវជ្រាវដែលមានដាក់បញ្ចូលកិច្ចការស្វ័យសិក្សា សហសិក្សា ឬការស្រាវជ្រាវបណ្ណាល័យដែលតម្រូវឱ្យនិស្សិត ត្រូវអាននិងស្រាវជ្រាវជាមួយធនធានអំណាន

៤. គ្រឹះស្ថានឧត្តមសិក្សា និងមជ្ឈមណ្ឌលស្រាវជ្រាវ ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ មជ្ឈមណ្ឌលរក្សាឯកសារ ឬមជ្ឈមណ្ឌលអប់រំឌីជីថលជាដើម ដើម្បីឱ្យបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់និងនិស្សិតគ្រប់កម្រិតសិក្សាអាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែន ឆ្លើយតបតាមតម្រូវការអ្នកអាន

៥. និស្សិតគ្រប់កម្រិតសិក្សាត្រូវខិតខំនិងចំណាយពេលវេលាដើម្បីអាន និងចាត់ទុកវប្បធម៌និងអកប្បកិរិយាអំណានជាផ្នែកមួយ នៃពេលវេលានិងភាពស៊ីវិល័យនៃជីវិតប្រចាំថ្ងៃ

៦. បងប្អូនជនរួមជាតិ ដែលជាមាតាបិតា ឬអ្នកអាណាព្យាបាល សូមជួយជំរុញនិងបង្កលក្ខណៈកាន់តែច្រើនថែមទៀត ជាពិសេសការលៃលកចំណាយនៅក្នុងគ្រួសារសម្រាប់ការទិញសម្ភារៈសិក្សា សៀវភៅអាន និងឧបករណ៍សម្រាប់អំណានដល់កូនៗ ដែលចាត់ទុកជាការវិនិយោគមួយដ៏សំខាន់ សម្រាប់ បង្កើនចំណេះដឹង និងអនាគតរបស់ពួកគេ។

ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ដែលហៅកាត់ថា "មូលនិធិ ស.គ.ន." និងហៅជាភាសាអង់គ្លេសថា The Research Creativity and Innovation Fund ដែលហៅកាត់ជាភាសាអង់គ្លេសថា "RCI Fund"។ គោលដៅចម្បងនៃមូលនិធិនេះ គឺរួមចំណែកលើកកម្ពស់វប្បធម៌នៃការស្រាវជ្រាវ បំផុសគំនិតច្នៃប្រឌិត និងជំរុញការធ្វើនវានុវត្ត ដើម្បីជាប្រយោជន៍ដល់វិស័យអប់រំ យុវជន និងកីឡា ដែលឆ្លើយតបទៅនឹងទីផ្សារពលកម្ម និងសាកលភាវូបនីយកម្ម។ មូលនិធិ ស.គ.ន. បានសម្រេចកំណត់ប្រធានបទ ជាអាទិភាពសម្រាប់ការគាំទ្រដោយមូលនិធិចំនួន៣ រួមមានឌីជីថលនីយកម្មសម្រាប់បដិវត្តឧស្សាហកម្ម៤.០ (Digitalization for IR.4.0) ការស្រាវជ្រាវអនុវត្តលើវិស័យកសិកម្ម (Applied Agricultural Research) និងការស្រាវជ្រាវគរុកោសល្យសតវត្សទី២១ (21st Century Pedagogy Research)។

ដោយមានការធ្វើអាទិភាពូបនីយកម្មទៅលើទិសដៅ នៃការប្រើប្រាស់ថវិកាមូលនិធិសម្រាប់ឆ្នាំ២០២០ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ការគាំទ្រដល់ការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សា (Text book) ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ គោលបំណងនៃការរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា គឺដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រីកសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូនដល់និស្សិត

ដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ លើសពីនេះទៀត ការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា មានគោលដៅដូចខាងក្រោម ៖

១. ឆ្លើយតបជាបន្ទាន់ចំពោះការខ្វះខាតធនធានសិក្សា ដែលជាតម្រូវការសិក្សារបស់និស្សិតនៅកម្រិតឧត្តមសិក្សា

២. លើកកម្ពស់ទំនើបភាវូបនីយកម្ម និងឧត្តមានុវត្តន៍នៃការរៀននិងបង្រៀន និងការស្រាវជ្រាវនៅលើមុខវិជ្ជា កម្មវិធីសិក្សា ឬមុខជំនាញជាក់លាក់

៣. បង្កើនភាពស៊ីជម្រៅក្នុងការកសាងវិជ្ជាជីវៈនិងបទពិសោធន៍សម្រាប់បាឋកសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ

៤. រួមចំណែកដល់ការកសាងភាពជាសហគមន៍វិជ្ជាជីវៈ ការចែករំលែកបទពិសោធន៍ និងវប្បធម៌នៃការរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា។

ក្រសួងអប់រំ យុវជន និងកីឡា បានវាយតម្លៃខ្ពស់ចំពោះការបោះជំហានប្រកបដោយមនសិការវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងបុគ្គលិកអប់រំទាំងអស់ ក្នុងការរៀបចំ រៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដើម្បីបង្កើនបរិមាណ លើកកម្ពស់គុណភាព និងពង្រឹងសមធម៌នៃធនធានសិក្សាជាខេមរភាសា ជូននិស្សិតដែលកំពុងបន្តការសិក្សា និងត្រៀមខ្លួនធ្វើការស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សាជាផ្នែកមួយនៃការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា និងជាធនធានសិក្សាដែលជាមូលដ្ឋានមួយដ៏សំខាន់ ក្នុងការគាំទ្រដល់ការបង្រៀន និងរៀន ហើយត្រូវមានបរិមាណគ្រប់គ្រាន់ ឆ្លើយតបទៅនឹងកម្មវិធីអប់រំ និងតម្រូវការសិក្សាស្រាវជ្រាវ។ ជាគោលការណ៍ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវមានសៀវភៅសិក្សាដែលប្រើជាគោលសម្រាប់មុខវិជ្ជានីមួយៗ។ ចំនួនសៀវភៅសិក្សាដែលគ្រប់គ្រាន់សម្រាប់ការស្រាវជ្រាវ និងការសិក្សារបស់និស្សិត ត្រូវមានយ៉ាងតិចមួយចំណងជើងក្នុងមួយមុខវិជ្ជា ហើយត្រូវតែម្កល់យ៉ាងតិច២ច្បាប់នៅក្នុងបណ្ណាល័យ ឬអាចរកបានតាមប្រព័ន្ធអេឡិចត្រូនិក។ ក្រសួងអប់រំ យុវជន និងកីឡា លើកទឹកចិត្តបន្ថែមទៀតជូនដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលបានស្នើសុំថវិកាមូលនិធិ ស.គ.ន រួច សូមចូលរួមបន្ថែមទៀតដើម្បីបង្កើនចំនួនចំណងជើងសៀវភៅ។ ចំណែកគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជនដែលពុំទាន់បានដាក់ពាក្យស្នើសុំថវិកាមូលនិធិ ដើម្បីរៀបរៀង និពន្ធ និងកែលម្អ សៀវភៅសិក្សានៅកម្រិតឧត្តមសិក្សា សូមរួសរាន់ចូលរួមដើម្បីជាគុណប្រយោជន៍ដល់តម្រូវការដ៏ទទូចនិងថ្លៃថ្លានៃនិស្សិតកម្ពុជាក្នុងការសិក្សា និងស្រាវជ្រាវនៅកម្រិតឧត្តមសិក្សា។

## សេចក្ដីបញ្ជាក់
## នៃមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍

សៀវភៅសិក្សានេះជាលទ្ធផលនៃការស្នើសុំអនុវត្តថវិកាមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងគម្រោងរៀបរៀង និពន្ធ និងកែលម្អសៀវភៅសិក្សា ដែលនឹងត្រូវប្រើប្រាស់នៅកម្រិតឧត្តមសិក្សា។ សៀវភៅសិក្សានេះ ត្រូវបានរៀបរៀង និពន្ធ ឬកែលម្អដោយមានការធានាអះអាងថាជាស្នាដៃរបស់អ្នកនិពន្ធផ្ទាល់ និងបានឆ្លងកាត់ត្រួតពិនិត្យ ផ្តល់យោបល់ និងវាយតម្លៃដោយក្រុមប្រឹក្សាអប់រំ ក្រុមប្រឹក្សាស្រាវជ្រាវ ឬក្រុមប្រឹក្សាដែលមានតម្លៃស្មើនៃគ្រឹះស្ថានឧត្តមសិក្សា និងតាមរយៈកិច្ចសន្យាដែលបានធ្វើឡើង និងដែលបានតម្កល់ទុកនៅមូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍។ រាល់ខ្លឹមសារ ការបកស្រាយ ឬរូបភាព ដែលមាននៅក្នុងសៀវភៅនេះ គឺជាជំហរនិងទស្សនៈផ្ទាល់របស់អ្នកនិពន្ធ ហើយពុំឆ្លុះបញ្ចាំង ឬជាតំណាងដល់មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍ នៃក្រសួងអប់រំ យុវជន និងកីឡាឡើយ។

# សេចក្តីថ្លែងអំណរគុណ


សៀវភៅ "**សេដ្ឋកិច្ចអភិវឌ្ឍន៍**" នេះអាចប្រសូត្រចេញបានក៏ដោយសារមានការចូលរួមនិង ការផ្តល់វិភាគទានយ៉ាងធំធេងពីបណ្តាអ្នកវិទ្យាសាស្ត្រ និងឥស្សរជនដែលមានបទពិសោធន៍នៅក្នុងផ្នែកស្រាវជ្រាវកសិកម្មជាច្រើនរូប។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់ការពិនិត្យ ជួយកែលម្អ អក្ខរាវិរុទ្ធ ឃ្លាប្រយោគ ខ្លឹមសារអត្ថបទ លះបង់ពេលវេលាដ៏មានតម្លៃមិនខ្លាចនឿយហត់ និងផ្តល់ជាមតិល្អៗក្នុងការរៀបចំសៀវភៅនេះដល់៖

- ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត **ង៉ោ ប៊ុនថាន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក៏ដូចជាអង្គភាពសាមី(សាកលវិទ្យាល័យភូមិន្ទកសិកម្ម)
- ឯកឧត្តមបណ្ឌិត **សាន វឌ្ឍនា** អនុរដ្ឋលេខាធិការនៃក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មូលនិធិស្រាវជ្រាវ គំនិតច្នៃប្រឌិត និងនវានុវត្តន៍
- សាស្ត្រាចារ្យរងបណ្ឌិត **ឃួន ថាវរៈ** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- លោក **ខុខ សុជាតិ** នាយករងផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
- គណៈកម្មការត្រួតពិនិត្យមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ និងគណៈកម្មការត្រួតពិនិត្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានជួយជ្រុមជ្រែងក្នុងការស្រាវជ្រាវ
- គណៈកម្មការត្រួតពិនិត្យ៖ លោកបណ្ឌិត សឹន សុទ្ធ លោកបណ្ឌិត ម៉ក់ ពុទ្ធី លោកបណ្ឌិត ឆាំង ហ៊ុយ លោកបណ្ឌិត ហែម ឡាច លោកបណ្ឌិត វង្ស ឌីណា លោក អេង លេង លោកស្រី ហ៊ូ ផល្លា លោកស្រី ឆាយ ស្រីល័ក្ខ និងលោកស្រី ឆាយ ស្រីមុំ
- អ្នកផ្តល់យោបល់នានា ក៏ដូចជាអ្នកផ្តល់ជាឯកសារយោងទាំងភាសាជាតិ និងភាសាបរទេសនានា
- ភរិយា និងកូនស្រីទាំងពីរជាទីស្រឡាញ់របស់ខ្ញុំ ព្រមទាំងមិត្តភក្តិដែលបានជួយជ្រោមជ្រែងទាំងអស់

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការដល់៖

- Prof. Dr. Joon-Keun Park, Professor Emeritus, Department of Agricultural Economics, Graduate School, Chonnam National University (CNU), Gwangju City, South Korea.
- លោកស្រី យ៉ែម ម៉ុយហ៊ីង
- កញ្ញា គង្គា សុជាតា និស្សិតឆ្នាំទី៤ ផ្នែកឱសថការីឧត្តម សាលាអន្តរជាតិ មហាវិទ្យាល័យឱសថការីនៃសាកលវិទ្យាល័យជិនណាន សាធារណរដ្ឋប្រជាមានិតចិន (International School, College of Pharmacy, Jinan University, China)។

- កញ្ញា គង្គា សិរីល័ក្ខ សិស្សថ្នាក់ទី៩ នៃសាលារៀនប៊ែលធីអន្តរជាតិ សាខាទី៩ នៃព្រះរាជាណាចក្រកម្ពុជា។

ដែលបានជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ និងឃ្លាប្រយោគ ការវាយអត្ថបទ ការរចនារូបភាព ដ្យាក្រាម និងក្រាភិចមួយចំនួនតាមកម្មវិធីកុំព្យូទ័រសម្រាប់ជាឧទាហរណ៍នៅក្នុងការគណនា និងការវិភាគទិន្នន័យនានានៅក្នុងវិធីសាស្រ្តរៀបចំតាមកម្មវិធីកុំព្យូទ័រនានាដូចជា៖ SPSS, SAS, MiniTab, GAME, ...។ល។

# អារម្ភកថា

សៀវភៅ សេដ្ឋកិច្ចអភិវឌ្ឍន៍ (Economics of Development) គឺជាសៀវភៅមួយដែលសិក្សាផ្តោតទៅលើកំណើនសេដ្ឋកិច្ចគ្រួសារ និងសង្គម ការមានកម្រិតជីវភាពធូរធារ ការមានការងារធ្វើក្នុងតំបន់ជនបទ ការកើនឡើងនៃប្រាក់សន្សំរបស់គ្រួសារ និងកំណើនវិនិយោគទុន ការកើនឡើងនៃប្រាក់ចំណូលគ្រួសារ និងការកើនឡើងនៃផលិតផលជាតិសរុប ជាដើម។ សេដ្ឋកិច្ចបរិស្ថានគឺជាបណ្តុំ ទស្សនាទាននៃទ្រឹស្តីមីក្រូសេដ្ឋកិច្ចអនុវត្តន៍ និងម៉ាក្រូសេដ្ឋកិច្ចអនុវត្តន៍ផងដែរ។

លើសពីនេះទៅទៀត នៅខាងចុងនៃសៀវភៅនេះមានជាសំណួរត្រួតពិនិត្យមេរៀន និងលំហាត់នៃសេដ្ឋកិច្ចបរិស្ថានផងដែរ។ កំណើននៃធនធានហិរញ្ញវត្ថុគ្រួសារ និងសហគ្រាសឯកជន បណ្តាលឲ្យមានការកើននៃវិនិយោគឯកជន និងភាពមានការធ្វើរបស់គ្រួសារ។ ភាពមានការធ្វើគឺជាឬសគល់នៃការរីកចម្រើននៃចំណូលគ្រួសារ ហើយវាក៏ជាឬសគល់នៃកំណើនសេដ្ឋកិច្ចជាតិ។

សៀវភៅនេះមិនមែនមានលក្ខណៈល្អបំផុតលើសសៀវភៅនានាផ្សេងទៀតនោះទេ វាគ្រាន់តែជាឯកសារស្រាវជ្រាវជាភាសាខេមរៈភាសាមួយដែលចូលរួមចំណែកក្នុងការផ្តល់ចំណេះដឹង និងជួយពង្រឹងគុណភាព សមត្ថភាពដល់និស្សិត បញ្ញវន្ត និងអ្នកសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

ខ្ញុំជឿជាក់ថា អ្នកខ្លះមានចិត្តចង់សរសេរដែរ តែកង្វះខាតជីវភាពរស់នៅ និងថវិកា អ្នកចេះដឹង និងបញ្ញវន្តជាច្រើនជាប់រវល់មមាញឹកធ្វើការឱ្យអង្គការឯកជន ក្រុមហ៊ុនអាជីវកម្មនានា អង្គការមនុស្សធម៌ ដើម្បីអ្វី គឺដើម្បីរកប្រាក់មកចិញ្ចឹមគ្រួសាររបស់គេ គេពុំបានយកចិត្តទុកដាក់ក្នុងការចងក្រងជាសៀវភៅ ឯកសារបច្ចេកទេស សម្រាប់ទុកឱ្យក្មេងជំនាន់ក្រោយនៅឡើយ។ បញ្ហាមួយទៀត អ្នកដែលទើបនឹងបញ្ចប់ថ្នាក់ឧត្តម(បរិញ្ញាបត្រ) ភាគច្រើន មានបទពិសោធន៍ផ្នែកបច្ចេកទេស និងចំណេះដឹងផ្នែកភាសាបរទេស ពុំទាន់បានជ្រៅជ្រះនៅឡើយ ដែលជាបញ្ហាមួយពិបាកដល់ការស្រាវជ្រាវរកឯកសារបច្ចេកទេស។

ខ្ញុំបាទដែលជាអ្នករៀបរៀងសៀវភៅនេះនឹងរង់ចាំទទួលនូវការរិះគន់កែលម្អក្នុងន័យស្ថាបនា និងការអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យឯកសារនេះកាន់តែមានគុណតម្លៃនិងភាពសុក្រិតថែមទៀត។ ខ្ញុំបាទសូមអភ័យទោសដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី បញ្ញវន្ត និស្សិត អ្នកស្រាវជ្រាវ និងប្រជាជនទាំងអស់ ព្រមទាំងមិត្តអ្នកអានទាំងអស់ផងដែរ ប្រសិនបើមានការខុសឆ្គងដោយអចេតនាក្នុងការប្រើឃ្លាប្រយោគ ឬកំហុសអក្ខរាវិរុទ្ធ ដែលកើតមាននៅក្នុងសៀវភៅនេះ។

ជាអវសានសេចក្តី ខ្ញុំបាទសូមជូនពរ ដល់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាង អ្នកស្រាវជ្រាវ បញ្ញវន្ត និស្សិត និងមិត្តអ្នកអានទាំងអស់សូមជួបតែនឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ

សុខៈ និងពលៈ ព្រមទាំងមានសុភមង្គលល្អប្រពៃទាំងក្នុងជីវិតផ្ទាល់ខ្លួន និងក្នុងជីវិតក្រុមគ្រួសារ ថែមទាំងមានសំណាងល្អ និងទទួលបាននូវសេចក្តីចម្រុងចម្រើនគ្រប់ពេលវេលាជានិច្ច។

ថ្ងៃសុក្រ ០១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ពស ២៥៦៥.
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១

**អ្នកនិពន្ធ**

**សាស្ត្រាចារ្យរង បណ្ឌិត ឆាយ គង្គា**

Assoc.Prof.CHHAY Kongkea, Ph.D.

# អំពីអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ សាស្ត្រាចារ្យរង បណ្ឌិត **ឆាយ គង្គា**
(Assoc. Prof. CHHAY Kongkea, Ph.D.)

**អាស័យដ្ឋាន** ៖ ភូមិសំបួរ សង្កាត់ជង្កា ខណ្ឌដង្កោ រាជធានីភ្នំពេញ

**ស្ថាប័នការងារ** ៖ មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ
សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ឯកទេស ឬមុខជំនាញ** ៖ បណ្ឌិតផ្នែក វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញសេដ្ឋកិច្ចកសិកម្ម

**ប្រវត្តិការសិក្សា៖**

- 2003-2006 Ph.D. Degree in Economics, Major in Agricultural Economics
Chonnam National University, Gwangju City, South Korea.
- 2001–2003 Master’s Degree in Economics, Major in Agricultural Economics
Chonnam National University, Gwangju City, South Korea.
- 1993-1998 Bachelor’s Degree in Economics, Major in Enterprise Management
Faculty of Law and Economics, Phnom Penh, Cambodia
[Present: Royal university of Law and Economics (RULE)]
- 1993-1996 Diplôme de Baccalauréat en sciences économiques, Faculté de droit et des sciences économiques, Royaume du Cambodge.
- 1990-1992 Diplima Up-Grading of Psychogical Pedagogy, Major in Mathematics,
Battambang Psychogical Pedagogy School, Battamabng Province.
- 1992-1993 Certificate of Preparatory Class, Institute of Economic Sciences (Present: National University of Management), Cambodia.
- 1990-1992 Diplima of Sinor Hight School, Battambang Secondary School, Battambang Province, Kingdom of Cambodia.

**បទពិសោធន៍ការងារ៖**

- 2007 - បច្ចុប្បន្ន៖ព្រឹទ្ធបុរសរង (Vice Dean) មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និង អភិវឌ្ឍន៍ជនបទ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ព្រះរាជាណាចក្រកម្ពុជា
- 2012 - បច្ចុប្បន្ន៖សាស្ត្រាចារ្យរង (Associate Professor) តាមអនុក្រឹត្យលេខ ៥៤៤ អនក្រ.តក ស្តីពីការតែងតាំងឋានៈជាសាស្ត្រាចារ្យរងជូនមន្ត្រីរាជការ និងគ្រូបង្រៀនថ្នាក់ឧត្តម ក្នុងវិស័យកសិកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា

ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ2012

- 1990 - 1992៖ជាប្រធានគណនេយ្យ នៃការិយាល័យគណនេយ្យ និងហិញ្ញវត្ថុ នៃក្រុមហ៊ុនដានីម៉ិច រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- 1998 - បច្ចុប្បន្ន៖គ្រូបង្រៀនតាមសាកលវិទ្យាល័យនានា៖ NUM, BBU, NIB, HRU, UME, …

# អំពីសហអ្នកនិពន្ធ



**នាម និងគោត្តនាម** ៖ជា សុភៈមករា

**អាសយដ្ឋានសព្វថ្ងៃ** ៖ ភូមិជន្លង សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប

**ទីកន្លែងកំណើត** ៖ ភូមិរវៀង ឃុំរវៀង ស្រុករវៀង ខេត្តព្រះវិហារ

**ស្ថាប័នការងារ** ៖ ការិយាល័យកសិ ឧស្សាហកម្ម នៃមន្ទីរកសិកម្ម-រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

**ឯកទេស ឬមុខជំនាញ** ៖- បរិញ្ញាប័ត្រជាន់ខ្ពស់វិទ្យាសាស្ត្រ ជំនាញ ការគ្រប់គ្រងកសិធុរកិច្ច (Taiwan(

- បរិញ្ញាប័ត្រជាន់ខ្ពស់ វិទ្យាសាស្ត្រ ជំនាញ គីមីជីវវិទ្យា )CNU, Korea(

## ប្រវត្តិការសិក្សា

- 2010-2012 Master’s Degree of Science, Major in Agribusiness Management, National Pingtung University of Science and Technology (NPUST), Pingtung City, Taiwan
- 2005-2007 Master’s Degree of Science, Major in Biotechnology, Chonnam National University (CNU), Gwangju City, South Korea.
- 1993-1997 Bachelor’s Degree of Science, Major in Forestry Management, Faculty of Forestry, Royal University of Agriculture (RUA), Phnom Penh, Cambodia
- 1992-1993 Certificate of Preparatory Class, Faculty of Medicine, Phnom Penh, Cambodia
- 1988-1992 Diploma of High School, KUBA Secondary School, Phnom Penh, Kingdom of Cambodia

## បទពិសោធន៏ការងារ

- 1998-2010 ៖ បម្រើការងារនៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- 2010-2013 ៖ បម្រើការងារនៅការិយ៉ាយផែនការ-ស្ថិតិ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប
- 2013-2021 ៖ បម្រើការងារនៅការិយ៉ាយកសិ-ឧស្សាហកម្ម នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប

## បទពិសោធន៏បង្រៀនពីឆ្នាំ ២០១២២០២១-

សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តសៀមរាប បាត់ដំបង និងខេត្តតាកែវ -

សាកលវិទ្យាល័យ -CUS សាខាខេត្តសៀមរាប និងកំពង់ធំ
-សាកលវិទ្យាល័យអង្គរ ខេត្តសៀមរាប។

# មាតិកា

បុព្វកថា និងសេចក្តីបញ្ជាក់នៃមូលនិធិ

ទំព័រ

សេចក្តីថ្លែងអំណរគុណ......i
អារម្ភកថា......iii
មាតិកា ......ix

## មេរៀនទី១
## សេដ្ឋកិច្ចអភិវឌ្ឍន៍ និងប្រទេសទុតិយលោក ទស្សនៈសកលលោក

១.១.តើមនុស្សមួយភាគបីរស់នៅរបៀបម៉េច?( How the other three quarters live) ..... ១
១.២.ការសិក្សាសេដ្ឋកិច្ច និងការអភិវឌ្ឍន៍...... ១
១.១.១. ធម្មជាតិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច Nature of Development Economic...... ១
១.១.២.តួនាទីយ៉ាងសំខាន់នៃតំលៃក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច ......២
១.៣. សេដ្ឋកិច្ចជាប្រព័ន្ធសង្គម ......២
១.៣.១.ប្រព័ន្ធសេដ្ឋកិច្ចបុរាណ (Traditional economic system) ......២
១.៣.២.ប្រព័ន្ធសេដ្ឋកិច្ចផែនការ (Planned economic system)......២

## មេរៀនទី២
## លក្ខណៈរួមរបស់ប្រទេសអភិវឌ្ឍន៍

២.១.ទំហំនៃប្រទេសមានភូមិសាស្ត្រ៖...... ៥
២.១.២.អាកាសធាតុ៖ ...... ៥
២.១.៣.ជលសាស្ត្រ និងទឹកជំនន់៖ ...... ៥
២.១.៤.អាងឈូងសមុទ្រថៃ៖...... ៥
២.១.៥.អាងទន្លេមេគង្គ ឬទន្លេធំ៖...... ៦
២.១.៦.ទន្លេមេគង្គលើ៖...... ៦
២.១.៧.ទន្លេមេគង្គក្រោម...... ៦
២.២.កម្រិតជីវភាពទាប...... ៦
២.២.១.ការបែងចែកប្រាក់ចំណូល ......៧
២.២.២.វិសាលភាពនៃភាពក្រក្រី ......៧
២.២.៣.សុខភាព ...... ៨
២.២.៤.ការអប់រំ...... ៨
២.៣.កម្រិតនៃផលិតផលទាប ......៨
២.៤. អត្រារីកចម្រើនខ្ពស់នៃសេដ្ឋកិច្ច ...... ៨
២.៥.កម្រិតកើនឡើងខ្ពស់នៃភាពអត់ការងារធ្វើ ...... ៩

២.៦.ការពឹងផ្អែកលើផលិតផលកសិកម្ម និងការនាំចេញផលិតផលលើកដំបូង .................. ៩
២.៧.ភាពអន់ថយ និងប្រជាជនកុះករនៃកម្ពុជា ........................................................១០

**មេរៀនទី ៣**

**ជម្រើសទ្រឹស្ដី និងអត្ថន័យ ការ អភិវឌ្ឍន៍**

៣.១.ការអភិវឌ្ឍន៍៖ អត្ថន័យ និងការវាស់វែង ............................................................ ១២
៣.១.១.ទស្សនៈឈានទៅមុខនៃការចូលរួមនៅជនបទ ....................................... ១៣
៣.២ អត្ថន័យនៃការអភិវឌ្ឍន៍ .......................................................................... ១៣
៣.៣ អត្ថន័យនៃកំណើនសេដ្ឋកិច្ច ...................................................................... ១៣
៣.៤.បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល ...............................១៤
៣.៣.១.ប្រាក់ចំណូលប្រជាជនក្នុងម្នាក់...........................................................១៤
៣.៣.២. ការកើនឡើងយ៉ាងលឿននៃចំនួនប្រជាជនសរុប ..................................១៦

**មេរៀនទី ៤**

**ប្រវត្តិសាស្ត្រវិវត្តន៍ចម្រើន និងសហសម័យ**

៤.១.ស្ថានភាពសេដ្ឋកិច្ចនៃកម្ពុជាតាមសម័យកាល ................................................... ១៧
៤.១.១.ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណន និងចេនឡា........................................ ១៧
៤.១.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ ..................................២២
៤.១.៣.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអាណានិគមបារាំង ................ ២៦
៤.១.៤.ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម.................. ២៨
៤.១.៥.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យសាអារណៈរដ្ឋខ្មែរ.................... ៣០
៤.១.៦.ស្ថានភាពវិស័យសេដ្ឋកិច្ចសម័យកម្ពុជាប្រជាធិបតេយ្យ ............................ ៣០
៤.២.យោបល់រួមស្ដីពីប្រវត្តិសេដ្ឋកិច្ច ឆ្នាំ ១៩៧៩-១៩៩១ .........................................៣៣
៤.២.១.ការស្ដាបនាឡើងវិញ ៖ ១៩៧៩-១៩៨១ ..........................................៣៣
៤.២.២.១៩៨១-១៩៨២:ការរៀបចំឱ្យមានរបៀប និង ការចាប់ផ្ដើមបទពិសោធសង្គមនិយម.............................................................................................. ៣៤
៤.២.៣.សង្គមនិយម និងការលំបាក៖ ១៩៨៣-១៩៨៦................................... ៣៥
៤.២.៤.និន្នាការនៃការធ្វើឱ្យងើបឡើងវិញនៃសង្គមនិយមនិងជោគជ័យនៃផ្នែកឯកជន៖ ១៩៨៧-១៩៩០ ........................................................................................ ៣៦
៤.២.៥.ការបញ្ចប់នៃសេដ្ឋកិច្ចចាស់ ៖ ឆ្នាំ ១៩៩១ ..........................................៣៧
៤.៣.ទិដ្ឋភាពប្រជាសាស្ត្រទូទៅ ............................................................................ ៣៨
៤.៣.១.រចនាសម្ព័ន្ធ អាយុ និងភេទ ............................................................ ៣៨
៤.៣.២.អត្រាកត់សម្គាល់.............................................................................. ៣៩
៤.៣.៣.ការវិវដ្ដបរិមាណ..............................................................................៤១

៤.៤.ប្រជាជនសកម្ម ........................................................................................ ៤២
៤.៤.១.ប្រជាជនទីក្រុង និងប្រជាជនជនបទ ........................................................ ៤២
៤.៤.២.សារៈសំខាន់នៃប្រជាជនសកម្ម ................................................................ ៤៣
៤.៤.៣.ការបែងចែកប្រជាជនសកម្ម.................................................................... ៤៤

## មេរៀនទី ៥
## និដ្ឋភាពវប្បធម៌សង្គម

៥.១.អត្តិភាពនៃជនជាតិភាគតិច .......................................................................... ៤៧
៥.១.១.ជនជាតិវៀតណាម ................................................................................ ៤៧
៥.១.២.ជនជាតិចិន ........................................................................................ ៤៨
៥.១.៣.ជនជាតិចាម និងម៉ាឡេ.......................................................................... ៤៩
៥.១.៤.ជនជាតិភាគតិចដទៃទៀត ....................................................................... ៥០
៥.២.សារៈសំខាន់នៃព្រះពុទ្ធសាសនា ....................................................................... ៥០
៥.២.១.សាវត្តរបស់ព្រះពុទ្ធ................................................................................ ៥១
៥.២.២.ប្រជាជន ............................................................................................ ៥១
៥.៣.កម្រិតការចេះដឹង ......................................................................................... ៥២

## មេរៀនទី ៦
## ការបណ្តាក់ទុន និងការប្រើប្រាស់ប្រភពកម្លាំង

៦.១.រចនាសម្ព័ន្ធនៃផលទុនជាតិ ............................................................................ ៥៤
៦.២.កំណើននៃផលទុនជាតិ.................................................................................. ៥៦

## មេរៀនទី ៧
## កសិកម្ម ( Agriculture )

៧.១. កត្តានានានៃផលិតកម្មកសិកម្ម និងរចនាសម្ព័ន្ធដីធ្លីកសិកម្ម ................................. ៦០
៧.២. ផលិតផលនៃផ្នែកកសិកម្ម............................................................................. ៦៣
៧.២.១.ស្រូវ.................................................................................................. ៦៤
៧.២.២.ដំណាំឱ្យផ្លែ.......................................................................................... ៦៥
៧.២.៣.ការចិញ្ចឹមសត្វ..................................................................................... ៦៥
៧.២.៤.ការនេសាទ .......................................................................................... ៦៦
៧.២.៥.កៅស៊ូ....................................................................................................... ៦៧
៧.៣. ការធ្វើពាណិជ្ជកម្ម ផលិតកម្ម កសិកម្ម .......................................................... ៦៧
៧.៣.១.សៀគ្វីប្រពៃណី ...................................................................................... ៦៧
៧.៣.២.និន្នាការកែលម្អសៀគ្វី.............................................................................. ៦៨

## មេរៀនទី ៨
## ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនឧស្សាហកម្ម


៨.១.ឧស្សាហូបនីយកម្មនៅកម្ពុជា ........ ៧០
៨.២.រចនាសម្ព័ន្ធឧស្សាហកម្ម........ ៧២
៨.៣.ឧស្សាហកម្មនានា........ ៧៤
៨.៣.១.ឧស្សាហកម្មសំណង់ និងសាធារណៈការ........ ៧៤
៨.៣.២. ឧស្សាហកម្មស្បៀង ........ ៧៥
៨.៣.៣. សាខា ថាមពល និងទឹក ........ ៧៦
៨.៣.៤. ឧស្សាហកម្មថ្នាំជក់........ ៧៦
៨.៣.៥. វិស័យឧស្សាហកម្មផ្សេងៗទៀត ........ ៧៦
៨.៤.លក្ខខ័ណ្ឌនានានៃអាជីវកម្មរបស់សហគ្រាស ........ ៧៧
៨.៥.រចនាសម្ព័ន្ធ និងការដឹកជញ្ជូន........ ៧៨
៨.៦.សេវាកម្មផ្សេងៗទៀត........ ៧៩


## មេរៀនទី ៩
## ការបម្លែងកសិកម្ម និងអភិវឌ្ឍន៍ជនបទ

Agricultural Transformation and Rural Development


៩.១.ភាពចាំបាច់នៃការពង្រីកកសិកម្ម និង អភិវឌ្ឍន៍ជនបទ (The Imperative of agricultural progress and Rural Development) ........ ៨០
៩.២.ភាពមិនទៅមុខ និងភាពលូតលាស់របស់កសិកម្ម (Agricultural Stagnation and Growth). ........ ៨១
៩.៣.រចនាសម្ព័ន្ធនៃបណ្ដាប្រទេសគពីយលោកដែលពឹងពាក់លើកសិកម្ម ........ ៨២
(The structure of Third world Agrarian systems) ........ ៨២
៩.៣.១.ទម្រង់ពីរបែបនៃកសិកម្មពិភពលោក (Two kinds of world Agriculture) ៨២
៩.៣.២.ចំពោះប្រទេសប្រទេសមិនទាន់អភិវឌ្ឍន៍........ ៨២


## មេរៀនទី ១០
## ការអប់រំ និងការអភិវឌ្ឍន៍ (Education and Development)


១០.១.ការអប់រំ និងធនធានខុស (Education and human resource) ........ ៨៧
១០.២.អប់រំ ក្នុងតំបន់អភិវឌ្ឍន៍ (A Profile of Education in developing regions) ........ ៨៨
១០.២.១.ចំណាយសាធារណៈលើវិស័យអប់រំ (Public Education Expenditure). ៨៨
១០.២.២. ការចុះឈ្មោះចូលរៀន(The Enrollment) ........ ៨៨
១០.២.៣. ការចេះអានសរសេរ (Literacy)........ ៨៩

១០.៣. ការអប់រំសង្គម និងការអភិវឌ្ឍន៍ ( Education Society and Development )......៩១
១០.៣.១.ការអប់រំ និងការរីកចម្រើននៃសេដ្ឋកិច្ច (Education and Economic Growth ) ....................................................................................................៩១
១០.៣.២.ការអប់រំ ភាពមិនស្មើភាព និងភាពក្រីក្រ (Education, inequality, and Poverty )...................................................................................................... ៩២
១០.៤.ការអប់រំ ការផ្លាស់ទីលំនៅក្នុងប្រទេស ( Education, internal migration ).......... ៩៣
១០.៥.ការអប់រំ និងការអភិវឌ្ឍន៍ជនបទ( Education and Rural Development ) ......... ៩៣
១០.៦ អប់រំ និងការផ្លាស់ប្ដូរទីលំនៅអន្តរជាតិ ( Education and international Migration )៩៤

## មេរៀនទី ១១
## ហិរញ្ញវត្ថុសាធារណៈ

១១.១. ការចំណាយសាធារណៈ ..........................................................................៩៦
១១.១.១.ការចំណាយតាមហិរញ្ញវត្ថុ .................................................................៩៦
១១.១.២.ការចំណាយនៃការប្រព្រឹត្តិទៅនៃកិច្ចការរដ្ឋបាល................................. ៩៧
១១.២. បំណុលសាធារណៈ ...............................................................................៩៨
១១.២.១.រចនាសម្ព័ន្ធ ចំណូល ........................................................................៩៨
១១.២.២.ពន្ធអាករ ..........................................................................................៩៩

## ជំពូកទី ១២
## គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច ( Rural Development Policy )

១២.១.ទំហំនៃគោលនយោបាយអភិវឌ្ឍន៍ជនបទ..................................................១០២
១២.២ សនិទានភាពនៃបទអន្តរាគមន៍របស់រដ្ឋាភិបាល ......................................... ១០៣
១២.៣ ស្ថានភាពនៅទីជនបទ ........................................................................... ១០៣
១២.៣.១បញ្ហាក្នុងការអភិវឌ្ឍន៏នៅជនបទ ..................................................... ១០៤
១២.៣.២.បណ្តុំនៃអត្រាប្រជាជននៅជនបទមានលក្ខណៈមិនរៀបរយ ................ ១០៤
១២.៣.៣.សេដ្ឋកិច្ចមិនឃ្លាតឆ្ងាយទេ ............................................................ ១០៤
១២.៣.៤.ភាពស្មើគ្នានៃមធ្យោបាយសេវាកម្មសាធារណៈ.................................. ១០៥
១២.៣.៥.ការកំណត់គោលដៅកម្មវិធីនៅជនបទ ............................................. ១០៥
១២.៣.៦.សុវត្ថិភាពចំពោះប្រជាជន និងទីកន្លែងសម្រាប់ការរស់នៅ.................. ១០៥
១២.៣.៧.គុណសម្បត្តិក្នុងការបំពេញប្រាក់ក្នុងពាណិជ្ជកម្ម ............................. ១០៦
១២.៣.៨.ការទប់ទល់ក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធសង្គម............................ ១០៦
១២.៤ កសិដ្ឋាន/ជនបទ .................................................................................១០៧
១២.៥.ទស្សនៈមិនត្រឹមត្រូវរបស់ប្រជាជននៅតាមតំបន់ជនបទ ............................. ១០៨
១២.៦.ការកំណត់និយមន័យនៃការអភិវឌ្ឍន៍ជនបទ.............................................. ១០៨

១២.៧ ជម្រើសនៃគោលនយោបាយអភិវឌ្ឍន៍ជនបទ .......... ១០៩
១២.៧.១.ការអប់រំ .......... ១០៩
១២.៧.២.សាលាហិរញ្ញវត្ថុប្រពៃណី .......... ១១០
១២.៧.៣.សុខភាពជនបទ .......... ១១១
១២.៨. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត .......... ១១៤
១២.៩.ការអភិវឌ្ឍផ្នែកឯកជននិងការបង្កើតការងារ .......... ១១៩
១២.១០.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស .......... ១២៦
១២.១១.សកម្មភាពនិងយុទ្ធសាស្ត្រ .......... ១៣១
១២.១២.វិភាគគោលនយោបាយកសិកម្ម .......... ១៣៥
១២.១៣.គ្រោះថ្នាក់នៃការផ្លាស់ប្តូរតម្លៃនៅក្នុងទីផ្សារ .......... ១៣៥

**បណ្ណាល័យសាស្ត្រ**( Bibliography )

# មេរៀនទី១
# សេដ្ឋកិច្ចអភិវឌ្ឍន៍ និងប្រទេសទុតិយលោក ទស្សនៈសកលលោក

## ១.១.តើមនុស្សមួយភាគបីរស់នៅរបៀបម៉េច ? ( How the other three quarters live )

មនុស្សទាំងអស់នៅក្នុងពិភពលោក នៅពេលដែលភ្ញាក់ពីដំណេកនៅពេលព្រលឹមតែងតែប្រឈមមុខនឹងថ្ងៃថ្មីមួយ នៅក្រោមកាលៈទេសៈខុសៗគ្នា។ អ្នកខ្លះគេរស់នៅក្នុងផ្ទះមយយដែលមានផាសុខភាពដែលមានបន្ទប់ច្រើន គេមានម្ហូបចំណីគ្រប់គ្រាន់ដើម្បីបរិភោគ មាន សំលៀកបំពាក់ទាន់សម័យ និង មានសុខភាពល្អ និង មានភាពមិនខ្វះខាតលុយកាក់។ ជាពិសេសទៅទៀត ឳពុកម្តាយ គេអាចមានគ្រប់គ្រាន់ក្នុងការអប់រំ និងបណ្តុះបណ្តាលកុនចៅគេទៀតផង។ ប៉ុន្តែមនុស្សមួយចំនួនធំ ប្រហែលជាច្រើនជាង ៣ ភាគ៥ នៃប្រជាជនពិភពលោក ៥៣ កោដ៏ បានជួបវាសនាដ៏អកព្វ គឺពួកគេរស់នៅដោយគ្មានំរក ឬ មានតែបន្តិចបន្តួចប៉ុណ្ណោះ គ្មានម្ហូបចំនីផ្គត់ផ្គង់គ្រប់គ្រាន់ សុខភាពមិនល្អ អវិជ្ជា គ្មានការងារធ្វើ ជីវិតរបស់គេអាប់អួរ ជាទីបំផុត។

## ១.២.ការសិក្សាសេដ្ឋកិច្ច និងការអភិវឌ្ឍន៍

ការសិក្សាសេដ្ឋកិច្ចអភិវឌ្ឍន៍ គឺជាការសិក្សាមួយថ្មី គួរជាទីចាប់អារម្មណ៍និងជាមែកជាងមួយដ៏ទូលាយនៃសេដ្ឋកិច្ច និង សេដ្ឋកិច្ចនយោបាយ។ Adam smith ជាអ្នកសេដ្ឋកិច្ចអភិវឌ្ឍន៍ទី១ ជាអ្នកត្រួសត្រាយទី១ លើសេដ្ឋកិច្ចអភិវឌ្ឍន៍ និងជាអ្នកមានចិត្តសិក្សាលើបញ្ហា និងដំណើរការសេដ្ឋកិច្ចអភិវឌ្ឍន៍ក្នុងប្រទេស Africa, Asia, and Latin America ដែលកើតឡើងតាំងពី៤ ទសវត្សមុន។ អ្នកខ្លះប្រកាសថាសេដ្ឋកិច្ចមិនមែនជាមែកជាងច្បាស់លាស់នៃសេដ្ឋកិច្ចក្នុងទស្សនៈដូចគ្នានោះទេ ដូចជា ម៉ាក្រូសេដ្ឋកិច្ច សេដ្ឋកិច្ចពលករ ហិរញ្ញវត្ថុទូទៅ និងរូបិយបណ្ណ័សេដ្ឋកិច្ច ដែលគេពោលអះអាងថា គឺជាការច្របូកច្របល់គ្នាមួយ និងមូលដ្ឋាននៃការមិនកែប្រែក្នុងការអនុវត្តន៏នៃវិស័យទាំងនោះ ប៉ុន្តែវាអនុវត្ត៏ជំតែម្តងទៅលើសេដ្ឋកិច្ចនីមួយៗណៃប្រទេស Africa, Asia, and Lation America.

### ១.១.១. ធម្មជាតិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច Nature of Development Economic

ប្រពៃណីសេដ្ឋកិច្ច វាទាក់ទងជាដមបូងលើសមត្ថភាព ឬ ភាពផ្តល់ផលល្អ, តំលៃមិនចាំបាច់ក្នុងការចែករំលែកនុវធនធានដែលអោយផលដោយកម្រ ហើយទាក់ទងជាមួយការរីកចម្រើនដ៏ល្អបំផុតនៃធនធានទាំងនោះ។

ប្រពៃណីសេដ្ឋកិច្ចមានន័យ Traditional Neoclassical Economic ដែលជាសេដ្ឋកិច្ចមូលធនដែលកំណត់លក្ខណៈដោយអធិបតេយ្យភាពនៃអ្នកប្រើប្រាស់ លទ្ធភាពនៃការរកប្រាក់ចំណេញអតិបរិមាណ សហគ្រាសឯកជន និង សុក្រិតភាពនៃការប្រកួតប្រជែង។ វាសង្កត់ធ្ងន់ទៅលើសមត្ថភាពនៃការ

ចែកផ្តល់ធនធានដែលក្រ តាមប្រព័ន្ធតំលៃ និងកម្លាំងនៃការផ្គត់ផ្គង់ និងតំរូវការ។ មានន័យថា ត្រូវតែផលិតនូវផលិតផលដែលមានតំលៃអតិបរិមា ដែលអាចធ្វើទៅបាន ដោយប្រើបច្ចេកទេសនៃការផលិត ដែលតំលៃអប្បបរិមា និង ពិចារណា លើប្រសិទ្ធភាពនៃតំរូវការទីផ្សារ។

សេដ្ឋកិច្ចនយោបាយដើរហួសប្រពៃណីសេដ្ឋកិច្ច សង្គម និង ស្ថាប័ន ដោយឆ្លងតាម រយៈក្រុមអ្នកសេដ្ឋកិច្ច និងក្រុមអ្នកនយោបាយដ៏ឆ្នើមដែលមានសមត្ថភាពលើការបែងចែករំលែកធនធានដែលកម្សត់នាពេលបច្ចុប្បន្ន ហើយក្នុងពេលអនាគត គឺដោយសារភាពមិនចុះសម្រុងគ្នានូវផលប្រយោជន៍ផ្ទាល់របស់គេ ឬ ក៏ទាក់ទងទៅនឹងទំនាក់តំនងរវាងនយោបាយ និងសេដ្ឋកិច្ច ដោយយកចិត្តទុកដាក់លើតួនាទីនៃអំនាចក្នុងការធ្វើសម្រេចិត្ត។

### ១.១.២.តួនាទីយ៉ាងសំខាន់នៃតំលៃក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច

សេដ្ឋកិច្ចជាវិទ្យាសាស្ត្រសង្គមមួយ។ សេដ្ឋកិច្ចទាក់ទិនទៅនិងកាតស្ថិតស្ថេរនៃមនុស្សជាតិ និងប្រព័ន្ធសង្គមដូចគ្នា។ ដូចបានបញ្ជាក់ខាងលើ ក្នុងផ្នែកសេដ្ឋកិច្ច អាចនិន្នាការ និងការប្រែប្រួលយ៉ាងធំធេងទៅតាមស្ថានការ វប្បធម៌ ពេលវេលារបស់ប្រទេសនីមួយៗ។

## ១.៣. សេដ្ឋកិច្ចជាប្រព័ន្ធសង្គម

ប្រព័ន្ធសេដ្ឋកិច្ចពិភពលោកចែកចេញជា ៤៖

### ១.៣.១.ប្រព័ន្ធសេដ្ឋកិច្ចបុរាណ (Traditional economic system)

សេដ្ឋកិច្ចបុរាណ ជាប្រព័ន្ធសេដ្ឋកិច្ចដែលពឹងផ្អែកលើមូលដ្ឋានប្រពៃណី ទំនៀមទំលាប់ សហគមន៍ គ្រួសារ ឬ សាសនា។

ប្រព័ន្ធសេដ្ឋកិច្ចបុរាណមានភាពពេញនិយមជាសេដ្ឋកិច្ចដើម ឬ មិនអភិវឌ្ឍន៍នោះឡើយ ដែលមានឧបករណ៍និងបច្ចេកទេសហួសសម័យ ។

ប្រព័ន្ធសេដ្ឋកិច្ចបុរាណ គឺពាក់ព័ន្ធនិងការពង្រីកការផលិតក្នុងវិស័យ កសិកម្មដើម្បីផ្គត់ផ្គង់ជីវភាព។

### ១.៣.២.ប្រព័ន្ធសេដ្ឋកិច្ចផែនការ (Planned economic system)

ក្នុងប្រព័ន្ធសេដ្ឋកិច្ចផែនការឬសេដ្ឋកិច្ចបញ្ជា អាជ្ញាធរកេណ្តាលរដ្ឋាភិ)បាលគឺជាអ្នកកំណត់ ( ដំណើរការប្រព្រឹត្តិទៅនៃសេដ្ឋកិច្ច និង ជាអ្នកធ្វើ សេចក្តីសំរេចចិត្ត ថាតើត្រូវផលិតអ្វី? ផលិតយ៉ាងដូចម្តេច ? បែងចែក យ៉ាងដូចម្តេច ? នរណាជាអ្នកទទួលយក ?

ក្នុងប្រព័ន្ធសេដ្ឋកិច្ចបញ្ជា អាជ្ញាធរកេណ្តាលតែងតែដាក់ចេញនូវគំរោង ផែនការស្មុគ្រស្មាញ និងមានលក្ខណៈល្អិតល្អន់ក្នុងការប្រព្រឹត្តិទៅនៃខឿនសេដ្ឋកិច្ចជាតិ ។

ប្រព័ន្ធសេដ្ឋកិច្ចផែនការ ត្រូវបានអនុវត្តន៍ច្រើនកាលពីជាងមួយទស្ស វត្សមុន តែបច្ចុប្បន្ននេះ ប្រទេសដែលអនុវត្តន៍ប្រព័ន្ធសេដ្ឋកិច្ចផែនការនេះ ដូចជាប្រទេសចិន គូបា...បានងាកចេញមកអនុវត្តន៍ ប្រព័ន្ធសេដ្ឋកិច្ច ទីផ្សារវិញ ។

## ក.ការជ្រើសរើសចំនាត់ថ្នាក់របស់ប្រទេសកំពុងអភិវឌ្ឍន៍

ជាសមាជិកនៃអង្គការសហប្រជាជាតិដែលជាប្រតទសទុតិយលោក។ ១៤៤ មានប្រទេស នៅពេលដែលប្រទេសភាគច្រើន ស្ថិតក្នុងភាពក្រីក្រ គសបានបែងចែកដាច់ពីគ្នា នូវវប្បធម៏ លក្ខខណ្ឌសេដ្ឋកិច្ច និងនយោបាយ។ នៅក្នុងប្រទេសទុតិយលោក មានប្រព័ន្ធចំណាត់ថ្នាក់ ៣៖

១ប្រព័ន្ធចំណាត់ថ្នាក់ធ្វើឡើងដោយអង្គការសហប្រជាជាតិ .

ដោយអង្គការសហប្រត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច .២

ដោយអង្គការធនាគារ។ .៣

ព្រះរាជាណាចក្រនោះ បានជួបប្រទះនឹងឧបសគ្គ ចាប់តាំងពីសតវត្សទី ១៣ មក នូវការបាត់លំនឹងពីរបែបដោយសារះ

ការផ្តាច់ព .កីប្រភពដើមរបស់វប្បធម៌ឥណ្ឌា ដោយសារការវាតទីរបស់ពួកមុយស៊ីនម៉ង់ នៅប្រទេសឥណ្ឌា ជាការផ្តាច់ចេញតាមរយៈការឆ្លងកាត់ពីសាសនាព្រហ្មញ្ញ មកកាន់ព្រះពុទ្ធសាសនា ថេរវាទ និងពីការផ្លាស់ប្តូរនៃការប្រើប្រាស់អក្សរ ពីសំស្ក្រឹត មក ភាសាបាលី ។ល។

ការគាបសង្កត់ ពី ពួកចោរព្រៃ គឺពួកសៀម។ .ខការប្រយុទ្ធគ្នានៅសមរភូមិអង្គរ បានបង្កនូវវិនាសកម្ម ដល់ប្រព័ន្ធធារាសាស្រ្តយ៉ាងធ្ងន់ធ្ងរ។

សរុបមក អ្វីទាំងអស់បាននាំទៅដល់ជាបឋមនូវការផ្លាស់ប្តូរនូវមនោគមវិជ្ជានៃរាជវង្ស ជានិមិត្តរូបមានជំនឿរឿងព្រះបាទត្រសក់ផ្អែម បន្ទាប់មកមានការផ្លាស់ប្តូរទីតាំងមូលដ្ឋាននយោបាយ និងកសិកម្ម នៃព្រះរាជាណាចក្រ មកកាន់ដីសណ្តរនៃទន្លេមេគង្គ នៅជ្រុងម្ខាង ជិតអតីតអាណាចក្រហ្វូណន នាសតវត្សទី ១៤ ។

នៅដំណាក់កាលនោះ ប្រពណី នយោបាយ និងវប្បធម៌ខ្មែរ បានស្ថិតនៅចន្លោះរវាងមួយផ្នែកប្រពណី ប្រវត្តិ សាស្រ្តរបស់ខ្លួន និងឡូហ្សិកនៃសង្គមកសិកម្មសម័យអង្គរ ហើយមួយផ្នែកទៀត មកជាការចាំបាច់ជានា ដែលត្រូវចងភ្ជាប់ជាមួយអតីតប្រពៃណីពាណិជ្ជកម្មផ្លាស់ប្តូរ ជាមួយបរទេសនៃសម័យហ្វូណន។ ជាភស្តុតាងនៃ ទំនាស់ទាំងនោះ គឺការលេចឡើងនៅការចាយប្រាក់នាសតវត្សទី ១៦ និងបង្កហេតុនៃឧបករណ៍សេដ្ឋកិច្ច ដ៏រស់ រវើកនេះ នៅតែស្ថិតនៅឯកកោ ពីទម្លាប់ខ្មែរបុរាណ ស្របទៅនឹងរូបភាព ដុយអាលីស ដែលការអភិវឌ្ឍទាំងផ្នែក បុរាណ និងសម័យ។

តាំងយូរយារណាស់មកហើយ លុយរៀលខ្មែរបានខ្ចីឈ្មោះលុយបរទេសមកសម្របតាម គឺសម្របតាមលុយរៀល ពួកអេស្ប៉ាញ៉ុលដែលជិះសំពៅមកធ្វើជំនួញនៅកម្ពុជា ហើយក៏ជាការលើកទឹកចិត្តដែរដល់

ដែលយកប្រាក់មកប្រើប្ ១៦ អ្នកសេដ្ឋកិច្ច សម័យសតវត្ស ទីរាស់ចាយវាយក្នុងផ្នែកសេដ្ឋកិច្ច ធ្វើឱ្យប្រជាជននៃសង្គមស្ថិតនៅក្នុងស្ថានភាពជាប់ទាក់ទងតិច ឬច្រើនជាមួយពួកបរទេស ដូចជា ចិន ម៉ាឡេ ជប៉ុន ពៃក្ស ហូឡង់ ព័រទុយហ្គេ និងបរទេសដទៃទៀត។

កម្ពុជាស្ថិតក្នុងទំនាស់បែបនេះ ដែលនាំទៅដល់ការឱ្យនិយមន័យ តុល្យការនឹងនមួយ ដែលពួកឈ្លានពានដូចជា ពួកវៀតណាម និងពួកថៃ មិនព្រមបញ្ឈប់នូវការឈ្លានពាននេះ តាំងពីសតវត្សទី ១៧ តាម រយៈការកេងប្រវញ្ច័យកទឹកដីខ្មែរ មិនឈប់ឈរ។

១៩ នៅក្នុងរយៈពេលពាក់កណ្តាលដើមសតវត្សទី ពេលដែលកម្ពុជាបានធ្លាក់ចូលទៅក្នុងដង្កាប់ប្រទេសនេះ បានត្រូវសង្គ្រោះដោយព្រះរាជវង្សពីរព្រះអង្គ គឺព្រះបាទសម្តេចព្រះអង្គច័ន្ទ ១៨០៦១៨៣៤- និងព្រះបាទអង្គឌួង ១៨៤៥ដែលព្រះអង្គទាំងពីរ បានទទួលការជោគជ័យក្នុងការទាក់ទាញការ ១៩៦០- យកចិត្តទុកដាក់របស់ពួកលោកខាងលិចដែលជាអ្នកគាំពារបរទេស ក្នុងសង្គ្រាមតាមតំបន់នានារបស់ពួកគេ។ ព្រះរាជបុត្រព្រះអង្គឌួង គឺព្រះបាទសម្តេចព្រះនរោត្តម ១៨៦០បានទទួលផ្លែផ្កាពីការបើក ១៩០៤- និងព្រះរាជាណាចក្រសៀម ដែលបានចុះ ៣ ចំហ ហើយកិច្ចព្រមព្រៀងនៃអាណាចក្រ ណាប៉ូឡេអុងទី ហត្ថលេខានៅបាងកក ទើបសង្គ្រោះបាននូវប្រពៃណីរាជានិយមខ្មែរ។

# មេរៀនទី២
# លក្ខណៈរួមរបស់ប្រទេសអភិវឌ្ឍន៍

ការពិណ៌នានៃភាពរួមគ្នា របស់ប្រទេសកំពុងអភិវឌ្ឍន៍តម្រូវអោយមានការត្រួតពិនិត្យនូវសមាសភាគទាំង៧នេះ៖

## ២.១.ទំហំនៃប្រទេសមានភូមិសាស្រ្ត៖

កម្ពុជា ជាប្រទេសវាលរាប ឬខ្ពង់រាប ជាទូទៅមានកំពស់ដីរាប ហើយស្ថានភាពទឹកដី គ្មានឧបសគ្គដល់គមនាគមន៍ឡើយ។ មណ្ឌលកណ្តាលរបស់ប្រទេស មានវាលរាបដែលត្រូវទឹកលិចយ៉ាងធំ ហើយនៅតាមបរិវេណព្រំដែន មានជួរភ្នំ តែមិនសូវខ្ពស់។

### ២.១.២.អាកាសធាតុ៖

មានរបបអាកាសធាតុខ្យល់មូសុង នៃតំបន់ប្រទេសក្តៅនៅទ្វីបអាស៊ី។ កម្រិតកម្តៅ មិនផ្លាស់ប្តូរច្រើនទេនៅក្នុងរយៈពេលមួយឆ្នាំៗ លើកលែងតែនៅតំបន់ភ្នំ។ ជាមធ្យម កម្តៅប្រចាំឆ្នាំក្នុងតំបន់វាលរាប គឺ អង្សារសេ ។ នៅខែមីនា មេសា ក ២៧ ខ្ពស់ជាងម្តៅឡើងខ្ពស់ នៅខែវិច្ឆិកា ធ្នូ ជាតុអាកាសមិនសូវក្តៅទេ ហើយចន្លោះនៃការផ្លាស់ប្តូរកម្តៅ មានកម្រិតតែ ៤ អង្សារសេ ប៉ុណ្ណោះ។

### ២.១.៣.ជលសាស្រ្ត និងទឹកជំនន់៖

សារៈសំខាន់នៃទន្លេ បឹង ស្ទឹង និងចរិតរបស់វា បានត្រូវចាត់ទុកថាមានប្រយោជន៍ ដល់សេដ្ឋកិច្ចកម្ពុជា។ គម្រោងនានាក្នុងនោះមានគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម របស់គណៈកម្មាធិការទន្លេមេគង្គ បានចាត់ចែងជុំវិញបញ្ហាធ្វើឱ្យ មានតម្លៃឡើងដល់ទន្លេមេគង្គ។

### ២.១.៤.អាងឈូងសមុទ្រថៃ៖

មិនតំណាងឱ្យផលប្រយោជន៍ទេ បើពិនិត្យលើចំណុចសេដ្ឋកិច្ច៖ ជាការប្រមូលផ្តុំនូវជំរាលទឹកធ្លាក់ ដែលមានកំណើតនៅក្នុងជួរភ្នំក្រវាញ ហើយធ្លាក់ទៅក្នុងឈូងសមុទ្រថៃ។ ប៉ុន្តែវាអាចផ្តល់ជាថាមពលវារីអគ្គិសនី ដូចជាទំនប់ភ្នំកំចាយនៅខេត្តកំពត ដែលបានរៀបចំកសាងម្តងរួចមកហើយ នៅចុងទសវត្ស ឆ្នាំ ១៩៦០ ។

### ២.១.៥.អាងទន្លេមេគង្គ ឬទន្លេធំ៖

ទន្លេមេគង្គប្រវែង ៤,២០០ គ.ម. ស្រោច ស្រពកម្ពុជា ចម្ងាយ ៥០០ គដែលគេហៅថា ទន្លេធំ .ម. ។

### ២.១.៦.ទន្លេមេគង្គលើ៖

គិតចាប់ពីក្រចេះ ឡើងតាមចរន្តទន្លេមេគង្គ ដែលនាវាមិនអាចបើកបរបាន មានដុះថ្ម ពេញផ្ទៃទន្លេ ដែលអាចសង់ទំនប់វារីអគ្គិសនី មានការចាប់ផ្តើមសិក្សា តាំងពីដើមឆ្នាំ ១៩៦០ មក
នៅសម្បូរ និងស្ទឹងត្រែង ។

### ២.១.៧.ទន្លេមេគង្គក្រោម

ចាប់ពីក្រចេះ នាវាអាចបើកបរ រហូតដល់សមុទ្រ។ នៅភ្នំពេញ ទន្លេមេគង្គបានទទួលដៃទន្លេឈ្មោះទន្លេសាប ហើយក៏មានការបែកចេញជាដៃមួយទៀតឈ្មោះថា ទន្លេបាសាក់ ដែលគេហៅទន្លេទាំងនេះថា ទន្លេចតុមុខ ។

## ២.២.កម្រិតជីវភាពទាប

ទីមួយ គឺការធ្វើជំរឿន ជាគោលការណ៍លម្អិតស៊ីក្នុងប្រទេសមួយចំនួនមនុស្សប្រុស អាយុ គុណសម្បត្តិ ការបែងចែកតាមតំបន់រស់នៅ មុខរបរ និងកំណើតរបស់គេសុទ្ធតែជាកត្តានៃតួលេខ ដែលជះឥទ្ធិពលទៅលើជីវភាព និងការវិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ដោយសារសោរៈសំខាន់នោះហើយ ដែលធ្វើឱ្យយើងចាប់ផ្តើមសិក្សាអំពីប្រជាពស្រ្តនៅកម្ពុជា។

ដើម្បីធ្វើការសិក្សា គេត្រូវមានប្រភពបីសំខាន់ៗ៖ ការសន្និដ្ឋាន ការអង្កេតពីអ្នកជំណើរ លទ្ធផលអង្កេតជាផ្នែកៗ។ តែគេក៏ត្រូវយកចិត្តទុកដាក់ផងដែរ។
ស្ថានភាពនៃប្រជាជនកម្ពុជា ជាបឋមគេឱ្យនិយមន័យតាមអាយុ និងតាមភេទ។ ស្ថានភាពនោះអាច គូសវាស់តាមពីរ៉ាមីតអាយុ។ ក្នុងសំណុំពីរ៉ាមីតយោង អាយុស៊ីមេទ្រីគ្នាហើយស្របទៅតាមភេទ។ សមាសភាពនោះមានភាពធម្មតា ហើយឆ្លុះបញ្ចាំងនូវចលនាធម្មជាតិរបស់ប្រជាជននោះ។ ព្រឹត្តិការណ៍សង្គ្រាម ទុរភិក្សដែល ធ្វើឱ្យរំជួយសមាសភាពនោះ និងចលនាអន្តោប្រវេសន៍អន្តរជាតិ និងរួមចំណែកធ្វើឱ្យមានការប្រែប្រួលយ៉ាង សំខាន់ដល់រូបភាពនៃពីរ៉ាមីត។

ក្នុងការលម្អិតពីរ៉ាមីត បង្ហាញពីភាពមិនទៀងទាត់នៃតួលេខនៃជំរឿន ដែលបញ្ចោញឱ្យឃើញថាប្រជាជនមានអាយុពី ៤ ទៅ ៩ ឆ្នាំ មានចំនួនច្រើនជាងប្រជាជនមានអាយុ ០ ឆ្នាំ ដល់ ៤ ឆ្នាំ។ ការខូចខាតចន្លោះនេះ ពន្យល់ដោយឡែកបាន ដោយការប្រព្រឹត្តទៅនៃអ្នកអង្កេតនានាដែលបានរៀបចំ បែងចែកកុមារ អាយុលើសពី ៤ ឆ្នាំ និងតិចជាង ៩ ឆ្នាំ ដាក់ចូលទៅក្នុងក្រុមអាយុ ៥ឆ្នាំ ពីព្រោះថាកុមារជាច្រើន ៩-

ឆ្នាំ មិនទាន់បានចុះនៅក្នុងបញ្ជីនៅឡើយ។ ជាប្រពៃណីនៅកម្ពុជា ការរាប់អាយុគិត ១ មានអាយុក្រោម ២ឆ្នាំ ទៅហើយ។ ឆ្នាំ កន្លះ ក៏រាប់ជា ១ ត្រឹមតែពីក្បាលឆ្នាំ ទោះបីទារក ទើបនឹងកើតបានជាង

ការខ្វះចន្លោះផ្សេងទៀត គឺភាពខុសគ្នារវាងប្រជាជន អាយុពី ១០ ទៅ ១៥ ឆ្នាំ និងភាពខុសសគ្នារវាង អាយុពី ១៥ ទៅ ២០ ឆ្នាំ។ មានកុមារអាយុលើសពី ១៥ ឆ្នាំ បែរជាប្រកាសថាអាយុតិចជាង ១៥ ឆ្នាំ ដោយខ្លាច គ្មានសិទ្ធិចូលរៀន។ រចនាសម្ព័ន្ធតាមអាយុ ត្រូវបានសរុបលើតារាងបញ្ជាក់៖

| Africa | Asia | Latin |
|---|---|---|
| Tanzania -0.3 | Bangladesh 0.4 | Mexico 2.6 |
| Kenya 1.9 | India 1.8 | Guatemala 1.4 |
| Uganda -2.6 | Indonesia 4.6 | brazil 4.3 |
| Materia  -2.6 | Philippines 1.9 | Peru 0.1 |

## ២.២.១.ការបែងចែកប្រាក់ចំណូល

ដើម្បបង្កើនខ្សល់ដកដង្ហើមដោយសារតែភាពមិនច្បាស់លាស់ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីជាតិកំណើត និងបញ្ជីមរណៈភាពនៅកម្ពុជា ហើយមិនអាចយកជាមូលដ្ឋានគិតគូរ ដល់អត្រាដែលបានបញ្ជាក់ពីចលនារបស់ប្រជាជន គេយកជាការបានតែចំពោះលទ្ធផលនានានៃការអង្កេត ដែលប្រព្រឹត្តទៅនៅឆ្នាំ ១៩៥៨ ១៩៥៩ ១៩៦២ និងមុនខែឧសភា ១៩៩៣ របស់អ៊ុនតាក់។

## ២.២.២.វិសាលភាពនៃភាពក្រក្រី

ភាពក្រីក្ររីករាលដាលនិងជាប់លាប់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនគឺជាបញ្ហាដ៏ធ្ងន់ធ្ងរបំផុតមួយដែលកំពុងប្រឈមមុខនឹងពិភពលោក។ ដើម្បីកាត់បន្ថយភាពក្រីក្រឱកាសការងារច្រើនត្រូវបង្កើតសម្រាប់ជនក្រីក្រ។ ដើម្បីសំរេចគោលដៅនេះការអភិវឌ្ឍឧស្សាហកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មគឺជាគន្លឹះពីព្រោះកសិកម្មអាចផ្តល់តែឱកាសការងារមានកំណត់ហើយវិស័យសេវាកម្មអាចក្លាយជាវិស័យឈានមុខគេក្នុងដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ជាការពិតណាស់ទោះបីជាបដិវត្តបៃតងនៅអាស៊ីបានបង្កើនផលិតកម្មគ្រាប់ធញ្ញជាតិយ៉ាងខ្លាំងក៏ដោយក៏វាមានផលប៉ះពាល់តិចតួចទៅលើតំរូវការពលកម្ម ដេ)វីដនិងអូអូសាគូឆ្នាំ ១៩៩៤។ ជាលទ្ធផលវាបានបង្កើនឱកាសការងារនៅក្នុងវិស័យមិនមែន ( កសិកម្មជាជាងក្នុងវិស័យកសិកម្មដែលបានចូលរួមចំណែកដោយផ្ទាល់ដល់ការកាត់បន្ថយភាពក្រីក្រនៅ ) អាស៊ីOtsuka et al ។ , 2009) ។

### ២.២.៣.សុខភាព

សកម្មភាពភាពក្រីក្រសុខភាពគឺជាអង្គការក្រៅរដ្ឋាភិបាលមួយដែលធ្វើការដើម្បីពង្រឹងប្រជាជនក្រីក្រនិងជួបការលំបាកក្នុងការតស៊ូដើម្បីសុខភាពធ្វើឱ្យប្រជាជនដែលមានការធ្វេសប្រហែសភាគច្រើនជាអាទិភាពខ្ពស់បំផុត។

### ២.២.៤.ការអប់រំ

កំរិតខ្ពស់នៃការអប់រំត្រូវបានផ្សារភ្ជាប់ជាមួយនឹងលទ្ធផលវិជ្ជមានជាច្រើនរួមមានៈ សុខភាពនិងសុខុមាលភាពល្អប្រសើរការជឿទុកចិត្តសង្គមខ្ពស់ចំណាប់អារម្មណ៍នយោបាយកាន់តែស៊ីជម្រៅខាងអាកប្បកិរិយាខាងនយោបាយទាបនិងអាកប្បកិរិយាអវិភាពតិចចំពោះជនអន្តោប្រវេសន៍។

## ២.៣.កម្រិតនៃផលិតផលទាប

ផលិតផលមានបួនកម្រិត ៖ ស(បង្ហាញក្នុងរូបភាពខាងក្រោម)្ទូលរូបីយាយីអាចបន្ថែមនិងសន្យា។ វត្ថុនីមួយៗមានសារៈសំខាន់ក្នុងការស្វែងយល់ដើម្បីដោះស្រាយតម្រូវការរបស់អតិថិជននិងផ្តល់ជូនអតិថិជននូវបទពិសោធន៍ពេញលេញ។

កំរិតផលិតផលទាំង ៥ គឺ:

- អត្ថប្រយោជន៍ៈតំរូវការមូលដ្ឋានរឺចង់បានដែលអតិថិជនពេញចិត្តដោយការប្រើប្រាស់ផលិតផលរឺសេវាកម្ម ...
- ផលិតផលទូទៅ៖ ...
- ផលិតផលរំពឹងទុក៖ ...
- ផលិតផលមានកាលៈទេសៈ៖ ...
- ផលិតផលសក្តានុពល។

## ២.៤. អត្រាកើនចម្រើនខ្ពស់នៃសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចគឺជាការកើនឡើងនៃការផលិតទំនិញនិងសេវាកម្មនៅក្នុងសេដ្ឋកិច្ច។ការកើនឡើងនូវទំនិញមូលធនកម្លាំងពលកម្មបច្ចេកវិទ្យានិងដើមទុនរបស់មនុស្សអាចចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច។អ្នកសេដ្ឋកិច្ចយល់ស្របថាអត្រាកំណើនផលិតផលក្នុងស្រុកសរុបល្អគឺស្ថិតនៅចន្លោះពី ២ ទៅ ៣ ភាគរយ។ កំណើនត្រូវការ ៣កំណើន) ដើម្បីរក្សាអត្រាគ្មានការងារធ្វើ។ផលិតផលក្នុងស្រុកសរុប % ៤ បានកើនឡើងក្នុងអត្រាប្រចាំឆ្នាំ (ផ។ ស។ ស) ផលិតផលក្នុងស្រុកសរុប (ប៉ាន់ស្មាន.0 ភាគរយនៅក្នុងត្រីមាសនេះបើយោងតាមការប៉ាន់ស្មានជាមុនដែលចេញផ្សាយដោយការិយាល័យវិភាគសេដ្ឋកិច្ច។

កំណើនសេដ្ឋកិច្ចច្រើនតែនាំទៅរកការកើនឡើងវិសមភាពពីព្រោះកំណើនផ្តល់អត្ថប្រយោជន៍ច្រើនជាងគេព្រោះពួកគេមានទ្រព្យនិងមានការងារដែលមានប្រាក់ខែខ្ពស់បំផុត។ កំណើនខ្ពស់ទំនងជាធ្វើឱ្យរដ្ឋាភិបា ... លមានលទ្ធភាពផ្តល់ជូនរដ្ឋសុខុមាលភាពនិងផ្តល់កម្រិតផលិតកម្មអប្បបរមា។

## ២.៥.កម្រិតកើនឡើងខ្ពស់នៃភាពអត់ការងារធ្វើ

អត្រាគ្មានការងារធ្វើខ្ពស់ គឺជាសញ្ញាមួយនៃវិបត្តិសេដ្ឋកិច្ច ប៉ុន្តែអត្រាគ្មានការងារធ្វើទាបបំផុតអាចជាសញ្ញានៃសេដ្ឋកិច្ចហួសកំរិត។ ភាពអត់ការងារធ្វើ អាចត្រូវបានចាត់ថ្នាក់ជាការកកិតវដ្តរចនាសម្ព័ន្ធឬស្ថាប័ន។

ភាពអត់ការងារធ្វើ អាចនាំឱ្យមានជំងឺធ្លាក់ទឹកចិត្តការគោរពខ្លួនឯងទាបការថប់បារម្ភនិងបញ្ហាសុខភាពផ្លូវចិត្តផ្សេងទៀតជាពិសេសប្រសិនបើបុគ្គលម្នាក់ពិតជាចង់បានការងារប៉ុន្តែមិនអាចរកការងារធ្វើបាន។ ភាពតានតឹងអាចកើតឡើងដែលបណ្តាលឱ្យមានភាពតានតឹងនិងសម្ពាធលើរាងកាយ។ បញ្ហាសេដ្ឋកិច្ចៈ ក្នុងពេលអត់ការងារធ្វើគ្មានប្រាក់ចំណូលដែលនាំឱ្យមានភាពក្រីក្រ។

## ២.៦.ការពឹងផ្អែកលើផលិតផលកសិកម្ម និងការនាំចេញផលិតផលលើកដំបូង

ប្រមាណ ២៥ ភាគរយនៃផលិតផលកសិកម្មរបស់សហរដ្ឋអាមេរិកតាមតម្លៃត្រូវបាននាំចេញជារៀងរាល់ឆ្នាំ។ ក្នុងចំណោម ១០នៃប្រាក់ចំណូលដែលប្រជាជនអាមេរិកចំណាយលើអាហារជារៀងរាល់ % ភាគរយទៀតសម្រាប់អាហារដែល ៥៤ ភាគរយសម្រាប់អាហារដែលបរិភោគនៅផ្ទះនិង ៤៦ ឆ្នាំមានបរិភោគនៅឆ្ងាយពីផ្ទះ។

❖ ការពឹងពាក់លើការនាំចេញ

សម្រាប់សេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើការនាំចេញភាពប្រែប្រួលទាំងប្រាក់ចំណូលនាំចេញនិងកំណើនសេដ្ឋកិច្ចទាក់ទងនឹងវិបត្តិសេដ្ឋកិច្ចធ្វើឱ្យពួកគេងាយរងគ្រោះបំផុត។ តាមគណនីទាំងអស់កំរិតខ្ពស់នៃ ... ការផ្តោតអារម្មណ៍នៃការនាំចេញមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយនឹងភាពប្រែប្រួលកាន់តែខ្លាំងនៅក្នុងប្រាក់ចំណូលនាំចេញនិងអត្រាកំណើនសេដ្ឋកិច្ច។




ដូច្នេះនៅពេលអតិថិជនពេញចិត្តនឹងផលិតផល។ នោះមានន័យថាការលាយទីផ្សារបានដំណើរការ។ ផលិតផលគឺជាបេះដូងនៃល្បាយទីផ្សារ។ វាជាអ្វីដែលទីបំផុតបង្កើតឬបំបែកយុទ្ធនាការទីផ្សារ។ ការយល់ដឹងអំពីកម្រិតនៃផលិតផលជួយក្នុងការរចនាផលិតផលជាក់ស្តែងនិងជួយអភិវឌ្ឍល្បាយទីផ្សារ។

តួលេខនៃចំនួនប្រជាជនមធ្យមក្នុង ១ គ.ម.² នៅក្នុងកម្ពុជា គឺ ៣៤ នាក់ វាមានកម្រិតទាប តែជាការភាន់ច្រឡំមួយ។ តាមពិតប្រជាជនកម្ពុជា មានការបែងចែកកន្លែងរស់នៅមិនស្មើគ្នាទេ។ ប្រទេសនេះផ្តល់នូវទិដ្ឋភាពមានលក្ខណៈ ជាប្រទេសដែលតំបន់ខ្លះមិនសូវមានប្រជាជននៅទេ និងភូមិភាគផ្សេងទៀតសម្បូរប្រជាជនកុះករ។ ចំណុចទីមួយ និយាយដល់សារៈសំខាន់នៃការរៀបចំបែងចែកប្រជាជន និងទីពីរនិយាយសារៈសំខាន់នៃបាតុភូតនៃការរៀបចំទីក្រុង។

## ២.៧.ភាពអន់ថយ និងប្រជាជនកុះករនៃកម្ពុជា

ខុសពីប្រទេសនានានៅអាស៊ី ដូចជា វៀតណាម ឬចិន ដែលបញ្ហាប្រជាជនច្រើនកុះករ ជាមូលដ្ឋាននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រទេសកម្ពុជា មិនមែនជាប្រទេសដែលមានប្រជាជនរស់នៅច្រើនកុះករនោះទេ ហើយ នោះជាកត្តាសំខាន់មួយ។ ប្រជាជននេះនៅមិនទាន់ចែកការរស់នៅតែប៉ុណ្ណោះ។ ប្រជាជននេះមានបញ្ហាត្រង់ថា កន្លែងខ្លះមានមនុស្សរស់នៅតិច កន្លែងខ្លះទៀតមានមនុស្សរស់នៅច្រើនហួសពេក។

២/៣ នៃប្រទេសស្ថិតនៅក្នុងភាពទទេ។ ភូមិភាគឥសាន្ត ភាគខាងជើង និងនិរតី នៃប្រទេសមានចំនួន ប្រជាជនទាបជាង ៥ នាក់ក្នុង ១ គ.ម.² ជា កម្ពុជាដែលគ្មានមនុស្សរស់នៅ ។

ប៉ុន្តែនៅភូមិភាគនៃ កម្ពុជាមនុស្សកុះករ ក៏មានរបាយប្រជាជនមិនស្មើគ្នាដែរ។ នៅតំបន់វាលរាប និងខ្ពង់រាបបាសាល់ មានមនុស្សរស់នៅ ១០០ នាក់ ក្នុង ១ គ.ម.² តែឃុំជាច្រើនមានមនុស្សរស់នៅតិច

ជាង ៥០ នាក់ ក្នុង ១ គ.ម.២ ហើយឃុំផ្សេងទៀត មានមនុស្សដល់ ២០០ នាក់ ក្នុង ១ គ.ម.២។ ការបែងចែកតំបន់រស់នៅគឺយោងទៅតាមលក្ខណៈភូមិសាស្រ្តជាកំណត់ ។

គេបែងចែកតំបន់ប្រជាជនជាច្រើនតំបន់៖

- តំបន់មានប្រជាជនច្រើនកុះករនៅតាមមាត់ទន្លេមេគង្គ បាសាក់ ទន្លេសាប ដែលមានប្រជាជន ពី ២០០ ដល់ ៦០០ នាក់ ក្នុង ១ គ.ម.២ ។
- តំបន់មានមនុស្សរស់នៅច្រើន គឺអ្នករស់នៅជុំវិញបឹងទន្លេសាប និងតំបន់ខាងកើតទន្លេមេគង្គ ដែលមានប្រជាជនរស់នៅតិច ។

ភូមិសាស្រ្ត ពន្យល់មិនច្បាស់លាស់ពីការបែងចែកការរស់នៅរបស់ប្រជាជនទេ។ តំបន់ដែលមានមនុស្សរស់នៅកុះករ មិនមែនជាកន្លែងដែលមានដី និងអាកាសធាតុល្អនោះទេ។ ដីខ្សាច់គ្មានជីជាតិ និងមានអាកាសធាតុស្ងួតនៃស្រុកជាច្រើននៅខេត្តតាកែវ កណ្តាល កំពង់ស្ពឺ មានមនុស្សរស់នៅលើសពី ១០០ នាក់ ឬ២០០ នាក់ ក្នុង ១ គ.ម.២ ក្នុងពេលដែលគេឃើញមានមនុស្សតិចជាង ១០០ នាក់ ក្នុង ១ គ.ម.២ រស់នៅតំបន់ដីសម្បូរជីជាតិនៃខេត្តបាត់ដំបង។

គឺប្រវត្តិសាស្រ្តទេ ដែលទទួលខុសត្រូវចំពោះបញ្ហានេះ។ ប្រជាជនបានកើនចំនួននៅតំបន់ដែលមានការកាប់គាស់ដីដែលមិនទាន់ដាំដុះនៅជិតៗបំផុត។ ជាអ្វីដែលលោក M. Delvert ឱ្យឈ្មោះថា «ការទន្ទ្រានយកដីកម្ពុជានៅនឹងកន្លែង»។

ជាលទ្ធផល នៅតំបន់ខ្លះៗ គឺតំបន់ដែលមានប្រជាជនរស់នៅដើមសម័យអាណានិគម ហើយមិនមែនជាតំបន់សម្បូរបែបរបស់ប្រទេសទេ តែមានមនុស្សច្រើនកុះករ។ នេះជាករណីដែលស្ថិតនៅភូមិភាគខាងត្បូងក្រុងភ្នំពេញ។ មនុស្សរស់នៅច្រើនកុះករមានលេចឡើងនូវការបែងចែកដីជាផ្នែកតូចៗ ហើយមានការធ្វើអាជីវកម្ម តូចៗ ។ ពេលខ្លះមានសកម្មភាពការងារបន្ថែម ដូចជា ឡើងត្នោត និងសិប្បកម្មជនបទ ដូចជា ត្បាញសូត្រ ជាង ដែក ជាងឈើ ដែលមានផលិតភាពការងារទាប ដែលនាំឱ្យមានបាតុភាពរត់ចោលជនបទ។

នៅកម្ពុជាមិនសូវមានអន្តោប្រវេសន៍ក្នុងស្រុកទេលើកលែងតែក្នុងសម័យសង្រ្គាមឆ្នាំ ១៩៧០-១៩៧៥ និង១៩៧៥-១៩៧៩។ ការរត់ចោលភូមិស្រុកចូលទីក្រុង និងការកែនដោយអាវុធចេញពីក្រុងទៅជនបទ ដោយ សារបញ្ហានយោបាយ សេដ្ឋកិច្ច គឺជាវិនាសកម្ម និងសោកនាដកម្មនៅកម្ពុជា។ បន្ទាប់មកមានការរត់ចូលទីក្រុង ដើម្បីរកការងារធ្វើ ដែលដើម្បីដោះស្រាយអ្វីទាំងនេះ រដ្ឋត្រូវមានវិធានការបង្កើនពលកម្ម អភិវឌ្ឍន៍ជនបទ ជៀស វាងបាតុភូតខាងលើ។

# មេរៀនទី ៣
# ជម្រើសទ្រឹស្តី និងអត្ថន័យ ការ អភិវឌ្ឍន៍

ក្រោយពីបានបញ្ចប់ជំពូកនេះ លោកអ្នកនឹងយល់ដឹងពីៈ

- ការអភិវឌ្ឍន៍ៈ អត្ថន័យ និងការវាស់វែង
- អត្ថន័យនៃការអភិវឌ្ឍន៍
- អត្ថន័យនៃកំណើនសេដ្ឋកិច្ច
- បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល

## ៣.១.ការអភិវឌ្ឍន៍ៈ អត្ថន័យ និងការវាស់វែង

ការធ្លាក់ចុះនូវអត្រាប្រជាជនជនបទបញ្ហាក្នុងការអភិវឌ្ឍន៍នៅជនបទដ៏ធំបំផុតគឺទាក់ទងក្នុងការរៀបចំ នូវគម្រោងសម្រាប់ជាមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុនៅពេលអនាគត។ ដូចនេះនៅទីប្រជុំជនជួបនូវបញ្ហាហិរញ្ញវត្ថុបែប នេះហើយសហគមន៍នៅជនបទត្រូវមានទំនាក់ទំនងក្នុងការបែងចែងនូវហិរញ្ញវត្ថុ។

លំអិតពីបញ្ហានានា និងផលវិបាករបស់ពួកគេមានដូចខាងក្រោមៈ

➢ ការអភិវឌ្ឍន៍ និងគំរោងបច្ចេកទេស សកម្មភាពក្នុងការរៀបចំទីក្រុង និងជនបទគឺមានចំនុចប្រសព្វនៃសកម្មភាពរបស់រាជរដ្ឋាភិបាល។ សកម្មភាពសេដ្ឋកិច្ចជនបទគឺពង្រីកនូវទីកន្លែងដាំ ដំណាំផ្លាស់, ដូច្នេះការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅក្នុងស្រុកនានា និងសភានៃរាជរដ្ឋាភិបាលត្រូវ បង្កើតនៅក្នុងការដោះស្រាយ និងពង្រីកនូវគំរោងមូលនិធិនៅជនបទ។ មូលនិធិនេះដូចជាទិញ គ្រឿងយន្ត និងផ្តល់នូវបច្ចេកទេសនៅក្នុងគម្រោងនៃសហគមន៍ និងការរៀបចំនៅជនបទ។ ប្រសិទ្ធភាពនៃគំរោងគឺអាស្រ័យនិងការជាប់ទាក់ទងនិងប្រជាជន និងមូលនិធិ។ ផលវិបាកនៃ គម្រោងដែលទទួលបានជោគជ័យ ការពិចារណាក្នុងការគ្រប់គ្រងនៃមូលនិធិ និងបង្កើន ឱកាសក្នុងការទទួលបានជោគជ័យនូវការផ្គត់ផ្គង់មូលនិធិ។

➢ ហិរញ្ញវត្ថុផ្ទាល់ខ្លួនជាប់ទាក់ទងនិងន័យផ្សេងៗទៀតនៃការកើនឡើងនូវចំណូលដែលមានដូចជាៈការបង់ពន្ធ ការប្រើប្រាស់លុយ និងសេវាកម្មសាធារណៈផ្សេងៗទៀត។ បន្ថែមពីនេះទៅ ទៀតតម្លៃនៃការផ្តល់សេវាកម្មនានាក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅជន បទ។ ហិរញ្ញវត្ថុផ្ទាល់ខ្លួនគឺជាមធ្យោបាយផ្ទាល់ខ្លួនដែលមិនអាចទៅរួច។ ផលវិបាកដែលចំបង ជាងគេគឺជាការគេចចេញពីការជំពាក់បំណុល និងការពន្យាពេលក្នុងការអភិវឌ្ឍន៍រហូតដល់ មូលនិធិធ្លាក់ចុះមក។

➢ ប្រាក់កំចី និងការផ្តល់នូវប្រាក់កំរៃគឺមានការប្រែប្រួលមួយចំនួនពីការកសាងហេដ្ឋារចនាសម្ព័ន្ធដែលមានតម្លៃថ្លៃពេក និងគោលដៅដ៏ជាក់លាក់សម្រាប់ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន ប្រព័ន្ធស្រោចស្រព ការពារភ្លើងឆេះ ចំណតរថយន្ត ភាពងាយស្រួលក្នុងការលំហែកាយ ចំនុចចាប់ផ្តើមភាគច្រើនគឺពិបាកក្នុងសហគមន៍ជនបទដើម្បីផ្តល់ឱ្យ និងដើម្បីឱ្យ អភិវឌ្ឍន៍សេដ្ឋកិច្ច។ ប្រភពនៃប្រាក់កំចៃសាធារណៈគួរយកចិត្តទុកដាក់លើការប្រាក់តិចតួច ប៉ុណ្ណោះ។ ផលវិបាកនៃប្រាក់កំចីសាធារណៈគឺការបង្កើននូវ

ការអភិវឌ្ឍន៍សេដ្ឋកិច្ច។ មូលដ្ឋាន គ្រឹះសម្រាប់ការផ្តល់សេវាកម្មសាធារណៈចាំបាច់ដូចជាឧបករណ៍ក្នុងការអភិវឌ្ឍន៍នូវគម្រោង ការអភិវឌ្ឍន៍លើវិស័យសេដ្ឋកិច្ច។ ការងារទូទៅ និងចំណូលគឺជាបំណុលឬឥណទាននៃហិរញ្ញ វត្ថុឬបដិជាននៅក្រោមអដ្ឋាធរសម្រាប់គោបំណង ដូចជាការបង្កើតហេដ្ឋារចនាសម្ព័ន្ធ។ ផលវិ បាកនានាគឺជាសមត្ថភាពនៃកំណើនក្នុងការប្រតិបត្តិនៃគម្រោងអភិវឌ្ឍន៍ និងសេវាកម្មផ្តល់ ប្រាក់កំចីនៅអនាគត។

### ៣.១.១.ទស្សនៈឈានទៅមុខនៃការចូលរួមនៅជនបទ

នៅជំពូកនេះដែរគឺត្រូវកំណត់បាននូវចំណុចប្រសព្វនៃគោលនយោបាយអភិវឌ្ឍន៍ជនបទ អង្គការកសិករ និងកសិដ្ឋាននូវកម្រិតបន្តិចបន្តួចពីបញ្ហាគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៅសម័យនេះ។ នៅក្នុងសៀវភៅនេះយើងអាចសន្និដ្ឋានបានថាយើងអាចធ្វើបាននូវការការពារសម្រាប់ការចំណាយរបស់រាជរដ្ឋាភិ បាលលើគម្រោងកសិដ្ឋាន គឺគ្មានផលប្រយោជន៍ល្អនោះទេ។ បន្ថែមពីនេះទៅទៀតការពិភាក្សាគោលនយោលើ គោលនយោបាយប្រភពធនធាន (ជំពូក១៣)បានបង្ហាញឱ្យឃើញថាមានការកើនឡើងគឺចាប់ផ្តើមពីកសិ កម្មធ្វើការបំផ្លាញដូចគ្នានេះដែរគឺចាប់ផ្តើមបង្កើតសហគមន៍ និងទំនាក់ទំនងពាណិជ្ជកម្មក្នុងការពង្រីក ការចែក ចាយ។ ភាពច្បាស់លាស់ពីគោលបំណងនៃការអប់រំសុខភាព ទំនាក់ទំនង ហេដ្ឋារចនាសម្ព័ន្ធ អ្នកស្រុកទាំង អស់នេះជាកសិករ។ ទោះបីជាគំរោងពាណិជ្ជកម្មនៅជនទកសិករភាគច្រើនគឺអាស្រ័យលើពាណិជ្ជកម្មមិនមែន កសិកម្មដែលជាចំណូលរបស់ពួកគាត់។ ចំនួននៃការធ្លាក់ចុះនូវឱកាសការងារក្រៅកសិកម្មដូចជាមិនកើនឡើងទេ

វាសមហេតុផលដែរសម្រាប់អ្នកស្រុកទាំងអស់រាប់បញ្ចូលទាំងកសិករ អ្នកដឹកនាំគោលនយោបាយក្នុង សហគមន៍ ពាណិជ្ជករ អ្នកអប់រំ អ្នកធ្វើការក្នុងមណ្ឌលសុខភាព និងនយោជិកផ្សេងៗទៀត និងអ្នកចូលនិវត្តន៍ ហើយអ្វីដែលល្អបំផុតសម្រាប់ពួកគេដូចជាការអភិវឌ្ឍន៍ក្នុងក្រុមនូវកិច្ចការត្រូវធ្វើការពិភាក្សារបស់ពួកគេផ្ទាល់។ កិច្ចពិភាក្សាផ្តោតលើគោលនយោបាយកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ជនបទ។ ការចូលរួមដែលធ្វើ ឱ្យគោលនយោបាយមានលក្ខណៈប្រសើរឡើងនូវគោលនយោបាយជនបទ។ វា និងជួយឧបត្ថម្ភដោយក្រុម ចំរុះប្រហែលពី២៥នៃអត្រាប្រជាជននៅសហរដ្ឋអាមេរិកទាំងអស់ %។

## ៣.២ អត្ថន័យនៃការអភិវឌ្ឍន៍

ការអភិវឌ្ឍសេដ្ឋកិច្ច : គឺមិនត្រឹមតែជាកំណើននៃទិន្នផលពិតប៉ុណ្ណោះទេប៉ុន្តែ ជាការបង្ហាញពីប្រភេទខុសគ្នារវាងទិន្នផលដែលត្រូវបានផលិតកន្លងមកវាក៏រួមបញ្ចូលផងដែរនូវការកើនឡើងបច្ចេកវិទ្យាសម្រាប់ផលិតនិងបែងចែកមុខចេញ( ទំនិញនិងសេវាកម្ម )។

## ៣.៣ អត្ថន័យនៃកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចគឺជាការកើនឡើងនៃសមត្ថភាពផលិតមុខចេញឲ្យបានច្រើនជាងមុននិងមានគុណភាពល្អដើម្បីបំពេញតម្រូវការនិងចំណង់ចំណូលចិត្តរបស់មនុស្សក្នុងសង្គមនិងបង្កើនចំណូលផលិតកម្ម។ កំណើនសេដ្ឋកិច្ចត្រូវវែកញែកភាពខុសប្លែកពីការអភិវឌ្ឍន៍សេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចអាចកើតមានឡើងបើទោះជាគ្មានការអភិវឌ្ឍន៍សេដ្ឋកិច្ចក៏ដោយ។

ពេលខ្លះមានការយល់ច្រលំអត្ថន័យរវាងពាក្យកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍន៍សេដ្ឋកិច្ច។

ឧទាហរណ៍ :ប្រទេសដែលពឹងផ្អែកលើផលិតកម្មប្រេងសម្រាប់នាំចេញមានអត្រា កំណើនសេដ្ឋកិច្ចតាមរយៈការប្រើប្រាស់មុខចូលយ៉ាងច្រើនសម្រាប់ផលិតមុខចេញ(ប្រេង)ក្នុងកំឡុងពេលដែលការអភិវឌ្ឍន៍សេដ្ឋកិច្ចមានតិចតួច។

មានកត្តាជាច្រើន កើតឡើងដែលជាឧបសគ្គសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ កត្តាទាំង នោះមានដូចជា៖

ក.បរិមាណនិងគុណភាពនៃកម្លាំងពលកម្ម : តែងជះឥទ្ធិពលទៅលើការអភិវឌ្ឍ សេដ្ឋកិច្ច។ តែការកើតមានឡើងនូវកម្លាំងពលកម្មដ៏ច្រើនមិនមានន័យថាធានាដល់ការ អភិវឌ្ឍសេដ្ឋកិច្ចនោះទេដូចជាកម្លាំងពលកម្មក្នុងប្រទេសឥណ្ឌាមានការខ្វះខាតការអប់រំនិងមិនមានជំនាញ ដូចនេះធ្វើឲ្យប្រទេសនេះនៅតែឋិតក្នុងស្ថានភាពក្រីក្រ។

ខ.បរិមាណនិងគុណភាពនៃមូលធនពិត :គឺមានសារសំខាន់សម្រាប់ការអភិវឌ្ឍ សេដ្ឋកិច្ច។មូលធនពិតជាទំនិញវិនិយោគឬជាសន្និធិក្នុងទម្រង់ជាវត្ថុធាតុដើមគ្រឿងម៉ាស៊ីននិងសម្ភារបរិក្ខាររូបវន្តផ្សេងៗទៀតដែលបម្រើឱ្យការផលិតទំនិញសម្រាប់អ្នកប្រើប្រាស់។ការផ្គត់ផ្គង់នៃមូលធនពិតអាស្រ័យទៅលើកម្រិតនៃការសន្សំនៅក្នុងប្រទេសនោះដែលបង្ហាញពីខុសគ្នារវាងចំណូលនិងការប្រើប្រាស់។

គ-កម្រិតនៃការប្រើប្រាស់បច្ចេកវិទ្យា :ត្រូវបានចាត់ទុកថាជាដំណើរការដ៏ល្អ សម្រាប់កត្តាផលិតកម្មដែលទាក់ទងទៅនឹងមុខចូលនៃធនធានសេដ្ឋកិច្ចរួមមានដីកម្លាំងពលកម្មនិងមូលធន។

ឃ- បរិមាណនិងគុណភាពនៃប្រភពធនធានធម្មជាតិក៏ជាកត្តាសំខាន់ផង ដែរព្រោះថាធនធានទាំងនោះត្រូវចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។

ង .ម្យ៉ាងទៀតកត្តាវប្បធ៌មសង្គមក៏ជះឥទ្ធិពលដល់ការ អភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ ប្រទេសមួយផងដែរដូចជាសាសនា(Religion) ការចូលចិត្តរបស់ប្រជាជន (consumer tastes)ជាដើម។

## ៣.៤.បម្រែបម្រួលតម្រូវការអតិថិជន និងកំណើនប្រាក់ចំណូល

### ៣.៣.១.ប្រាក់ចំណូលប្រជាជនក្នុងម្នាក់

ប្រទេសនីមួយៗត្រូវបានចាត់ទុកថាជាប្រទេសមានការអភិវឌ្ឍតិចឬច្រើនមានឬក្រគឺអាស្រ័យទៅលើការកំណត់ពីទំហំនៃផលិតផលជាតិសរុបរបស់ប្រជាជនម្នាក់ៗដែលជារង្វាស់ជាក់ស្តែងនៃតម្លៃទំនិញនិងសេវាកម្មត្រូវបានផលិតនិងមាននៅលើទីផ្សារដោយគិតជាមធ្យមរបស់ប្រទេសនីមួយៗ។ក្នុងឆ្នាំ

១៩៩៧មាន៦៣ប្រទេសដែលមានប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងម្នាក់ចំនួន៧៨៥ដុល្លារឬតិចជាងនេះ។ប្រទេសទាំងនោះមានចំនួន៣៥ភាគរយនៃចំនួនប្រជាជនសរុបនៅលើពិភពលោកប៉ុន្តែមានតែប្រាំភាគរយប៉ុណ្ណោះនៃផលិតផលជាតិសរុបរបស់ពិភពលោក។

តារាងខាងទី3.1 ក្រោមបង្ហាញអំពីការរបស់ប្រជាជនរបស់ប្រទេសមួយចំនួន។

### តារាង៣.១.ការរបស់ប្រជាជនរបស់ប្រទេសមួយចំនួន

| Income Groups | Money per Capita GNP | Country Rank |
|---|---|---|
| **Low Income** | | |
| Bangladesh | 270$ | 106 |
| Ethiopia | 110 | 122 |
| India | 390 | 92 |
| Nigeria | 260 | 114 |
| Pakistan | 490 | 94 |
| **Lower middle** | | |
| China | 860 | 65 |
| Philippines | 1220 | 63 |
| Russian federation | 2740 | 59 |
| Ukraine | 1040 | 82 |
| **Upper middle** | | |
| Brazil | 4720 | 47 |
| Hungary | 4430 | 39 |
| Mexico | 3680 | 35 |
| Poland | 3590 | 46 |
| **High** | | |
| Canada | 19 290 | 10 |
| France | 26050 | 11 |
| Japan | 37850 | 6 |
| United States | 28740 | 2 |

Source: The World Bank, World Development Report, 1998/99( Washing, D.C: The World Bank, 1998. ),190-96

## ៣.៣.២. ការកើនឡើងយ៉ាងលឿននៃចំនួនប្រជាជនសរុប

ទោះបីជាអត្រាជាទូទៅនៃកំណើនប្រជាជនសរុបនៅលើពិភពលោកត្រូវបានថយចុះចាប់តាំងពីចុងទស្សវត្សឆ្នាំ១៩៧០ក៏ដោយក៏អត្រាតួលេខប្រជាជនសរុបទូទាំងពិភពលោកប្រចាំឆ្នាំមានការកើនឡើងគិតជាមធ្យមប្រហែល១០០លាននាក់ក្នុងមួយឆ្នាំ។ស្ទើរតែទាំងអស់នៃកំណើននេះគឺកើតឡើងនៅក្នុងប្រទេសក្រីក្រដែលក្នុងនោះអត្រាផ្តល់កំណើតកើនឡើងខ្ពស់ចំណែកអត្រាមរណភាពថយចុះ។ តារាងទី4.2 ខាងក្រោមបង្ហាញអំពីកំណើននៃចំនួន ប្រជាជនសរុបរបស់ប្រទេសមួយចំនួនពីឆ្នាំ 1980ដល់ឆ្នាំ1997។

**តារាង៣.២.កំណើននៃចំនួន ប្រជាជនសរុបរបស់ប្រទេសមួយចំនួនពីឆ្នាំ 1980ដល់ឆ្នាំ1997**

| Population ( Millions ) | 1980 | 1997 |
|---|---|---|
| **Rich Nations** | | |
| Canada | 25 | 30 |
| France | 54 | 59 |
| Japan | 117 | 126 |
| United Stated | 227 | 268 |
| **Poor country** | | |
| China | 981 | 1127 |
| India | 687 | 961 |
| Pakistan | 83 | 127 |

Source: The World Bank, World Development Report, 1998/99( Washington,D.C: The World Bank. 1998 ),194-95

ក-ភាពក្រីក្រះប្រជាជនជាងមួយពាន់លាននាក់នៃចំនួនប្រជាជនសរុបនៅលើពិភព លោក មាន ៥,៨ពាន់លាននាក់រកចំណូលបានតិចជាងមួយដុល្លារនិងប្រហែលពីរពាន់ លាននាក់រកចំណូលបានតិចជាង២ដុល្លារក្នុងមួយថ្ងៃ។

ខ-អនក្ខរភាពះក្មេងៗប្រហែល២៧៥លាននាក់នៅលើពិភពលោកស្ថិតនៅក្នុង អនក្ខរភាពដោយសារពួកគេរស់នៅក្នុងប្រទេសក្រីក្រដែលមិនមានសាលារៀន។ពួកគេនឹងក្លាយទៅជា យុវវ័យដែលមិនមានចំណេះដឹងនិងជំនាញដែលអាចប្រកួតប្រជែងជាមួយ យុវជនផ្សេងៗ ទៀតក្នុងពិភពលោកជិតមួយភាគបីនៃចំនួនប្រជាជនសរុបនៅលើពិភព លោកគឺស្ថិតនៅក្នុង អនក្ខរភាពនិងចំនួនពីរភាគបីទៀតជាស្ត្រីភេទដែលទទួលបានការអប់រំ តិចជាងបុរស។

# មេរៀនទី ៤
# ប្រវត្តិសាស្ត្រវិកចម្រើន និងសហសម័យ

ការសិក្សាប្រជាជនកម្ពុជា ត្រូវសិក្សាក្នុងនាមប្រជាជននោះធ្វើពលកម្ម។ នេះជាការគិតគូរបញ្ហាប្រជាសាស្ត្រនៅក្រោមមុំនៃសេដ្ឋកិច្ច។ ជាមតិមួយ ធ្វើយ៉ាងណាប្រមូលផ្ដុំឱ្យបាននូវតួលេខមុនឆ្នាំ ១៩៥៨ ស្ដីពីប្រជាជនសកម្ម និងតួលេខនៅឆ្នាំ ១៩៩៣ ក្រោយសង្គ្រាមជាងពីរទសវត្ស។ ប្រជាជនសកម្មនេះឯងដែលតំណាងឱ្យថាមពលពិសេសក្នុងផ្នែកសេដ្ឋកិច្ច។

## ៤.១.ស្ថានភាពសេដ្ឋកិច្ចនៃកម្ពុជាតាមសម័យកាល

### ៤.១.១.ស្ថានភាពសេដ្ឋកិច្ចសម័យហ្វូណន និងចេនឡា

#### ក.ការស្វែងយល់អំពីឬសគល់សេដ្ឋកិច្ចមុនសម័យហ្វូណន

បើយើងងាកមើល អំពីបុរប្រវត្តិសាស្ត្រខ្មែរអោយបានឆ្ងាយបន្តិច ពោលគឺក្នុងសម័យកាលមុនគ.ស (មុនពេលកកើតរដ្ឋ ហ្វូណន) និងតាមរយៈលទ្ធផលកំណាយបុរាណវត្ថុនៅស្ថានីយ៍ ស្រាវជ្រាវ) ស្ថានីយ៍ សំរោង សែន រន្លង់ផ្ដៅ និងម្លូព្រៃ (គឺបានរកឃើញនូវវត្ថុតាងជាច្រើន ខ្លះជារបស់របរប្រើប្រាស់ធ្វើពីដែក ស្ពាន់ លង្ហិន ខ្លះទៀតធ្វើរអំពីដីឥដ្ឋ ឬដុត ខ្លះទៀត ធ្វើពីឆ្អឹងសត្វ និងខ្លះទៀត ធ្វើពីថ្មរំលីង(។

ចំពោះប្រដាប់ប្រដាប្រើប្រាស់ធ្វើអំពីថ្មរំលីង គេឃើញមាន ផ្លែ ពូថៅគ្រប់យ៉ាង ពន្លាក ញញួរ អន្លង់សម្បកឈើ កាំបិត ថ្មសំលៀង អង្រែ ពុម្ពចាក់កវ ត្រល់ ខ្មោសកោសស្បែក កងដៃ កងជើង អង្កា និងគ្រឿងអលង្ការផ្សេងៗទៀត។ រីឯប្រដាប់ប្រដាធ្វើអំពីឆ្អឹងសត្វ គេ ឃើញមាន ផ្លែព្រួញ ផ្លែសន្ទូច មូលដេរ កាំបិត កណ្ដៀវ និងធ្វើគ្រឿងអលង្ការ ដែលមានខ្លះទៀតធ្វើអំពីសម្បកខ្ចងដៃរ។ ដោយឡែក ប្រដាប់ប្រដាធ្វើអំពីដីឥដ្ឋរួមមាន បំណែកឆ្នាំង ក្រឡ ចានគ្រប់ប្រភេទ គ្រឿងអលង្ការប្រកបដោយក្បូរក្បាច់រចនាល្អបវរក្នុងកម្រិតសិល្បៈទឹកដៃ យ៉ាងស្ទាត់ជំនាញទៀតផង។ វត្ថុប្រើប្រាស់ដែលធ្វើអំពីលោហៈជាតុវិញ គេឃើញមានផ្លែព្រួញ ផ្លែជឹង កណ្ដៀវ ពន្លាក ជាដើម ដែលធ្វើឡើង ពីលោហៈជាតុដែក និងស្ពាន់។ ក្រៅពីបានរុករកឃើញនូវសំណល់ បុរាណវត្ថុទាំងអស់នេះ គេក៏បានប្រទះឃើញទៀតនូវ ឆ្អឹងសត្វត្រកួត ឆ្អឹងអណ្ដើកកន្ធាយ ត្រី ជ្រូក គោ ឆ្កែ មាន់ និងឆ្អឹងសត្វចតុបាទផ្សេងៗ ជាច្រើនទៀត ។

សរុបសេចក្ដីមក បើយើងពិនិត្យពិចារណាទៅលើកាកសំណល់ កំណាយបុរាណវត្ថុតាងទាំងអស់ដែលពួកកុលសម្ព័ន្ធខ្មែរដើម បានផលិត និងបានប្រើប្រាស់នោះ យើងអាចធ្វើសេចក្ដីសំយោគបានដូចខាងក្រោមនេះ៖

- ខ្មែរយើងនៅយុគថ្មរំលីង និងយុគលោហៈ មានការរីកលូតលាស់ខាងវិស័យសិប្បកម្មយ៉ាងទូលំទូលាយប្រកបដោយទេពកោសល្យ ច្នៃប្រឌិតខ្ពស់រួចស្រេចទៅហើយ។

- ចំពោះ វត្ថុតាងសម្រាប់ចាក់ពុម្ពផ្អែកល្ពៅ អង្រែ (សម្រាប់បុកស្រូវ) ផ្លែសន្ទូច និងឆ្អឹងសត្វស្រុកគ្រប់ប្រភេទ បង្ហាញថា ខ្មែរយើងចេះធ្វើបរកសិកម្មដាំដុះ ការចិញ្ចឹមសត្វ និងនេសាទ ដែលជាវិស័យសេដ្ឋ កិច្ចកសិកម្មដ៏សំខាន់បំផុត ក្នុងការផ្គត់ផ្គង់ស្បៀងអាហារ។
- រីឯ វត្ថុប្រើប្រាស់ដែលផលិតពីវត្ថុធាតុផ្សេងៗ ដូចជា ផ្លែព្រួញ កណ្ដៀវ ផ្លែដឹង ពន្លាក បានស្ដែងឡើងអោយឃើញនូវពន្លកនៃការចាប់ ផ្ដើមក្នុងវិស័យឧស្សាហកម្មស្ពលោហៈ។

លើសពីនេះទៀតបើយើងវិភាគទៅតាមគោលការណ៍និយមន័យ សេដ្ឋកិច្ច យើងឃើញថា ជីវភាពរស់នៅ និងទម្រង់ផលិតកម្មរបស់ខ្មែរ នាជំនាន់បុរេប្រវត្តិ ព្រមទាំងទំនាក់ទំនងដោះដូរ ក្នុងសង្គមកុលសម្ព័ន្ធ យើងអាចសន្និដ្ឋានបានថា នៅសម័យកាលនោះ គឺបានកើតមានឡើង នូវទម្រង់បឋម នៃសកម្មភាពសេដ្ឋកិច្ច សង្គម រួចស្រេចទៅហើយ។

## ខ.សេដ្ឋកិច្ចកម្ពុជាសម័យហ្វូណន

សេដ្ឋកិច្ចប្រទេសកម្ពុជាក្នុងសម័យហ្វូណន បានបន្តដំណើររបស់ខ្លួន តភ្ជាប់ពីជំនាន់បុរេប្រវត្តិសាស្ត្រ ដែលជាមូលដ្ឋានគ្រឹះនៃវិស័យសេដ្ឋកិច្ចដំបូងបង្អស់ ក្នុងនោះមានវិស័យកសិកម្ម សិប្បកម្ម និងសេវាកម្ម ដែលបានបន្តនិរន្តរភាព ចូលមកដល់សម័យកាលក្រោយៗទៀត។ ផ្អែកតាមឯកសារមួយចំនួន បានបង្ហាញអំពីការរីកលូតលាស់ គួរអោយកត់សម្គាល់ លើវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ខ្មែរយើង ក្នុងសម័យហ្វូណន ដែលបានធ្វើអោយរដ្ឋនេះ ក្លាយទៅជាអាណាចក្រនគរភ្នំ ដែលជាមហាអំណាចមួយមានអនុភាពនយោបាយ កិត្យានុភាពល្បីល្បាញ និងឥទ្ធិពលយោធាដ៏ខ្លាំងក្លា គ្របដណ្ដប់លើជ្រោយនៃភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ។

- វិស័យកសិកម្ម

នៅសម័យហ្វូណន វិស័យកសិកម្មមានការរីកចម្រើនយ៉ាងខ្លាំងក្លា នេះបើតាមការបញ្ជាក់ពីឯកសារមួយចំនួន ព្រោះវិស័យនេះ បានផ្គត់ផ្គង់សេចក្ដីត្រូវការស្បៀងអាហារសម្រាប់ប្រជាជនក្នុងស្រុក ហើយព្រមទាំងបាន បម្រើអោយការនាំចេញទៀតផង ជាពិសេសផលិតកម្មដំណាំស្រូវ ដំណាំរួមផ្សំ គ្រឿងទេស និងសត្វព្រៃ។ភាពជោគជ័យលើវិស័យកសិកម្មនេះ បណ្ដាលមកពីព្រះរាជានូវគ្រប់រជ្ជកាលនៃអាណាចក្រហ្វូណនបានយកចិត្តទុកដាក់ខ្ពស់លើការរៀបចំនយោបាយអភិវឌ្ឍន៍ សេដ្ឋកិច្ច កសិកម្មបានត្រឹមត្រូវជាពិសេសបានរៀបចំនយោបាយធារាសាស្ត្រ ពោលគឺការកសាងនូវទំនប់ទឹក ប្រឡាយដឹកស្រះទឹក អាងស្តុកទឹកដើម្បីផ្គត់ផ្គង់ធនធានទឹកបម្រើអោយវិស័យកសិកម្មអោយបានគ្រប់គ្រាន់ និងគ្រប់រដូវកាល។

ចំពោះវិស័យសិប្បកម្ម នាសម័យហ្វូណន ក៏មានសន្ទុះលឿន លឿនខ្លាំងក្លាណាស់ដែរ។ ខ្មែរយើងជំនាន់នោះ ចេះធ្វើកិច្ចការជាច្រើន ដែលទាក់ទងនឹងវិស័យសិប្បកម្ម។ សិប្បករហ្វូណន អាចផលិតនូវផលិតផលប្រើប្រាស់ជាច្រើនប្រភេទដូចជា ចេះត្បាញរវៃអំបោះសូត្រ ត្បាញក្រណាត់ ចេះស្លូវកែវយ៉ាងស្ទាត់ជំនាញ ឆ្លាក់គ្រឿងអលង្ការ ធ្វើពី លោហៈមានតម្លៃ ក្នុងនោះមានការធ្វើចិញ្ចៀន កងដៃ កងជើង ខ្សែ

ដៃ ខ្សែកាន់ កងកាន់ អង្កាំ មានចានប្រាក់ ចានមាស ថាស ប្រកបដោយ សិល្បៈក្បូរក្បាច់រចនាចម្លាក់ក្នុងទេពកោសល្យទឹកដៃដ៏ល្អ ប៉ិនប្រសព្វ ខ្ពស់ណាស់។ វត្ថុសិប្បកម្មរបស់សិប្បករខ្មែរសម័យហ្វូណន បាននាំចេញទៅបង្អួតនៅតាមទីផ្សារក្រៅប្រទេស នៃភូមិភាគអាស៊ីខាងត្បូង ជាពិសេស នាំចេញទៅប្រទេសចិន។ ក្រៅពីនេះទៀត គេឃើញមាន សិប្បកម្មធ្វើទូក សំពៅធំៗឆ្លងកាត់សមុទ្រ ធ្វើរទេះធ្វើគ្រឿងក្រអូប និងចេះសូនរូប និងធ្វើចម្លាក់ទេវរូបពីលោហៈធាតុសំរិត ពីថ្ម និងពីឈើ។

- វិស័យពាណិជ្ជកម្ម

គួរបញ្ជាក់ថា ព្រះរាជាណាចក្រហ្វូណន ជារដ្ឋមួយដែលមានសកម្មភាពពាណិជ្ជកម្មយ៉ាងខ្លាំងក្លា។ នៅសម័យនោះ ដោយសារតែការរៀបចំស្រុកទេសបានត្រឹមត្រូវ ធ្វើអោយវិស័យពាណិជ្ជកម្មជួញដូរទូទៅហាក់មានដំណើរការទៅមុខជាលំដាប់។ ម្យ៉ាងទៀត យើងមានកំពង់ផែ អន្តរជាតិអូរកែវ ដែលបានបំពេញតួនាទីរបស់ខ្លួនប្រកបដោយភាពទាក់ទាញ ហេតុដូចនេះហើយទើបកំពង់ផែអន្តរជាតិមួយនេះ បានក្លាយទៅជាទីគាប់ចិត្ត និងទី ជំនួបប្រសព្វពាណិជ្ជកម្មអន្តរជាតិយ៉ាងសំខាន់ ពាណិជ្ជកម្មក្នុងស្រុក និងឈ្មួញបរទេស) ចម្រុះជាតិសាសន៍ យ៉ាងច្រើនកុះករ។ សកម្មភាពពាណិជ្ជកម្មទាំងអស់នេះ បញ្ជាក់អំពីការរីកលូតលាស់ផ្នែកផលិតកម្មក្នុងស្រុកសម្រាប់ការនាំចេញ និងបង្ហាញអំពីតម្រូវការប្រើប្រាស់របស់ប្រជាជនម្ចាស់ស្រុកចំពោះការនាំចូល ហើយក៏ឆ្លុះបញ្ចាំងអំពីការរីកលូតលាស់នូវ ទម្រង់មីក្រូសេដ្ឋកិច្ច និងម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិបថបើកចំហរទៀតផង។

- វិស័យគមនាគមន៍

យើងដឹងហើយថា វិស័យគមនាគមន៍ គឺជាវិស័យគន្លឹះ ព្រោះជាមធ្យោបាយសម្រាប់សម្របសម្រួលដល់ការដឹកជញ្ជូនផលិតផលទៅ កាន់ទីផ្សារគោលដៅ និងការធ្វើដំណើររបស់ប្រជាជនទៅគ្រប់ទិសទីទាំងអស់ ហើយការរីកលូតលាស់វិស័យពាណិជ្ជកម្ម ក៏ដូចជាវិស័យសេដ្ឋកិច្ច និងសង្គមផ្សេងៗទៀតទៅបានអាស្រ័យដោយមានការទ្រ ទ្រង់សម្របសម្រួលពីវិស័យគមនាគមន៍ដឹកជញ្ជូននេះឯង។

នៅសម័យអាណាចក្រហ្វូណន វិស័យគមនាគមន៍មិនទាន់មាន ការរីកចម្រើនខ្លាំងក្លាទេ ហើយប្រជាជនខ្មែរនិយមធ្វើដំណើរ និងដឹក ជញ្ជូនផលិតផលតាមផ្លូវគោក និងផ្លូវទឹក។ ហេតុដូចនេះហើយ ដើម្បីងាយស្រួលក្នុងការដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែសមុទ្រ ឬដឹកជញ្ជូនទំនិញដែលនាំចូលពីក្រៅប្រទេសមកកាន់រាជធានី និងទីប្រជុំជន គេបានអោយប្រជារាស្ត្រ ជីកព្រែកខ្វាត់ខ្វែងប្រទាក់គ្នា តភ្ជាប់រហូតដល់កំពង់ផែសមុទ្រអន្តរជាតិអូរកែវ។

- វិស័យសំណង់

សំណាងរាជធានី វ្យាធបុរៈ) បច្ចុប្បន្ននៅអង្គរបុរី ខេត្តតាកែវ (ក៏ ដូចជាសំណង់ ទីក្រុងដ៏ទៃទៀតក្នុងព្រះរាជាណាចក្រហ្វូណនដែរ បានរៀបចំឡើងដោយមានកំពែងយ៉ាងរឹងមាំសម្រាប់ការពារខ្លួន និងមានជីក គួរទឹកព័ទ្ធជុំវិញ ព្រមទាំងមានចិញ្ចឹមសត្វក្រពើក្នុងនោះផង។ សំណង់ស្ថាបត្យកម្មនៃព្រះបរមរាជវាំងទាំងអស់ បានស្ថាបនាឡើង អំពីឈើដែល មានធ្វើជាប្រាសាទ ឬធ្វើជាដំណាក់ជាច្រើនជាន់។

នៅសម័យអាណាចក្រហ្វូណន គេឃើញមានផងដែរនូវសំណង់ បណ្ណាល័យជាតិធំៗ ដែលសម្បូរទៅដោយសៀវភៅ មានក្បួនតម្រាសាស្ត្រាគម្ពីរ និងកម្រងឯកសារសព្វបែបយ៉ាងតម្កល់ទុកនៅទីនោះ។ ទាំងនេះបង្ហាញថាអ្នកគ្រប់គ្រងរបស់ខ្មែរយើងនៅសម័យនោះ បានយកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំសិក្សាធិការ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ។

នៅក្រៅក្រុង ប្រជារាស្ត្រខ្មែរតែងតែប្រមូលផ្តុំគ្នារស់នៅ ដោយបង្កើតជាភូមិ ស្រុក ទីប្រជុំជនធំៗ ដែលមានផ្ទះពី ៥០ ទៅ ៦០ខ្នង និងមានជីកស្រះទឹកសម្រាប់ការប្រើប្រាស់រួមគ្នា។សំណង់លំនៅដ្ឋានរបស់ពួកគេសង់ឡើងអំពីឈើ សង់លើជន្ទល់ខ្ពស់ពីដី និងមានប្រកស្លឹកចាក។

- វិស័យហិរញ្ញវត្ថុ

យោងតាមឯកសារប្រវត្តិរូបិយវត្ថុខ្មែរ បានបញ្ជាក់ថា រូបិយវត្ថុរបស់ខ្មែរយើងក្នុងសម័យកាលនោះមាន ៣ប្រភេទ ដែលបានបោះពុម្ពប្រើប្រាស់ក្នុងសតវត្សទី២ រហូតដល់ សតវត្សទី៦ រូបិយវត្ថុ ក្នុងសម័យកាលហ្វូណន។ តាមរយៈស្ថានីយ៍កំណាយបុរាណវត្ថុនៅឯ អង្គរបុរី ខេត្តតាកែវ និងនៅស្ថានីយ៍ អូរកែវ )ខេត្តក្រមួនសរ ទឹកដីកម្ពុជាក្រោម (គឺបានរកឃើញនូវវត្ថុតាងនៃរូបិយវត្ថុខ្មែរទាំងអស់នេះ។ រូបិយវត្ថុទាំង ៣ប្រភេទនោះ មានរូបិយវត្ថុ ខ្យងស័ង្ខ រូបិយវត្ថុ ព្រះអាទិត្យ និង រូបិយវត្ថុ រូបពស់ ដែលមានទំហំ វិជ្ឈមាត្រ និងទម្ងន់ខុសៗគ្នា។ គេអាចប្រើប្រាស់រូបិយវត្ថុទាំងមូលតែម្តង ឬអាចយកទៅពុះជៀកជាជម្រៀកៗសម្រាប់ការចរាចរលើទីផ្សារ ស្របទៅតាមតម្រូវការប្រើប្រាស់ និងសមាមាត្រនឹងតម្លៃទំនិញ ដែលត្រូវដោះដូរគ្នា។[24]

ក្រៅពីនេះ តាមរយៈឯកសារផ្សេងទៀត បានអះអាងថា នៅសម័យនោះ ក៏មានការប្រើប្រាស់នូវរូបិយប័ណ្ណបរទេសជាច្រើនប្រភេទជាពិសេស នៅតំបន់កំពង់ផែអន្តរជាតិអូរកែវ ដែលជាទីក្រុងបុរាណនៅ ជាប់មាត់សមុទ្រ ដែលរូបិយប័ណ្ណបរទេសទាំងនោះមានរូបិយប័ណ្ណ រ៉ូម៉ាំង ឥណ្ឌា និងចិន)អាយុកាលនៃរូបិយប័ណ្ណបរទេសទាំងនោះ ស្ថិតក្នុង គ.សទី១ មកម្ល៉េះ(។ ចំពោះកិច្ចការពន្ធដារវិញ ប្រជាជនហ្វូណនបានបង់ពន្ធជូនរាជការ ជារូបិយវត្ថុ ជាមាស ប្រាក់ ត្បូងមានតម្លៃ គុជ គ្រឿង ក្រអូប និងផ្សេងៗទៀត។

សរុបមក ពត៌មានជាមូលដ្ឋាន និងភស្តុតាងទាំងអស់នេះ អាចអោយយើងសន្និដ្ឋានបានថា នៅសម័យហ្វូណនមានការរីកលូតលាស់ ខាងវិស័យហិរញ្ញវត្ថុសាធារណៈមួយកម្រិតរួចទៅហើយ ព្រោះមានស្ថាប័នរដ្ឋដែលទទួលខុសត្រូវលើកិច្ចការទាំងអស់នេះ ពោលគឺមានប្រព័ន្ធធនាគារ ដែលជាស្ថាប័នគ្រប់គ្រងកិច្ចការនយោបាយរូបិយវត្ថុជាតិ និងមានបេឡាជាតិជាឃ្លាំងប្រាក់) ឃ្លាំងព្រះរាជទ្រព្យ (ដែលមានតួនាទីក្នុងការរក្សាការពារ និងចាត់ចែងចំណូលចំណាយរដ្ឋ។

## គ.សេដ្ឋកិច្ចកម្ពុជាសម័យចេនឡា

- វិស័យកសិកម្ម

នៅសម័យចេនឡា ពុំបានរកឃើញឯកសារណាមួយដែលបាន បញ្ជាក់ច្បាស់លាស់ អំពីការរីកលូតលាស់នៃវិស័យកសិកម្មនោះឡើយ ប៉ុន្តែអ្វីដែលយើងអាចកំណត់បាននោះ យើងឃើញថា មានការទាក់ទងនឹងការបង្កើតទីក្រុង ឰសានបុរៈ) នៅក្បែរស្ទឹងសែន (និងការឡើងគ្រងរាជ្យសម្បត្តិរបស់ព្រះអង្គម្ចាស់បុស្សរៈ នៅឯសម្ភុបុរៈ ដោយតាំងអំណាច ជាអាណាចក្រចេនឡាទឹកលិច) រដ្ឋចេនឡាទឹកលិច (ដែលបច្ចុប្បន្នស្ថិតនៅស្រុកសម្បូរ ខាងលើក្រុងក្រចេះ។

ហេតុការណ៍ខាងលើនេះ តិចឬច្រើនមានការទាក់ទងទៅនឹងការ សិក្សាច្បាស់លាស់អំពីនយោបាយទឹក ព្រោះស្ទឹងសែន អាចបង្ហូរចូលក្នុងស្រះ ឬប្រឡាយព័ទ្ធជុំវិញទីក្រុង ឬក្នុងអាងស្តុកទឹកឯទៀតៗ ដែលធ្វើអោយមានទឹកគ្រប់គ្រាន់បម្រើអោយវិស័យកសិកម្មដាំដុះ។ ចំពោះការកំណត់យកទីក្រុងសម្ភុបុរៈ សម្រាប់ជារាជធានីនៃរដ្ឋចេនឡាទឹកលិច ប្រហែលជានៅតំបន់នោះជាតំបន់មានបឹង ទន្លេលាតសន្ធឹងលើអាងទន្លេ មេគង្គ ពីល្បាក់ខោន រហូតមកដល់សមុទ្រ។ ដោយឡែកនៅរាជធានី វ្យាធបុរៈវិញ ដំណើរការវិស័យកសិកម្ម បានបន្តសកម្មភាពដូចធម្មតា ប្រកបដោយភាពជោគជ័យ តាំងពីសម័យអាណាចក្រហ្វូណនមកម្ល៉េះ។ ដូច្នេះបើពិនិត្យលើហេតុផលជាមូលដ្ឋានខាងលើនេះ យើងអាចសន្និដ្ឋានថា វិស័យកសិកម្មនៅសម័យចេនឡា មានការរីកលូតលាស់ជាប្រក្រតី។

- វិស័យសិប្បកម្ម

វិស័យសិប្បកម្មបានរស់រានជាមួយនឹងជីវភាពរស់នៅរបស់ខ្មែរយើងតាំងពីសម័យយូរលង់ណាស់មកហើយ ហេតុនេះយើងមិនមានមន្ទិលណាមួយអំពីការលូតលាស់របស់វិស័យនេះទេ។

យោងតាមឯកសារខ្លះក៏បានបញ្ជាក់បន្ថែមអំពីស្ថានភាពរបស់វិស័យសិប្បកម្មនេះដែរ ពោលគឺ នៅសម័យចេនឡា សិប្បកម្មផលិតកម្មពីវត្ថុធាតុដើមនានា ត្រូវបានសិប្បករខ្មែរចេនឡាបន្តកិច្ចការរបស់ខ្លួនជាធម្មតា។ ក្នុងនោះយើងឃើញមាន របស់របរដែលធ្វើអំពីវត្ថុធាតុដើមដី មានដូចជា ភាជន៍ ចាន ផ្ទាំង ក្អម កោដ្ឋ) ធ្វើពីដីដុត (ឥដ្ឋ ផលិតបាយអរ) ដែលផ្សំពីកំបោរលាយជាមួយស្ករ សម្រាប់សំណង់ផ្ទះ និងប្រាសាទ (និងរបស់របរប្រើប្រាស់ផ្សេងៗទៀត។ ម្យ៉ាងទៀត ដូចគ្នាដែរនឹងសម័យ ហ្វូណន ប្រជារាស្ត្រចេនឡា គឺជាជាងទងប្រកបដោយទេពកោសល្យ ស្ទាត់ជំនាញ ក្នុងការធ្វើគ្រឿងអលង្ការពីលោហៈធាតុផ្សេងៗ ដូចជា ការ ធ្វើចិញ្ចៀន ក្រយ៉ា កងដៃ ក្រវិលមាស ក្រវិលប្រាក់ ពីស្ពាន់ និងសំណ និងចេះស្លៀកែវធ្វើជាកងដៃ ធ្វើអង្កាំពាក់នៅកដៃ និងក ដែលជាគ្រឿង លម្អ។

ក្រៅពីនេះសិប្បកម្មតម្បាញសូត្រ ក្រណាត់សំពត់ ការសូនរូប សិប្បកម្មចម្លាក់ពីលោកហៈពីថ្ម និងឈើ ចេះធ្វើទូកធ្វើរទេះ និងធ្វើ សំពៅតូច ធំ បម្រើអោយវិស័យពាណិជ្ជកម្ម និងចម្បាំងទៀតផង។

- វិស័យគមនាគមន៍

ដូចដែលយើងបានដឹងរួចមកហើយថា វិស័យគមនាគមន៍ គឺជាវិស័យមួយដ៏សំខាន់ក្នុងការធ្វើទំនាក់ទំនង សម្របសម្រួលគ្រប់ចលនា សង្គម សេដ្ឋកិច្ច និងនយោបាយ។ មានឯកសារខ្លះ ក៏បានលើកឡើង អំពីស្ថានភាពនេះដែរក្នុងសម័យចេនឡា ដោយគ្រាន់តែបានបញ្ជាក់ថា វិស័យគមនាគមន៍ក្នុងសម័យ

កាលនោះ មាន២ប្រភេទ គឺ គមនាគមន៍ ផ្លូវគោក និងផ្លូវទឹក ហើយប្រជាជនបានប្រើប្រាស់សត្វដំរី គោ សេះ និងប្រើស្នែងរទេះ សម្រាប់ធ្វើជាមធ្យោបាយដឹកជញ្ជូនផ្លូវគោក និងប្រើប្រាស់ ទូក សំពៅ សម្រាប់ធ្វើគមនាគមន៍តាមផ្លូវទឹក និងមានកំពង់ផែ ជាចំណត និងជាទីប្រសព្វសំខាន់ៗ។

- វិស័យហិរញ្ញវត្ថុ

នៅសម័យចេនឡា គេបានរកឃើញរូបិយប័ណ្ណបរទេសជាច្រើន ដែលមានប្រភពមកពីបណ្តាទ្វីបផ្សេងៗគ្នា ដូចជា រូបិយប័ណ្ណឥណ្ឌា រូម៉ាំង ក្រិច និងចិន ដែលធ្លាប់បានចូលមកធ្វើទំនាក់ទំនងពាណិជ្ជកម្មនៅកំពង់ផែអន្តរជាតិអូរកែវ ឬមានទំនាក់ទំនងនយោបាយការទូត នៅ អង្គរបុរី នៅ សុផានបុរី នៅ កញ្ជនៈបុរី) ប្រទេសថៃបច្ចុប្បន្ន(។

ម៉្យាងទៀត រាជរដ្ឋាភិបាលនាសម័យអាណាចក្រចេនឡា ដែលមានប្រពៃណីគ្រប់គ្រងប្រទេសតាមលទ្ធិរាជាធិបតេយ្យឥណ្ឌា ក៏បានបន្តរៀបចំនូវរចនាសម្ព័ន្ធគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈដូចសម័យហ្វូណននោះដែរ។ តាមឯកសារខ្លះ លើកឡើងថា ប្រភពចំណូលរបស់រដ្ឋ បានមកពីការបង់ពន្ធរបស់ប្រជារាស្ត្រ ប្រាក់កាក់ ជាមាស ជារបស់របរមានតម្លៃ និងជាគ្រឿងក្រអូប ដែលអាចលក់ប្តូរយកសាច់ប្រាក់ ឬទុកសម្រាប់ការប្រើប្រាស់របស់រដ្ឋ។

### ៤.១.២. ទស្សនៈទាន នៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអង្គរ

យើងពិនិត្យឃើញថា ព្រះរាជារបស់ខ្មែរយើងបានជ្រើសរើស យកទីតាំងភូមិសាស្ត្រតំបន់អង្គរដើម្បីតាំងរាជធានី មិនមែនប្រព្រឹត្តទៅ ដោយចៃដន្យនោះទេ ពីព្រោះថា តំបន់នេះស្ថិតនៅចំកណ្តាលនៃព្រះរាជាណាចក្រ។ ម្យ៉ាងទៀត តំបន់នេះ ជាទីប្រជុំជននៃផ្លូវជំនួញ ទាំងផ្លូវ គោក និងផ្លូវទឹក ហើយសម្បូរទៅដោយធនធានធម្មជាតិគ្រប់បែបយ៉ាង ដូចជា មច្ឆាជាតិ) នៅតំបន់បឹងទន្លេសាប (ម្រឹគីម្រឹគា និងនៅក្នុងព្រៃ មាន ប្រភេទឈើល្អៗ។ ក្រៅពីនោះ តំបន់នេះមានថ្មភក់សម្រាប់ជាវត្ថុធាតុដើម ក្នុងការសង់ប្រាសាទនៅលើភ្នំគូលែន។ល។ ឯវាលទំនាបជុំវិញតំបន់នោះសុទ្ធសឹងជាវាលទំនាបដែលពោរពេញទៅដោយជីជាតិ សម្រាប់ប្រកបរបរដំណាំកសិកម្មសព្វសារពើ។[35]

ស្ថានភាពភូមិសាស្ត្រដ៏ប្រពៃនេះ រួមផ្សំជាមួយនឹងបច្ចេកទេសផលិតកម្មដ៏ចំណាន និងធនធានមនុស្សដែលឧស្សាហ៍ព្យាយាម ចេះ តស៊ូស្វិតស្វាញក្នុងការងារ បានធ្វើអោយវិស័យកសិកម្មខ្មែរនៅសម័យកាលនោះមានការរីកចម្រើនជាអតិបរមា។

ម្យ៉ាងទៀត នៅប្រទេសកម្ពុជាយើងនាសម័យកាលនោះ ការអភិវឌ្ឍសេដ្ឋកិច្ច ពឹងផ្អែកលើវិស័យកសិកម្ម ហើយវិស័យកសិកម្មតែង តែពឹងផ្អែកទៅលើមេឃ ឬប្រវាស់នឹងមេឃ។ បើខ្យល់រដូវមានការប្រែប្រួល ភ្លៀងធ្លាក់ច្រើនខែ ធ្វើអោយវិស័យកសិកម្មអាចទទួលរងគ្រោះខូច ខាតដោយសារតែទឹកជំនន់។ ម្យ៉ាងទៀត មានឆ្នាំខ្លះភ្លៀងធ្លាក់តិចពេក ធ្វើអោយដំណាំស្រូវផ្តល់ផលមិនគ្រប់គ្រាន់ សម្រាប់បំពេញសេចក្តីត្រូវ ការក្នុងស្រុក។ ដូច្នេះហើយ ទើបនៅសម័យអង្គរ ព្រះរាជាមានបំណង ចង់គ្រប់គ្រងទៅលើការប្រែ

ប្រួលវិស័យជលសាស្ត្រ ដែលតែងតែមាន ភាពមិនទៀងទាត់ តាមរយៈការស្ថាបនានៅជុំវិញរាជធានីអង្គរ នូវបឹងធំៗដែលហៅថា បារាយណ៍ សម្រាប់សន្សំទឹកភ្លៀងនូវរដូវវស្សា គួបផ្សំជាមួយ ទឹកស្ទឹងសៀមរាប ដែលហូរចុះពីលើភ្នំគូលែន។ លុះផុតរដូវវស្សា គេអាចចែកចាយទឹកបារាយណ៍ទាំងនោះ តាមប្រឡាយនានាបង្ហូរចូលទៅក្នុងស្រែ។ តាមរយៈមធ្យោបាយនេះ នាំអោយគេអាចធ្វើស្រែបានពីរដង បន្តបន្ទាប់គ្នា ហើយនៅរដូវប្រាំង គេអាចធ្វើដំណាំស្រវម្តងទៀតនៅបាតបារាយណ៍ដែលទីនោះមានដីល្បាប់ដ៏មានជីជាតិ ហើយនឹងមានសភាពសើមស្រាប់។

ការស្ថាបនាបារាយណ៍ជំនាន់នោះគឺជាសមិទ្ធិមួយធំសម្បើមណាស់។ បើយើងគ្រាន់តែលើកយកបារាយណ៍បីសំខាន់ៗមកពិភាក្សា យើងឃើញថា គួរឲ្យស្ងើចសរសើរពន់ពេកណាស់ ដូចជាបារាយណ៍លលៃ មានបណ្តោយប្រវែង ៣ គ.ម និងទទឹង ០,៨ គ.ម អាចផ្ទុកទឹក បានរហូតដល់ ៦.០០០.០០០ ម៣ រីឯបារាយណ៍ខាងកើត មានបណ្តោយ ប្រវែង ៧ គ.ម និងទទឹងប្រវែង ១,៨ គ.ម អាចផ្ទុកទឹកបានប្រមាណជាង ៣០.០០០.០០០ម៣ ចំណែកឯបារាយណ៍ខាងលិចមានបណ្តោយប្រវែង ៨គ.ម និងទទឹងមានប្រវែង ២,២ គ.ម អាចផ្ទុកទឹកមិនតិចជាង ៤០.០០០.០០០ម៣ នេះយើងមិនទាន់រាប់បណ្តាញជលគតិជាច្រើនទៀត ដែលគេស្ថាបនារបៀបគ្នានេះ នៅតាមបណ្តាខេត្តទាំងឡាយទៀតផង។

ហេតុដូចនេះហើយ ទើបលោក B.Groslier បានពោលថា នៅសម័យនោះ ធនធានទឹកនៅតំបន់អង្គរមិនជាខ្វះទេ តែចំណោទបញ្ហា ស្ថិតនៅត្រង់ថា តើធ្វើយ៉ាងណាដើម្បីចែកចាយទឹកអោយបានទៅដល់គ្រប់ទីកន្លែង។ លោកបានបន្ថែមទៀតថា ដោយខ្មែរមានដូនតាជាអ្នកជំនាញខាងនយោបាយទឹក គេក៏បានបន្តនយោបាយទឹកនេះតទៅទៀត ដោយបានបោះជំហានយ៉ាងវែងក្នុងវិស័យនេះ បានសេចក្តីថា គេបានផ្លាស់ប្តូរបច្ចេកទេសបញ្ចេញទឹកពីស្រែ ទៅជាការបញ្ចូលទឹកទៅក្នុងស្រែវិញ។ ឯនយោបាយសន្សំទឹក ដើម្បីបង្ហូរទៅក្នុងស្រែនៅពេលដែលគេត្រូវការ ត្រូវបានរៀបចំយ៉ាងម៉ត់ចត់ តាំងពីសម័យកាល ព្រះបាទឥន្ទ្រវរ្ម័នទី១ ដោយព្រះអង្គបានយកព្រះទ័យទុកដាក់នឹងវិស័យកសិកម្ម ដែលជាធម្មតាពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង និងខ្យល់រដូវ។ ការកើនឡើងនូវចំនួនប្រជាពលរដ្ឋ តម្រូវអោយគេធ្វើការប្រឹងប្រែងបង្កើនផលិតផលកសិកម្មបន្ថែមទៀត យ៉ាងណាមិញ ព្រះបាទឥន្ទ្រវរ្ម័នទី១ បានរៀបចំនយោបាយទឹក តាមរបៀបដែលប្រទេសចេនឡា ធ្លាប់មានរួចមកហើយ ពោលគឺ ទប់ទឹកបង្ខាំងទុកនៅក្នុងទំនប់ធំៗ រួចដឹកប្រឡាយបង្ហូរទឹកនោះ បញ្ចូលទៅក្នុងស្រែផង ហើយបញ្ចូលទៅក្នុងស្រះធំៗ និងប្រឡាយផ្សេងៗទៀតនៅក្នុងទីក្រុងផងក្នុងទិសដៅ ទុកប្រើប្រាស់ជាប្រយោជន៍សាធារណៈ។

នយោបាយទឹករបៀបនេះ ត្រូវបានព្រះរាជានៅជំនាន់ក្រោយៗ ជាពិសេស នៅសម័យអង្គរតែម្តងដែលគេបានអនុវត្តជាបន្តទៀតយ៉ាង ម៉ត់ហ្មត់ជាហេតុនាំអោយកើតមានភាពសម្បូរសប្បាយដល់ប្រទេសជាតិអស់រយៈកាលជាច្រើនសតវត្ស។ យើងគួរធ្វើការសិក្សាអំពីនយោបាយទឹក និងការរីកចម្រើននៃសេដ្ឋកិច្ចខ្មែរនៅសម័យអង្គរអោយបាន ពិស្តារបន្ថែមទៀត ព្រោះវាជាមូលដ្ឋានមួយដ៏សម្ខាន់ ដែលញ៉ាំងអោយអរិយធម៌ខ្មែរជំនាន់នោះមានការរីកលូតលាស់រុងរឿងដល់កំពូល។

ក្រៅពីនេះទៀត មានអ្នកប្រាជ្ញជាច្រើនបានធ្វើការត្រិះរិះពិចារ អោយណាអំពីឥទ្ធិពលនៃមជ្ឈដ្ឋានរូបវន្តទៅលើកំណើននៃអរិយធម៌ខ្មែរ ដូចជាលោក P.Gourou បានសរសេរថា កត្តាភូមិសាស្ត្រ និងនយោបាយទឹក ប្រាកដជាមានសារៈសំខាន់ណាស់ក្នុងការញ៉ាំងអោយអរិយធម៌នៃប្រទេសមួយ មានការរីកចម្រើនរុងរឿង ក៏ប៉ុន្តែជួនកាលគេអាចជួបប្រទះនូវបញ្ហាចំឡែកមួយទៅវិញ ពោលគឺដោយសារតែស្ថានភាពទឹកដីអំណោយផល អាចធ្វើអោយមនុស្សទៅរាខ្ជិលច្រអូស មិនចេះប្រឹងប្រែង ប្រយុទ្ធជាមួយនឹងធម្មជាតិ ព្រោះគេអាចរស់នៅបានស្រួលដោយមិនចាំ បាច់រវល់ខ្វាយខ្វល់ច្រើននោះឡើយ។ ហេតុនេះតើមានអ្វីទៀតជាគ្រឿងផ្សំដែលជំរុញអោយគេ ធ្វើដំណើរឆ្ពោះទៅរកវឌ្ឍនភាព។ ត្រង់ចំណុចនេះយើងមានការពិភាក្សាថា តើត្រូវការកត្តាផ្សេងៗអ្វីទៀត ដែលជាមូលដ្ឋានទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ច នាយុគសម័យអង្គរ។

ក្នុងចំណុចនេះ ប្រសិនបើយើងលើកយកកត្តាមរត៌កវប្បធម៌ពីអតីតកាលមកពិចារណា ពោលគឺកត្តាមរត៌កជាទេពកោល្យ និងសមិទ្ធិ ផល ដែលខ្មែរក្នុងយុគសម័យមុនៗបានបន្សល់ទុក នោះយើងអាចយល់ បានបន្ថែមទៀតអំពីមូលហេតុនៃការរីកចម្រើនរបស់អរិយធម៌អង្គរ។ ខាងក្រោមនេះ គឺជាមរត៌កវប្បធម៌ ក្នុងសម័យហ្វូណន និងចេនឡា។

- កត្តាមនុស្ស និងមរត៌កពីអតីតកាលជុំវិញវិស័យសេដ្ឋកិច្ច

គេដឹងថាខ្មែរនៅសម័យអង្គរជាជនជាតិឧស្សាហ៍ ហើយបំណងធំបំផុតគឺការធ្វើអោយរីកចម្រើនលូតលាស់លើគ្រប់វិស័យ និងភាពសម្បូរសប្បាយរុងរឿងរបស់ប្រទេសជាតិ។ ជាភស្តុតាងនៃវត្ថុបំណងនេះ ព្រះរាជានៅសម័យអង្គរ បានបញ្ជាអោយវិចិត្រករអង្គរឆ្លាក់ក្បាច់ រឿងកូរសមុទ្រទឹកដោះនៅលើប្រាសាទជាច្រើន និងនៅគ្រប់ច្រកទ្វារ ចូលនៃបុរីអង្គរធំជាដើម ព្រោះទឹកអម្រឹតដែលហូរចេញពីការកូរសមុទ្រ ទឹកដោះនេះ គឺជានិមិត្តរូបនៃថាមពលខាងការងារ និងការប្រណាំង ប្រជែងបង្កើតផលិតផលយ៉ាងជាក់ច្បាស់។ ម្យ៉ាងទៀតការសិក្សាតាម ផ្លូវចិត្តវិទ្យា អំពីសិល្បៈខ្មែរបុរាណ បានផ្តល់ព័ត៌មានជាច្រើនទៀត ស្តីពីការតស៊ូ ចិត្តអំណត់ និងសេចក្តីប្រាថ្នាយ៉ាងមុតមាំរបស់ខ្មែរជំនាន់នោះ ចំពោះអ្វីដែលខ្លួនចាត់ថា ល្អប្រសើរ។

ប៉ុន្តែបើយើងពិនិត្យឲ្យបានដិតដល់ យើងឃើញថាការប៉ងប្រាថ្នា អោយមានការរីកលូតលាស់នេះមានតាំងពីសម័យមុនៗមកម្ល៉េះ ពោលគឺ តាំងពីសម័យហ្វូណន និងសម័យចេនឡា។ ប្រវត្តិវិទូជាច្រើនយល់ថា ពេលដែលខ្មែរមកតាំងរាជធានីនៅអង្គរ ខ្មែរមានអរិយធម៌ខ្ពង់ខ្ពស់ មួយរួចទៅហើយ ជាងនេះទៀតអរិយធម៌នេះគ្រាន់តែធ្វើអោយលូត លាស់ថែមទៀត នៅសម័យអង្គរតែប៉ុណ្ណោះ។ យើងនឹងធ្វើការបង្ហាញនូវលក្ខណៈសម្បត្តិទាំងឡាយដែលជាមរត៌កពីអតីតកាល ដោយត្រួសៗ ដូចតទៅ ៖

- នៅសម័យហ្វូណន អ្នកស្រុកចេះប្រកបការងារជំនាញ ៖
    - ពូកែរកស៊ីលក់ដូរ ជាពិសេស ធ្វើជំនួញតាមផ្លូវសមុទ្រ
    - ជាសិប្បករយ៉ាងចំណាន ចេះឆ្លាក់ឈើ ត្បាញសូត្រ និង ផលិតប្រដាប់ប្រដាផ្សេងៗយ៉ាងស្ទាត់ជំនាញ

- ជាជាងចម្លាក់ និងជាងសំណង់រាជវាំង ប្រាសាទ
- ជាអ្នកជំនាញខាងនយោបាយទឹកផ្នែកដីសណ្តរ

• នៅសម័យចេនឡា ខ្មែរមានជីវភាពរស់នៅផ្សេងពីមុនបន្តិចហើយខ្មែរជំនាន់នោះ ៖

- ជាសិប្បករយ៉ាងស្ទាត់ជំនាញ។
- ជាជាងសំណង់យ៉ាងប៉ិនប្រសព្វបង្គួរទៅហើយ
- ជាអ្នកបន្តវេននយោបាយទឹកពីសម័យហ្វូណន ប៉ុន្តែតាមបែបទំនើបថ្មីមួយ ពោលគឺគេលើកទំនប់ ឃាំងទឹកទុកប្រើប្រាស់នៅរដូវរាំងស្ងួត
- ជាអ្នកជំនាញខាងចម្បាំង និងពង្រីកទឹកដី។

ដូច្នេះមរត៌កវប្បធម៌ ដែលខ្មែរហ្វូណន និងចេនឡាបានបន្សល់ ទុកអោយខ្មែរសម័យអង្គរ គឺមានតម្លៃពន់ពេកណាស់ នេះពុំទាន់និយាយ ពីមរត៌ក ជាប្រពៃណីផ្នែកវប្បធម៌ទេ។ ទេពកោសល្យរបស់មនុស្សខ្មែរ បានធ្វើអោយអ្វីៗដែលមានកាលពីមុនមក អោយកាន់តែរីកលូតលាស់ និងកាន់តែប្រសើរឡើងជាលំដាប់ ដែលនៅក្នុងលោកយើងនេះសឹងរក អរិយធម៌ណា មកប្រៀបផ្ទឹមអោយស្មើពុំបានឡើយ។

➢ **សេចក្តីសន្និដ្ឋាន**

សរុបមក ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាយុគសម័យអង្គរ មានខ្លឹមសារដូចខាងក្រោមនេះ ៖

• ព្រះរាជា បានកំណត់យកទីតាំងភូមិសាស្រ្តតំបន់អង្គរ មកតាំង ជារាជធានី ក៏ព្រោះតែតំបន់នេះមានជ័យភូមិល្អ ម្យ៉ាងទៀតគឺជាតំបន់ ដែលសម្បូរទៅដោយសម្បត្តិធនធានធម្មជាតិគ្រប់ប្រភេទដែលជួយទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
• ការបន្តការអភិវឌ្ឍនយោបាយធារាសាស្រ្ត គឺជាមធ្យោបាយមួយ ដ៏សំខាន់បំផុត ក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចកសិកម្មផលិតកម្ម។
• ការប្រើប្រាស់ទេពកោសល្យ ដែលជាកេរ្តិ៍មរតក៌វប្បធម៌របស់ប្រជារាស្ត្រខ្មែរដែលមានស្រាប់តាំងពីសម័យកាលមុនៗ បានជួយធ្វើអោយវិស័យសេដ្ឋកិច្ចផលិតកម្មគ្រប់ប្រភេទ បន្តការរីកលូតលាស់ទៅ មុខឥតឈប់ឈរ។
• ការប្រកាន់យករបបរាជានិយមបែបលទ្ធិទេវរាជ និង សាសនា ដែលធ្វើអោយប្រជារាស្រ្តមានការជឿជាក់ និងគោរពប្រតិបត្តិតាមបញ្ជា របស់ព្រះមហាក្សត្រ (ជាអាទិទេព) ចូលរួមក្នុងកិច្ចការសាធារណៈ និង កិច្ចការ អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

សរុបសេចក្តីមក ដោយមានការគ្រប់គ្រងគោលនយោបាយ សេដ្ឋកិច្ចបានត្រឹមត្រូវ តាមរយៈការសំយោគបញ្ចូលគ្នានូវទីតាំងភូមិសាស្រ្តដែលមានលក្ខណៈអំណោយផល មានសម្បត្តិធម្មជាតិគ្រប់គ្រាន់ មានគោលនយោបាយធារាសាស្រ្តល្អ មានមរត៌ក និងទេពកោសល្យដ៏ ល្អប្រពៃ រួមផ្សំជាមួយនឹងការប្រកាន់

យកលទ្ធិទេវរាជដ៏មានប្រសិទ្ធិភាព) សម្រាប់យុគសម័យកាលនោះ( ដែលទាំងអស់នេះ គឺជាគោលគំនិត និងជាមូលដ្ឋានគ្រឹះនៃទស្សនៈអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ព្រមទាំងអរិយធម៌អង្គរយ៉ាងពិតប្រាកដ។

### ៤.១.៣.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យអាណានិគមបារាំង

ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រដ្ឋការបារាំងមានគោលបំណងបង្កើតសិទ្ធិឯកជនលើដីធ្លី ស្រែចំការតាមបែបមូលធននិយម។ ស្របតាមកិច្ចព្រមព្រៀងចុះថ្ងៃទី ១៧ មិថុនា ១៨៨៤ និងស្របទៅតាមក្រមមួយចំនួនរបស់ព្រះមហាក្សត្រនរោត្តម និងសារាចរនានារបស់ទេសាភិបាលជាន់ខ្ពស់រដ្ឋការអាណានិគមបារាំងបានអនុវត្តច្បាប់នៃការផ្តល់កម្មសិទ្ធឯកជនលើដីធ្លី។ នៅក្នុងកិច្ចព្រមព្រៀងខាងលើនេះបានចែងថា "ចាប់ពីពេលនេះតទៅ ដីទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា ដែលពីមុនជាកម្មសិទ្ធិផ្ទាល់របស់រាជបល្ល័ង្ក ឈប់ទៅជាដីដែលគេមិនអាចទិញបានទៀតឡើយ"។ នៅក្នុងរាជក្រឹត្យព្រះបាទនរោត្តម ចុះថ្ងៃ ទី ១១ កក្កដា ១៨៩៧ មានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សាទុកនូវសិទ្ធិក្នុងការបែងចែកដីទំនេរទាំងអស់របស់ព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់កម្មសិទ្ធិដីសម្បទាន អាចប្រើប្រាស់ពេញច្បាប់របស់ខ្លួន ក្នុងការរក្សាកម្មសិទ្ធិឯកជនចំពោះវើទិញ ឬក៏ផ្តល់ជាសម្បទាន" មាត្រា ១២។ នៅក្នុងសារាចរចុះថ្ងៃទី ២៩ ធ្នូ ១៨៩៧ ស្ថានភាពច្បាប់បានត្រូវ កំណត់ច្បាស់លាស់ដោយមានសេចក្តីបញ្ជាក់ថា "រាជរដ្ឋាភិបាលរក្សា នូវសិទ្ធិរបស់ខ្លួនក្នុងការលក់ ឬបែងចែកដីទាំងឡាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធ្វើអោយដីទាំងនោះ ទៅជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ដី ជានារ៉ាប់រងដល់ស្ថេរភាពនៃកម្មសិទ្ធិលើដីទាំងនោះ ហើយព្រមទាំងបង្កបង្កើតល័ក្ខខ័ណ្ឌដ៏ប្រសើរក្នុងការប្រើប្រាស់ដីអោយ មានទំហំច្រើនជាអតិបរមា ក្នុងការធ្វើដំណាំស្រូវ ដែលអាចបង្កើត ទ្រព្យសម្បត្តិរបស់ម្ចាស់ដីព្រោះថា នៅក្នុងប្រទេសកម្ពុជាមានសល់ដី ទំនេរ និងមិនទាន់ត្រួសត្រាយមានទំហំធំធេង" ។

ដើម្បីដំណើរការឡើងនូវក្រឹត្យច្បាប់ខាងលើអោយមានប្រសិទ្ធ ភាពនៅថ្ងៃទី២៥ មេសា ១៩០២ មានការចុះផ្សាយរាជក្រឹត្យរបស់ព្រះមហាក្សត្រនរោត្តម ដែលនៅក្នុងនោះមានសេចក្តីបង្គាប់ដល់ភូមិទាំង អស់អោយចុះបញ្ជីដីធ្លី និងម្ចាស់ដីត្រូវបញ្ជាក់អំពីទំហំដីច្បាស់លាស់។

និន្នាការបែបនេះ ទាក់ទងនឹងការបង្កើតក្រសួងសុរិយោដី ការរៀបចំគម្រោងកសិដ្ឋានតាមបែបអឺរ៉ុប និងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចក្នុងការផ្តល់ដីសម្បទាន ដល់ក្រុមហ៊ុនទាំងឡាយដោយរដ្ឋការអាណានិគមបារាំង។

ពួកអាណានិគមបារាំង បានខិតខំបង្កើតក្រសួងសុរិយោដីនៅក្នុងប្រទេស ដើម្បីដំណើរការចុះបញ្ជីដីធ្លី។ ការចុះបញ្ជីដោយក្រសួង សុរិយោដី បានប្រព្រឹត្តទៅនៅឆ្នាំ ១៩០៦ ម្តង ឆ្នាំ ១៩១៨ ម្តង និង នៅ សម័យឆ្នាំ ១៩៣០-១៩៤៥ ម្តងទៀត។ បើនិយាយអោយខ្លីទៅ ការចុះបញ្ជីដីធ្លីបានប្រព្រឹត្តទៅនៅក្នុងសម័យកាលនៃរបបអាណានិគមនិយមទាំងមូល។ ម្ចាស់ដីដែលអាចក្លាយទៅជាអ្នកមានកម្មសិទ្ធិដីធ្លី លុះត្រាតែដីរបស់

ខ្លួន ត្រូវបានចុះបញ្ជីត្រឹមត្រូវដោយក្រសួងសុរិយោដីដោយមានលិខិតបញ្ជាក់ថា មានការបង់ពន្ធ និងចុះបញ្ជីត្រឹមត្រូវ ។

ដោយយោងតាមច្បាប់ស្តីពីការកាន់កាប់ដីធ្លីដែលបានអនុម័តរួចមក រដ្ឋការអាណានិគម បានបែងចែកដីឡូត៍ធំៗ ដល់ពលរដ្ឋបារាំងជាពិសេសដល់ក្រុមហ៊ុនផ្តាច់មុខសម្រាប់ការដាំដំណាំកសិកម្មស្រូវ ពោត កាហ្វេ ម្រេច កៅស៊ូ និងសម្រាប់ការចិញ្ចឹមសត្វ។ ដីឡូត៍ធំៗ ជាច្រើនបានត្រូវបែងចែកដល់បណ្តាមន្ត្រីខ្មែរដែលបានធ្វើការសហការ យ៉ាងសកម្មជាមួយរដ្ឋបាលអាណានិគមបារាំង។

តាំងដើមដំបូងមកម្ល៉េះ បន្ទាប់ពីការតែងតាំងរបបអាណាព្យាបាលបារាំងនៅកម្ពុជា ទេសាភិបាលជាន់ខ្ពស់ មានសិទ្ធិបែងចែកដីធ្លី ជាលក្ខណៈសម្បទានដោយឥតគិតថ្លៃ ហើយដោយមានទំហំរហូតដល់ ១.០០០ ហិកតា។ លុះនៅឆ្នាំ ១៩២៨ ទំហំដីសម្បទាន ដែលរដ្ឋការអាណាព្យាបាលបានបែងចែកអោយ បានត្រឹមតែកម្រិតប្រមាណជា ៣០០ ហិកតា វិញប៉ុណ្ណោះ។ នៅឆ្នាំ ១៩៣១ ការផ្តល់ដីសម្បទានត្រូវបានផ្លាស់ប្តូរទៅតាមលក្ខណៈរូបភាពលក់ដេញថ្លៃ ហើយដែលមានការអនុញ្ញាតអោយចូលរួមដេញថ្លៃ មិនមែនសម្រាប់តែពលរដ្ឋបារាំងនោះទេ ប៉ុន្តែពួកអភិជន ឬនាហ៊ឺនខ្មែរក៏អាចចូលរួមផងដែរ។ តាមទិន្នន័យនាឆ្នាំ ១៩៣០ ទំហំដីសម្បទានដែលបែងចែកដោយរដ្ឋការអាណាព្យាបាលបារាំង មានចំនួនពី ១៩០.០០០ ដល់ ២០០.០០០ ហិកតា។ ក្នុងនោះពលរដ្ឋបារាំង បានទទួលដីសម្បទានដែលមានទំហំទៅដល់ ៧០ %រីឯដីសម្បទានដែលនៅសល់ត្រូវបានបែងចែកជាពិសេសដល់អភិជនខ្មែរទាំងឡាយ។

គួរបញ្ជាក់ថា កសិករជាង ៨០ %ដែលជាអ្នកស្រែចំការ ក៏បានក្លាយជាម្ចាស់កម្មសិទ្ធិឯកជនលើដីធ្លីរបស់ខ្លួន។ កាលនោះនៅប្រទេស កម្ពុជា នៅមានដីទំនេរច្រើន ហើយការត្រួតត្រាលើដីទាំងនោះ មិនចាំ បាច់ទាមទារអោយមានការចំណាយប្រាក់ច្រើនទេ។ ដីស្រែទាំងឡាយ ប្រកបដោយដីជាតិហើយជាមធ្យមកសិករម្នាក់ៗ មានកម្មសិទ្ធិមិន លើសពី ៥ហិកតា។ ក្នុងបណ្តាកសិករទាំងនោះ មានកសិករចំនួនពី ១,២ ទៅ ២ % ប៉ុណ្ណោះដែលមានដីស្រែចំការលើសពី១០ហិកតា។

ក្រៅពីគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចខាងលើនេះ រដ្ឋការអាណាព្យាបាលបារាំងបានបង្កើតវិធីសាស្ត្រទាញយកផលប្រយោជន៍ ផ្សេងទៀត តាមរយៈការបង្កើតរបាំងពន្ធអាករគ្រប់ប្រភេទ តាំងពីការ យកពន្ធលើមនុស្ស លើការចិញ្ចឹមសត្វ និងលើផលដំណាំកសិកម្ម រហូត ដល់ពន្ធនាំចេញ-នាំចូល ដែលតម្លៃអត្រាពន្ធទាំងនោះមានការប្រែប្រួលគ្រប់ពេលវេលា ដោយធ្វើយ៉ាងណា បម្រើផលប្រយោជន៍ដល់សេដ្ឋកិច្ច របស់ប្រទេសបារាំង។ ជាងនេះទៀត ប្រទេសកម្ពុជានៅក្នុងសម័យកាលនោះ ក៏បានក្លាយទៅជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើមកសិកម្ម សម្រាប់បម្រើអោយឧស្សាហកម្មបារាំង ហើយក្លាយជាអ្នកទទួលទិញនូវទំនិញ ផលិតសម្រេចពីប្រទេសបារាំងមកវិញ។

សរុបសេចក្តីមក ទស្សនៈទានសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យអាណានិគម គឺទាក់ទងនឹងនយោបាយបែងចែកដីសម្បទាន ដើម្បីក្លាយទៅជាកម្មសិទ្ធិឯកជន ក្នុងទិសដៅអភិវឌ្ឍន៍ វិស័យកសិកម្ម និងឈានទៅរកការអភិវឌ្ឍឧស្សាហកម្មធុនស្រាល។ ក្នុងលក្ខណៈនេះ រដ្ឋមានតួនាទីជាអ្នកបែង

ចែកដ៏ស្របច្បាប់ និងទទួលបានមកវិញនូវប្រាក់ចំណូលតាមរូបភាពបង់ពន្ធលើដីធ្លី និងលើផលដំណាំ ក៏ដូចជាលើប្រាក់ចំណេញ។ ទន្ទឹមនឹងនោះដែរ អាណាព្យាបាលបារាំង បានបង្កើតគោលនយោបាយពន្ធអាករ ដែលកេងប្រវ័ញ្ចលើប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់ ហើយធ្វើអោយសេដ្ឋកិច្ចខ្មែរទាំងមូល បានស្ថិត នៅក្នុងសភាពក្រីក្រដដែល។ រីឯការវិនិយោគសាធារណៈ និងការបែងចែកមកវិញនូវចំណូលពន្ធអាករ មិនបានផ្តល់នូវភាពយុត្តិធម៌ និងការរីកចម្រើនដល់សេដ្ឋកិច្ចជាតិ និងសង្គមខ្មែរ នាសម័យកាលនោះឡើយ។

### ៤.១.៤.ទស្សនៈទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសម័យសង្គមរាស្ត្រនិយម

ចាប់តាំងពីយុគសម័យដើមមកម្ល៉េះ ប្រទេសខ្មែរយើងជាប្រទេស ដែលប្រកបរបរកសិកម្មជាធំ ហើយផលិតផលដែលផលិតចេញពីដី គឺមានអានុភាពខ្លាំងក្លាណាស់ចំពោះសេដ្ឋកិច្ចជាតិ។ ដូចជានៅក្រោមរបប អាណាព្យាបាលបារាំងប្រទេសខ្មែរបានយកវិស័យកសិកម្មធ្វើជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច។ រីឯវិស័យអាជីវកម្មផ្សេងៗទៀត គឺមានតិចតួច ស្តួចស្តើងណាស់ ដូចដែលយើបានសិក្សារួចមកហើយ ពោលគឺមានតែរបរសិប្បកម្មបន្តិចបន្តួច និងកម្មន្តសាលតូចតាចប៉ុណ្ណោះ ហើយវិស័យទាំងនោះស្ថិតនៅក្នុងកណ្តាប់ដៃជនបរទេស។ ដោយសារតែកង្វះខាតផ្នែកឧស្សាហកម្មនេះហើយ ទើបធ្វើអោយវិស័យបច្ចេកទេស និងបច្ចេកវិទ្យានៅសម័យកាលនោះ ពុំមានការជឿនលឿន។ នៅខណៈពេលនោះ ប្រទេសយើងបានធ្វើការនាំចេញទៅក្រៅប្រទេសនូវភោគផលធម្មជាតិ ហើយនាំចូលមកវិញនូវផលិតផលឧស្សាហកម្ម សម្រាប់យកមកប្រើ ប្រាស់ក្នុងស្រុក។

ក្រោយពីបានទទួលឯករាជ្យមក រាជរដ្ឋាភិបាលខ្មែរបានជម្រុញអោយវិស័យសេដ្ឋកិច្ចគ្រប់ផ្នែកមានសន្ទុះកើន ឡើង ហើយរដ្ឋាភិបាល ក៏បានធ្វើការគ្រប់គ្រង និងកាន់កាប់យកផ្នែកសំខាន់ៗខ្លះ ដែលជាអាយុជីវិតនៃសេដ្ឋកិច្ចជាតិ។

ចំពោះគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជានាសម័យកាលនោះ រាជរដ្ឋាភិបាល បានកំណត់គោលដៅ ៣យ៉ាង គឺ

- កសាងសេដ្ឋកិច្ចថ្មី តាមរយៈការធ្វើជាតូបនីយកម្ម ផ្នែកឧស្សាហកម្ម ពាណិជ្ជកម្ម និងស្ថាប័នហិរញ្ញវត្ថុ ដោយប្រើប្រាស់ជំនួយបរទេស។
- ជ្រៀតចូលជាសមាជិកភាពនៃស្ថាប័នធនាគារពិភពលោក ដូច ជា ADB, IMS និង IBRD។
- បង្កើតច្បាប់វិនិយោគអោយមានការទាក់ទាញ ដើម្បីអូសទាញទុនវិនិយោគពីបរទេស និង វិនិយោគក្នុងស្រុកតាមរយៈការធ្វើឯកជនភាវូបនីយកម្ម វិស័យពាណិជ្ជកម្ម ធនាគារ និងឧស្សាហកម្ម ។

ទាក់ទងទៅនឹងទស្សនៈទាននៃការអភិវឌ្ឍវិស័យកសិកម្ម រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើគោលនយោបាយពង្រីកដីស្រែចំការថ្មី ការជ្រើសរើសពូជស្រូវ និងពូជដំណាំ ការប្រើប្រាស់ជីធម្មជាតិគួបផ្សំនឹងជីគីមី ការអភិវឌ្ឍនយោបាយទឹក និងការផ្តល់ឥណទានយ៉ាងច្រើនក្នុងវិស័យកសិកម្ម។

បើយើងពិនិត្យមើលអោយបានពិស្តារ ទៅលើកម្មវិធីលម្អិតនៃការអភិវឌ្ឍវិស័យកសិកម្មយើងឃើញថា រាជរដ្ឋាភិបាលសម័យនោះបានបែងចែកថវិការដ្ឋប្រមាណ ២៥ %សម្រាប់ការវិនិយោគលើវិស័យកសិកម្ម) ជាលក្ខណៈឥណទាន និងមិនមែនឥណទាន (ជាពិសេសទៅលើដំណាំសំខាន់ៗជាមូលដ្ឋានដូចជា ដំណាំស្រូវ កៅស៊ូ ពោត កប្បាស ត្នោត តែ និងកាហ្វេ ព្រមទាំងបានវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធជារាសាស្ត្រ សម្រួលដល់ការធ្វើកសិកម្មច្រើនរដូវកាល។

ក្រៅពីនេះ រដ្ឋាភិបាលបានជម្រុញអោយកសិករខ្មែរចេះប្រើប្រាស់ជី ថ្នាំសម្លាប់សត្វល្អិត ចេះធ្វើទំនើបកម្មកសិកម្ម ដោយប្រើប្រាស់ត្រាក់ទ័រ និងបរិក្ខារកសិកម្មផ្សេងៗទៀត និងលើកលែងពន្ធនាំចូលលើសម្ភារៈកសិកម្មទាំងនោះ។ សំខាន់ជាងនេះទៀត នៅក្នុងគោលនយោបាយអភិវឌ្ឍន៍កសិកម្មយើងពិនិត្យឃើញថា រដ្ឋាភិបាលបានផ្តល់ដី កសិកម្ម និងចេញប័ណ្ណកម្មសិទ្ធិជូនប្រជាកសិករ បានបង្កើតស្ថានីយ៍ស្រាវជ្រាវកសិកម្ម និងជ្រើសរើសភូមិកសិកម្មគម្រូ ពិសេសទៀត រដ្ឋបានធ្វើការកំណត់តម្លៃផលិតផលកសិកម្ម ដើម្បីអោយកសិករអាចជ្រួតជ្រាបជាមុនអំពីតម្លៃទីផ្សារងាយស្រួលក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងផែនការផលិតកម្មរបស់ខ្លួន។

ចំពោះទស្សនៈទាននៃការអភិវឌ្ឍ វិស័យឧស្សាហកម្ម រាជរដ្ឋាភិបាលបានជម្រុញការសាងសង់នូវរោងចក្រជាច្រើនដូចជា រោងចក្រ តម្លើង គ្រឿងយន្ត រោងចក្រចម្រាញ់ប្រេងកាត រោងចក្រស្រាបៀររោងចក្រវាយនភ័ណ្ឌ រោងចក្រស៊ីម៉ង់ត៍ រោងចក្រក្រដាស រោងចក្រផលិតកែវ រោងចក្រផលិតកង់រថយន្ត រោងចក្រផលិតឱសថ រោងចក្របាវ ក្រចៅ រោងចក្រត្រីខកំប៉ុង រោងចក្រក្តារបន្ទះ និងផ្សេងៗទៀតនៅទូទាំងប្រទេសនៃព្រះរាជាណាចក្រកម្ពុជា។

ផ្សេងពីនេះទៀត ទាក់ទងទៅនឹងវិស័យសេវាកម្ម យើងឃើញថា រាជរដ្ឋាភិបាលបានពង្រីកហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការសាងសង់កំពង់ផែសំខាន់ៗ ដើម្បីធ្វើទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយបណ្តាប្រទេសជាច្រើននៅលើពិភពលោក។ គួរបញ្ជាក់ថា ការធ្វើពាណិជ្ជកម្មក្រៅប្រទេស គឺបានស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការរបស់រដ្ឋក្នុងភាគហ៊ុន ៦០ %ជាដើមទុនរបស់រដ្ឋ និង ៤០ ជាដើមទុនរបស់ឯកជន។ ម្យ៉ាងទៀតរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច ពាណិជ្ជកម្ម ដោយបានបង្កើតក្រុមហ៊ុននាំចេញ-នាំចូលរបស់ជាតិ ក្នុងគោលបំណងគ្រប់គ្រងចរាចរលំហូរទំនិញចេញពីក្នុងស្រុក និងលំហូរចូលពីបរទេស ក្នុងទិសដៅធានាបាននូវតុល្យភាពជញ្ជីងពាណិជ្ជកម្ម និងទទួលបាននូវអត្ថប្រយោជន៍ដល់សេដ្ឋកិច្ចជាតិ។ ទន្ទឹមនឹងនេះដែរ រដ្ឋបានបង្កើតក្រុមហ៊ុនជាតិ ចែកចាយទំនិញក្នុងស្រុក ដើម្បីកាត់បន្ថយនូវគម្លាត និងអន្តរការីសេដ្ឋកិច្ច) ឈ្មួញកណ្តាល (ពោលគឺធ្វើយ៉ាងណាអោយអ្នកផ្គត់ផ្គង់ទំនិញ និងអ្នកប្រើប្រាស់បានខិតជិតគ្នា។

ដោយឡែកចំពោះវិស័យសិក្សាធិការជាតិ និងសុខាភិបាលសាធារណៈវិញ ដែលជាវិស័យគន្លឹះនាសម័យកាលនោះ រាជរដ្ឋាភិបាលបានធ្វើការជម្រុញយ៉ាងខ្លាំងក្លា ដោយពង្រីកការបណ្តុះបណ្តាលធន ធាន

មនុស្សលើគ្រប់កម្រិតសិក្សា និងគ្រប់ជំនាញ ព្រមទាំងធ្វើការពង្រីកវិស័សុខាភិបាល និងវប្បធម៌ជាតិ ដែលនៅសម័យអាណានិគមពុំត្រូវបានយកចិត្តទុកដាក់។

## ៤.១.៥.ទស្សនៈទាននៃការអភិវឌ្ឍសេដ្ឋកិច្ចសម័យសាធារណៈរដ្ឋខ្មែរ

ផ្ទុយពីសម័យសង្គមរាស្ត្រនិយម យុទ្ធសាស្ត្រសំខាន់ៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម នាសម័យសាធារណៈរដ្ឋខ្មែរ គឺជាការទទួលយកនូវប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចជាតិ តាមរូបភាព សេដ្ឋកិច្ចទីផ្សារសេរី។ នៅសម័យនោះ ប្រព័ន្ធសេដ្ឋកិច្ចជាតិទាំងមូលត្រូវបានរៀបចំឡើង ដោយថតចម្លងនូវក្បួនខ្នាត នៃការធ្វើសេដ្ឋកិច្ចទីផ្សារសេរីរបស់សហរដ្ឋអាមេរិក យកមកអនុវត្តផ្ទាល់នៅក្នុងប្រទេសកម្ពុជា ដោយដំណើរការសេដ្ឋកិច្ចជាតិទាំងមូល ពឹងផ្អែកទាំងស្រុងលើវិស័យឯកជន ហើយរដ្ឋដើរតួជាអ្នកសម្របសម្រួល និងធ្វើនិយ័តកម្មក្នុងយន្តការសេដ្ឋកិច្ច ។ ជាលទ្ធផល មូលដ្ឋានសេដ្ឋកិច្ចសំខាន់ៗ ត្រូវបានផ្ទេរទៅអោយ ផ្នែកឯកជនជាអ្នកគ្រប់គ្រង ជាពិសេសវិស័យពាណិជ្ជកម្ម ដែលជាវិស័យគន្លឹះនាសម័យនោះ។

## ៤.១.៦.ស្ថានភាពវិស័យសេដ្ឋកិច្ចសម័យកម្ពុជាប្រជាធិបតេយ្យ

### ក.វិស័យកសិកម្ម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានឈរលើទស្សនៈវិស័យថា មានស្រូវគឺមានអ្វីៗទាំងអស់។ ដូច្នេះក្នុងរបប ប៉ុល ពត ពួកគេបានបង្ខំប្រជាជនអោយទៅរស់នៅតាមទីជនបទ ហើយបង្ខំអោយធ្វើស្រែចំការយ៉ាងធ្ងន់ធ្ងរ។កសិករទាំងអស់ បានធ្វើការងារជាសមូហភាព ដោយបង្ខំ ដូចសត្វធាតុ ។

នៅសម័យកម្ពុជាប្រជាធិបតេយ្យ ប្រជាពលរដ្ឋស្ទើរតែ ១០០ %ត្រូវបានពួកអង្គការបង្ខំអោយធ្វើការងាររួមគ្នា ប្រកបរបរកសិកម្មយ៉ាងធ្ងន់ធ្ងរជាទីបំផុត ទាំងយប់ទាំងថ្ងៃមិនថាឈឺឬជានោះទេ ពោលគឺយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្មែរក្រហម គឺការពង្រឹងវិស័យកសិកម្ម សម្រាប់ការផ្គត់ផ្គង់វិស័យសេដ្ឋកិច្ចទាំងមូល។[161] ដោយពឹងផ្អែកលើវិស័យកសិកម្មនេះ ប្រទេសកម្ពុជាបានត្រូវធ្វើសមូហភាវូបនីយកម្ម និងជាតូបនីយកម្ម លើគ្រប់វិស័យនៃខឿនសេដ្ឋកិច្ចជាតិទាំងមូល។ ជាមួយនេះផងដែរ ពួកថ្នាក់ដឹកនាំរបស់អង្គការ បានបង្កើតនយោបាយ ខ្លួនទីពឹងខ្លួន ដោយរដ្ឋាភិបាលគ្រប់គ្រងលើកម្លាំងពលកម្មទាំងអស់ អោយដាំដំណាំស្រូវ និងធ្វើការងារជីកប្រឡាយ លើកទំនប់ទឹកជីកស្រះ និងបំពេញការងារយ៉ាងធ្ងន់ធ្ងរផ្សេងៗទៀត ព្រោះពួកគេបានមើល ឃើញពីបទពិសោធន៍នៃភាពរីកចម្រើនដ៏ខ្លាំងក្លានៅសម័យអង្គរ ដោយសារតែប្រព័ន្ធធារាសាស្ត្រនេះ។

ថ្វីត្បិតតែប្រទេសកម្ពុជានាសម័កាលនោះ បានទទួលយកឯកទេសកម្មខាងការផលិតស្រូវក៏ដោយក៏ប៉ុន្តែប្រជាជនខ្មែរពុំមានអាហារបរិភោគគ្រប់គ្រាន់នោះទេ ពីព្រោះផលិតផលអស់ទាំងនោះ ត្រូវផ្តល់ ជាជំនួយអោយទៅប្រទេសចិន។[162] ជាទូទៅក្នុងមួយថ្ងៃៗ ប្រជាជនខ្មែរសម័យនោះ គេអោយហូបតែបបររាវ ២ពេល ប៉ុណ្ណោះក្នុងមួយថ្ងៃ។

ក្នុងការប្រកបរបរកសិកម្ម ប្រជាជនខ្មែរត្រូវបានរៀបចំជាសហករណ៍ សម្រាប់បង្កបង្កើនផល ដោយមានការរៀបចំជាក្រុមសាមគ្គីតូចៗ នៅតាមបណ្តាភូមិនិមួយៗនៃទីជនបទ ស្រែចំការ ដែលភាគច្រើនជ្រើសរើស យកកម្លាំងយុវជន) កងចល័ត (ធ្វើជាកម្លាំងស្នូល ដើម្បីអនុវត្តអោយបានតាមផែនការបង្កបង្កើនផលទាំងយប់ទាំងថ្ងៃ) ក្រោមពាក្យស្លោកថា ផលិតស្រូវគឺ ៣ តោន/ហិកតា(។ [163]ប្រព័ន្ធធារាសាស្ត្រ បានបន្សល់ទុក រហូតដល់បច្ចុប្បន្ននេះ។ ចំណែកឯធនធានធម្មជាតិ ក្នុងសម័យនោះ ត្រូវបានប្រើប្រាស់អស់លទ្ធភាព ហើយសូម្បីតែកំប្លោកក៏ត្រូវអូសយក មកកាប់ចិញ្ច្រាំធ្វើជាជីសម្រាប់ដាក់ស្រែអស់ដែរ។

ក្រៅពីដំណាំស្រូវ ការដាំបន្លែ ផ្លែឈើ ថ្នាំជក់ ចិញ្ចឹមសត្វ និងនេសាទវិញ បក្សកុម្មុយនីស្តបានអោយប្រជាពលរដ្ឋ ដែលមានវ័យចាប់ពីអាយុ ៥០ឆ្នាំ ឡើងទៅ និងអ្នកទោសកម្រិតស្រាល ទទួលយកភារកិច្ចទាំងនោះ។ ផ្ទៃដីបង្កបង្កើនផលអាចមានដល់ទៅ ២.៤ លាន ហិកតា រួមទាំងដីទំនាបខ្ពង់រាបដីល្បាប់ដីមានដីជាតិ និងដីហិលមួយចំនួនទៀត។ ប៉ុន្តែការអនុវត្តកន្លងមក កម្ពុជាប្រជាធិបតេយ្យ ធ្វើបានតែ ៥៨ % នៃផ្ទៃដីដាំដុះតែប៉ុណ្ណោះ។ ដូច្នេះហើយ អ្នកសេដ្ឋកិច្ចសម័យនោះ បានបង្កើតផែនការសម្រាប់ពង្រីកផ្ទៃដីដាំដុះ និងផែនការពង្រីកការដាំ ដុះស្រូវរយៈពេល៤ឆ្នាំ។ ចំពោះទិន្នផលស្រូវល្អបំផុតនៅសម័យនោះ អាចទទួលបានប្រហែលជា ២ តោន ទៅ ២,៣តោនប៉ុណ្ណោះក្នុងមួយហិកតា។

ប៉ុន្តែអ្វីដែលគួអោយកត់សម្គាល់នោះ ប្រជាជនខ្មែរក្នុងរបប ប៉ុល ពត គឺរកតែបបរាវហូបក៏មិនបានឆ្អែតផង។ តាមឯកសារខ្លះបង្ហាញថា នៅឆ្នាំ ១៩៧៧ ភូមិភាគពាយ័ព្យអាចប្រមូលផលស្រូវបានប្រហែលតែ ពី ៧០០.០០០ ទៅ ៩០០.០០០ តោន ប៉ុណ្ណោះ ប៉ុន្តែជាលទ្ធផលក្នុងឆ្នាំ ១៩៧៨ ភូមិភាគនេះ គឺបានខ្វះស្រូវពី ៧០០.០០០ ទៅ ៨០០.០០០តោន ដែលនាំអោយកើតមានគ្រោះទុរ្ភិក្ស ព្រោះស្រូវទាំងនោះ ត្រូវបានមជ្ឈិមបក្សនាំចេញទៅបរទេស។ បើយោងតាមឯកសារបក្ស នៅឆ្នាំ១៩៧៧ គឺបានដាក់បទបញ្ជាអោយភូមិភាគ នេះត្រូវតែផលិតស្រូវអោយបាន ១.៦២០.០០០ តោន ដែលមួយភាគធំ សម្រាប់ធ្វើការនាំចេញទៅលក់នៅបរទេស។

ដោយឡែកនៅឆ្នាំ ១៩៧៦ ស្រូវភាគច្រើនគឺមជ្ឈិមបក្សបាន ទទួលពីភូមិភាគបូព៌ាទៅវិញ ប៉ុន្តែលុះដល់ឆ្នាំ ១៩៧៧-១៩៧៨ មជ្ឈមបក្សលែងទទួលបានស្រូវពីភូមិភាគនេះហើយ ព្រោះការដឹកនាំក្នុងតំបន់នេះ បានយកចិត្តទុកដាក់លើកម្រិតជីវភាពប្រជាជនប្រសើរជាងតំបន់ដ៏ទៃទៀតក្នុងប្រទេសខ្មែរ ដែលជាមូលហេតុនៃការចាប់ផ្តើងឡើងនូវទំនាស់ផ្ទៃកនយោបាយ និងការស្លាប់របស់លោក សោ ភឹម។

## ខ.វិស័យឧស្សាហកម្ម និងសិប្បកម្ម

ក្នុងរបបដិវត្តន៍កុំម្មុយនីស្តកម្ពុជា បានផ្លាស់ប្តូរទីតាំងរោងចក្រពីទីក្រុង ទៅជនបទវិញ។ ពួកអង្គការបានកៃច្នៃម៉ាស៊ីនយានយន្តមួយចំនួន តាមរយៈការស្លម៉ាស៊ីនទាំងនោះ រួចចាក់ជាផ្ទាំង ថាស ខ្ទះ ជាដើម។ ចំពោះផលិតកម្មឧស្សាហកម្ម ដែលប្រទេសកម្ពុជាធ្លាប់មានពីមុនមកដូចជា រោងចក្រ សហគ្រាស មធ្យោបាយដឹកជញ្ជូន និងផ្លូវគមនាគមន៍ ត្រូវបានកំទេចចោលទាំងស្រុង។ ចំពោះវិស័យសិប្បកម្ម

គឺពុំមានអ្វីជាដុំកំភួននោះទេ ព្រោះប្រជាពលរដ្ឋគ្មានពេលសម្រាប់ចាក់ជាម្ជុកស្លឹកត្នោត និងស្មូនឆ្នាំង សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនទេ) ព្រោះជាកម្មសិទ្ធិរួម ប្រជាជនមានកម្មសិទ្ធិតែស្លាបព្រាមួយ និងកំប៉ុងទឹកដោះគោមួយប៉ុណ្ណោះ សម្រាប់ដាក់ទឹកបរិភោគ(។ ហើយអ្វីដែលពួកអង្គការបង្ខំ អោយធ្វើនៅតាមភូមិនិមួយៗនោះគឺធ្វើ បង្គី ចប និង កណ្តៀវច្រូតស្រូវ ដែលជាឧបករណ៏ផលិតកម្មកសិកម្មសំខាន់បំផុតក្នុងសម័យប៉ុល ពត។

## គ.វិស័យសេវាកម្ម

### គ.១.វិស័យពាណិជ្ជកម្ម

វិស័ពាណិជ្ជកម្ម ត្រូវបានបំបាត់ចោលទាំងស្រុង ព្រោះជាសេដ្ឋ កិច្ចក្នុងទ្រង់ទ្រាយ និងទម្រង់អន់ថយ ជាសេដ្ឋកិច្ចបែបសម័យបុរេប្រវត្តិ ព្រោះគេបានបំបាត់ក្រដាសប្រាក់ ទីផ្សារ និងទំនាក់ទំនងដោះដូរ។

ប៉ុន្តែដោយសារតែភាពអត់ឃ្លានរបស់ប្រជាពលរដ្ឋបានបង្ខំ អោយមានការដោះដូរស្រូវអង្ករដោយលួចលាក់ជាមួយរបស់របរដែល ពួកប្រជាជនមូលដ្ឋានចាស់)ជាម្ចាស់ស្រុកមុនរបបខ្មែរក្រហម(មានតម្រូវការដូចជា នាឡិការ ឬគ្រឿងអលង្កការផ្សេងៗពីព្រោះសម័យនោះគឺគ្មានការចរាចរជារូបិយវត្ថុ នោះទេ។

ចំពោះពាណិជ្ជកម្មក្រៅប្រទេសត្រូវបានផ្អាក ប៉ុន្តែបានដំណើរការឡើងវិញ នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ ១៩៧៧ ជាមួយប្រទេសចិន ដែលជាដៃគូរពាណិជ្ជកម្មដ៍សំខាន់។ បើតាមផែនការរបស់ ពួកខ្មែរក្រហម គឺនៅឆ្នាំ ១៩៧៨ គេមានគម្រោងនាំស្រូវអង្ករចេញ ចំនួន ១.៦២៩.០០០ តោន ។ នៅក្នុងផែនការ៤ឆ្នាំរបស់ ប៉ុល ពត គេមានគម្រោងនាំចេញអង្ករ អោយបានជិត ៤ដង ដោយសង្ឃឹមថា ទទួលបានរូបិយប័ណ្ណប្រមាណ ១.៣ ពាន់លានដុល្លា។[171]

ថ្វីត្បិតតែយើងឃើញមាន ការដោះដូររវាងកម្ពុជា និងចិន លើផលិតផលស្រូវ និងសព្វាវុធ ប៉ុន្តែមិនមែនជាពាណិជ្ជកម្មនោះទេ គឺជាជំនួយទៅវិញទៅមក។ ចំពោះទំហំពាណិជ្ជកម្មមានក្នុងតម្លៃត្រឹមតែ ៣ ឬ ៤លាន ដុល្លារប៉ុណ្ណោះ។ ក្រោយមកក៏បានទំនាក់ទំនងជាមួយប្រទេស បារាំង អង់គ្លេស និងសហរដ្ឋអាមេរិក ដោយឆ្លងកាត់តាមហុងកុង។

### គ.២.វិស័យគមនាគមន៍

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានផ្លូវដែក ផ្លូវទឹក និងផ្លូវថ្នល់។ ហើយនៅលើដី គឺមានរទេះគោ និងនៅលើទឹកមានទូក។ ដោយសារតែគោលនយោបាយនាំប្រជាជនឆ្ពោះទៅរកម្ហូបអាហារ ព្រោះពិបាក) ដូច្នេះ រថភ្លើង និងរថយន្ត ត្រូវបានផ្អាកការ (ដឹក ស្បៀងអាហារយកទៅផ្គត់ផ្គង់ដល់ប្រជាជននៅទីក្រុងប្រើប្រាស់ ហើយគេប្រើប្រាស់រទេះគោ ទូក និងថ្មើរជើងជំនួសវិញ។

### គ.៣.វិស័យហិរញ្ញវត្ថុ

ក្រោយពីបានវាយរំលំរដ្ឋាភិបាល លន់ នល់ មកពួកខ្មែរក្រហម បានឡើងកាន់អំណាច ហើយធ្វើការបិទមិនអោយមានការចាយលុយ និងមិនអោយមានការដោះដូរទៀតទេ។ ប៉ុន្តែ បក្សកុំមុយនីស្តកម្ពុជាសម័យនោះ គេបានបោះពុម្ពក្រដាសប្រាក់ដែរ។ ហើយរូបិយវត្ថុទាំងនេះ បានបោះពុម្ពនៅក្នុងឆ្នាំ ១៩៧៥ និងគ្រប់គ្រងដោយធនាគារកម្ពុជា។ ការបោះពុម្ពសាច់ប្រាក់នេះ មានគោលបំណង៣យ៉ាងគឺ៖

- ជានិមិត្តរូបដើម្បីបំភ័នភ្នែកសកលលោក
- សម្រាប់ទូទាត់ពាណិជ្ជកម្មជាមួយបរទេស (ចិនជាដើម)
- ទុកបើកប្រាក់បៀវត្សដល់កម្មាភិបាលរបស់ពួកគេ។

ប៉ុន្តែយើងពិនិត្យឃើញថា ជាក់ស្តែង រូបិយវត្ថុទាំងអស់នោះ ពេញមួយសម័យកាលនៃរបប ប៉ុល ពត ពុំបានចរាចរនោះឡើយ។

## ៤.២.យោបល់រួមស្តីពីប្រវត្តិសេដ្ឋកិច្ច ឆ្នាំ ១៩៧៩-១៩៩១

ពេលធ្វើការវិភាគពីសភាពការណ៍សេដ្ឋកិច្ច និងលទ្ធផលទាំងឡាយ យើងអាចបញ្ជាក់បានពីប្រវត្តិសេដ្ឋកិច្ចវាងឆ្នាំ ១៩៧៩-១៩៩១

ចលនានៃសេដ្ឋកិច្ចនេះអាចចែកជាដំណាក់កាលយោលតាមទិសដៅកំណត់នៃគោលការណ៍ដឹកនាំ។

### ៤.២.១.ការស្តារបនាឡើងវិញ ៖ ១៩៧៩-១៩៨១

**ក.១៩៧៩-១៩៨០ ៖** ការស្រូបយកផលប៉ះពាល់របស់ខ្មែរក្រហម

១- ឆ្នាំ ១៩៧៩ ជាឆ្នាំនៃការចាប់ផ្តើមសូន្យ នៃសេដ្ឋកិច្ចកម្ពុជាដោយមានឧស្សាហកម្មមួយគ្មានការចាត់ចែងពីពាណិជ្ជកម្មមួយដែលគ្មានសកម្មភាពទាំងស្រុង និងផលិតកម្មកសិកម្ម គិតជាភាគរយតិចតួចពីឆ្នាំ១៩៧៩ ។ ផលិតកម្មស្រូវ ០.៥៦០ លានតោនគឺ១៥% នៃឆ្នាំមុន សង្គ្រាម គឺមនុស្សម្នាក់ៗមានអង្ករជាអាហាតិចជាង ១០០ គីឡូក្រាម ស្មើនឹង ១/៤ នៃតម្រូវការ ស្បៀងចិញ្ចឹមប្រជាជនកម្ពុជា ចំណែកការនេសាទ ក៏ថយចុះក្នុងសមាមាត្រដូចគ្នាដែរ ។ នៅពេលនោះកម្ពុជារស់បានដោយសប្បុរសធម៌ និងសាមគីភាពអន្តរជាតិ ។

២-សេដ្ឋកិច្ចបានវិលទៅកត់ត្រាបានក្នុងស្ថិតិនៃឆ្នាំ ១៩៨០ ផលិតកម្មស្រូវ លោតផ្លោះដល់ ១/៧ លានតោន ប៉ុន្តែអនុភាពស្បៀងនៅខ្វះប្រហែល ១/៤ ទៀត។ បរិមាណត្រូវការខាងផ្នែកសាច់ក៏កាន់តែច្រើនតែសត្វពាហនៈពេលនោះមានតែ ១លានក្បាល ឯត្រីសាច់ផ្តល់បានតែ ៨ គ.ក្រ.ក្នុងមនុស្សម្នាក់ ក្នុងមួយឆ្នាំ ដែលមុនសង្គ្រាមម្នាក់ប្រើសាចដល់ទៅជិត ៤០ គីឡូក្រាម។ គេក៏គិតផងដែរនៅតួលេខនៃស្ថិតិទាក់ទងផលិតកម្ម ឧស្សាហកម្ម ២៥.៧ លាន U.S.D.។ ពាណិជ្ជកម្មចាប់ផ្តើម ឯឧបករណ៍ផ្លាសប្តូររូបិយវត្ថុបានកើនឡើង គឺលុយរៀលថ្មី ។

## ៤.២.២.១៩៨១-១៩៨២:ការរៀបចំឱ្យមានរបៀប និង ការចាប់ផ្ដើមបទពិសោធសង្គមនិយម

**ក-ក្នុងឆ្នាំ ១៩៨១**

មិនត្រឹមតែក្បាលម៉ាស៊ីនសេដ្ឋកិច្ចទេ ដែលបានត្រូវដាក់ឱ្យដំណើរការ ។ ក្នុងស្ថានភាពស្មុគស្មាញ គេក៏ពិនិត្យឃើញនៅកំណើនប្រជាប្រចាំ នៃទិន្នន័យផលិតកម្មប្រពៃណី ដែលបានបន្តជាយុទ្ធសាស្ត្រនៃកំណើននៅសតវត្សក្រោយមកទៀត ប៉ុន្តែភាគច្រើននៃតួលេខសេដ្ឋកិច្ចទំនើប ហាក់ជាមានជីវិត ទោះបីតួលេខស្ថិតិនោះនៅពេលខ្លះឆ្ងាយពីការពិតក៏ដោយ ។

ក្នុងចំណមការបញ្ជាក់នៅផលិតផលប្រពៃណីគេរក្សាបាននៅឧទាហរណ៍ដូចតទៅ ៖

- ក្នុងទស្សនៈវិស័យយូរអង្វែង ស្រូវនឹងផ្ដល់ពី ២៤០ គ.ក្រ.ក្នុងមនុស្សម្នាក់ៗនៅដើមឆ្នាំ១៩៨០ ទៅ ២៧០ គ.ក្រ.នៅឆ្នាំ១៩៩០ ។

- ការនេសាទ និងការចិញ្ចឹមសត្វ ។

ក្នុងចំណោមតួលេខផលិតកម្មទំនើប គេឃើញដូចតទៅ ៖

- ជាការបញ្ជាក់នៅរយៈពេលខ្លី ផលិតផល ជ័រកៅស៊ូឆ្លងពី ១.៣-៤ ពាន់តោននៅចុងដំណាក់កាលនោះក៏ដូផលិតផលបន្លែវាំង ឆ្នាំ ១៩៨០ ទៅ ១៩៨១ ឡើងទៅដល់ ១៩០ ពាន់តោន ។

- ការសន្និដ្ឋានបានស្តែងចេញជាសុទិដ្ឋិនិយម ក្នុងផលិតកម្ម ឧស្សាហកម្មគឺ ១៧.៨ លានដុល្លារអាមេរិក ហើយអ្វីដែលមានការពិតច្រើននោះ គឺមានតម្លៃជុំវិញ ១១ លានដុល្លារ អាមេរិកជាតួលេខផលសរុបមធ្យម នៃសហគ្រាសមធ្យម និង តូចដែលមានពលករ ពី ១៥នាក់ ឡើងទៅដល់ឆ្នាំ ១៩៩០ ។

- ចំពោះបញ្ហាពាណិជ្ជកម្ម ក៏មានអត្ថាធិប្បាយប្រហែលគ្នាដែរ តួលេខនៃស្ថិតិគួរលើកទឹកចិត្ត គឺ ៣៥ លានដុល្លារអាមេរិក ឬការប្រុងប្រយ័ត្នចំពើតួលេខនេះ អាចថាតួលេខនេះចែកនឹង២ គឺ ១៧លានដុល្លារអាមេរិក។

**ខ-នៅក្នុងឆ្នាំ ១៩៨២**

វិស័យឧស្សាហកម្ម ឈរនៅលើផលិតកម្ម ដែលមានតម្លស ១៣.២លានដុល្លារអាមេរិករួមទាំងជុំនួយអន្តរជាតិ និងពាណិជ្ជកម្មក្នុងប្រទេសផង ។

សភាពការបែបនេះលេចឡើមានក្តីសង្ឃឹម និងមានផាសុខភាព ទោះបីមានថាមពល និងការអភិវឌ្ឍផ្នែកឯកជន តែរដ្ឋបាលបានទទួលស្គាល់ នូវការពិតពាណិជ្ជកម្មរីកចម្រើន និងផលិតកម្ម ឧស្សាហកម្ម ដែលជាមូលដ្ឋានចង់ឆ្លងកាត់ទៅរកស៊ីបែបសេដ្ឋកិច្ចសង្គមនិយម។

## ៤.២.៣.សង្គមនិយម និងការលំបាកៈ ១៩៨៣-១៩៨៦

### ក.១៩៨៣-១៩៨៣៖ ការទទួលជោគជ័យមួយ នៃសេដ្ឋកិច្ចសង្គមនិយម

ក្នុងរយៈពេលពីរគេអាចជឿថា បទពិសោធសេដ្ឋកិច្ចសង្គមនិយម អាចទទួលបានជោគជ័យព្រោះ៖

១.ភាគច្រើននៃការបញ្ជាក់ នៃតួលេខមានកំណើនពេញ៖

- កៅស៊ូមានផលិតភាពឡើងវិញ មានចំនួន ០.៦ តោនក្នុងមួយហិចតា

- ពាណិជ្ជកម្មឆ្លង ពី ២១.២ លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៣ ដល់ ៣០.៤ លាន ទៅ ឆ្នាំ ១៩៨៤ ជាកំណើនបន្ទាន់ពាណិជ្ជកម្ម ក្រៅប្រទេសសរុបដែលកើនទ្វេក្នុងរយៈ ៣ឆ្នាំ ឆ្លងពី ២៩.៧ លានដុល្លារអាមេរិក នៅ ឆ្នាំ១៩៨២ ដល់ ៣៥ លាន នៅឆ្នាំ ១៩៨៣ និងដល់ ៥៩ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៤ ។

២.តួលេខ គណនេយ្យ មានស្ថេរភាព និងមានការកែលម្អ៖

- លុយរៀលមានភាពរឹងមាំហើយអត្រារបស់ខ្លួនជាផ្លូវការគឺ ៤-៧ រៀល/ដុល្លារអាមេរិក

- អត្រាគម្រប់នៃការផ្លាស់ប្តូរទំនិញ បានកែលម្អយឺតៗ ក្រោយពេលរណបទៅនិងក្រៅប្រទេសប៉ុន្មានឆ្នាំមុន ។ អត្រានោះកើនពី ៧.៨% ឆ្នាំ ១៩៨២ ទៅ ១២.៣ នៅឆ្នាំ១៩៨២ បន្ទប់មកដល់ ១៣.៧% នៅឆ្នាំ ១៩៨៤ ដោយសារមានកំណើននៃការនាំចេញ ដែលឆ្លងពី៤.៣លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៣ ដោយសារកំណើនមានទិន្នផលនៃពលករ ហើយបន្ទាប់មកមានការធ្លាក់ចុះនៃតម្លៃផលិតកម្មមកដល់ ១២.២ លានដុល្លារអាមេរិក។

### ខ.១៩៨៥-១៩៨៦: ការលំបាកលើគ្រប់វិស័យ

ចំណាក់កាលថ្មីនៃសង្គមនិយម កាមការលំបានដោយសារមានការបញ្ជាក់តួលេខសេដ្ឋកិច្ចតួទៅជាផ្លូវថយចុះជាសក្ខីកម្ម គឺជាភាពអន្តរាយជាបន្តបន្ទាប់ នៃម៉ាស៊ីនសេដ្ឋកិច្ចផ្លូវការ៖

- ក្នុងវិស័យឧស្សាហកម្មការចាប់ផ្តើមពីឆ្នាំ ១៩៨៤ ដល់មានផលិតកម្ម ១២.២លានដុល្លារអាមេរិក រឹងមាំមារយៈពេលយូរទោះបីជាភាពច្បាស់លាស់នៃមីក្រូសេដ្ឋកិច្ចនៃការស្តារឡើងវិញ ដែលនៅឆ្នាំ ១៩៨៥ ផលិត កម្មឡើងដល់តម្លៃ ១២.៨ លានដុល្លារអាមេរិក ដល់ ១៣.១លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៦ ។

ការជំរុញខ្លាំងខ្លានាំឱ្យការធ្លាក់ចុះនៃផលិតភាពការងារ ។

- ស្ថានភាពវិស័យកសិកម្មនៅទីក្រុង៖ ស្រូវមានផលិតផលត្រឹម ១.៨ លានតោនតែដោយសារកំណើនប្រជាជនរហ័សពេកដោយឱ្យមានឧនភាពស្បៀង ។

ការធ្លាក់ចុះនៃនយោបាយសេដ្ឋកិច្ចសង្គមនិយម គឺមានអត្ថន័យត្រង់ការបញ្ឈប់ការផលិតនៃសហគ្រាសទីពីរ របស់រដ្ឋដែលទទួលការវិនិច្ឆ័យថា រកស៊ីមិនសូវចំណេញ ។

វិធានការរបស់រដ្ឋបានត្រឹមតែធ្វើឱ្យផ្នែកឯកជនឈានចូលធ្វើសកម្មភាពសេដ្ឋកិច្ច ជំនួយជាបន្ត

បន្ទាប់នៅសេដ្ឋកិច្ចសមូហភាពដែលមានការអភិវឌ្ឍខ្លួនឯងតែម្តង ៖

- ដោយសារហេតុផលឧស្សាហកម្ម ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋ ជាឯកជនឬនៅក្នុងស្រុក មានកំណើនរហូតក្នុងពេលពីឆ្នាំនោះហើយមានល្បឿនលើសសាធារណៈឆ្ងាយណាស់ សគ្រាសរដ្ឋមានចំនួន ៨៧% នៃផលិតកម្ម ឧស្សាហកម្មនៅឆ្នាំ១៩៨៤ នៅសល់តែជាង ៥៣% ទេនៅឆ្នាំ ១៩៨៦ ។ សហគ្រាសឯកជនតូចៗ មានកំណើន ៥ដង ក្នុងរយៈប៉ុន្មានខែសោះ ។

- សភាពការកាន់តែច្បាស់ទៅទៀតចំពោះពាណិជ្ជកម្មឯកជនដែលមានកំណើន លើសពាណិជ្ជកម្មរដ្ឋដែលពេលមុននោះរដ្ឋមានចំនួនជាង ៤៦% នៃពាណិជ្ជកម្ម ឆ្នាំ ១៩៨៥ និងចុះដល់ ៣៩% នៅ ឆ្នាំ ១៩៨៦ ។

ពាណិជ្ជកម្មគិតជាតម្លៃ គឺចុះ ១/៣ គឺពី ៥៩ ដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៤ មកត្រឹម ៤១ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៥ ហើយបន្ទាប់មក នៅទ្រឹងត្រឹម ៤៦.៨ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៦ និង ២៨.៨លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៧ ។

## ៤.២.៤.និន្នាការនៃការធ្វើឱ្យងើបឡើងវិញនៃសង្គមនិយមនិងជោគជ័យនៃផ្នែកឯកជន៖ ១៩៨៧-១៩៩០

### ក.១៩៨៧-១៩៨៨

គាត់ខិតខំធ្វើឱ្យងើបឡើងវិញ នៅចំពោះមុននៃការបាត់បង់បន្តិចម្តងៗ នៃអំណាចសេដ្ឋកិច្ចក៏មានបំណងធ្វើសកម្មភាពជាថ្មី ជួយដល់វិស័យសេដ្ឋកិច្ចមួយចំនួន នឹងដឹកនាំឃោបាយឯកជនភាវូបនីយកម្មផង ១០% នៃរោងចក្ររដ្ឋលក់ឱ្យឯកជន ។ វិធានការនោះគ្រាន់តែជាការបញ្ចូលខ្យល់ អុកស៊ីហ្សែន ជួយអ្នកជំងឺធ្ងន់ធ្ងរប៉ុណ្ណោះ ។

ដោយយល់ឃើញថាភាគចំណែក នៃសេដ្ឋកិច្ចហាក់ដូចជាថយចុះផលិតផលឧស្សាហកម្មត្រួតពិនិត្យដោយក្រសួង កើនពី ១៣.១ លានដុល្លារ អាមេរិកនៅឆ្នាំ ១៩៨៦ ដល់ ១៦ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៧ និង ១៨.៥ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៨៨ ហើយផលិតភាពឧស្សាហកម្ម តាមពលកម្មកើនក្នុងពេលមួយ ពី១,២៣ លានដុល្លារ នៅ ឆ្នាំ១៩៨៧ ដល់ ១,៤៣ លានដុល្លារ ១៩៨៨ ។

គេត្រូវមើលឱ្យឃើញនូវការរីចម្រើនផលិតកម្មបារី ក្នុងរយៈពេលពីឆ្នាំចំនួនប្រាក់នៃតម្លៃលក់បារីកើនលើសតម្លៃឧស្សាហកម្មសរុប។ ប៉ុន្តែដើម្បីប្រឈមមុខនឹងសភាពការចំណាយសង្គ្រាមរដ្ឋបានបូជាព្រៃឈើដើម្បីទប់ទល់ និងភាពខ្វះខាតនៃជញ្ជីងពាណិជ្ជកម្ម ជំនួសឱ្យការនាំជ័រកៅស៊ូចេញ ដែលកម្រិតកើនឡើងដល់កម្ពស់ទៅហើយ ហើយថយចុះក្រោយ ១៩៨៧ ។ ការខិតខំរបស់រដ្ឋ គឺបានរួមចំណែកដោយផ្នែកឯកជនដែលបានពន្លកឡើងទៅតាមរបៀបរបបសង្គម ចាប់ពីផ្នែកកសិកម្ម ដែលកំពុងរៀបចំជាកម្មសិទ្ធឯកជនឡើងវិញ។ គេពិនិត្យឃើញ៖

- ការកើនឡើងវិញនៅផលិតភាពផ្នែកនេសាទ ពីឆ្នាំ ១៩៨៧ ដែលផលិតផលមានការលោតផ្លោះ

ពី ៦៩.១ ពាន់តោន នៅឆ្នាំ ១៩៨៦ កើនដល់ ៨២.១ ពានតោន នៅឆ្នាំ ១៩៨៧ ដែលការហូបចុករបស់ប្រជាជនកើនពី ៩.២ ដល់ ១០.៦ គ.ក្រ.ក្នុងមនុស្សម្នាក់ៗក្នុង១ឆ្នាំ ។

- ការស្តារឡើងវិញមួយនៃជីវភាពកសិកម្ម ដែលមានផ្ទៃដាំដុះជាស្រូវ ពីឆ្នាំ ១៩៨ កើនឡើងហើយ ផលិតផលបន្លែកើនទ្វេ ពីឆ្នាំ ១៩៨៧ ១៦៦.១ ពាន់តោន នៅឆ្នាំ ១៩៨៨ មានចំនួន ២៦៦.៥ ពាន់តោន ។

គួររំលឹកផងដែរ នៅវិស័យឧស្សាហកម្ម ដែលកំណើនផ្នែកឯកជនកើនស្មើផ្នែកឧស្សាហកម្មរដ្ឋ។ ចំពោះពាណិជ្ជកម្មរដ្ឋត្រួតត្រាផ្នែកនោះនៅឆ្នាំ ១៩៨៨ មានតែ ១/៤ ប៉ុណ្ណោះ ។

**ខ.១៩៨៩-១៩៩០៖ ផ្លូវអនុគ្រោះដល់សេដ្ឋកិច្ចសង្គមនិយម**

ការខិតខំលើកកម្ពស់ឡើងវិញ នៃសេដ្ឋកិច្ច គឺដូចភ្លើងចម្បើង

- ផលិតផលលើឧស្សាហកម្មក្រោមការគ្រប់គ្រងរបស់ក្រសួងជួលរលំធ្លង ១៨.៥ លានដុល្លារ អាមេរិក នៅឆ្នាំ ១៩៨៨ មកត្រឹម ១៣.៦ លាន នៅឆ្នាំ ១៩៩០ ដែលអត្រាផលិតភាពនៃពលករធ្លាក់ចុះដល់ ៩៧០ ដុល្លារ នៅឆ្នាំ ១៩៩០ ។ ផលិតផលផ្នែកឧស្សាហកម្មនេះកំពុងមានការប្រួលប្រែផលអំណោយនៅក្នុងផ្នែកឯកជន នៅឆ្នាំ១៩៨៩ ដែលនៅឆ្នាំ ១៩៩០ មាននៅសល់តែ ៣០% ប៉ុណ្ណោះ ។

- ជាទូទៅតួលេខរដ្ឋ មានភាពមិនច្បាស់លាស់ល្អទេតែតថភាពសេដ្ឋកិច្ច ដែលឃើញមានពិត គឺការចិញ្ចឹមសត្វ គឺមានចំនួន ០.៤៣ ក្បាល ក្នុងមនុស្សម្នាក់ចាប់ពី ឆ្នាំ ១៩៨៩ មក ។ នៅខាងក្រោយផ្ទាំងស្បៃផ្សេងនៃស្ថិតិផ្លូវការ មានការកើនឡើននៅតថភាពនៃសេដ្ឋកិច្ចនោះ គឺផ្នែកឯកជន៖

- ផលិតកម្មឯជននៃសកម្មភាពឧស្សាហកម្ម កើនឡើង ពី ១៦.៦ លានដុល្លារអាមេរិក នៅ ឆ្នាំ ១៩៨៨ ដល់ ១៩ លាន នៅឆ្នាំ ១៩៨៩ បន្ទាប់មកកើនដល់ ៣២.២ លានដុល្លារអាមេរិក នៅឆ្នាំ ១៩៩០ ។

- ចំណែកផ្នែកពាណិជ្ជកម្មឯកជនគឺមាន ៩០% នៃការផ្លាស់ប្តូរ

## ៤.២.៥.ការបញ្ចប់នៃសេដ្ឋកិច្ចចាស់ ៖ ឆ្នាំ ១៩៩១

ឆ្នាំ ១៩៩១ ជាឆ្នាំនៃជោគជ័យ របស់ពួកឯកជនក្លាយជាក្បាលម៉ាស៊ីន សេដ្ឋកិច្ចកម្ពុជាដើរតាមវិធាន ផ្ទាល់នៃការអភិវឌ្ឍនៃការនាំចូលឯកជនកើនឡើង ៣ដង នៃការនាំចេញ។

ឧស្សាហកម្មគ្រប់គ្រងដោយរដ្ឋ គឺមានការស្តារ និងការលោតផ្លោះ ពី ១៣.៦ លានដុល្លារអាមេរិក នៅឆ្នាំ១៩៩១ គឺស្មើនឹង ១៣% ដែលមានតម្លៃសំខាន់ៗ នៃរដ្ឋករ និងបារី ដែលត្រួតពិនិត្យមើលផ្នែកឯកជន គឺកើនដល់ ១៣៨ លានដុល្លារអាមេរិកនៅឆ្នាំ ឆ្នាំ១៩៩១ ។ ការបោះបង់ចោលផ្នែករដ្ឋ បានប្រព្រឹត្តទៅតាមប្រតិបត្តិការ នៃចលនាពីរ៖

១.ទីមួយ ការបើកឱ្យទុនបរទេសចូលក្នុងចំណោមគម្រោង ៣០០ មានគម្រោង ៥៥ ដែលបាន

អនុម័តពីឆ្នាំ ១៩៨៩ ហើយក្រុមហ៊ុនចម្រុះ ជាង ៥០ បានដំណើរការរួចហើយ នៅពាក់កណ្តាលឆ្នាំ ១៩៩២ ប៉ុន្តែគេឃើញថាមានតែចំនួន ២០ សហគ្រាសថ្មីទេ ដែលរៀបចំរចនាសម្ព័ន្ធឧស្សាហកម្មថ្មី។ ក្រុមហ៊ុនចម្រុះមានទាក់ទង ផ្នែកសក្តានុពលដែលមានទិន្នផលខ្ពស់ពិសេសសេវាកម្ម ពួកថៃមាន ៥៦ គម្រោង កសិឧស្សាហកម្មរោងចក្របាវ ក្រចៅ រោងចក្រកៅស៊ូ ស្ករ ក្រដាស់ ...ក្នុងនោះមានការស្តាររោងចក្រស៊ីម៉ង់ ចក្រីទីង ដោយចិនប្រជាមានិត សង់នៅឆ្នាំ ១៩៦០ ដោយជំនួយចិនបម្រើ ៨០% នៃតម្រូវការគម្រោងមានលក្ខណៈនយោបាយកំពុងចរចារ ។

២.ដោយឡែកការរំសាយជាតូបនីយកម្ម ពីខែ វិច្ឆិកា ១៩៩១ សហគ្រាសជាកម្មសិទ្ធសមូហភាពមានភាពងាយស្រួលដែលកាន់កាប់ដោយ កិរិយាធិបតេយ្យ ។ នៅខែ មិថុនា ឆ្នាំ១៩៩២ រោងចក្រ ៤៩ ក្នុងចំណោម ៥៣ នៃក្រសួងឧស្សាហកម្ម បានប្រគល់ពួកវិនិយោគបរទេស ក្នុងរោងចក្រ ១០ បានត្រូវលក់ ៣១ រោងចក្រ ៨ ទៀត បញ្ចូលជាក្រុមហ៊ុនចម្រុះ ។ រោងចក្រនៃក្រុងភ្នំពេញ បានប្រគល់ឱ្យឯកជន ហើយខេត្តនានាក៏មានចលនាដូចគ្នាដែរ ។

ចុងឆ្នាំ ១៩៩២ ផលិតផលឧស្សាហម្មសរុប លើកឡើងតែថាមពល និងសេវាកម្មសឹងតែទាំងអស់បានត្រូវផ្ទេកឯកជនរ៉ាប់រង។ សរុបមកគេបានចូលទៅក្នុង ពិភពសេដ្ឋកិច្ចមួយទៀត។ រដ្ឋនៅសល់តែសមត្ថកិច្ចនយោបាយប៉ុណ្ណោះ។ នរណាជាអ្នកគ្រប់គ្រងសេដ្ឋកិច្ច? ហើយគ្រប់គ្រងដោយរបៀបណា។

## ៤.៣.ទិដ្ឋភាពប្រជាសាស្ត្រទូទៅ

ដោយសារជំរឿននាឆ្នាំ១៩៦២ គេប្រមូលបានតួលេខជាបរិមាណសឹងតែច្បាស់លាស់ស្តីអំពីប្រជាជន កម្ពុជា ។ ស្ថិតិ ក៏បានបញ្ជាក់ ១៩៩៣ សម័យកាលមុនថ្ងៃបោះឆ្នោតទូទៅនាខែឧសភា ˝ អ៊ុនតាក់ ˝ កាន់តែច្បាស់ ថែមទៀតនូវការវិវដ្តប្រជាសាស្ត្រកម្ពុជា ឆ្លងកាត់វិនាសកម្មជាងពីរទសវត្ស។ ការសិក្សាប្រព្រឹត្តទៅជាបន្តបន្ទាប់ នៅផ្នែកផ្សេងៗទៀត ដែលឱ្យនិយមន័យដល់ចលនារបស់ប្រជាជន ហើយចុងបញ្ចប់ការវិវដ្តជាបរិមាណទូទៅ នៃប្រជាជនកម្ពុជា។

### ៤.៣.១.រចនាសម្ព័ន្ធ អាយុ និងភេទ

ស្ថានភាពនៃប្រជាជនកម្ពុជា ជាបឋមគេឱ្យនិយមន័យតាមអាយុ និងតាមភេទ។ ស្ថានភាពនោះអាច គូសវាស់តាមពីរ៉ាមីតអាយុ។ ក្នុងសំណុំពីរ៉ាមីតយោង អាយុស៊ីមេទ្រីគ្នាហើយស្របទៅតាមភេទ។ សមាសភាព នោះមានភាពធម្មតា ហើយឆ្លុះបញ្ចាំងនូវចលនាធម្មជាតិរបស់ប្រជាជននោះ។ ព្រឹត្តិការណ៍សង្គ្រាម ទុរភិក្ស ដែល ធ្វើឱ្យរំជួយសមាសភាពនោះ និងចលនាអន្តោប្រវេសន៍អន្តរជាតិ និងរួមចំណែកធ្វើឱ្យមានការប្រែប្រួលយ៉ាង សំខាន់ដល់រូបភាពនៃពីរ៉ាមីត។

ក្នុងការលម្អិតពីរ៉ាមីត បង្ហាញពីភាពមិនទៀងទាត់នៃតួលេខនៃជំរឿន ដែលបញ្ជាញឱ្យឃើញថាប្រជាជនមានអាយុពី ៤ ទៅ ៩ ឆ្នាំ មានចំនួនច្រើនជាងប្រជាជនមានអាយុ ០ ឆ្នាំ ដល់ ៤ ឆ្នាំ។ ការ

ខូចខាតចន្លោះនេះ ពន្យល់ដោយឡែកបាន ដោយការប្រព្រឹត្តទៅនៃអ្នកអង្កេតនានាដែលបានរៀបចំ បែងចែកកុមារ អាយុលើសពី ៤ ឆ្នាំ និងតិចជាង ៩ ឆ្នាំ ដាក់ចូលទៅក្នុងក្រុមអាយុ ៥-៩ ឆ្នាំ ពីព្រោះថាកុមារជាច្រើនមានអាយុក្រោម ១ ឆ្នាំ មិនទាន់បានចុះនៅក្នុងបញ្ជីនៅឡើយ។ ជាប្រពៃណីនៅកម្ពុជា ការរាប់អាយុគិតត្រឹមតែពីក្បាលឆ្នាំ ទោះបីទារក ទើបនឹងកើតបានជាង ១ ឆ្នាំ កន្លះ ក៏រាប់ជា ២ឆ្នាំ ទៅហើយ។ការខ្វះចន្លោះផ្សេងទៀត គឺភាពខុសគ្នារវាងប្រជាជន អាយុពី ១០ ទៅ ១៥ ឆ្នាំ និងភាពខុសសគ្នារវាង អាយុពី ១៥ ទៅ ២០ ឆ្នាំ។ មានកុមារអាយុលើសពី ១៥ ឆ្នាំ បែរជាប្រកាសថាអាយុតិចជាង ១៥ ឆ្នាំ ដោយខ្លាចគ្មានសិទ្ធិចូលរៀន។ រចនាសម្ព័ន្ធតាមអាយុ ត្រូវបានសរុបលើតារាងបញ្ជាក់ដូចតទៅ៖

**តារាង១.១ រចនាសម្ព័ន្ធតាមអាយុ នៃយុវជនរបស់កម្ពុជា**

| អាយុ | ប្រជាជន (%) |
|---|---|
| 0 - ១៩ | ៥៣ |
| ២០ ៥៩ - | ៤២ |
| ៦០ - | ៥ |

តួលេខទាំងនេះ បង្ហាញពីលក្ខណៈសំខាន់នៃរចនាសម្ព័ន្ធតាមអាយុនៃយុវជនរបស់កម្ពុជា។

## ៤.៣.២.អត្រាកត់សម្គាល់

ដោយសារតែភាពមិនច្បាស់លាស់ នៃការចុះបញ្ជីអត្រានុកូលដ្ឋាន បញ្ជីជាតិកំណើត និងបញ្ជីមរណៈភាពនៅកម្ពុជា ហើយមិនអាចយកជាមូលដ្ឋានគិតគូរ ដល់អត្រាដែលបានបញ្ជាក់ពីចលនារបស់ប្រជាជន គេយកជាការបានតែចំពោះលទ្ធផលនានានៃការអង្កេត ដែលប្រព្រឹត្តទៅនៅឆ្នាំ ១៩៥៨ ១៩៥៩ ១៩៦២ និងមុនខែឧសភា ១៩៩៣ របស់អ៊ុនតាក់។

### ក.កំណើត

អត្រាកំណើតរស់ នាឆ្នាំ ១៩៥៨-១៩៥៩ ផ្តល់តួលេខ ៤២ %ហើយតាមជំរឿនឆ្នាំ ១៩៦២ ដែលខិតខំរកកំណើតក្នុងរយៈពេលមួយឆ្នាំ ផ្តល់តួលេខ ៤០។ អត្រាទាំងនេះសុទ្ធតែខ្ពស់ បើប្រៀបធៀបទៅ % នឹងអត្រាកំណត់សម្គាល់នៅប្រទេសអឺរ៉ុបតែជាអត្រាទាប បើគេមើលធៀបនឹងតួលេខនៅឯ ទ្វីបអាហ្វ្រិក និងអាមេរិក ព្រមទាំងតួលេខប្រទេសនៅអាស៊ីអាគ្នេយ៍។ អត្រា ៤០ %.ទៅ ៤២ %.នោះ គឺជាអត្រាកំណើតនៅកម្ពុជាពិតឬទេ? ដូចគេបានដឹងហើយថាអត្រាកំណើតបានផ្តល់ឲ្យនូវបាតុភូតជាគំនិតប្រហាក់ប្រហែលប៉ុណ្ណោះប្រជាជនទាំងអស់ រួមមានមនុស្សជាច្រើន ទាំងកុមារ ទាំងចាស់ទុំ ហើយស្ថិតនៅក្នុងស្ថានភាពខុសៗគ្នា។

ការប្រើប្រាស់ ដែលហៅថា អត្រាកំណើត អាចឱ្យយើងដឹងបង្គួរព ″ អត្រាកំណើតពិសេស ‶ី បាតុភូតនោះ។ នៅលើមូលដ្ឋាននៃជំរឿនឆ្នាំ ១៩៦២ អត្រាកំណើតទូទៅ គឺ ១៧៥% ដែលនេះ គឺជាអត្រាទាប ចំពោះ ប្រទេសក្តៅ។ នៅអាហ្វ្រិក អាមេរិកឡាទីន អត្រាកំណើតមានចំនួន ២៥០ %។

អត្រាកំណើតទូទៅ គឺជាចំនួនកុមារកើតមករស់ ក្នុងរយៈពេលមួយឆ្នាំ ចែកនឹងចំនួនប្រជាជនភេទស្ត្រី ដែលមានអាយុពរពោះបាន គឺស្ត្រីមានអាយុចន្លោះ ១៥ ទៅ ៤៩ ឆ្នាំ។

បាតុភូតទាំងនោះ អាចពន្យល់បាន ដោយសារការខ្វះខាតនៃការចុះបញ្ជីកំណើត។ ក្នុងករណីនេះ អត្រាដែលបានគិតគូរ ពិតជាមានកម្រិតទាបជាងអត្រាពិត។ មានបញ្ហាពីរត្រូវយកមកគិត គឺការពន្លូតកូន និងការធ្វើមិនឱ្យមានកូន តែមិនសូវកើតមានបែបនេះទេនៅកម្ពុជា ជាពិសេសនៅទីក្រុង។ មានបាតុភូតបញ្ជាក់ថា ៨៣% នៃស្ត្រីដែលមានអាយុពី ១៥ ទៅ ២០ឆ្នាំ និង៣២% នៃស្ត្រីដែលមានអាយុពី ២០ ទៅ ២៥ មិនទាន់រៀបការ។ ស្ត្រីមេម៉ាយក៏ច្រើន ដោយសារសង្គ្រាម។ ក្រោយឆ្នាំ ១៩៧៩ ស្រីមានចំនួន ៦០% នៅក្នុងសង្គម ក្នុងនោះស្ត្រី មេម៉ាយមានកម្រិតខ្ពស់។ កំណើតខុសច្បាប់មានចំនួនតិចតួចទេនៅកម្ពុជា។

ការពន្យល់នូវបាតុភូតនានា មិនទាន់គ្រប់គ្រាន់នៅឡើយ ចំពោះកម្រិតទាបនៃអត្រាកំណើតដែលបានចុះក្នុងបញ្ជី ហើយអ្នកជំនាញការបានណែនាំឱ្យកែតម្រូវនូវអត្រាកំណើតទាបបែបនេះ។ ការអនុវត្តនូវអត្រាតាមអាយុនៃប្រជាជនកំណើតជាស្ត្រីភេទនាឆ្នាំ ១៩៦២ ដោយមានការបែងចែកតាមក្រុមអាយុ បានត្រូវទទួលស្គាល់ថាការសន្និដ្ឋានកំណើតនាឆ្នាំ ១៩៦២ មានការកែតម្រូវតួលេខពី ៤២ % ដល់ ៤៤.៥% ។

តួលេខនោះ នៅមិនឆ្ងាយពីការពិតទេ។ យើងសន្មត់នូវអត្រាកំណើតនៅកម្ពុជានាឆ្នាំ ១៩៦២ ថាមាន តួលេខ ៤៤% ហើយអត្រាកំណើតក្រោយសង្គ្រាម ដែលធ្វើជំរឿនដោយអ៊ុនតាក់ គឺ ២.៨% នាឆ្នាំ ១៩៩៣ ។

កំណើតតាមអាយុនៃប្រជាជនជាស្ត្រីភេទនាឆ្នាំ ១៩៦២ ដោយមានការបែងចែកតាមក្រុមអាយុ បានត្រូវទទួលស្គាល់ថាការសន្និដ្ឋានកំណើតនាឆ្នាំ ១៩៦២ មានការកែតម្រូវតួលេខពី ៤២ % ដល់ ៤៤.៥% ។

តួលេខនោះ នៅមិនឆ្ងាយពីការពិតទេ។ យើងសន្មត់នូវអត្រាកំណើតនៅកម្ពុជានាឆ្នាំ ១៩៦២ ថាមាន តួលេខ ៤៤%ហើយអត្រាកំណើតក្រោយសង្គ្រាម ដែលធ្វើជំរឿនដោយអ៊ុនតាក់ គឺ ២.៨% នាឆ្នាំ ១៩៩៣ ។

អត្រាស្លាប់តាមអាយុ និងភេទ មានភាពមិនច្បាស់លាស់ជាងអត្រាស្លាប់ទូទៅ។ មរណៈភាពរបស់កុមារមានចំនួន ១២៧ %.ជាអត្រាខ្ពស់ហួសហេតុ។ ស្ត្រីភេទនៅជនបទមានមរណៈភាពក្នុងអត្រាខ្ពស់នៅពេលឆ្លងទន្លេ។

**ខ. កំណើនធម្មជាតិ**

បើអត្រាកំណើននាឆ្នាំ ១៩៦០ មានចំនួន ៤៤ ‰ ហើយអត្រាមរណៈភាពមាន ១៨‰ គឺអត្រាកំណើន ប្រជាជនពេលនោះមានចំនួន ២៦ ‰។ អត្រានេះ ប្រហាក់ប្រហែលនឹងការសន្និដ្ឋានរបស់អ៊ុនតាក់នាឆ្នាំ ១៩៩៣ មុនពេលបោះឆ្នោតទូទៅ គឺ ២៨‰ ។

ការយល់ដឹងគ្រប់គ្រាន់នៃអត្រាទាំងបីខាងលើ នាំឱ្យយើងពិចារណាលើការវិវដ្តនៃប្រជាជនកម្ពុជាបាន កាន់តែច្បាស់លាស់។

### ៤.៣.៣.ការវិវដ្តបរិមាណ

ប្រជាជនកម្ពុជាក្នុងសម័យរុងរឿង ពិសេសសម័យអង្គរ ក៏គ្មានចំនួនប្រជាជនពិតប្រាកដដែរ។ គេគ្រាន់តែដឹងថាពេលនោះប្រទេសមានប្រជាជនច្រើន ឬមានចំនួនច្រើនជាងពេលបច្ចុប្បន្ន។ នៅមុនឆ្នាំ ១២០០ តួលេខមានចំនួន ១០,០០០,០០០ នាក់ វាដូចជាច្រើនណាស់សម្រាប់ពេលនោះ បើសិនយើងគិតទៅដល់ផ្ទៃដីនៃព្រះរាជាណាចក្រ ដែលធំជាងសព្វថ្ងៃប្រហែល ៥-៦ ដង។ ពិតណាស់ហើយ នៅក្នុងរយៈពេលចំនួនរាប់សតវត្ស នៃសង្គ្រាមស៊ីវិល និងសង្គ្រាមជាមួយបរទេស ពិសេសជាមួយពួកសៀម ដែលតែងតែជម្លៀសប្រជាជន ពីខេត្តដែលគេដណ្តើមបានទៅខេត្តផ្សេងៗទៀត ពេលខ្លះប្រជារាស្ត្រទាំងនោះត្រូវគេសម្លាប់រង្គាលទៀតផងនោះ គេឃើញចំនួនប្រជាជនកម្ពុជា ពិតជាថយចុះយ៉ាងពិតប្រាកដ។

ការសន្និដ្ឋានដំបូងៗ ពីបញ្ហាប្រជាជន បានប្រព្រឹត្តទៅចាប់ពីវត្តមានដំបូងរបស់បារាំង។ ប្រទេសកម្ពុជា បើនិយាយចំពោះទឹកដីសព្វថ្ងៃ មានប្រជាជនចំនួន ១,០០០,០០០ នាក់។ លោក Aymonnier ជាមនុស្សតែមួយ ដែលបានសន្និដ្ឋាននៅក្នុងសៀវភៅកំណត់ហេតុរបស់លោកថា នៅឆ្នាំ ១៩០០ កម្ពុជាមានប្រជាជន ចំនួនប្រមាណ ២,៣០០,០០០ នាក់ ក្នុងនោះខ្មែរមាន ១,២០០,០០០ នាក់ ជាង ៨០០,០០០ នាក់ទៀត ជាខ្មែរដែលត្រូវគេកាត់ខេត្តភាគខាងលិច និងខាងកើតពីកម្ពុជា ឱ្យទៅវៀតណាម និងជនអន្តោប្រវេសន៍ជាង ៣០០,០០០ នាក់។

ចេញពីតួលេខ ចំនួនប្រជាជននៅឆ្នាំ ១៩៦២ ដែលជាតួលេខមានការធានាច្បាស់លាស់ គឺគេគិតទាំងជន អន្តោប្រវេសន៍ផងដែរ។ តួលេខនោះមានចំនួនខ្ពស់ជាង។ ការជំរឿននាឆ្នាំ ១៩២១ មានចំណុចខ្វះខាតចំនួន ប្រជាជនដល់ទៅ ២០០,០០០ នាក់ ស្មើនឹង ៧%។ ចំនួននេះមិនច្រើនហួសពេកទេ ព្រោះការធ្វើជំរឿនរបស់ ពួកអាណានិគម មានគោលដៅផ្អែកពន្ធអាករ។

អត្រាកំណើនប្រជាជននាឆ្នាំ ១៩៦២ កំណត់ថាមាន ២៦‰ ។ ដូច្នេះប្រជាជនកម្ពុជាមានចំនួន ៨ លាននាក់ គិតដល់ឆ្នាំ ១៩៧៥។ បើអត្រាកំណើននេះថយចុះខ្លាំង បញ្ជាក់ " អនុភាពនៃរចនាសម្ព័ន្ធ " ឆ្នាំ គឺជាអ្នកទើបនឹងកើតថ្មី ១៤ ទៅ ០ ថាប្រជាជនមិនកើនឡើងរហ័សទេ។ ជំនាន់អ្នកដែលមានអាយុមានសភាពខ្ពស់។ " សក្តានុពលកំណើន " នោះ គឺកុមារមានចំនួនច្រើន។ នៅក្នុងរចនាសម្ព័ន្ធសព្វថ្ងៃ

## ៤.៤.ប្រជាជនសកម្ម

ការសិក្សាប្រជាជនកម្ពុជា ត្រូវសិក្សាក្នុងនាមប្រជាជននោះធ្វើពលកម្ម។ នេះជាការគិតគូរបញ្ហាប្រជាសាស្ត្រនៅក្រោមមុំនៃសេដ្ឋកិច្ច។ ជាមតិមួយ ធ្វើយ៉ាងណាប្រមូលផ្តុំឱ្យបាននូវតួលេខមុនឆ្នាំ ១៩៥៨ ស្តីពីប្រជាជនសកម្ម និងតួលេខនៅឆ្នាំ ១៩៩៣ ក្រោយសង្គ្រាមជាងពីរទសវត្ស។ ប្រជាជនសកម្មនេះឯងដែលតំណាងឱ្យថាមពលពិសេសក្នុងផ្នែកសេដ្ឋកិច្ច។

### ៤.៤.១.ប្រជាជនទីក្រុង និងប្រជាជនជនបទ

គេធ្វើការកត់ចំណាំច្រើនបែប ស្តីពីការបែងចែករវាងប្រជាជនទីក្រុង និងប្រជាជនជនបទ។

ក.បាតុភូតពីរនៃការរៀបចំទីក្រុង គឺទើបនឹងកើតមាន ហើយមានការអភិវឌ្ឍខ្លះៗនៅកម្ពុជា។ ការរៀបចំទីក្រុងនានានៅឆ្នាំ ១៩៦០ បានធ្វើឱ្យ តំបន់ជនបទ ដាច់ខុសពី តំបន់ទីក្រុង។ ក្រុងថ្មីៗបានកើតប្រជាជន ១៩៦២ ឡើងដូចជា ទីក្រុងភ្នំពេញ បូកគោ កែប គីរីរម្យ និងក្រុងនៃទីរួមខេត្តទាំងអស់។ ក្នុងឆ្នាំ ៦០០ ក្រុងមានចំនួន,០០០ នាក់ ស្មើនឹង ១០% នៃប្រជាជនសរុប។ នៅឆ្នាំ ១៩២១ ប្រជាជនទីក្រុងមានតែ ១៣០,០០០ នាក់ទេ លើសពី ៥% នៃប្រជាជនទូទៅបន្តិច។ វាកើតមានបាតុភាពធ្វើអន្តោប្រវេសន៍ពីជនបទ មកទីក្រុង នៅក្រោយ សង្គ្រាមលោក ក៏ដូចនៅឆ្នាំ ១៩៨០ និង១៩៩០ ដែរ។ ការចាកចោលជនបទនេះ មាននិន្នាការឆាប់បន្ទាន់ ។ នៅ ឆ្នាំ ១៩៦៧ ប្រជាជនទីក្រុងមានចំនួន ៧០០,០០០ នាក់ ស្មើ ១២% នៃប្រជាជនសរុប។ ក្រោយសង្គ្រាម តាម ស្ថិតិអ៊ុនតាក់នាឆ្នាំ ១៩៩៣ ប្រជាជនក្រុងភ្នំពេញមានចំនួនកើនឡើងដល់ ១ លាននាក់ ដោយមិនទាន់រាប់បញ្ចូលប្រជាជនដែលចេញ និងចូលក្រុងប្រចាំថ្ងៃនៅឡើយ។ ប្រជាជនទីក្រុងទាំងនេះមានប្រភពដើមនៅជនបទ។ សង្គ្រាមរវាងពួកបារាំង និងវៀតមិញ ពីឆ្នាំ ១៩៤៨ ដល់ ១៩៥៤ បានធ្វើឱ្យប្រជាជនជនបទប្រមូលផ្តុំ រស់នៅតាមផ្លូវជាតិ ហើយពេលសង្គ្រាមចប់គេមិនវិលទៅភូមិដ្ឋានវិញទេ គឺវិលមករកទីក្រុងដូចជា ក្រោយថ្ងៃ ៧ មករា ១៩៧៩ ដែរ។ កម្លាំងចលនាសំខាន់ ដែលធ្វើឱ្យមានអន្តោប្រវេសន៍ពីជនបទ មកកាន់ទីក្រុង គឺចលនាសេដ្ឋកិច្ចៈ កសិករក្រីក្រ រកប្រភពបន្ថែមសម្រាប់ចិញ្ចឹមគ្រួសារ ហើយអ្នកខ្វះការងារធ្វើនៅជនបទ ស្វែងរកការងារនៅទីក្រុង។

បញ្ហាសំខាន់មួយទៀត គឺអនក្ខរកម្ម ដែលនៅឆ្នាំ ១៩៦២ នៅក្នុងក្រុងមានអ្នកមិនចេះអក្សរ ៣២% និងជនបទមាន ៦១% ។

ខ. ការកើនឡើងនៃប្រជាជនសរុប ប្រព្រឹត្តទៅទន្ទឹមគ្នានឹងការកើនឡើងនៃប្រជាជនជនបទ។ ផ្ទុយគ្នា ស្រឡះពីអ្វីដែលកើតមាននៅអឺរ៉ុប និងជប៉ុន ការកើនឡើងនៃប្រជាជនមិនត្រូវបានស្រូបយកដោយទីក្រុងទេ។ រវាងឆ្នាំ ១៩២១ និង១៩៦៦ ប្រជាជនកម្ពុជាបានកើនឡើងដល់ ៣,១៤០,០០០ នាក់ ហើយនៅទីក្រុងកើនឡើង ដល់ ៦០០,០០០ នាក់ ។ ផលិតភាពកសិកម្មត្រូវតែកើនឡើងតាមចំនួននៃមនុស្ស និងតាមរយៈផ្ទៃដីដាំដុះ បើគេ ចង់ឱ្យចំណូលផលរបរពិតនៃកសិករបានកើនឡើង។

ប្រជាជនកម្ពុជា មាននៅជនបទជិត ៩០% ។ ការសិក្សាពីប្រជាជនសកម្ម អាចឱ្យយើងរកលក្ខណៈពិសេសរបស់សេដ្ឋកិច្ចកម្ពុជាពិសេសផ្នែកពលកម្មសម្រាប់ចលនារៀបចំទីក្រុងដែលបានចាប់ផ្ដើមរួចមកហើយ។

### ៤.៤.២.សារៈសំខាន់នៃប្រជាជនសកម្ម

ប្រជាជនសកម្ម បានត្រូវគេឱ្យនិយមន័យថា ជាកន្សោមមនុស្សដែលធ្វើពលកម្មទទួលបាននូវកម្រៃ។ ព្រះសង្ឃ លោកអាចារ្យនៃសាសនាទាំងអស់ រួមទាំងអ្នកស្វែងរកការងារធ្វើ និងអ្នកមានជំងឺបណ្ដោះអាសន្ន ក៏សុទ្ធតែជាប្រជាជនសកម្មក្នុងសេដ្ឋកិច្ចដែរ។ តែប្រជាជនដ៏ទៃទៀតបានត្រូវចាត់ទុកថា ប្រជាជនអសកម្ម។

ក. នៅឆ្នាំ ១៩៦២ ប្រជាជនសកម្មនៅកម្ពុជាមានចំនួន ២,៥០០,០០០ នាក់ ប្រហែល ៤៤% នៃប្រជាជនសរុប។ តួលេខនេះ ប្រហាក់ប្រហែលនឹងប្រជាជនដែលមានអាយុ ១៥ ដល់ ៦០ ឆ្នាំ ដែលមាន ២,៨០០,០០ នាក់ ស្មើនឹង ៥១% នៃប្រជាជនសរុប។ រចនាសម្ព័ន្ធ អាចផ្ដល់នូវភាពទន់ខ្សោយនៃប្រជាជនសកម្ម ធៀបនឹង ប្រជាជនសរុប។ កំណើនអត្រាកម្រិតខ្ពស់នៅកម្ពុជា បញ្ជាក់ពីជន មាន អសកម្ម។ ជនសកម្ម ច្រើនជាង

ការថយចុះនៃមរណៈភាព នឹងបង្កើនទម្ងន់ដល់មនុស្ស ដែលភាគច្រើនគ្មានសកម្មភាពពលកម្ម ហើយការសិក្សារបស់យុវជន និស្សិត ពន្យឺតពេលនៃការចូលខ្លួនរបស់ពួកគេទៅក្នុងទីផ្សារពលកម្ម។ នេះជាបញ្ហាសំខាន់ ដែលផលិតភាពការងាររបស់មនុស្សម្នាក់ៗ កើនឡើងយឺតជាងផលិតផលតាមពលកម្មនីមួយៗ នោះគឺផលិតភាពការងារ។ មួយផ្នែកនៃការរីកចម្រើនសេដ្ឋកិច្ច នឹងត្រូវបាន តាមរយៈការថយ ស៊ីចុះនៃអត្រាសកម្មភាព។

បើគិតដល់មនុស្សដែលមានអាយុ ១៥ ដល់ ៦០ ឆ្នាំដែលគ្មាន ៥០០ គឺមាន សកម្មភាព,០០០ នាក់ ដែលរស់នៅតែក្នុងផ្ទះ។ គេបានកត់សម្គាល់ទៀតថាមនុស្សអាយុក្រោម ១៥ ឆ្នាំ និងលើលពី ៦០ ឆ្នាំក៏មានច្រើន ណាស់ដែរ។ មិនបាច់សង្ស័យឡើយផលិតភាពការងារ គឺមិនខ្ពស់នោះទេ។

ខ. ការវិភាគយ៉ាងល្អិតល្អន់ នៃអត្រាសកម្មភាពផ្សេងៗ ដែលអាចឱ្យយើងគិតគូរបាន នាំទៅរកការកត់ ចំណាំ ដូចតទៅៈ

ជាធម្មជាតិ ប្រជាជនសកម្មភេទប្រុស មានសារៈសំខាន់ជាងប្រជាជនសកម្មភេទស្ត្រី។

ប៉ុន្តែការពិតនៃតួលេខនៃភេទស្ត្រី សកម្ម គឺមានអត្រាសកម្មភាពខ្ពស់គួរឱ្យកត់សម្គាល់ គឺ ៣៧% នៃ ប្រជាជន។ នៅក្នុងវិស័យកសិកម្ម ស្ត្រីដើរតួនាទីពលកម្មដូចបុរស។ នៅក្នុងវិស័យផ្សេងទៀត គឺមានភាពខុស គ្នា។ អត្រាសកម្មភាពនៃប្រជាជនសកម្មភេទស្ត្រី នៅក្នុងវិស័យមិនមែនកសិកម្ម ឬនៅទីក្រុងមានចំនួនទាប។ ស្ត្រីភេទនៅកម្ពុជាធ្វើការតិចតួចណាស់ បើគេមានប្តីជាអ្នកក្រុង។ ប៉ុន្តែនៅជនបទស្ត្រីក៏រកស៊ីមុខរបរផ្សេងៗដែរ បើសិនប្តីគេជាកសិករ។

ជាគោលការណ៍ ក្នុងមតិបែបនេះ ទើបអត្រាសកម្មភាពមានកម្រិតខ្ពស់ជាង នៅក្នុងប្រជាជនកសិករ ជាងប្រជាជនមិនមែនកសិករ ឬនៅជនបទច្រើនជាងនៅទីក្រុង។ នៅកម្ពុជាប្រជាជនសកម្មផ្នែកបុរស ក៏កត់សម្គាល់ឃើញមាន ខ្លាំងនៅមជ្ឈដ្ឋានជនបទ ក្នុងវិស័យកសិកម្ម ជាងមជ្ឈដ្ឋានទី សកម្មភាពក្រុង ឬមិនមែនកសិកម្ម។ តាមការប្រែប្រួលនៃរចនាសម្ព័ន្ធអាយុ និងយោលទៅតាមមជ្ឈដ្ឋាននានា មានស្ថានភាពផ្ទុយទៅវិញ ដែលនាំឱ្យមានអត្រាសកម្មភាពមិនសូវខ្ពស់នៅជនបទ ជាងនៅទីក្រុង។ យើងត្រូវមើលឱ្យឃើញនូវអានុភាពនៃភាពគ្មានការងារធ្វើនៅទីក្រុង ឬការខ្វះពលកម្មនៅជនបទ។ នៅទីក្រុងការរកពលកម្មមកធ្វើមិនសូវលំបាកទេ តែនៅជនបទបែរជាមានការលំបាកក្នុងការរកការងារធ្វើ ដោយសារកសិកម្មរណបទៅនឹងរដូវកាល ឯនៅទីក្រុងមាន
ឧស្សាហកម្មដែលទើបនឹងចេញពន្លកថ្មី និងមានសេវាកម្មផ្សេងៗច្រើនជាងនៅជនបទ។

នៅកម្ពុជា មានភាពអត់ការងារធ្វើនៅគ្រប់ផ្នែក ហើយផលិតភាពការងារនៅខ្សោយណាស់។ តែក្នុងវិស័យកសិកម្ម ជាឧទាហរណ៍ ការកាប់គាស់ដីស្រែ ចំការថ្មី ការដោះមីនចេញពីដីស្រែ ការអភិវឌ្ឍដំណាំស្រូវ ជា រៀងរាល់ឆ្នាំ ជានាបាននូវពលកម្មដល់កសិករ ដើម្បីពង្រីកផលិតភាពការងារឱ្យកើនឡើងតាមរយៈធ្វើកសិកម្ម ដើម្បីបម្រើពាណិជ្ជកម្ម។

## ៤.៤.៣.ការបែងចែកប្រជាជនសកម្ម

នៅមុនឆ្នាំ ១៩៧០ ក៏ដូចនៅក្រោយឆ្នាំ ១៩៩០ ប្រជាជនសកម្មនៅកម្ពុជាគិតតាមផ្នែកទាំងបីនៃវិស័យសេដ្ឋកិច្ចមិនមានអ្វីប្រែប្រួលទេ៖

- ផ្នែកទីមួយ .......................................... ៨១ %
- ផ្នែកទីពីរ ............................................ ៤ %
- ផ្នែកទីបី .......................................... ១៥ %

ផ្នែកពលកម្មក្នុងកសិកម្ម មានកម្រិតខ្ពស់ជាងគេ។ នៅក្នុងប្រទេស បាន ១៥ ចំនួន ឱនាភិវឌ្ឍន៍ បែងចែកពលកម្មតាមផ្នែកសេដ្ឋកិច្ចដូចតទៅ៖

- ផ្នែកទីមួយ ........................................... ៥២%
- ផ្នែកទីពីរ ............................................ ១៨%
- ផ្នែកទីបី ............................................. ២៦%

ដូចនេះយើងឃើញថាភាគច្រើននៃពលករកម្ពុជាបូជាកម្លាំងកាយ ដើម្បីវិស័យកសិកម្ម រុក្ខកម្ម នេសាទ ប្រមាញ់។ ការអង្កេតឆ្នាំ ១៩៥៨ អាចបញ្ជាក់រូបភាពនៃសកម្មភាពនានា តាមរយៈការបែងចែកភាគរយនៃពលករ សរុបនៃវិស័យកសិកម្ម៖

- អ្នកដាំដុះស្រូវ ................................. ៨១%
- កសិករផ្សេងទៀត ................................. ១៦%

- អ្នកនេសាទ .................................. ៣%

តួលេខនេះ បញ្ជាក់ពីសារៈសំខាន់នៃដំណាំស្រូវ។ កសិករជាង ៨០% តំណាងឱ្យ ៦៥% នៃប្រជាជនសកម្មសរុបនៅឆ្នាំ ១៩៦២ មានចំនួន ១,៧០០,០០០ នាក់ ដែលធ្វើពលកម្មស្រូវ។

ប្រៀបធៀបពលកម្មនៅក្នុងឧស្សាហកម្មក៏លេចចេញនូវរូបភាពមិនទាន់រីកចម្រើនដែរ។ នៅឆ្នាំ ១៩៦២ តាមជំរឿនមួយគេរាប់ឃើញពលករក្នុងវិស័យកម្មន្តសាលមានចំនួនតិចជាង ៧០,០០០ នាក់តែប៉ុណ្ណោះ និងមានចំនួនជាង ២០,០០០ នាក់ នៅក្នុងវិស័យសំណង់ និងសាធារណៈការ ហើយមានពលករប្រហែលរាប់ពាន់នាក់ ក្នុងវិស័យជីករ៉ែ ផលិតផលអគ្គិសនី ទឹក និងឧស្ម័ន។ សរុបមក មានចំនួនតិចជាង ១០០,០០០ នាក់ទេ។

ការសន្និដ្ឋាននានានៃក្រសួងការងារនាឆ្នាំ ១៩៦២ បានបញ្ជាក់តួលេខខុសគ្នាបន្តិចបន្តួច ស្តីពីការចែក ពលកម្មក្នុងវិស័យឧស្សាហកម្ម ដែលមានតួលេខចំនួន ១១០,០០០ នាក់ រាប់ទាំងកម្មករផ្នែកសំណង់ដែលមាន ចំនួន ១៣,០០០ នាក់ និងផ្នែកថាមពលដែលគេចាត់ចូលក្នុង វិស័យទី៣ ។

ប្រជាជនសកម្មធ្វើការនៅក្នុងផ្នែកទីពីរ ទោះបីជាមានការរីកចម្រើន ក៏នៅតែមានសភាពខ្សោយនៅ ឡើយ។ នៅពេលនោះ មានមិនលើសពី ៤% នៃប្រជាជនសកម្មសរុបនោះទេ។

ផ្នែកនៃវិស័យទីបី មានសារៈសំខាន់ទីបី ព្រោះមានចំនួនតិចជាង ៤០០,០០០ នាក់ ធ្វើការនៅក្នុងផ្នែក នេះ។ ជំរឿនឆ្នាំ ១៩៦២ បានផ្តល់តួលេខចំនួន ៣៩៧,០០០ នាក់ ក្នុងនោះមាន ៣៧,០០០ នាក់ ស្ថិតនៅក្នុង សកម្មភាព ពិបាកដាក់ឈ្មោះឱ្យ។

- ដឹកជញ្ជូន និងគមនាគមន៍ .................................. ១%
- ពាណិជ្ជកម្ម និងធនាគារ .................................. ៦%
- សេវាកម្មផ្សេងទៀត .................................. ៧%

តាមការសិក្សារបស់លោក M. KUZ NETS ថា តួលេខមធ្យមនៃប្រទេសឱនាភិវឌ្ឍន៍ចំនួន១៥៣ មានតារាងបង្ហាញថា៖%, ៧%, ១២%។ ដូចនេះ ប្រទេសកម្ពុជានៅមានចំណុចឱនាភិវឌ្ឍន៍នៃសេវាកម្មនិងការងារដឹកជញ្ជូន ដែលមិនបានស្តារឡើងវិញទាំងស្រុង ពីការបំផ្លាញនៃសង្គ្រាម។

នៅឆ្នាំ ១៩៦៧ ក្រសួងការងារ បានផ្តល់តួលេខថា ប្រជាជនសកម្មនៅក្នុងវិស័យសេវាកម្ម មានចំនួន ៣៨០,០០០ នាក់៖

- សំណង់ ថាមពល .................................. ១៣.១០០ នាក់
- ពាណិជ្ជកម្ម .................................. ៩១.០០០ នាក់
- ដឹកជញ្ជូន .................................. ៤៨.៧០០ នាក់
- ផ្នែកសាធារណៈការ .................................. ៩៣.៨០០ នាក់
- ផ្នែកសាសនា .................................. ៦៤.៥០០ នាក់
- សេវាកម្ម សហគ្រាស .................................. ១.៣០០ នាក់

- សេវាកម្ម លំហែកាយ ................................ ៣.៤០០ នាក់
- សេវាកម្ម បុគ្គលិក ................................ ៦០.០០០ នាក់

ការសិក្សាពីប្រជាជនសកម្ម បញ្ជាក់ពីគំនូសជាមូលដ្ឋាននៃសេដ្ឋកិច្ចកម្ពុជា។ វានៅសល់តែការបញ្ជាក់ថា ប្រជាជនសកម្មនោះ គេផលិត និងប្រើប្រាស់អ្វីខ្លះនៅកម្ពុជា។

# មេរៀនទី ៥
# ទិដ្ឋភាពវប្បធម៌សង្គម

លក្ខណៈវប្បធម៌សង្គមមានសារៈសំខាន់ជាបន្ថែមដើម្បីស្វែងយល់ពីសេដ្ឋកិច្ចនៅកម្ពុជា និងជាពិសេសសំខាន់ចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ ឧបសគ្គនៃការលូតលាស់សេដ្ឋកិច្ច គឺស្ថិតនៅក្នុងគំនិតរបស់សង្គម ដែលពាក់ព័ន្ធ ទៅនឹងបញ្ហាកត្តាសង្គមទាំងឡាយ និងពីចិត្តសាស្ត្រសង្គមនោះ ដែលមានតថភាពរបស់ខ្លួននៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការសិក្សាវិទ្យាសាស្ត្រនានា មានចំណុចខ្វះខាតស្ទើរតែទាំងស្រុង នៅលើបញ្ហាការធ្វើអត្ថាធិប្បាយពី ចិត្តសាស្ត្រសង្គម ដែលរួមចំណែកដល់ការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ច។

ក្រោយរំលឹកត្រង់ចំណុចជនជាតិខ្មែរ យើងដឹងថា ជនជាតិនេះជាជនជាតិដើមនៅជ្រោយឥណ្ឌូចិន មិនខុសអ្វីពីជនជាតិឥណ្ឌូនេស៊ី ម៉ាឡេ ដែលមានសម្បុរស្រដៀងគ្នា ហើយបានបង្កើតជាកូនកាត់ជាតំណរជាមួយពួកឥណ្ឌា ពួកព័រទុយហ្គេ ពួកអេស្ប៉ាញ ឡាវ ថៃ វៀតណាម បារាំង និងចិន។ យើងកត់សម្គាល់បញ្ហាបីចំណុច ដែលមានផលលំបាកយ៉ាងធ្ងន់ធ្ងរទៅលើវិស័យសេដ្ឋកិច្ចៈ អត្ថិភាពនៅកម្ពុជានៃសារៈសំខាន់ នៃចិត្តសាស្ត្រជនជាតិភាគតិច នៃព្រះពុទ្ធសាសនា ដែលជាសាសនារបស់ប្រជាជនភាគច្រើន និងនៃកម្រិតចេះដឹងទាបរបស់ ប្រជាជន។

## ៥.១.អត្ថិភាពនៃជនជាតិភាគតិច

អត្ថិភាពនៃសារៈសំខាន់របស់ជនជាតិភាគតិច វប្បធម៌ និងសាសនាទាំងឡាយជាលក្ខណៈមួយពិសេសរបស់ប្រទេសកម្ពុជា។

ជនជាតិពីរ ដែលតាមផ្លូវច្បាប់ត្រូវបានគេបែងចែកដោយឡែក គឺៈ ជនជាតិចិន និងវៀតណាម ដែលត្រូវគេចាត់ទុកជាជនបរទេស។ ជនជាតិទាំងពីរនេះ មានចំណុចខុសគ្នា។ សហគមជនជាតិចិនភាគច្រើនបានចូលរស់នៅលាយឡំសាច់ឈាម បង្កាត់ពូជជាមួយខ្មែរ។ ឯពួកជនជាតិវៀតណាម មិនអាចបញ្ចូលគ្នាបានទេ។

### ៥.១.១.ជនជាតិវៀតណាម

នៅឆ្នាំ ១៩៦៧ មានជនជាតិវៀតណាមប្រហែល ២៥០,០០០ នាក់ ស្មើនឹង ៤% នៃប្រជាជនសរុប។ កាលនោះ ពួកវៀតណាមមានច្រើននៅភ្នំពេញ ពិសេសនៅតាមក្រុងនានា នៅតាមព្រំដែន កម្ពុជា-វៀតណាម លើដងទន្លេ ពិសេសក្នុងតំបន់បឹងទន្លេសាប។

ជនជាតិវៀតណាម មានសារៈសំខាន់ខាងសេដ្ឋកិច្ច លើវិស័យបីសំខាន់គឺ សិប្បកម្ម សំណង់ និងនេសាទ។ ក្នុងសម័យអាណានិគម ជនជាតិវៀតណាម បានបម្រើការមួយចំនួន ក្នុងវិស័យរដ្ឋបាល និងសេ

វាកម្មនានា ប៉ុន្តែរដ្ឋធម្មនុញ្ញ នៃអតីតព្រះរាជាណាចក្រកម្ពុជា បានហាមជនបរទេសចូលបម្រើក្នុងវិជ្ជាជីវៈផ្សេងៗ។

១/៤ នៃជនជាតិវៀតណាម កាន់សាសនាកាតូលិក។ ក្នុងកំណត់ហេតុរបស់លោក M. Delvert បាន និយាយថា ជនជាតិវៀតណាមជាជនជាតិមួយ ដែលមានគ្រោះអាសន្នខាងផ្នែកនយោបាយ ហើយមិនមែនជាទី ពេញចិត្តនៃប្រជាជនក្នុងស្រុកទេ។

នៅក្នុងរដ្ឋប្រហារឆ្នាំ ១៩៧០ ជនជាតិវៀតណាមនៅកម្ពុជា បានត្រូវកាប់សម្លាប់ និងដេញចេញអស់ពី កម្ពុជាដោយពួកខ្មែរក្រហម។ ពេលដែលពួកខ្មែរក្រហមដួលរលំពីអំណាច ពួកជនជាតិនេះបានវិលត្រឡប់មកវិញក្នុងចំនួនមិនទាន់ពិតប្រាកដ។ បើតាមការប្រកាសរបស់ក្រសួងមហាផ្ទៃ សព្វថ្ងៃចំនួនជនជាតិវៀតណាម មានជិតស្មើនឹងកាលឆ្នាំ ១៩៦៧ ។

## ៥.១.២.ជនជាតិចិន

ជនជាតិចិននៅកម្ពុជា ពិបាកឱ្យនិយមន័យណាស់។ គេអាចប្រើនូវលក្ខណៈ ៤ យ៉ាង សម្រាប់សម្គាល់៖

- លក្ខណៈជនជាតិ ជាជនជាតិចិន គឺជាអ្នកដែលមានឈាមជ័រជាជនជាតិចិន
- លក្ខណៈផ្លូវច្បាប់ ជាជនជាតិចិនដែលកាន់លិខិតឆ្លងដែនចិន
- លក្ខណៈភាសាជាចិន ជាជនជាតិចិនដែលនិយាយភាសាចិននៅផ្ទះ
- លក្ខណៈវប្បធម៌ ជាអ្នកដែលដឹងខ្លួនថាជាចិន

លក្ខណៈទីមួយមិនអាចយកជាការបាន ព្រោះចិនជាច្រើនបានបញ្ចូលសាច់ឈាមជាមួយខ្មែរតាម រយៈអាពាហ៍ពិពាហ៍។ ជនអន្តោប្រវេសន៍ចិនមានយូរលង់ណាស់មកហើយ តាំងពីសម័យអង្គរនៃសតវត្សទី ១៣។ នៅឆ្នាំ ១៨៥០ ដល់ ១៩៥០ អន្តោប្រវេសន៍នៃចិន បានត្រូវកាត់បន្ថយ ដោយបារាំង លើកលែងតែនៅ តុងកឹង និងអានណាម ដោយឡែកនៅកម្ពុជា គ្មានការអនុញ្ញាតនូវអន្តោប្រវេសន៍ចិនឡើយ។

ការធ្វើអន្តោប្រវេសន៍នេះ គឺជាការធ្វើអន្តោប្រវេសន៍មនុស្សប្រុស។ បុរសទាំងនោះ បានរៀបការជាមួយ ស្ត្រីខ្មែរ ហើយបានបង្កើតកូនចៅកាត់ខ្មែរចិន ពួកកូនកាត់ខ្មែរចិននេះ រស់នៅតាមក្រុងនានា និងនៅតាមមាត់ទន្លេ នានា។ នៅក្រុងភ្នំពេញ ជនជាតិចិន ឬជនជាតិកាត់ខ្មែរចិន មានប្រមូលផ្តុំសឹងតែពេញភ្នំពេញ។ ហើយជនជាតិ ទាំងនេះក៏មានការរៀនសូត្រខ្ពស់នៅតាមអនុវិទ្យាល័យ និងមហាវិទ្យាល័យ។ បច្ចុប្បន្នជនជាតិខ្មែរ ក៏បានរត់ចូលទីក្រុងយ៉ាងច្រើនណាស់ដែរ ហើយបានធ្វើឱ្យសមាមាត្រនេះមានការប្រែប្រួល។

ភាពរាំរែកនៃការបញ្ជាក់តួលេខពិត នៃជនជាតិចិន គឺមកតែពីបញ្ហាកូនកាត់នេះឯង ពោល គឺពិបាកក្នុងការកំណត់សញ្ជាតិ។ នៅមានកូនកាត់ខ្មែរចិន ដែលកំណត់យកសញ្ជាតិចិន តែភាគច្រើនបាន

កំណត់យកសញ្ជាតិខ្មែរ។ បើគេយកសញ្ជាតិជាខ្មែរ នោះគេនឹងទទួលបាននូវសិទ្ធិខាងសេដ្ឋកិច្ចដ៏មានសារៈសំខាន់។

លក្ខណៈខាងភាសា មានការលំបាកក្នុងការកំណត់ថាជាខ្មែរ ឬចិនណាស់។ នៅហ្វីលីពីន តាមជំរឿនមួយបានបញ្ជាក់ថា អ្នកដែលចាត់ទុកថាជាចិន ច្រើនជាងអ្នកដែលចេះនិយាយភាសាចិនទៅទៀត។ រឿងនេះក៏កើតមាន នៅឥណ្ឌូនេស៊ី និងម៉ាឡេស៊ីដែរ។ ករណីបែបនេះ ក៏កើតមាននៅកម្ពុជាដែរ។

លក្ខណៈសំខាន់ដែលបញ្ជាក់ថាជាចិន គឺផ្នែកវប្បធម៌។ អ្នកដែលជាចិន គឺអ្នកដែលគោរពប្រពៃណី ជំនឿ សាសនា ទំនៀមទម្លាប់ និយាយភាសា និងរបៀបរស់នៅជាចិន។ ចំណុចសំខាន់មួយ គឺនៅត្រង់វិធីនៃការធ្វើពិធីបុណ្យសព បើសពត្រូវបានគេកប់ នោះជាជនជាតិចិន។ បើសពត្រូវគេដុតបូជាវិញ នោះគេជាជនជាតិខ្មែរ។

នៅឆ្នាំ ១៩៦៦ ជនជាតិចិនត្រូវបានគេសន្និដ្ឋានថាមានចំនួន ៣៨០,០០០ នាក់ ស្មើនឹង ៥% នៃប្រជាជនកម្ពុជា។ ចិនជាឈ្មួញ ពួកគេកាន់កាប់ពាណិជ្ជកម្មសឹងតែ ១០០% នៅកម្ពុជា ពិសេសពាណិជ្ជកម្មស្រូវ អង្ករ និងកសិផល។ នៅតាមភូមិនីមួយៗមានយ៉ាងតិចចិនមួយគ្រួសារដែរ ដែលជាអ្នកលក់ទំនិញឱ្យខ្ចីបុល និងទិញ កសិផលពីកសិករខ្មែរ។ ចិនក៏ជាសិប្បករ ជាសហគ្រិន ជាកម្មករ។ មានចិនដែលជាកសិករមកពីកោះហាយណាំ ជាអ្នកដាំម្រេចនៅកំពត។ ពីមុនក៏ដូចសព្វថ្ងៃសហគមចិននៅរក្សាបានសិទ្ធិបង្កើតសហគម ដែលមានការចាត់ ចែងជាសាលារៀន មានវត្តអារាម កាសែត និងការភ្ជាប់ទំនាក់ទំនងជាមួយប្រទេសដើម និងសមាគមចិន នៅប្រទេសនានានៅអាស៊ីអាគ្នេយ៍។

ចិន និងវៀតណាម បង្កើតបានជាក្រុមសហគមន៍ ដែលមិនអាចបញ្ចូលបាននូវតួនាទីផ្លូវច្បាប់ និងសកម្មភាព សេដ្ឋកិច្ច មិនដូចសភាពការណ៍ពួកជ្វីស នៅអឺរ៉ុប ដូចពីមុននោះទេ។

### ៥.១.៣.ជនជាតិចាម និងម៉ាឡេ

ជាក្រុមជនជាតិសំខាន់ទីបី។ លើផ្លូវច្បាប់ ជនជាតិទាំងនេះត្រូវបានបញ្ចូលជាជនជាតិភាគតិចដើមនៅកម្ពុជា។ ពួកគេមានសិទ្ធិដូចជនកម្ពុជាដែរ។ ប្រភពដើមនៃជនជាតិនេះ គឺជាជនជាតិភាគតិច ដែលមានវប្បធម៌ និងសាសនា។ ពួកចាម និងម៉ាឡេ ទទួលអនុភាព ម៉ូលស្លុយម៉ង ហើយគេតែងហៅថា ខ្មែរអ៊ីស្លាម។

នៅឆ្នាំ ១៩៦៧ មានជនជាតិចាមចំនួនប្រហែល ១៥០,០០០នាក់ នៅកម្ពុជា។ ពួកចាមទាំងនេះ មកពីមាត់សមុទ្រ ក្រោយពេលដែលអាណាចក្រចំប៉ា បានត្រូវបំផ្លាញដោយពួកវៀតណាម ដាណាង-ញ៉ាចាង ។ ពួកម៉ាឡេ មកពីស៊ូម៉ាត្រា កោះជ្វា និងជ្រោយម៉ាឡេស៊ី។ ពួកចាម និងជ្វា បានរស់នៅលាយឡំគ្នា។ ប៉ុន្តែប្រពៃណី ភាសា និងពិសេសសាសនា ដែលពួកគេគោរពបូជាហើយបានរក្សាប្រកាន់យកខុសពីជនជាតិកម្ពុជា។

ពួកខ្មែរអ៊ីស្លាម រស់នៅតាមខេត្តកំពត កំពង់ចាម តាមដងទន្លេមេគង្គ និងទន្លេសាប។

នៅក្នុងសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ពួកខ្មែរអ៊ីស្លាម ក៏ដូចពួកជនជាតិភាគតិចឯទៀតដែរ មានតួនាទីយ៉ាងសំខាន់ ។ ពួកគេជាអ្នកនេសាទ ជាអ្នកដឹកជញ្ជូន ជាឈ្មួញ អ្នកកាប់ឈើ និងជាឈ្មួញពាហនៈ។ សាសនារបស់ពួកគេ មិនហាមឃាត់ការសម្លាប់សត្វទេ។ ពួកខ្មែរអ៊ីស្លាម ជាក្រុមមានសារៈសំខាន់ ដែលបានត្រូវបញ្ចូលតាមផ្លូវច្បាប់ គ្រាន់តែមានការបែងចែកខាងសង្គមតែប៉ុណ្ណោះ។

### ៥.១.៤.ជនជាតិភាគតិចដទៃទៀត

ក្រុមជនជាតិភាគតិចដទៃទៀត ក៏ត្រូវបានបញ្ចូលគ្នាដូចករណី ជនជាតិឡាវ នៅខេត្តស្ទឹងត្រែង ពួកភូមា ឥណ្ឌា ឬពួកប៉ាគីស្ថាន រួមជាមួយពួកជនជាតិដើមដែលគេហៅថា ខ្មែរលើ រស់នៅតំបន់ព្រៃភ្នំតាមបរិវេណព្រំដែនកម្ពុជា។ ពួកជនជាតិទាំងនោះ ទទួលបានការទទួលស្គាល់ខាងផ្លូវច្បាប់ ថាជាជនមានសញ្ជាតិកម្ពុជា។ ពួកខ្មែរលើមានចំនួនប្រហែល ៥០,០០០ នាក់ ធ្វើកាដាំដុះដំណាំ ចំការដុតព្រៃពនេចរ និងបន្ថែមដោយការប្រមាញ់ និងនេសាទ ការបេះផលព្រៃឈើ និងសិប្បកម្ម។ សារៈសំខាន់ផ្នែកសេដ្ឋកិច្ចនៃពួក ជនជាតិភាគតិចទាំងនោះ ដូចជាមិនសូវមានទំហំធំទេ។

## ៥.២.សារៈសំខាន់នៃព្រះពុទ្ធសាសនា

គេបានដឹងថា ចាប់ពីដើមសម័យទីមួយនៃ គ.ស. ភូមិភាគឥណ្ឌូចិន បានទទួលឥទ្ធិពល នៃចរន្តអរិយធម៌អាស៊ីធំពីរះ អរិយធម៌ឥណ្ឌា និងអរិយធម៌ចិន។ នៅកម្ពុជា អរិយធម៌ឥណ្ឌានេះ បានរក្សានូវលំនឹងយ៉ាងនឹង។ ការចាត់ចែងនយោបាយព្រះរាជាណាចក្រកម្ពុជាប្រមូលផ្តុំ «វប្បធម៌ សំស្ក្រឹត សិល្បៈ ច្បាប់ វិទ្យាសាស្ត្រ អក្សរសាស្ត្រ និងពិសេសសាសនាឥណ្ឌា» បានត្រូវអនុម័តយកមកអនុវត្តតាម។ ចាប់ពីសតវត្សទី១៣មក ឥទ្ធិពលឥណ្ឌា ចេះតែពង្រីកឡើង។ វប្បធម៌ឥណ្ឌា បានចាក់ឫសយ៉ាងជម្រៅរឹងមាំនៅកម្ពុជា ភូមា ថៃ។ លោក M.COEDES បានធ្វើនៅក្នុងជ្រោយឥណ្ឌូចិនដែលទទួលឥទ្ធិពលឥណ្ឌា ជាមួយជនជាតិឥណ្ឌាម្នាក់ ហើយបានធ្វើកាអង្កេតប្រតិកម្មនានា ដើម្បីសន្និដ្ឋានថា ដល់ចំណុចណាទៅ ដែលបរិយាកាសសង្គមវប្បធម៌ កើតមានឡើងពីឥទ្ធិពលឥណ្ឌា នៅក្នុងប្រទេសនោះ រាប់ទាំងចរិតខាងក្រៅ រហូតដល់របៀបគោរព សំពះគ្នា ការលើកដៃសំពះប្រណម នៅលើក្បាល លើទ្រូង រហូតដល់សីលធម៌រស់នៅប្រចាំថ្ងៃ។

កេរ្តិ៍ដំណែលឥណ្ឌាដែលមានសារៈសំខាន់នោះគឺ ព្រះពុទ្ធសាសនា ហើយប្រជាជនខ្មែរសឹងតែទាំង ស្រុងសុទ្ធតែកាន់ព្រះពុទ្ធសាសនា។ រាជរដ្ឋធម្មនុញ្ញក៏បានបញ្ជាក់ថា «ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ»។

យើងបានដឹងថា ព្រះពុទ្ធសាសនា មានដើមកំណើតពីឥណ្ឌា ហើយរីកចម្រើនរាលដាលនៅទូទាំង អាស៊ី។ ប៉ុន្តែព្រះពុទ្ធសាសនា មិនដូចសាសនា កាតូលិក ឬអ៊ីស្លាម នោះទេ។ ព្រះពុទ្ធសាសនា ជាទស្សនៈវិជ្ជាជាចរន្តនៃទ្រឹស្តី គំនិត ដូចជាទស្សនៈវិជ្ជារបស់ ប្លាតុងជាដើម។ ព្រះពុទ្ធសាសនា មានគថភាពឃើញទំនាស់នៅក្នុងសង្គម។

គេអាចបំភ្លឺបានអំពីបញ្ហា ដោយបែងចែកឱ្យបានច្បាស់លាស់រវាងសាវគ្គរបស់ «ព្រះពុទ្ធ-ព្រះសង្ឃ និងពុទ្ធសាសនិក»។

### ៥.២.១.សាវគ្គរបស់ព្រះពុទ្ធ

នៅកម្ពុជា គេគោរពបូជាតាមបែបព្រះពុទ្ធសាសនា ហីនយាន ហៅថា យានតូច ដែលកើតជាបន្តនៅស្រីលង្ការ ភូមា ឡាវ និងថៃ។ វាជាយានដែលនៅជិតប្រភពនៃព្រះពុទ្ធសាសនា។

ទោះបីមានលក្ខណៈជាបុគ្គលនិយម នៃទស្សនៈវិជ្ជារបស់ព្រះសមណគោត្តម សាវគ្គព្រះអង្គ បានប្រមូលផ្តុំនៅក្នុងវត្ត។ សាវគ្គ ក្លាយជាព្រះសង្ឃ ដែលមានការចាត់ចែងតាមឋានានុក្រម។ ព្រះសង្ឃមិនដូចសង្ឃកាតូលិកទេ ព្រះសង្ឃ មិនមែនជាអ្នកកណ្តាល ចម្លងបុណ្យបាបរវាងមនុស្ស និងអាទិទេពនោះទេ។ ទោសៈ មោហៈ លោភៈ ជាហិង្សាដែលព្រះពុទ្ធហាម ព្រះអង្គបង្គាប់ឱ្យយើងខិតខំជួយអ្នកក្រីក្រ សមាធិធ្វើបុណ្យសន្សំកុសល ប្រព្រឹត្តដោយគ្មានហិង្សា។ ព្រះសង្ឃអាចសឹកបាន តាមបំណងប្រាថ្នា។ តាមប្រពៃណីបុរសខ្មែរត្រូវទៅបួសពីរ ឬបីខែ ឬយ៉ាងតិចមួយដងក្នុងមួយជីវិត។ តែសព្វថ្ងៃ ប្រពៃណីនេះបានថយចុះហើយ។ លោក Matini បានបញ្ជាក់ថា ព្រះសង្ឃនៃព្រះពុទ្ធសាសនានៅកម្ពុជាមានវិន័យចាត់តាំង ដែលបែងចែកជាពីរផ្នែកៈ មហានិកាយ និងធម្មយុត្តិកនិកាយ។ ឋានានុក្រមនៃព្រះសង្ឃ បានត្រូវអនុម័តដោយព្រះរាជា ជាអ្នកការពារសាសនា ហើយមាន លក្ខណៈប្រហែលនឹងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា មានអំណាច និងមានស្ថេរភាព។ ឋានានុក្រមនៃព្រះពុទ្ធសាសនាបានរួមចំណែកវិភាគទានដ៏មានឥទ្ធិពលនៅក្នុងផ្នែកសីលធម៌ និងនយោបាយ ដែលព្រះសង្ឃមាន នៅក្នុងប្រជាជនកម្ពុជា ។

### ៥.២.២.ប្រជាជន

អ្នកដែលជាពុទ្ធសាសនិកជន រួមមានអាចារ្យ និងពុទ្ធសាសនិកជនទាំងអស់ ដែលខិតខំ គោរពបូជា ទៅតាមធម៌របស់ព្រះពុទ្ធ។ ក្នុងការគោរពបូជានៃប្រជាជននេះរួមមាន ការសន្តោសប្រណី ការគោរព ព្រះពុទ្ធរូប និងមានព្រហ្មញ្ញសាសនាលាយឡំផង ដូចជាការសែនព្រេនជាដើម ។ល។ ដែលគ្មាននៅក្នុងទស្សនៈវិជ្ជារបស់ព្រះពុទ្ធ ។ អ្នកស្រី Lacouture បាននិយាយថាៈ វត្តមានរបស់ព្រះសង្ឃនៅក្នុងពិធីមួយនោះ ជាអ្នកនាំមកនូវសុភមង្គល។

ជាក់ស្តែងប្រជាជនកម្ពុជា ជា អ្នកកាន់ព្រះពុទ្ធសាសនា ឬពុទ្ធសាសនិក តាមសីលធម៌របស់ខ្លួន។ ការគោរពជីវិត មិនហ៊ានកាប់សម្លាប់សត្វ ចង់បានកិត្តិយស ស្មោះត្រង់ជិតស្និទ្ធ ការបដិសេធមិនឱ្យសេពសុរា គ្រឿងញៀន ការគោរពស្ត្រីភេទ គឺត្រូវបានអប់រំ និងមានវិធានការអនុវត្ត។ នៅមានការលំបាកក្នុងការសន្និដ្ឋានដល់ឥទ្ធិពលផ្នែកសេដ្ឋកិច្ច ចំពោះជំនឿ និងការអនុវត្តបែបនេះ។

- គេតែងនិយាយថា ព្រះពុទ្ធសាសនា ក្នុងនាមនៃការងារទេសនា គឺធ្វើឱ្យធុញទ្រាន់ចំពោះខ្លួនឯង

និងពិភពលោកបន្តយនូវការប្រើប្រាស់ និងការផ្តួចផ្តើម រហូតដល់ក្លាយជាឧបសគ្គនៃការអភិវឌ្ឍសេដ្ឋកិច្ច។ និក្ខេបទនេះមានការលំបាកក្នុងការគាំទ្រ។ ឧទាហរណ៍នៅប្រទេសជប៉ុនការរីកចម្រើនសេដ្ឋកិច្ច គឺមានការរួមវិភាគ ទានរបស់ព្រះពុទ្ធសាសនា។ ចំណុចទីមួយ ព្រះពុទ្ធសាសនា ជាសីលធម៌របស់ប្រជាជន។ ក្នុងនាមនៃទ្រឹស្តី របស់ព្រះពុទ្ធសាសនា មានសារៈសំខាន់ខាងសេដ្ឋកិច្ច។

- អ្នកខ្លះថា វត្ត មានទម្ងន់ដល់សេដ្ឋកិច្ចនៃប្រទេស យោងទៅតាមនិក្ខេបទរបស់ពួក Radicale ។

គេថាចំណូលសកម្មមួយចំណែករបស់ប្រជាជន បានបូជាចំពោះព្រះពុទ្ធសាសនា។ ចំនួនព្រះសង្ឃក៏មានច្រើនណាស់ដែរ បើពិនិត្យលើប្រជាជនសកម្មជាព្រះសង្ឃ គឺមានចំនួន ៦០,០០០ អង្គ គឺស្មើនឹង ៥% នៃប្រជាជនសកម្មបុរស។ ប៉ុន្តែព្រះសង្ឃ ពិសេសចៅអធិការនៃវត្តនីមួយៗ នៅក្នុងភូមិសុទ្ធតែជាអ្នកផ្តួចផ្តើមគំនិត។ លោក M. Delvert និយាយដល់ការចំណាយក្នុងពិធីបុណ្យ និងការសាងសង់អាគារសាសនានានា គឺជាការចំណាយថវិកាដ៏ធ្ងន់ធ្ងររបស់ប្រជាជនកម្ពុជាគ្រប់រូប។

ការអង្កេតមួយទៀតថា ក្រៅពីផ្តល់នូវសេចក្តីត្រូវការផ្នែកនយោបាយ ឬសាសនាដល់ប្រជាជន ការ ចំណាយរបស់ប្រជាជន ដើម្បីសាសនាក៏មិនបានបញ្ចូលទៅក្នុងគណនេយ្យជាតិទៀតផង។ ប៉ុន្តែគេភ្លេចថា ជាយូរមកហើយ វត្តអារាម ព្រះសង្ឃ ជាជម្រកនៃវប្បធម៌ខ្មែរ ជាកន្លែងដែលរក្សាអក្សរសាស្ត្រខ្មែរ។ ព្រះសង្ឃ ជាគ្រូ បង្រៀន។ យុវជនខ្មែរត្រូវឆ្លងកាត់វត្តអារាមច្រើនឆ្នាំ រៀនសរសេរ រៀនអាន។ ដូចនេះហើយ បានជាគេតែង និយាយថា អ្នកបានបួសគឺជាអ្នកចេះដឹង ហើយអត្រាអនក្ខរកម្មផ្នែកបុរសនៅកម្ពុជាមានទាបណាស់។ ការរីកចម្រើនលើវិស័យអប់រំសាធារណៈ បានបន្ថយតួនាទីរបស់វត្តអារាមលើវិស័យអប់រំ តែក៏នៅមានការអប់រំផ្នែកសាសនា ផងដែរ។

សរុបមក សារៈសំខាន់នៃព្រះពុទ្ធសាសនាក្នុងផ្នែកសេដ្ឋកិច្ច គឺមិនមែនជាឧបសគ្គ ឬជាហ្រាំងទប់ពន្យឺតនោះទេ។

## ៥.៣.កម្រិតការចេះដឹង

ពួកអាណានិគម បានរៀបចំរចនាសម្ព័ន្ធយ៉ាងសំខាន់ តែចំពោះវិស័យអប់រំនៅកម្ពុជា ពួកគេមិនយកចិត្តទុកដាក់សោះ។ វិស័យអប់រំ មានការកែប្រែយឺតបំផុត ព្រោះការបណ្តុះបណ្តាល ត្រូវចំណាយពេលយូរ ណាស់។ ទោះបីជាមានការខិតខំ ដ៏ខ្លាំងក្លារបស់រាជរដ្ឋាភិបាលក៏ដោយ ក្រោយសម័យឯករាជ្យ ប្រជាជនកម្ពុជានៅតែជួបបាតុភាពនៃអនក្ខរកម្ម ដែលនាំឱ្យមានផលវិបាកធ្ងន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

នៅឆ្នាំ ១៩៦២ សិស្ស ៨៥,០០០ នាក់ ស្មើនឹង ២% នៃប្រជាជនអាយុជាង ១០ ឆ្នាំ បានប្រឡងជាប់ បញ្ចប់បឋមសិក្សា។ សិស្សបានបញ្ចប់មធ្យមសិក្សាមានចំនួន ១២,០០០ នាក់ គឺនៅតិចនៅឡើយ។ តួលេខទាំង នេះ មានចំនួនតិច ប្រៀបធៀបនឹងប្រជាជនសរុប។

ការអប់រំ ប្រព្រឹត្តទៅជាភាសាបារាំង។ ការអប់រំនោះ វាស្របនឹងការអប់រំពួកអភិជនបារាំង តែមិន

សមស្របនឹងសេចក្តីត្រូវការរបស់កម្ពុជាឡើយ។ ការសម្របភាសាបរទេស អាចត្រូវបានពន្យល់បាន បារាំង ប៉ុន្តែឥទ្ធិពលប្រពៃណីពួកអភិជនទាំងនោះ សា ថាសិស្សចាប់យកបានតែផ្នែកខ្លះនៃមេរៀនតែប៉ុណ្ណោះ។រៈ សំខាន់ របស់វា គឺជាមេសូត្រ ជាជាងការពិចារណា ហើយយកសញ្ញាបត្រ ជាជាងការចេះដឹង។

នៅពេលបច្ចុប្បន្ន កម្រិតអប់រំសិក្សានៅតែខ្វះខាតទាំងបរិមាណ និងគុណភាព។ នៅកម្ពុជា មានការខ្វះខាតនូវក្របខ័ណ្ឌដែលត្រូវបណ្តុះបណ្តាលទាំងផ្នែកបច្ចេកទេស ទាំងមន្ត្រីរដ្ឋបាល ទាំងផ្នែកដំណាំដាំដុះ គណនេយ្យ វិស្វករ អ្នកសេដ្ឋកិច្ច និងទាំង ដែលមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋ សហគ្រិនកិច្ច។

អ្នកដឹកនាំកម្ពុជាដឹងពីបញ្ហា ហើយក៏បានខិតខំព្យាបាលជំងឺនេះ។ នៅកម្ពុជា មានតែយុវជនពាក់កណ្តាលបញ្ញាវ័ន្ត ការិយាល័យនិយម តែបញ្ហាពលកម្មថ្មីស្របតាមតិចណូឡូស៊ី សម្រាប់បម្រើវិស័យឧស្សាហកម្ម សេវាកម្ម មានមិនគ្រប់គ្រាន់។ នោះជាសភាពការណ៍ ដែលចេញមកពីការសម្របសម្រួលប្រព័ន្ធអប់រំជាតិ មិនស្របនឹងសេចក្តីត្រូវការរបស់បរទេស។

# មេរៀនទី ៦
# ការបណ្តាក់ទុន និងការប្រើប្រាស់ប្រភពកម្លាំង

យើងចាប់យកទិដ្ឋភាពទូទៅនៃផលទុនជាតិមកពិនិត្យនូវរចនាសម្ព័ន្ធ គឺបំណែកដែលបានផលិតតាមផ្នែកសកម្មនីមួយៗ ហើយមួយផ្នែកទៀតសិក្សាពីសាខាសេដ្ឋកិច្ចដែលជាប់ទាក់ទងគ្នាពីមួយទៅមួយ។ បន្ទាប់មកយើងសិក្សាពីកំណើននៃផលិតផល គឺកំណើនសេដ្ឋកិច្ចកម្ពុជា។

## ៦.១.រចនាសម្ព័ន្ធនៃផលទុនជាតិ

ក. ការសិក្សាពីប្រជាជនសកម្ម បានធ្វើឱ្យលេចចេញលក្ខណៈកសិកម្មនៃសេដ្ឋកិច្ចកម្ពុជា។ លក្ខណៈទាំងនោះ មិនសូវលេចចេញច្បាស់លាស់ពេកទេ នៅពេលដែលគេវិភាគរចនាសម្ព័ន្ធផលិតកម្ម លើភាគរយនៃផលិតផលដុលរបស់ជាតិ។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ផ្នែកទីមួយ | ៤៩ | ៤៨ | ៤៨ |
| ផ្នែកទីពីរ | ១៩ | ២០ | ២០ |
| ផ្នែកទីបី | ៣២ | ៣២ | ៣២ |

សារៈសំខាន់នៃផ្នែកសេវាកម្ម មានកាន់តែធំឡើង។ ភាគចំណែកនៃផ្នែកសេវាកម្មក្នុងផលទុនដុល របស់ជាតិ កាន់តែមានសារៈសំខាន់ខ្លាំងឡើងទៀត ប្រៀបនឹងប្រទេសឱនាភិវឌ្ឍន៍។

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ផ្នែកទីមួយ | ៤២ | ៤២ | ៤២ |
| ផ្នែកទីពីរ | ១៧ | ១៨ | ១៧ |
| ផ្នែកទីបី | ៤១ | ៤០ | ៤១ |

ការសិក្សារបស់លោក N.KOTNETS ពីក្រុមប្រទេសឱនាភិវឌ្ឍន៍ចំនួន ៣០ ឃើញថាតួលខមធ្យម មានដូចតទៅ គិតជាផលទុនសរុបះ

| | |
|---|---|
| ផ្នែកទីមួយ | ៤៦ |
| ផ្នែកទីពីរ | ១៨ |
| ផ្នែកទីបី | ៣២ |

សារៈសំខាន់នៃផ្នែកទាំងបីក្នុងផលទុនជាតិ គឺគួរឱ្យកត់សម្គាល់ នៃភាគចំណែករបស់ផ្នែកសេវាកម្មនេះនៅក្នុងប្រជាជនសកម្មដែលមានតែ ១៥% ប៉ុណ្ណោះ។ ការប្រៀបធៀបនេះ បញ្ជាក់ថាការបែងចែកផលទុនមិន ស្មើភាពគ្នាទេ។

នៅក្នុងវិស័យរដ្ឋបាល គឺមានតែប្រាក់បៀវត្សរបស់មន្ត្រីទេ ដែលបានកត់ចូលក្នុងគណនេយ្យជាតិ តែការគិតគូរបញ្ចូលនូវសេវាកម្មរបស់រដ្ឋបាល មិនទាន់បានគិតគូរដល់នៅឡើយទេ។

ខ. ការប្រុងប្រយ័ត្ន ក៏ត្រូវគិតគូរថែមទៀត នូវការបកស្រាយតួលេខនៃតារាងផ្លាស់ប្តូរ រវាងសេដ្ឋកិច្ច ដែលបានរៀបចំនៅឆ្នាំ ១៩៦២ និង១៩៦៣ ។ មិនមែនជាតម្លៃបន្ថែមនោះទេ តែជាផលិតផលនៃសាខានេះ ឬសារៈប្រយោជន៍នៃការប្រើប្រាស់នូវផលិតផលនៃផ្នែកសេដ្ឋកិច្ចនោះ។ យើងសួរថា តើផលិតផលនៃផ្នែកនោះ មកពីការនាំចូល ឬជាផលិតផលក្នុងស្រុក។ តើជាផលិតផលនាំចេញ ឬសម្រាប់ប្រើប្រាស់ចុងក្រោយ តើជាការផ្តុំទុន ឬសម្រាប់ផ្តល់ដល់សាខាសេដ្ឋកិច្ចដទៃទៀត? ក្នុងការបញ្ជាក់ពីទំនាក់ទំនងរវាងសាខា និងសាខានេះហើយ ដែលធ្វើឱ្យយើងសិក្សាស៊ីជម្រៅអំពីសេដ្ឋកិច្ចនៃកម្ពុជា។

គេកត់សម្គាល់ថា ភាគចំណែកនៃការនាំចូលក្នុង ផលិតផលសរុប នៃសាខានីមួយៗប្លែកៗគ្នា៖

| | | |
|---|---|---|
| ផលិតផលបន្លែ និងសាច់សត្វ | ........................................... | ១.៦ |
| ផលិតផលស្បៀង | ........................................... | ១៥ |
| ថាមពល | ........................................... | ២៥ |
| វត្ថុធាតុដើម, ពាក់កណ្តាលសម្រេច | ........................................... | ២៧ |
| ផលិតផលឧស្សាហកម្ម និងអគ្គិសនី | ........................................... | ៦៦ |
| វាយនភ័ណ្ឌ និងស្បែក | ........................................... | ៧៦ |
| ផលិតផលឧស្សាហកម្មផ្សេងៗ | ........................................... | ៤៧ |
| សំណង់, ការងារសាធារណៈ | ........................................... | ០ |
| សេវាកម្មនានា | ........................................... | ៣ |

តួលេខបង្ហាញទាំងឡាយក៏មានសារៈសំខាន់ពីការនាំចេញ និងការងារផ្សេងៗទៀត ។ ផលិតផលផ្នែក ថាមពល បានត្រូវយកទៅប្រើប្រាស់ចុងបញ្ចប់តែម្តងសម្រាប់សហគ្រាស គ្រួសារ និងរដ្ឋបាលអស់ចំនួន ៦០%។ ៤០% ដែលនៅសល់ត្រូវបានយកទៅប្រើសម្រាប់ភ្នាក់ងារកណ្តាលនៃសាខាដទៃទៀត ដូចជា៖

| | | |
|---|---|---|
| សេវាកម្ម | ........................................... | ៨.៩ |
| សំណង់ និងសាធារណៈការ | ........................................... | ៦.៤ |
| វត្ថុធាតុដើម, ពាក់កណ្តាលសម្រេច | ........................................... | ៥.៥ |
| ពាណិជ្ជកម្ម | ........................................... | ៥.៥ |
| ថាមពល | ........................................... | ៥.៤ |

ផលិតផលស្បៀង .......................................... ៤.០

គេអាចដឹងបាននូវអតិថិជន សំខាន់ៗនៃផ្នែកនីមួយៗ នៅលើតារាងខាងលើ ដែលជារចនាសម្ព័ន្ធបច្ចេកទេសនៃផលិតកម្មនៅកម្ពុជាយើង អាចឱ្យយើងដឹងពីអានុភាពដែលជាភាពចាំបាច់នៃសាខានីមួយៗ ដើម្បីបង្កើតនូវនោះ។

ដើម្បីផលិតបាន ១០០ រៀល ១៩៦០ រៀលឆ្នាំនៃផលិតផលឧស្សាហកម្ម ផ្នែកយន្តកម្ម និងអគ្គិសនី គេត្រូវចំណាយ៖

២៤ រៀល សម្រាប់ ផលិតផលយន្តកម្ម និងអគ្គិសនីឧស្សាហកម្ម

១៩ រៀល សម្រាប់ ផលិតផលផ្នែកឧស្សាហកម្មផ្សេងៗទៀត

០៨ រៀល សម្រាប់ ផលិតផលបន្លែ និងសាច់សត្វ

០៦ រៀល សម្រាប់ វត្ថុធាតុដើម និងពាក់កណ្ដាលសម្រេច

០៣ រៀល សម្រាប់ ថាមពល

ដើម្បីផលិតបានតម្លៃ ១០០ រៀល នូវផលិតផល កម្ពុជា ឧស្សាហកម្ម យន្តសាស្ត្រ និងអគ្គិសនី មានតម្លៃទាបជាងសាខា ខ្លឹមសារនៃការនាំចូល រៀល លើទំនិញនាំចូល។ ២៧ ត្រូវ នាំចូល និងចំណាយដទៃទៀត៖

វាយនភ័ណ្ឌ និងស្បែក .......................................... ២១

សំណង់ និងសាធារណៈការ .......................................... ១៨

ផលិតផលឧស្សាហកម្មផ្សេងៗ .......................................... ១០

ថាមពល .......................................... ៩

វត្ថុធាតុដើម, ពាក់កណ្ដាលសម្រេច .......................................... ៨

គេអាចទាញចេញនូវតារាងផ្លាស់ប្ដូរ រវាងសាខានានា នូវព័ត៌មាន ស្ដីពីរចនាសម្ព័ន្ធផលិតផលក្នុងស្រុក។

## ៦.២.កំណើននៃផលទុនជាតិ

ការវិវដ្តពីឆ្នាំ ១៩៥២ មានកត្តាល្អ គឺ ថ្លៃនឹងន មានផលិតផលក្នុងប្រទេស និងតម្លៃបន្ថែមតាមផ្នែក នីមួយៗ។ ទាំងអស់នេះជាកតិកាសម្រាប់គណនា សន្និដ្ឋានតម្លៃបន្ថែមតាមផ្នែកសេដ្ឋកិច្ចនីមួយៗ ជាមូលដ្ឋាន និងមានការប្រុងប្រយ័ត្នចំពោះការបកស្រាយពីអត្រាកំណើន។

ដោយឡែក ការគណនាពីអត្រាកំណើនក្នុងរយៈពេលមួយ ប៉ុន្តែអត្រានោះ ចំណុះទៅនឹងពេលវេលា ដែលបានកំណត់មួយ។ កំណត់កាលនោះ អាចចាប់ផ្ដើមពីឆ្នាំ ដែល ល្អ ហើយបញ្ចប់នៅឆ្នាំ អាក្រក់

ដែលនឹងលេចចេញនូវអត្រាកំណើន អាក្រក់ មានអត្រាកំណើនខ្ពស់ ហើយត្រូវបញ្ចប់បន្តទៀតនៅក្នុងឆ្នាំខ្សោយ។

យើងអាចធ្វើកាបញ្ជក់នូវមតិចំនួនបី នៃអត្រាកំណើនៈ

**ក. មតិទីមួយ** សេដ្ឋកិច្ចកម្ពុជា មានការលូតលាស់ គឺពីឆ្នាំ ១៩៥២ ដល់ ១៩៦៣ ។ នៅឆ្នាំ ១៩៦៣ ជាឆ្នាំជាឆ្នាំនៃ ១៩៦៣ នៃកំណើន។ ប៉ុន្តែនៅឆ្នាំ លើសពីការសន្និដ្ឋាន ហើយអត្រាកំណើន ល្អ ជាឆ្នាំនៃដំណាក់ការចុងបញ្ចប់ ១៩៦៣ ការផ្លាស់ប្តូរ នយោបាយ សេដ្ឋកិច្ច បើពិនិត្យលើចំណុចសេដ្ឋកិច្ច។ ដែលត្រូវបែងចែកដំណាក់កាល។ អត្រានានា មានដូចតទៅៈ

| | | ១៩៥២-១៩៦៣ |
|---|---|---|
| ផ្នែកទីមួយ | ............................................... | ៣.២ |
| ផ្នែកទីពីរ | ............................................... | ៨.២ |
| ផ្នែកទីបី មិនរាប់ផ្នែករដ្ឋបាលទេ | ............................................... | ៦.៧ |
| ផលទុនដុលជាតិ | ............................................... | ៥.១ |
| ផ្នែកទីបី សេវាកម្ម រាប់ចូលនូវរដ្ឋបាល | ............................................... | ៨.៧ |
| ផលទុនដុលជាតិ | ............................................... | ៥.៩ |

យើងដឹងហើយថា អត្រាកំណើនប្រជាជនប្រចាំឆ្នាំនៃតំណាក់កាលនោះ គឺ ២.៦% ។ ដើម្បីបាននូវ អត្រាកំណើនប្រចាំឆ្នាំសម្រាប់មនុស្សម្នាក់ៗ ក្នុងស្ថានភាពផ្លាស់ប្តូរខ្លះៗ គេបន្ថែមនូវអត្រាកំណើនប្រជាជន ទើបគេឃើញនូវកំណើនអត្រាសេដ្ឋកិច្ច។

សេដ្ឋកិច្ចកម្ពុជានាពេលនោះ បានកើនឡើងតាមអត្រាកំណើនប្រចាំជាមធ្យមលើសពី ៥% ក្នុងមួយឆ្នាំនោះគេនឹងរកបានផលទុននៃមនុស្សម្នាក់ៗ កើនឡើងជាមធ្យម ២.៥% ក្នុងមួយឆ្នាំ។ អត្រានេះ មានភាពគ្រប់គ្រាន់ពេញចិត្ត។ ជាអត្រាដែលគេបានឃើញនៅក្នុងប្រទេសអឺរ៉ុបខាងលិច។ ប៉ុន្តែជាអត្រាខ្ពស់ជាងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

**ខ. មតិពីរ** អាចទាញចេញពីការពិនិត្យ នូវអត្រានៃកំណើន ដែលជាភាគចំណែកនៃផ្នែកនីមួយៗ របស់
សេដ្ឋកិច្ចកម្ពុជា រួមវិភាគទានដល់កំណើនផលទុនជាតិសរុប។ អត្រាទាំងនោះមិនស្មើគ្នាទេ។

ផ្នែកឧស្សាហកម្ម ជាផ្នែកដែលមានអត្រាខ្ពស់ជាងគេ ស្មើនឹងអត្រាមធ្យម ៨% ក្នុងមួយឆ្នាំ។ ការរីកចម្រើនរហ័សនេះ ដោយសារចំណុចចេញដំណើរមានលក្ខខ័ណ្ឌនៃការអភិវឌ្ឍ។ ទោះបីយ៉ាងណា អត្រាកំណើនវិស័យឧស្សាហកម្ម មិនមែនជាអត្រាកំណើននៃផលទុនជាតិដែរ។

ការរីកចម្រើនផ្នែកវិស័យកសិកម្ម មានប្រហែល ៣.៥% ក្នុងមួយឆ្នាំនេះ ជាការជ្រើសរើសឆ្នាំ ល្អ គឺ ឆ្នាំ ១៩៦៣ ជាឆ្នាំបញ្ចប់។ ផលិតផលកសិកម្មរបស់មនុស្សម្នាក់ៗ បានកើនឡើងប្រហែល ១% ប៉ុណ្ណោះ ជាមធ្យមក្នុង ១ ឆ្នាំ។ គ្មានអ្វីគួរឱ្យព្រួយបារម្ភនោះទេ ព្រោះប្រជាជនកម្ពុជាអាចហូបអាហារតាម

ឃ្លាន ព្រោះនេះជាការរីកចម្រើនមួយដ៏ហ៊ានហើយ។ ប៉ុន្តែអត្រាកំណើនទាបផ្នែកកសិកម្មបែបនេះ បើមិនខំទៀតទេ នោះអាចជាឧបសគ្គនៃការអភិវឌ្ឍសេដ្ឋកិច្ចទៅវិញ។ ការអភិវឌ្ឍសេដ្ឋកិច្ចត្រូវការចំណែកវិស័យឧស្សាហកម្ម និងសេវាកម្មខ្លាំងក្លា តែភាគចំណែកនៃវិស័យកសិកម្ម ត្រូវថយចុះក្នុងផលទុនជាតិសរុប។ រឿងនេះមានន័យថា អត្រាកំណើនវិស័យឧស្សាហកម្ម និងសេវាកម្ម ត្រូវខ្ពស់ជាងវិស័យកសិកម្ម។ ប៉ុន្តែដំបូងត្រូវធ្វើឱ្យអត្រាកំណើនវិស័យកសិកម្មកើនខ្ពស់សិន ទើបវិស័យទាំងពីរកើនខ្ពស់ដែរ។ នៅក្នុងរយៈពេលខ្លី ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវមានអត្រាកំណើនមិនមែនកសិកម្មកើនឡើងលើសពី ២ ដង នៃវិស័យកសិកម្មទេ។ ការកំណត់នូវអត្រាខ្ពស់បំផុតនេះ ធ្វើឱ្យមាន លទ្ធភាពនៃការរីកចម្រើនទូទៅ។ ជាអានុភាព វិស័យកសិកម្មត្រូវផ្តល់ជាបរិមាណផលនៃកំណើន ទាំងចំណូល រូបិយវត្ថុ ទាំងអំណាចទំនិញ និងការសន្សំដែលជាមូលដ្ឋានចាំបាច់នៃការរីកចម្រើនដល់វិស័យឧស្សាហកម្ម និងសេវាកម្ម។

ការរីកចម្រើននៃវិស័យសេវាកម្ម បានកើនរហ័ស នៅក្នុងដំណាក់កាលនោះ បើគេរាប់បញ្ចូលទាំងសេវាកម្ម រដ្ឋបាលផង។ អត្រាកំណើនប្រចាំឆ្នាំមាន ៨% ចន្លោះឆ្នាំ ១៩៥២-១៩៦៣ ប៉ុន្តែនៅដំណាក់កាលចុងក្រោយពីឆ្នាំ ១៩៥៩ ដល់ ១៩៦៣ អត្រាកំណើនមានតែ ៥% ប៉ុណ្ណោះ។ នេះហើយជាការលំបាកក្នុងការបកស្រាយនូវ សារៈសំខាន់នៃការរីកចម្រើននៃវិស័យសេវាកម្ម។




**គ. មតិទីបី** គឺពិនិត្យលើសង្វាក់នៃកំណើន ដែលមានការយឺតចុះមកវិញនៅប៉ុន្មានឆ្នាំចុងក្រោយ។ នៅឆ្នាំ ១៩៦៤ ផលទុនរបស់ជាតិបានកើនឡើងតែ ១.៩% ទេ ប្រៀបនឹងឆ្នាំ ១៩៦៣ ។ ហើយសន្ទស្សន៍បានបង្ហាញពីអត្រាកំណើនចុះយឺតៗជាបន្តបន្ទាប់នៅឆ្នាំ ១៩៦៥, ១៩៦៦, ១៩៦៧ ។ ផលិតផលស្រូវបានថយចុះជាបន្តបន្ទាប់បានធ្វើឱ្យសកម្មភាពឧស្សាហកម្មដែលជាប់ទាក់ទងនឹងស្រូវ ម៉ាស៊ីនកិនស្រូវ ការក៏ថយចុះដែរ។ តួលេខនៃវិស័យដទៃទៀត ក៏បង្ហាញថា ដឹកជញ្ជូន ជួញដូរផលិតផល អាល់កុល ។ល។ អគ្គិសនី សំណង់ វាយនភ័ណ្ឌ យន្តសាស្ត្រ ។ល។ ក៏មាននិន្នាការថយចុះដូចគ្នាដែរ។ ផ្នែកឧស្សាហកម្ម

នេះគឺជាហ្វ្រាំងនៃកំណើនមួយនៃផលទុនជាតិ ដែលបានកើតមានឡើងនៅកម្ពុជា មុននឹងចូលនៅក្នុងភ្លក់ភ្លើងសង្គ្រាមជាង ២ ទសវត្ស ហើយតំណាក់កាលស្ដារនាពេលបច្ចុប្បន្ន ធ្វើឱ្យផលិតផលផ្គត់ផ្គង់បម្រើមិនទាន់សេចក្ដីត្រូវការ។

# មេរៀនទី ៧

## កសិកម្ម ( Agriculture )

នៅក្នុងវិស័យកសិកម្ម មានប្រជាជនសកម្ម ធ្វើការងារចំនួន ៨០% ហើយរួមវិភាគទានដល់ផលទុនជាតិចំនួនជាង ៤០% ។ យើងនឹងសិក្សាជាបន្តបន្ទាប់នូវកត្តាផលិតកម្មកសិកម្មធម្មជាតិ នៃផលិតកម្មនេះ ហើយនៅចុងបញ្ចប់សិក្សាពីបញ្ហាពាណិជ្ជកម្ម វិស័យកសិកម្ម។

### ៧.១. កត្តានានានៃផលិតកម្មកសិកម្ម និងរចនាសម្ព័ន្ធដីធ្លីកសិកម្ម

ក្រៅពីពលកម្ម ដីដាំដុះ គឺជាកត្តាសំខាន់នៃផលិតលកម្មកសិកម្ម។ លក្ខណៈគួរឱ្យកត់សម្គាល់នៅទីនេះ គឺគ្មានបញ្ហាដីធ្លីជាប្រចាំនៅកម្ពុជាទេ។

**ក.** ដីដាំដុះមិនខ្វះទេ ហើយផ្ទៃដីនេះចេះតែកើនជាប្រចាំ។ ការកើនឡើងនៃផ្ទៃដីដាំដុះនេះ មិនស្មើគ្នាទេ យោងទៅតាមប្រភេទដំណាំ។ ផ្ទៃដីដាំដុះកៅស៊ូកើនឡើងជាប្រចាំ តែឆ្លងកាត់សង្គ្រាម ២ ទសវត្ស ផ្ទៃដីអាជីវកម្ម កៅស៊ូថយចុះ មិនទាន់បានស្តារឱ្យបានស្មើមុនសម័យសង្គ្រាមនៅឡើយ។ ផ្ទៃដីដាំកៅស៊ូស្មើនឹង ២% នៃផ្ទៃដីដាំ កៅស៊ូនៅទូទាំងប្រទេស។ ផ្ទៃដីដាំដុះសម្រាប់ដំណាំផ្សេងៗទៀតក្រៅពីស្រូវមានការផ្លាស់ប្តូរខ្លាំងក្លាណាស់ ដូចជា ពោត កប្បាស សណ្តែកដី ម្រេច។ ឧទាហរណ៍ គួរឱ្យចាប់អារម្មណ៍គឺ ដីដាំពោត៖ ចន្លោះឆ្នាំ ១៩៤០-១៩៤១ ផ្ទៃដី ដាំពោតមានចំនួនលើសពី ២៥០,០០០ ហិចតា ចន្លោះ ១៩៤៥-១៩៤៦ មាន ១,០០០ ហិចតា ហើយសព្វថ្ងៃមានតែ ១៥០,០០០ ហិចតាប៉ុណ្ណោះ។ គឺមានតែផ្ទៃដីដាំស្រូវទេ ដែលមានចំនួនពី ៧០% ទៅ ៩០% នៃផ្ទៃដីដាំដុះសរុប។ ផ្ទៃដីដាំស្រូវនេះទៀតក៏រណបតាមឆ្នាំមួយទៅមួយដែរ ឆ្នាំខ្លះភ្លៀងធ្លាក់ល្អ ឆ្នាំខ្លះទឹកជំនន់។ និន្នាការទឹកភ្លៀង មិនសូវច្បាស់លាស់។ ចន្លោះរវាងឆ្នាំ ១៩៤០-១៩៦០ អត្រាកំណើនប្រជាជនកើនឡើងប្រហែល ២៣ ហើយ ផ្ទៃដីដាំដុះស្រូវក៏កើនឡើងក្នុងសង្វាក់ប្រហែល ២% ក្នុងមួយឆ្នាំដែរ។ ផ្ទៃដីដាំដុះក្នុងមនុស្សម្នាក់ មិនថយចុះទេ តែកើនឡើងបន្តិចៗដែរ។

**ខ. ភាពយឺត Elasticité៖** នៃការផ្តល់ដីដាំដុះនេះ ហើយដែលគ្មានការចោទឡើងនូវបញ្ហាដីធ្លីដាំដុះ ប្រចាំនៅកម្ពុជា។

ទីមួយ ភាគច្រើននៃកសិករកម្ពុជា គឺជាម្ចាស់កម្មសិទ្ធិដីធ្លី។ នៅកម្ពុជា មិនសូវមានពលករស៊ីឈ្នួលទេ ក្នុងវិស័យកសិកម្ម មានតែកម្មករចំការកៅស៊ូតែប៉ុណ្ណោះ។

តួលេខកម្មករកសិកម្មគ្មានចំនួនច្បាស់លាស់ទេ។ ប៉ុន្តែគេដឹងថានៅឆ្នាំ ១៩៦២ នាតំបន់ជនបទមានកម្មករប្រភេទនេះ ចំនួន ១៥០,០០០ នាក់ ស្មើ ៧% នៃប្រជាជនសកម្មនៅតាមតំបន់នានាទាំងនោះ។ ហើយបើគេដកចេញនូវមន្ត្រីនានា ព្រះសង្ឃ និងកម្មករមិនមែនកសិកម្ម នោះគេសន្និដ្ឋានថា កម្មករកសិកម្មមានចំនួនតិចជាង ១០០,០០០ នាក់ គឺស្មើនឹង ៥% នៃប្រជាជនសកម្មជាកសិករទូទៅនៅសម័យ

នោះ។ នៅរដូវដាំដុះ ច្រូតកាត់ មានការអំពាវនាវ កម្មករបណ្តោះអាសន្នតាមរដូវ មកជួយធ្វើការងារ គឺជាកម្មករស៊ីឈ្នួលប្រចាំថ្ងៃ។

កសិករជាម្ចាស់កម្មសិទ្ធិរួមមាន ៨០០,០០០ គ្រួសារ នាឆ្នាំ ១៩៦២ ដែលបែងចែកភាគរយៈ

| | | |
|---|---|---|
| ម្ចាស់កម្មសិទ្ធិ | ............................................. | ៨៤ |
| កសិដ្ឋាន និងម្ចាស់បំណុល | ............................................. | ៦ |
| ម្ចាស់កសិដ្ឋានបុលបណ្តាក់ | ............................................. | ៧ |
| អ្នកមិនមែនឯកទេសខាងកសិកម្ម | ............................................. | ៣ |

ការបុលបណ្តាក់ពាក់កណ្តាល គឺបានត្រូវម្ចាស់កម្មសិទ្ធិដីធ្លីផ្តល់ពូជឱ្យ។ អត្រាបែងចែកមានផលប្រយោជន៍ដ៏ខ្លាំងដល់ម្ចាស់ដី ជាការអនុវត្តនៅក្នុងប្រទេសឱនាភិវឌ្ឍន៍។ ការជួលដី យោងទៅតាមដីល្អ ថ្លៃជាង ដីមធ្យម។ ជួនកាលថ្លៃឈ្នួលគិតជាស្រូវ។ ដោយសារការផ្តល់ដីសម្បូរអត្រាថ្លៃឈ្នួលដីមិនខ្ពស់ទេ។ ការខ្ចីបុលយកឈ្នួលដី ប្រប្រឹត្តទៅជាបណ្តោះអាសន្ន ដោយកសិករជាម្ចាស់ដី ដែលចង់ពង្រីកផ្ទៃដីអាជីវកម្ម ។

ទីពីរ ការបែងចែកកម្មសិទ្ធិដីធ្លី គឺមិនខុសគ្នាពេកទេ។ លោក M. Delvert ពិនិត្យឃើញសំណូមពរតួលេខនាឆ្នាំ ១៩៥៦ ជាភាគរយដូចតទៅ៖

| | | |
|---|---|---|
| កម្មសិទ្ធិ តិចជាង ១ ហ.ត. | ............................................. | ៥៥ |
| កម្មសិទ្ធិ ពី ១ ទៅ ២ ហ.ត. | ............................................. | ២៥ |
| - ពី ២ ទៅ ៥ ហ.ត. | ............................................. | ១២ |
| - ពី ៥ ទៅ ១០ ហ.ត. | ............................................. | ៧ |
| - ពី ១០ ទៅ ២០ ហ.ត. | ............................................. | ១ |
| - លើសពី ២០ ហ.ត. | ............................................. | ០.២ |

តួលេខនេះ មិនសូវច្បាស់លាស់ទេ តែបានបញ្ជាក់ថា កម្មសិទ្ធិដីធ្លីធំៗមានតិចតួចទេនៅកម្ពុជា។ តួលេខនេះចាស់ ផ្តល់ឱ្យដោយលោក Henry នាឆ្នាំ ១៩៣០។ ទាំងព្រះរាជា ទាំងព្រះរាជវង្ស ទាំងវត្តអារាម ទាំងពួកពាណិជ្ជករ អ្នកមាន ទាំងមន្ត្រីជាន់ខ្ពស់ មានដីនៅទីនេះ ឬទីនោះ មិនលើសពី ២០ ហិចតា ដែលមិនមានតួនាទីសំខាន់ក្នុងវិស័យកសិកម្មឡើយ។ ក្រុមហ៊ុនធំៗដែលដាំកៅស៊ូ ៥,០០០ ហិចតា ក្នុងក្រុមហ៊ុននីមួយៗ ទៅលើដីក្រហម មិនមែនជាម្ចាស់កម្មសិទ្ធិដីនោះទេ គេគ្រាន់តែជួលដីជាសម្បទាន តាមគោលការណ៍ច្បាប់រដ្ឋតែប៉ុណ្ណោះ តាមប្រពៃណីនៅកម្ពុជា ពួកអ្នកមានមិនមែនជាម្ចាស់ដី ម្ចាស់ឧស្សាហកម្មទេ តែជាពួកពាណិជ្ជករ ឬ មន្ត្រីនានា។ នោះហើយជាស្នាមសង្គមសេដ្ឋកិច្ចកម្ពុជា។

ទោះបីផ្ទៃដីត្រូវបានបែងចែកឡើងវិញឱ្យកសិករ ក្រោយពីធ្វើសមូហកម្មជាសហករណ៍សមូហភាព អស់រយៈពេលជាង បីឆ្នាំ ក៏សមាសភាពនៃកម្មសិទ្ធិដីដាំដុះ មិនមានការប្រែប្រួលច្រើនទេ។ រាជរដ្ឋាភិបាល អនុញ្ញាតឱ្យមានការសម្បទានដី សម្រាប់អាជីវកម្មដំណាំផ្សេងៗរយៈពេល ៦០ ឆ្នាំ ។

កម្មសិទ្ធិធំៗ ក៏គ្មានសារៈសំខាន់អ្វីដែរ នៅទូទាំងប្រទេស ដែលនៅមានខ្លះៗ នៅខេត្តបាត់ដំបង និងស្វាយរៀង។ កម្មសិទ្ធិដីធំៗទាំងនោះ មាននិន្នាការលិចបាត់ទៅវិញ។ ប៉ុន្តែបាតុភាពមួយបានកើតឡើង គឺពួក ពាណិជ្ជករ និងមន្ត្រីនានាបានទិញដីយកមកជួល។ នៅឆ្នាំ ១៩៦២ គ្រួសារចំនួន ៣០,០០០ ដែលមិនមែនជាកសិករ ជាម្ចាស់ កម្មសិទ្ធិដីទាំងនោះ។

ដូចនេះឃើញថា កម្ពុជាជាប្រទេស ដែលមានកម្មសិទ្ធិដីធ្លីតូចៗ។

**គ.** លទ្ធផលដែលមានការខិតខំធ្វើអាជីវកម្ម កសិកម្ម ភាគច្រើននៅកម្ពុជាគឺកម្មសិទ្ធតូចៗ និងមធ្យម។

ការបែងចែកអាជីវកម្ម ធ្វើឡើងដោយឯកជន ខាងកសិកម្ម ដែលអាចគិតជាភាគរយនៅឆ្នាំ ១៩៦២ ដូចតទៅ៖

| | | ចំនួនអាជីវកម្ម | ផ្ទៃដីធ្វើអាជីវកម្ម |
|---|---|---|---|
| តិចជាង ១ ហ.ត. | ............................................. | ៣១ | ៥ |
| ១ ទៅ ២ ហ.ត. | ............................................. | ២២ | ១០ |
| ២ ទៅ ៥ ហ.ត. | ............................................. | ៣៣ | ៣៨ |
| ៥ ទៅ ១០ ហ.ត. | ............................................. | ១០ | ២៥ |
| ១០ ទៅ ២០ ហ.ត. | ............................................. | ៣.៤ | ១៦ |
| លើសពី ២០ ហ.ត. | ............................................. | ០.៦ | ៦ |

ផ្ទៃដីដាំដុះ ជាមធ្យមដាំស្រូវ ម្នាក់មានដីមធ្យម ១.៣ ហ.ត. ។ ផ្ទៃដីនេះ គឺច្រើនណាស់។ នៅប្រទេសអាស៊ី លើកលែងតែភូមា និងថៃ គ្រួសារកសិករ មានដីដាំស្រូវក្នុងមួយគ្រួសារពី ០.២ ហ.ត. ទៅ ២ ហ.ត. ហើយអ្នកដែលមានដីធ្វើអាជីវកម្មខ្ពស់បំផុត គឺពី ០.៤ ដល់ ០.៦ ។

**ឃ.** សារៈសំខាន់នៃកត្តាផលិកម្មផ្សេងៗទៀត មិនសូវមានអានុភាពពេកទេ។ កសិករធ្វើ ការងារជាមួយ ដើមទុនតិច គោ ១ នឹម ឬក្របី នង្គ័ល រនាស់ កណ្តៀវ និងរទេះ តែខ្វះឧបករណ៍ទាំងនេះមិនបានឡើយ។ ការធ្វើ អន្តរតូបនីយកម្មគ្រាន់តែជាការចាប់ផ្តើម៖ នាឆ្នាំ ១៩៦៣ មានត្រាក់ទ័រចំនួន ៦០០ គ្រឿង ក្នុងនោះ ៤០០ គ្រឿង នៅក្នុងខេត្តបាត់ដំបង ។

ការប្រើប្រាស់ជីគីមី ក៏ចាប់ផ្តើមនៅក្នុងមជ្ឈដ្ឋានកសិករដែរ។

| | | គិតជាតោន |
|---|---|---|
| ១៩៦១ | ........................................... | ៩៥០ |
| ១៩៦២ | ........................................... | ១,៤០០ |
| ១៩៦៣ | ........................................... | ៦,៦០០ |
| ១៩៦៤ | ........................................... | ៨,៥០០ |
| ១៩៦៥ | ........................................... | ៤,៦០០ |

១៩៦៦ ........................................ ១១,៧០០
១៩៦៧ ........................................ ១៣,៣០០

ក្រោយឆ្នាំ ១៩៨០ ដើមឆ្នាំ ១៩៩០ ការអនុញ្ញាតឱ្យឯកជននាំចូលជីគីមី កើនឡើងរាប់ម៉ឺនតោនក្នុងមួយឆ្នាំ។ តាមតួលេខខាងលើ គឺការប្រើប្រាស់ជី ៥ គ.ក្រ. ក្នុង ១ ហ.ត. ប្រៀបធៀបប្រទេសជប៉ុន ៨០០ គ.ក្រ. តៃវ៉ាន់ ២០០ គ.ក្រ. ឬស្រីលង្កា ៥០ គ.ក្រ. ។ ប៉ុន្តែតួលេខនេះ ឈរនៅខាងមុខប្រទេសភូមាដែរ។

## ៧.២. ផលិតផលនៃផ្នែកកសិកម្ម

យើងពិនិត្យមើល ផ្នែករចនាសម្ព័ន្ធនៃផលិតផលកសិកម្ម ដោយវិភាគលើផលិតកម្មផ្សេងៗ និងការវិវដ្ត របស់ដំណាំទាំងនេះ។

សម្រាប់ឆ្នាំ ១៩៦២ និង១៩៦៣ មានការផ្តល់នូវតម្លៃបន្ថែម តាមរយៈការបង្វិលនៃចម្លងការច្រើនមានដូចជា៖

| | ១៩៦២ | ១៩៦៣ | ១៩៩៦៤ |
|---|---|---|---|
| ស្រូវ | ៣៤ | ៤១ | ៣៥ |
| ដំណាំឱ្យផ្លែ | ១១ | ១២ | ៩.៥ |
| ដំណាំបន្លែ | ៩ | ៨ | ១០ |
| ការចិញ្ចឹមសត្វ | ៧ | ៦ | ១៣ |
| កៅស៊ូ | ៧ | ៧ | ៦ |
| នេសាទ | ៧ | ៧ | ៦ |
| ព្រៃឈើ | ៤ | ៤ | ៨ |
| ពោតក្រហម | ២ | ២ | ៣ |
| ស្ករត្នោត | ២ | ៣ | ១.៥ |
| ដំណាំផ្សេងៗ | ១៥ | ១១ | ៧ |

រចនាសម្ព័ន្ធនេះ មិនត្រូវកែប្រែច្រើនទេ ក្នុងតំណាក់ការក្រោយសង្គ្រាម។ គួរកំណត់សម្គាល់ថា ស្រូវមិន មែនដំណាំតែមួយគត់នៅកម្ពុជានោះទេ។ ផលិតផលកៅស៊ូ ជាចំណែកធំមួយទៀតនៃវិស័យកសិកម្មប្រទេស ដែលមានចំនួន ជាង ៦០,០០០ ហ.ត. ស្មើនឹង ២% នៃផ្ទៃដីដាំកៅស៊ូបានតែប៉ុណ្ណោះ។ គេក៏ឃើញមានដំណាំឱ្យ ផ្លែ ដំណាំបន្លែ ជាច្រើនទៀត។

## ៧.២.១.ស្រូវ

ស្រូវ ជាដំណាំសំខាន់នៃកម្ពុជា ព្រោះផលិតផលនេះ បានរួមវិភាគទាន ដល់ទៅ ១/៣ នៃផលិតកម្មហើយជាមូលដ្ឋាននៃស្បៀងអាហារ និងជាទំនិញនាំចេញទីមួយរបស់ប្រទេស ព្រោះយើងដឹងហើយថា ៦៤% នៃ ប្រជាជនសកម្មកម្ពុជា គឺជាកសិករដែលដាំដុះស្រូវលើផ្ទៃដី ពី ៧០% ទៅ ៩០%។ ផ្ទៃដីដាំស្រូវ ពលករសកម្ម ចូលរួមដាំដុះ និងផលិតកម្ម មានដូតទៅៈ

- ផលិតផលសរុបកើនជានិច្ចក្នុងសង្វាក់ ស្មើនឹងកំណើនប្រជាជន។ សង្វាក់នេះ មាននិន្នាការថយចុះនៅចុងឆ្នាំក្រោយមក ពិសេសក្នុងសម័យសង្គ្រាម។ ក្រោយសង្គ្រាម ដោយសារមើនច្រើនពេក ផ្ទៃដីនៅមិនទាន់ស្តារដូចមុនសង្គ្រាមនៅឡើយ។ ប្រជាជនមានស្រូវហូបគ្រប់គ្រាន់ ហើយមានកសិផលនាំចេញទៀតផង។

- ផលិតផលក៏ដូចផ្ទៃដាំដុះ មានការផ្លាស់ប្តូរជារៀងរាល់ឆ្នាំ ដោយសាររបបទឹកភ្លៀងមិនទៀងទាត់។ ដូចនេះ សេដ្ឋកិច្ចកសិកម្មនៅតំបន់ក្តៅ ក៏ដូចកម្ពុជាដែរ មានភាពផ្សងព្រេងច្រើន។

- ផលិតភាពនៃពលករម្នាក់ៗ បានកើនឡើងជានិច្ចសឹងខ្លាំងក្លាតាំងពីដើមសតវត្សមក ។ ទំហំនៃចលនាពលកម្មបានបញ្ជាក់នៃតថភាពនៃបាតុភូតនោះ។ ការថយចុះនៃភាពអត់ការងារធ្វើ ក្នុងផ្នែកកសិកម្មដែល ពីមុននេះមានច្រើនបំផុត។ ការកើនឡើងនៃពលកម្មសង្គម កើនឡើងដោយអនុភាពនៃការពង្រីកផ្ទៃដីដាំដុះថ្មី ដោយមនុស្សម្នាក់ៗ ដែលកើនឡើងពី ០.៥ ហ.ត. ក្នុង ១ នាក់ ឡើងដល់ ១.៣ ហ.ត. នាពេលសព្វថ្ងៃ។

- ទិន្នផលស្រូវ មិនទាន់បានកើននៅឡើយទេ តាំងពីសតវត្សទី ២០ មក ។ ទិន្នផលស្រូវនៅកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដែលទាបបំផុតនៅក្នុងលោក។ ក្រៅពីកូនភូមិសាស្ត្រ កម្ពុជានៅមានភាពទន់ខ្សោយខាងវិធានការផ្សេងៗ ។ ការពង្រីកផ្ទៃដីដាំដុះច្រើន ក៏ជាដើមហេតុនៃទិន្នផលទាបនេះដែរ។ ដីដែលត្រួសត្រាយថ្មី ភាគច្រើនជាដីខ្វះដីជាតិ។ ប៉ុន្តែកម្ពុជា អាចធ្វើប្រពលវប្បកម្មស្រូវបាន។ គំរូជាច្រើនមានការណែនាំ ឧបត្ថម្ភដោយសេវាកម្ម រដ្ឋាភិបាល កសិករខ្លះអាចបង្កើនទិន្នផលស្រូវដល់ពី ៣ ទៅ ៤ តោន ក្នុងមួយហិចតា។ ការធ្វើប្រពលវប្បកម្មនេះ ជាចំណុចសំខាន់នៃសេដ្ឋកិច្ចកសិកម្មកម្ពុជា។

- តាមរយៈអ្នកបច្ចេកទេសកម្ពុជាឱ្យដឹងថា ការធ្វើប្រពលវប្បកម្មស្រូវ គឺតាមរយៈបំប៉នដីស្រែដោយដី ធម្មជាតិ ការរៀបចំភ្លឺទប់ទឹក ការប្រើដីគីមី ការជ្រើសរើសពូជថ្មី ទិន្នផលខ្ពស់ ការអនុម័តយកបច្ចេសទេសដាំដុះ និងតាមរយៈនយោបាយធារាសាស្ត្រ ដែលផ្តល់ដល់ការធ្វើប្រព័ន្ធធារាសាស្ត្រតូចៗ ។

ផលស្រូវពាក់កណ្តាល ទុកសម្រាប់ប្រើប្រាស់ក្នុងស្រុក។ តួលេខនាឆ្នាំ ១៩៥៩ ដល់ ១៩៦៤ បានបញ្ជាក់ពីការប្រមូលផលស្រូវប្រើប្រាស់ដូចតទៅៈ

- ប្រើប្រាស់ក្នុងប្រទេស .................................. ៥០
- នាំចេញ .................................. ២៣
- ពូជ .................................. ៧

- ធ្វើពាណិជ្ជកម្ម .................................. ៥
- ផ្គត់ផ្គង់ដល់ឈ្មួញកណ្តាល .................................. ៥
- បាត់បង់ និងដាក់ជង្រុក .................................. ១០

ផលិតផលស្រូវ ថយចុះក្នុងប៉ុន្មានឆ្នាំចុងក្រោយមុនសង្គ្រាម ១៩៦៥-១៩៦៦-១៩៦៧ គឺមានបរិមាណទាបជាងឆ្នាំ ១៩៦៣-១៩៦៤ ។ លក្ខខ័ណ្ឌអាកាសធាតុ ជាកត្តាកំណត់នៃការថយចុះនេះ។ ការធ្វើពាណិជ្ជកម្ម ស្រូវនៃការប្រមូលផលឆ្នាំ ១៩៦៤-១៩៦៥ មិនបានល្អទេ។ ថ្លៃស្រូវធ្លាក់ចុះពី ២,២៨០ រៀល ក្នុងមួយតោន នាឆ្នាំ ១៩៦៣ ទៅ ១,៨៧០ រៀល នាឆ្នាំ ១៩៦៤ ។ កសិករដែលបាត់ក្តីសង្ឃឹមពីការលក់ផលស្រូវ បានបន្ថយការខិតខំ។

## ៧.២.២.ដំណាំឱ្យផ្លែ

ដំណាំឱ្យផ្លែ ក៏បានឱ្យតម្លៃបន្ថែមច្រើនដែរ ។ តម្លៃបន្ថែមនោះ ស្មើនឹង ៣.៥ នៃតម្លៃបន្ថែមរបស់ដំណាំស្រូវ។ តែផលិតផល មិនបានបញ្ជាក់តួលេខច្បាស់លាស់ ។

ផលិតផលផ្លែឈើ មានភាគរយ ដូចខាងក្រោម នាឆ្នាំ ១៩៦២-១៩៦៣

ពពួកក្រូច .................................. ៤០
ចេក .................................. ៣០
សាច់ដូង .................................. ១០
ដទៃទៀត .................................. ២០

ដំណាំផ្លែឈើខ្វះបច្ចេកទេស មានទិន្នផលមធ្យមទាប។ ដំណាំនេះ ដាំយកផ្លែហូបក្នុងស្រុក ៩០% ។ នៅខេត្តបាត់ដំបង កំពង់ចាម ។ ផ្លែក្រូចពោធិ៍សាត់ បានត្រូវនាំចេញ និងជាវត្ថុធាតុដើមទឹកក្រូច។

ដំណាំបន្លែសណ្តែកខៀវ ប៉េងប៉ោះ ត្រសក់ សាលាដ ឪឡឹក មាននៅគ្រប់កន្លែង ពិសេសតាមមាត់ទន្លេ មេគង្គ ដែលដីនេះក៏ត្រូវដាំដុះផងដែរ នូវដំណាំឧស្សាហកម្មដូចជា ពោតក្រហម ថ្នាំជក់ មនកប្បាស ជាដើម។ កាដាំដំណាំចំការ មានភាពជាប្រពលវប្បកម្ម ជាងការដាំដុះស្រូវ។ តែទិន្នផលនៅទាប គឺបាន ១០ តោនក្នុងមួយ ហិចតានូវបន្លែ។ លើកលែងតែសណ្តែកខៀវ សណ្តែកសៀង ដែលធ្វើពាណិជ្ជកម្មបានសម្រាប់នាំចេញ។ បន្លែគ្រប់ គ្រាន់សម្រាប់ប្រើប្រាស់ក្នុងប្រទេស។ ចង់នាំចេញបាន លុះណាតែបន្ថយថ្លៃដើម តាមរយៈការអនុវត្តបច្ចេកទេសដាំដុះ ចាត់តាំងពាណិជ្ជកម្មបន្លែ ដោយបង្កើតរោងចក្រកែច្នៃ។

### ៧.២.៣.ការចិញ្ចឹមសត្វ

ការចិញ្ចឹមសត្វ គឺជាផលិតកម្មកសិកម្មសំខាន់មួយដែរនៅកម្ពុជា។ ការកើនឡើងនៃចំនួនសត្វពាហនៈ ត្រូវរាប់បញ្ចូលទៅជាផលិតកម្មសំខាន់ និងរួមវិភាគទានដល់តម្លៃបន្ថែមដូចជា ការផ្គត់ផ្គង់ឱ្យដល់ឈ្មួញកណ្ដាលសម្រាប់យកសត្វទៅកន្លែងសត្តឃាតដែរ។

រវាងឆ្នាំ ១៩៥៥-១៩៥៧ និង១៩៦៣-១៩៦៥ ចំនួនជ្រូកកើនឡើងទ្វេ។ ចំនួនគោ និងក្របីកើនឡើង ពី ៦០% - ៨០% ក្នុងរវាងឆ្នាំខាងលើ។ ទោះបីត្រូវបំផ្លាញដោយសង្គ្រាមក្រោយឆ្នាំ ១៩៧៥-១៩៧៩ ចំនួនសត្វ ពាហនៈនេះ បានកើនឡើងវិញក្នុងអត្រាមួយខ្ពស់។

ក្នុងតម្លៃបន្ថែម គឺផលិតកម្ម ជ្រូក ដែលមានសារៈសំខាន់។ តាមតួលេខឆ្នាំ ១៩៦២ ជ្រូកមានប្រហែល ៤០០,០០០ ក្បាល ត្រូវបានផ្គត់ផ្គង់ជាអាហារប្រចាំឆ្នាំនៅកម្ពុជា ហើយជាង ១០០,០០០ ក្បាលសម្រាប់នាំចេញ។ ចំពោះគោ និងក្របី តួលេខដែលផ្ដល់ជាសេចក្ដីត្រូវការមានចំនួនពី ៥០,០០០ និង២០,០០០ ក្បាល ប្រចាំឆ្នាំ។ ប្រជាជនខ្មែរ ហូបសាច់ និងត្រីជាអាហារ។

ប៉ុន្តែការចិញ្ចឹមសត្វ ឬការចិញ្ចឹមគោ ក្របីមានផលប្រយោជន៍ជាមធ្យោបាយអូសទាញ និងដឹកជញ្ជូន៖

- សត្វ គោ ក្របី នៅកម្ពុជា ផ្ដល់ជាពលកម្ម ភ្ជួររាស់ ដឹកជញ្ជូន។ ប៉ុន្តែការប្រើប្រាស់គោនៅកម្ពុជាមានចំណុចខ្វះខាតត្រង់ថា ប្រើតែគោឈ្មោល ហើយមួយឆ្នាំប្រើតែ ៦០ ថ្ងៃ។ ការពង្រីកសត្វហ្វូង សម្រាប់នាំចេញ ឬយកទឹកដោះ មិនទាន់មានការអភិវឌ្ឍនៅឡើយ។
- សត្វពាហនៈផ្ដល់អាចម៍ជាជី ហើយផ្ទៃដីស្រែចំការរាប់លានហិចតាត្រូវការជីបែបនេះ។
- មេគោគួរតែផ្ដល់ទឹកដោះ ប៉ុន្តែនៅកម្ពុជា គ្មានករណីបែបនេះទេ ដោយសារការខ្វះលទ្ធភាព នៃបច្ចេកទេស។

ការអភិវឌ្ឍដំណាំស្រូវនៅកម្ពុជា ត្រូវឆ្លងកាត់ការចិញ្ចឹមសត្វ ព្រោះចំការស្រែ ចិញ្ចឹមសត្វពាហនៈទាំង នោះ តាមរយៈចំបើង ហើយផ្ទុយមកវិញ សត្វទាំងនោះ ចិញ្ចឹមស្រែចំការវិញដោយផ្ដល់អាចម៍ជាជីស្រស់។

### ៧.២.៤.ការនេសាទ

ការនេសាទ មានភាពជាគ្រួសារ និងសិប្បកម្ម ប៉ុន្តែត្រីជាអាហារមូលដ្ឋានប្រចាំថ្ងៃ បែបជាមច្ឆាស្រស់ ងៀត ប្រឡាក់ ឆ្អើរ ឬជាប្រហុក ផ្អក ឬជាទឹកត្រី។ ការនេសាទប្រព្រឹត្តទៅ នៅទឹកសាប និងសមុទ្រ។

ផលិតផលទឹកសាប មានបរិមាណថយចុះ និងបាត់ពូជត្រីជាច្រើន ក្នុងរយៈពេលជាង ៤០ ឆ្នាំកន្លងមក។ ការសិក្សាបញ្ជាក់ថា តួលេខ ១០០,០០០ តោន ត្រីស្រស់ក្នុងមួយឆ្នាំ។

រហូតមកដល់សព្វថ្ងៃនេះ ការនេសាទទឹកប្រៃ នៅមិនទាន់អភិវឌ្ឍន៍នៅឡើយ ហើយការបែងចែកការងារនៅមិនទាន់ច្បាស់លាស់។ ការនេសាទទឹកប្រៃធ្វើសម្រាប់ការនាំចេញ ព្រោះប្រជាជននៅមាត់សមុទ្រ មានចំនួនតិចណាស់។ ប្រៀបធៀបមុនសម័យសង្គ្រាមលោក ផលត្រីសមុទ្រក៏ថយចុះដែរ ហើយទីផ្សារខាងក្រៅ ដូចជាមិនទាន់ផ្សារភ្ជាប់នឹងផលិតផលសោះ។ ផលិតផលសរុបមានចំនួន ៤០០,០០០ តោនក្នុងមួយឆ្នាំ។

មួយភាគនៃត្រីទាំងនោះ គឺសម្រាប់នាំចេញ។ ដោយខ្វះវត្ថុជាតុដើម រោងចក្រសម្រាប់កែច្នៃត្រីសមុទ្រ មាន ដំណើរការអាក់អន្លល។ ការនាំចេញភាគច្រើន ធ្វើដោយលួចលាក់។ ការប្រើប្រាស់ក្នុងស្រុក ក៏មានសារៈសំខាន់ណាស់ដែរ។

ធនធាននេសាទ ជាប្រភពធនធានប្រពៃ ដែលផ្តល់អាហារមានជាតិប្រូតេអ៊ីន ដល់ប្រជាជនកម្ពុជា ប៉ុន្តែការធ្វើអាជីវកម្មមិនទាន់មានទិន្នផលខ្ពស់ ហើយមិនរក្សាបាននូវបរិយាកាសជុំវិញ ព្រោះមានការរំលោភច្បាប់នេសាទ ។

### ៧.២.៥.កៅស៊ូ

កៅស៊ូ មានឈ្មោះល្បី ជាដំណាំចំការធំៗ ដែលបានបញ្ចូលមកកម្ពុជាដោយក្រុមហ៊ុនអឺរ៉ុបចំនួន ៦ ចាប់ពីឆ្នាំ ១៩២០ មក នៅលើដីមានដីជាតិ-ដីក្រហម ដែលធានាបាននូវផលិតផលនេះ។ ចាប់ពីឆ្នាំ ១៩៥៧ រដ្ឋាភិបាលបានលើកទឹកចិត្តការអភិវឌ្ឍដំណាំកៅស៊ូ ជាលក្ខណៈគ្រួសារ ហើយបង្កើតជាក្រុមហ៊ុនរដ្ឋនៅឡាបានសៀក ខេត្តរតនគិរី។

ក្នុងវិស័យនេះ មានការកត់ចំណាំពីរ ដែលពិនិត្យឃើញ៖ ដំណាំកៅស៊ូ ជាដំណាំនាំចេញ។ ជ័រកៅស៊ូ មិនត្រូវបាននាំចេញផៅទេ គឺត្រូវបានធ្វើការកែច្នៃជាបឋមសិន រោងចក្រនានានៅតាមក្រុមហ៊ុនបានកែច្នៃជាកៅស៊ូក្រែប។ ក្រៅពីនេះរោងចក្រ និងសិប្បកម្ម កម្មន្តសាល កែច្នៃកង់ឡាន កង់ម៉ូតូ កង់ បានត្រូវបង្កើតឡើង ដោយប្រើប្រាស់មួយភាគតូច នៃបរិមាណផលិតផលពាក់កណ្តាលសម្រេច។

## ៧.៣. ការធ្វើពាណិជ្ជកម្ម ផលិតកម្ម កសិកម្ម

ពិនិត្យលើរចនាសម្ព័ន្ធបែងចែកដីធ្លី ផលិតកម្មកសិកម្មនៅកម្ពុជា មិនសូវមានការកេងប្រវ័ញ្ចនោះ យើងឃើញលើចំណុចពាណិជ្ជកម្មកសិផល ដំណាក់កាលនៃការទិញថោក លក់ថ្លៃ ។

### ៧.៣.១.សៀគ្វីប្រពៃណី

លោក M. Delvert បានពណ៌នាថា៖ ចិនដែលមានហាងលក់ដូរ ក្នុងភូមិនីមួយៗ បំពេញបាននូវតួនាទីពីរ៖ ផ្តល់ដល់កសិករនូវការទិញ។ ពួកនេះប្រមូលទិញកសិផលនាំចេញ។ នៅក្នុងហាងនោះមានទំនិញគ្រប់ប្រភេទ ដែលកសិករត្រូវការចាប់ពីគ្រឿងទេស រហូតដល់ ស្ករ ទឹកដោះគោ ខោអាវ ម៉ុងក្ទួយ។

ល។ ទំនិញទាំងនោះ ចិនបានឱ្យកសិករមុនពេលប្រមូលផល។ កសិករត្រូវការលុយ ទំនិញដែលចិនផ្តល់ឱ្យហើយ ត្រូវសងមកវិញនៅពេលប្រមូលផលជា ពោត ស្រូវ ថ្នាំជក់។ល។ ពួកចិនតាមភូមិនេះ តែងទទួលប្រាក់ពីពួកឈ្មួញធំៗ ពីទីក្រុង ដែលមានក្រុមហ៊ុននាំចេញ នាំចូល ដែលភាគច្រើនជាកូនកាត់ចិន។

ផ្ទុយទៅវិញ តាមរយៈសៀគ្វីនេះ សម្រាប់ការនាំចេញ កសិករត្រូវសងជាស្រូវ កប្បាស សណ្តែក ឬ ផលិតផល ដែលបេះពីព្រៃ ដូចជា ក្រវាញ ដង្គោ ឬស្នែង ភ្លុក ពីការប្រមាញ់មកឱ្យចិន។ ពួកអ្នកប្រមូលកសិផលទាំងនោះ ធ្វើការច្រកកសិកផលក្នុងបាវ ដឹកតាមរថយន្ត ទូកថ្ងៃ។ សព្វថ្ងៃ ដោយសារម៉ាស៊ីនកិនស្រូវមានកើនឡើងច្រើន ការប្រមូលទាំងនោះធ្វើឡើងដោយម្ចាស់ម៉ាស៊ីនកែច្នៃធំៗ។ ពួកពាណិជ្ជករទាំងនោះ ខ្ចីលុយពីធនា គារយក លុយទៅឱ្យពួកឈ្មួញកណ្តាលជាអ្នកប្រមូលទិញ។ សៀគ្វីពាណិជ្ជកម្មបែបនេះប្រព្រឹត្តទៅជាធម្មតា។

ទោះបីកសិករមិនបានខ្ចីប្រាក់ពីឈ្មួញតាមភូមិក៏ដោយ ក៏ពេលខ្លះបានបង្ខំចិត្ត លក់ក្នុងតម្លៃថោក ព្រោះគេខ្វះជង្រុក ឃ្លាំងស្តុក។ គេលក់ពេលប្រមូលផល ដែលពេលនោះតម្លៃកសិផលទាបណាស់។ នៅទីផ្សារអន្តរជាតិមានការផ្គត់ផ្គង់ខ្ពស់។ កសិករខ្វះមធ្យោបាយដឹកជញ្ជូន ត្រូវលក់នៅក្នុងចំការស្រែ។

គេឱ្យខ្ចីបណ្តាក់មុនដល់កសិករ ក្នុងអត្រាការប្រាក់ខ្ពស់ ១០% ក្នុងមួយខែ។ ក្នុងពេលដែលកសិករត្រូវការសម្ភារបម្រើផលិតកម្ម ឬបុណ្យទាន ពួកចិននៅតាមភូមិធ្វើកាឱ្យខ្ចីមុន។ កសិករទាំងនោះគ្មានការបែងចែករវាងឥណទានប្រើប្រាស់ និងឥណទានសម្រាប់ផលិតកម្មទេ។ ហេតុដូចនេះហើយ បានជាមានការកេងប្រវ័ញ្ចខ្ពស់លើកសិករ ។

ប៉ុន្តែប្រព័ន្ធកសិកម្មនេះ មានប្រសិទ្ធិភាពណាស់។ គឺការរកស៊ីបែបនេះ បានរួមចំណែកដល់ការនាំចេញកសិផលកម្ពុជា។ ចេញពីប្រព័ន្ធនេះ បានធានាដល់ការផ្គត់ផ្គង់នូវកសិផលតម្រូវការជាតិ និងអន្តរជាតិ។ នៅជង្រុកម្ខាងពួកឈ្មួញក៏បានលើកទឹកចិត្តកសិករឱ្យខំផលិត ទោះបីជាមានការទិញថោក លក់ថ្លៃកប់ក្តោងក៏ដោយ។

### ៧.៣.២.និន្នាការកែលម្អសៀគ្វី

ដោយគិតទៅដល់កតិកាសង្គម ដាងផលប្រយោជន៍សេដ្ឋកិច្ច នៃប្រព័ន្ធចាស់នោះ រដ្ឋអំណាចសាធារណៈបានខិតខំកែលម្អសៀគ្វីពាណិជ្ជកម្ម ពិសេសការប្រមូលផលស្រូវ ឬក៏ការប្រមូលផលស្រូវ និងកសិផលមួយភាគសម្រាប់នាំចេញ។

ជាបឋម គឺការធ្វើជាតូបនីយកម្មធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដែលសម្រេចឡើងនាខែវិច្ឆិកា ១៩៦៣ មុនពេលធ្វើពាណិជ្ជកម្មនៃការប្រមូលផលឆ្នាំ ១៩៦៤ ដែលមានគោលដៅបញ្ចប់នូវឯកជនមកនៅក្រោមដៃរបស់រដ្ឋអំណាចសាធារណៈ ដែលលោក M. Delvert និយាយពីតួនាទីរបស់សូណិចស៊ីមក្នុងការនាំស្រូវចេញរបស់កម្ពុជា។

ស្រូវមួយភាគបានត្រូវសូណិចស៊ីម ទិញពីឈ្មួញឯកជន ប៉ុន្តែគេបានទិញពីអង្គការសាធារណៈបីផ្សេងទៀតដែលបានប្រកួតជាមួយឈ្មួញឯកជន គឺ សូរាប៉ា អូរ៉ុក និងសាត្រា។

សូរាប៉ា ក្រុមហ៊ុនប្រមូលស្រូវ ជាសាខារបស់សូណិចស៊ីម ដែលទទួលបន្ទុកប្រមូលស្រូវ។ អូរ៉ុក ជា ការិយាល័យនៃរាជសហករណ៍ ត្រួតពិនិត្យការប្រព្រឹត្តទៅនៃសហករណ៍ ដែលខិតខំលក់ដូរផលិតផលរបស់សមាជិកខ្លួន។ សាត្រា ជាសាខារបស់ អូរ៉ុក ជាសេវាប្រមូលទិញ និងកែច្នៃ និងរៀបចំលក្ខខ័ណ្ឌកសិផល ដែលប្រមូលផលពីកសិករដែលមិនទាន់ក្លាយជាសមាជិកសហករណ៍។

អង្គការសាធារណៈទាំងនេះ មានភាពទន់ខ្សោយអស់រយៈពេលជាយូរ ។ ប៉ុន្តែ អូរ៉ុក កាន់តែមានតួនាទី សំខាន់ខ្លាំងឡើង។ នៅឆ្នាំ ១៩៦៧ ការធ្វើពាណិជ្ជកម្ម អូរ៉ុក បានប្រមូលស្រូវក្នុងបរិមាណពាក់កណ្តាល ផ្តល់ដល់ សូណិចស៊ីម សម្រាប់នាំចេញ។

ពាណិជ្ជកម្មឯកជន មិនមានការលុបបំបាត់ចោលទេ ប៉ុន្តែការផ្តាច់មុខប្រមូលផលពីមុនបានថយចុះ។

# មេរៀនទី ៨
# ការទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនឧស្សាហកម្ម

កម្ពុជា គ្មានប្រពៃណីឧស្សាហកម្មទេ។ ចំណែកសិប្បកម្មទៀតសោធ តាំងពីដើមមក មិនទាន់មានភាពរីកចម្រើនទេ។ ពួកអាណានិគម មិនបានបានរៀបចំធ្វើឧស្សាហូបនីយកម្ម លើប្រទេសដែលគេបានចាត់ទុកថា គ្រាន់តែជាអ្នកផ្គត់ផ្គង់នូវកសិផល ក៏ដូចជាអ្នកប្រើប្រាស់ទំនិញចុងក្រោយ។ ឧស្សាហកម្មសូត្រ កប្បាស បានរលាយទៅវិញក្នុងសម័យអាណានិគម។

ហេតុនេះហើយ ឧស្សាហកម្មមុននេះ គឺគ្មានអត្ថិភាពទេ រហូតមកដល់មុនពេលឯករាជ្យនាឆ្នាំ ១៩៥៣។ នាឆ្នាំ ១៩៤២ ក្រៅពីរោងចក្រកែច្នៃជ័រកៅស៊ូ មានតែរោងចក្រសុរាគារកម្ពុជាប៉ុណ្ណោះ ដែលជាឧស្សហកម្ម។ សហគ្រាសកើតថ្មីៗ ដូចជាស្លរប្រេង ម៉ាស៊ីនកិនស្រូវ ផលិតស្បៀង ឥដ្ឋ តម្បាញ សុទ្ធតែជារោងជាង លក្ខណៈគ្រួសារ និងសិប្បកម្ម ។ ចំនួននិយោជិកឧស្សាហកម្មពេលនោះមានតិចជាង ១,០០០ នាក់។

ចាប់ពីពេលឯករាជ្យ កម្ពុជាបានចូលក្នុងមាគ៌ាឧស្សាហូបនីយកម្មដោយខ្វះស្ថិតិពិត។

## ៨.១.ឧស្សាហូបនីយកម្មនៅកម្ពុជា

ដើម្បីវិភាគបានល្អនូវការរីកចម្រើនដ៏ខ្លាំងក្លា ដែលសម្រេចឡើងក្នុងវិស័យឧស្សាហកម្ម គេត្រូវយកទ្រឹស្ដីមកបែងចែក រវាងការកើនឡើងនៃទុនឧស្សាហកម្ម គឺការវិវឌ្ឍនៃការវិនិយោគ និងការកើនឡើងជាបន្តបន្ទាប់ នូវផលិតកម្មឧស្សាហកម្ម។

អ្វីដែលបញ្ជាក់លក្ខណៈនៃផ្នែកឧស្សាហកម្ម ហើយនិងភាពខុសគ្នានៃផ្នែកកសិកម្ម ហើយជាបឋមពីផ្នែកសេវាកម្ម គឺនៅត្រង់មានការកើនឡើងនៃផលិតកម្ម Du flux មិនអាចមានលទ្ធភាពបាន បើគ្មានការកើនឡើងនៃទុន Du stock ។ អត្ថន័យមួយទៀតទុនជាកត្តាសំខាន់នៃផលិតកម្មឧស្សាហកម្ម។ បើការវិវឌ្ឍនៃកត្តា និងផលិតកម្មនៅមានចំណងរវាងគ្នានោះ គេមិនអាចបែងចែកបានទេ។ ដូចនេះហើយបានជាយើងត្រូវសិក្សា ដាច់ដោយឡែក។ យើងអាចសិក្សា និងវិភាគបានពីទំនាក់ទំនងដែលចងភ្ជាប់រវាងគ្នា និងការវិវឌ្ឍរបស់វា មេគុណនៃទុន និងផលិតភាព ជាឧបករណ៍ដែលត្រូវលត់ដុំនៅក្នុងការវិភាគនេះ។

ប៉ុន្តែ តាមការអនុវត្តវាមានគ្មានលទ្ធភាព ដើម្បីប្រមូលផ្ដុំរាល់អត្ថន័យនៃការវិវឌ្ឍទុនឧស្សាហកម្មនៅ កម្ពុជា។ តួលេខជាច្រើន ដែលទុកស្នាមការវិវឌ្ឍនៃចំនួនសហគ្រាសឧស្សាហកម្ម ផ្ដល់នូវគំនិតនៃការរីកចម្រើន ដែលសម្រេចបាន។ គេត្រូវការនូវតួលេខនៃវិស័យនោះ ហើយពិសេសចំណុចខុសៗគ្នា។ តួលេខដែលរាយការណ៍ពីការវិនិយោគទុនឧស្សាហកម្ម គ្មានលក្ខណៈគ្រប់គ្រាន់សោះ។

មានស្នាមនៃការវិវឌ្ឍនៃថ្លៃនឹងននៃតម្លៃបន្ថែម ដែលទុកជាឯកសារ ដោយវិស័យឧស្សាហកម្ម និងគោលការណ៍សមាសភាព បានត្រូវគណនាក្នុងរយៈពេលឆ្នាំ ១៩៥២-១៩៦៤ ហើយបង្ហាញនូវការជានា

ច្រើន។ គឺឯកសារនោះហើយ ដែលយើងអាចបែងចែកបាន រវាងទុនវិនិយោគ ឬទុនឧស្សាហកម្ម និងផលិតកម្មឧស្សាហ- កម្ម។

ការរួមវិភាគទានតម្លៃបន្ថែមនៃផ្នែកឧស្សាហកម្មបានកើនទ្វេ ក្នុងរយៈពេលនោះ ដែលគេអាចសន្មត់នូវការកើនឡើងនៃអត្រាប្រចាំឆ្នាំមធ្យមលើសពី ៨% ។

អត្រាកំណើនមានភាពខុសគ្នាពីសាខាមួយទៅមួយ។ អត្រាមានកម្រិតខ្ពស់ ចំពោះឧស្សាហកម្មដែលគ្មានអត្ថិភាពនាពេលមុននេះ៖ អុកស៊ីហ្សែន អាសេទីឡែន ក្រដាស ក្លារបន្ទះ ។ អត្រាកើនឡើងដល់ ១៣% ចន្លោះឆ្នាំ ១៩៥២-១៩៦៣ នៃវិស័យសំណង់ និងសាធារណៈ និងសម្ភារៈសំណង់ ទន្ទឹមនោះឧស្សាហកម្មបម្រើសំណង់ ក៏កើនឡើងដែរ។ ផ្នែកផលិតបារី និងឈើគូស កើនឡើងដល់ ៨% ។ ផ្នែកជួសជុលគ្រឿងយន្ត អគ្គិសនី ទឹក ភេសជ្ជៈ និងឧស្សាហកម្មផ្សេងទៀតមានអត្រាកំណើន ៨% ដែរ។

ផ្ទុយទៅវិញ មានការរីកចម្រើនយឺត តែ ២% ក្នុងផ្នែកឧស្សាហកម្មស្បៀង និងឧបករណ៍សម្ភារៈកសិកម្ម។ ចាប់ពីឆ្នាំ ១៩៦៣ ការរីកចម្រើនឧស្សាហកម្មនៅកម្ពុជា ហាក់ដូចជាជួបឧបសគ្គមួយចំនួន។ ឆ្នាំ ១៩៦៤ ជាឆ្នាំចុងក្រោយ ដែលគេមានតួលេខជារួមមានការកត់សម្គាល់នូវភាពថយចុះនៃសកម្មភាពសំណង់ និងការងារ សាធារណៈ។ តួលេខនៃឆ្នាំបន្តបន្ទាប់ មិនអាចនិយាយថាផ្នែកទី ២ នេះ បន្តអត្រាកំណើនខ្ពស់ទេ។ វាលេចឡើងនូវទុទិដ្ឋិនិយម។ ការប្រើប្រាស់អគ្គិសនី ដែលជាមូលដ្ឋានសំខាន់នៃប្រទេសរីកចម្រើន បែរជានៅនឹងថ្កល់។ ផ្នែកសំណង់ ដែលជាដើមហេតុនៃឥទ្ធិពលលើវិស័យដទៃ ហាក់ដូចជាមិនអាចងើបឡើងឱ្យស្មើមុនឆ្នាំ ១៩៦៣ បានឡើយ។ តួលេខនៃផលរបរនៃសាខាជាច្រើនរបស់ឧស្សាហកម្មដូចជា ស្បៀង តំបាញ រោងពុម្ព ក្រដាស យន្តសាស្ត្រ បានថយចុះនៅឆ្នាំ ១៩៦៦ ប្រៀបឆ្នាំ ១៩៦៥ ដែលមុននេះគឺឆ្នាំ ១៩៦៤ មានភាពរីកចម្រើន សន្ទស្សន៍ទាំងនេះ ត្រូវបានបកស្រាយដោយប្រុងប្រយ័ត្ន ដែលជាចំណុចកត់សម្គាល់នូវការទ្រឹង និងថយចុះនៅឆ្នាំ ១៩៦៣ មក។

គេក៏ត្រូវគូសបញ្ជាក់ផងដែរ អំពីតួនាទីនៃអំណាចសាធារណៈ ក្នុងអភិក្រមនៃឧស្សាហូបនីយកម្ម។ រដ្ឋមិនឈរនៅតែឯងទេក្នុងការធ្វើអន្តរាគមន៍ ដោយបង្កនូវលក្ខខ័ណ្ឌនៃការអភិវឌ្ឍនៃការផ្តួចផ្តើមផ្នែកឯកជន។ បើខ្វះជំនឿក្នុងប្រសិទ្ធភាពនៃការផ្តួចផ្តើម រដ្ឋចាំបាច់ចូលរួមដោយផ្ទាល់។

រដ្ឋបានកសាងរោងចក្រ ពេលបញ្ចូលទុកជាមួយឯកជនក្នុងសហគ្រាសនានា ដែលហៅថា សេដ្ឋកិច្ចចម្រុះពេលខ្លះទទួលជំនួយពីបរទេសជាអំណោយ ឬខ្ចីបុល។ ដូចនេះហើយបានជាមានការរីកចម្រើនផ្នែកឧស្សាហកម្ម នៃវិស័យសាធារណៈ ដូចជារដ្ឋាករទឹក រោងចក្រក្រដាស វាយនភ័ណ្ឌបឹកន្លែង សុរាគាររោងចក្រកង់រថយន្ត រោង ចក្រធ្មេចកប្បាស រោងចក្រស្ករ ក្លារបន្ទះ ឥដ្ឋ បារក្រចៅ អារឈើ ទឹកក្រូច កែវ ។ល។ និងពាក់ កណ្តាល សាធារណៈ ដូចវិស័យ អគ្គិសនី បារី ឈើគូស ផលិតជីផូស្វាត។ ប៉ុន្តែ សារៈសំខាន់នៃផ្នែកសាធារណៈនេះត្រូវផ្តល់គុណភាពជាជាងមានតែបរិមាណ។

ប៉ុន្តែរហូតដល់ពេលបច្ចុប្បន្នការរីកចម្រើនផ្នែកឧស្សាហកម្ម គឺកើនឡើងដោយវិស័យទុនឯកជនដែលបានវិនិយោគនៅកម្ពុជា ក៏មានវណ្ណៈសហគ្រិនដែរ។ នៅកម្ពុជា មនុស្សចេះធ្វើផលរបរដ៏មានថាមពល

ចេះសន្សំ ចេះធ្វើការ ដើម្បីប្រាក់ចំណេញ ឬជាពពួកមនុស្សមានសមត្ថភាពបង្កើត និងដឹកនាំសហគ្រាស គឺពួកខ្មែរកូនកាត់ចិន។ ទីនេះ ពាណិជ្ជកម្ម អូសទាញសកម្មភាពអាជីវកម្មជាងឧស្សាហកម្ម។ ពួកគេក្លាយពីពាណិជ្ជករ ទៅជាឧស្សាហករ។

ឧស្សាហូបនីយកម្មនៅកម្ពុជា បានប្រព្រឹត្តទៅពុំសូវមានរបៀបរបបបន្តិច។ តួនាទីរបស់សហគ្រាសឯកជនបានបង្ហាញពីបាតុភាពអាណាធិបតេយ្យ៖ ពួកមូលធនរកប្រាក់ចំណូល គ្មានការដឹកនាំដោយផែនការរួមទេ។ ឃើញអ្វីចំណេញ នាំគ្នាបោះទុនចូលទីនោះភ្លាម។ ការមិនបានសិក្សាស្រាវជ្រាវផ្នែកសេដ្ឋកិច្ចនៃតថភាព និងលទ្ធភាព ធ្វើឱ្យប្រតិបត្តិការមិនបានក្នុងតម្លៃមួយខ្ពស់ ហើយនាំកើតជាឧបសគ្គក្នុងទិសដៅអភិវឌ្ឍន៍ឧស្សាហកម្ម នៃពុទ្ធិមួយសមស្រប។

តាមធម្មជាតិនៃកម្ពុជា ផែនការមួយដែលមានទិសដៅល្អត្រឹមត្រូវ លុះត្រាតែគិតគូរដល់លក្ខខ័ណ្ឌធម្មជាតិគិតដល់អាកាសធាតុ ធនធានក្នុងដី ថាមពល រ៉ែ ធនធានមនុស្ស ដែលមានវត្ថុធាតុដើមបម្រើឧស្សាហកម្ម ក្នុងតម្លៃមួយទាប ទើបប្រកួតប្រជែងបាន។ កសិផលនាំចេញ លើកលែងតែកៅស៊ូត្រូវកែច្នៃជាទំនិញ ទើបនាំចេញមានតម្លៃ។ ត្រូវដាំកប្បាស អំពៅ សម្រាប់ជាវត្ថុធាតុដើមនៃរោងចក្រកែច្នៃ។ ការជ្រើសរើសបែបនោះ គឺជាបញ្ហាលំបាក។

នៅប៉ុន្មានឆ្នាំក្រោយនេះ មានសេចក្តីសម្រេចចិត្តវិនិយោគច្រើនណាស់ដែរ ទាំងផ្នែករដ្ឋ និងសហគ្រិន ឯកជន ដោយមិនបានគិតគូរដល់ទីផ្សារលក់ដូរ ការផ្គត់ផ្គង់ និងទីផ្សារទីតាំងទៀតផង។ នេះហើយបានជាមានការអភិវឌ្ឍឧស្សាហកម្មដ៏លឿនបំផុតនៅកម្ពុជា ដោយគ្មានចោទឡើងនូវបញ្ហាទេនោះ។ ជាបឋម គេត្រូវសិក្សាពី រចនាសម្ព័ន្ធឧស្សាហកម្មនេះសិន។

## ៨.២.រចនាសម្ព័ន្ធឧស្សាហកម្ម

រចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាមិនត្រូវបានស្គាល់ច្បាស់លាស់នៅឡើយទេ។ គេមិនទាន់មានព័ត៌មាន ច្បាស់លាស់ពីសមត្ថភាពផលិតកម្មនៅឡើយ។ តាមរយៈគណនេយ្យសេដ្ឋកិច្ច ដែលជាវិធានការស្ថិតិពន្ធដារនោះ ធ្វើឱ្យគេឃើញពីទំហំនៃការបែងចែករចនាសម្ព័ន្ធឧស្សាហកម្ម តាមទំហំ តាមខេត្ត និងតាមផ្នែក។

- ការបែងចែកតាមទំហំសហគ្រាសឧស្សាហកម្ម ដែលថាមានទំហំធំ តាមរយៈតួលេខពន្ធអាករលើប្រាក់ចំណេញឧស្សាហកម្ម គឺការបង់ពន្ធលើសពី ១,៥០០ រៀល ។ មានតែសហគ្រាស ១០% ទេ ដែលមានផលទុនលើសពី ១០០,០០០ រៀល ។ ៩០% នៃសហគ្រាសឯទៀតមានលក្ខណៈជាសិប្បកម្ម។ ការស្រាវជ្រាវឯកសារឆ្នាំ ១៩៦៥ នៅភ្នំពេញ អនុញ្ញាតឱ្យបែងចែកតួលេខនៃផលរបរ ជាលានរៀលដូចតទៅ៖

| | | |
|---|---|---|
| ០ តិចជាង.១ | ............................................ | សហគ្រាស ៣៩ |
| ០.១ ទៅ ០.៥ | ............................................ | សហគ្រាស ៥៩ |

០.៥ ទៅ ១.០ ............................................ សហគ្រាស ៣៥
១.០ ទៅ ៥.០ ............................................ សហគ្រាស ២៦
៥.០ ទៅ ២៥.០ ............................................ ១៣ សហគ្រាស
២៥ លើសពី.០............................................ ៧ សហគ្រាស

សហគ្រាសជាង ៥០ នៅរាជធានីភ្នំពេញ មានលក្ខណៈជាសហគ្រាសឧស្សាហកម្ម។ ក្រុមនោះមានផលរបរលក់លើសពី ១ លានរៀល ។ ប៉ុន្តែសហគ្រាសទាំងនោះ មិនស្ថិតនៅភ្នំពេញទេ។

- ការបែងចែកតាមភូមិសាស្ត្រ៖ គឺនៅភ្នំពេញ និងខេត្តកណ្ដាលដែលមានសហគ្រាសជាច្រើន។ ប៉ុន្តែសហគ្រាសទាំងនោះមានចំនួនតែ ៤០% នៃសហគ្រាសរបស់ប្រទេស។ ក្រុងព្រះសីហនុ កំពង់ចាម កំពង់ធំ ព្រៃវែង និងបាត់ដំបង ក៏ជាមជ្ឈមណ្ឌលឧស្សាហកម្មដែរ។

បើគិតដល់សារៈសំខាន់នៃសហគ្រាស មានការផ្លាស់ប្ដូរតារាងដ៏សំខាន់។ គេឃើញថា ភ្នំពេញជាមជ្ឈមណ្ឌលឧស្សាហកម្មរបស់ប្រទេសព្រោះ ៧៥% នៃផលរបរដែលបានប្រកាសពីសហគ្រាសនៅកម្ពុជាបានសម្រេចឡើងដោយសហគ្រាសនៅភ្នំពេញ។ ពិនិត្យលើសារៈសំខាន់នេះ ខេត្តបាត់ដំបង ឈរនៅជួរទី ២ ជាមជ្ឈមណ្ឌលឧស្សាហកម្ម ទាំងចំនួនសហគ្រាស ដែលមានលក្ខណៈជាឧស្សាហកម្ម មានផលទុនដែលត្រូវបង់ពន្ធលើសពី ១០០,០០០ រៀល ជាផលរបរ។

សង្ខេបមក មានសហគ្រាសជាច្រើន នៅលើទឹកដីកម្ពុជា តែសហគ្រាសធំៗ គឺនៅភ្នំពេញ និងបន្ទាប់មកនៅខេត្តបាត់ដំបង។

- ការបែងចែករវាងផ្នែកឯកជន និងសាធារណៈនៃសហគ្រាស និងសកម្មភាពនានានៃឧស្សាហកម្ម ក៏ជាលក្ខណៈនៃរចនាសម្ព័ន្ធសំខាន់ណាស់ដែរ។ គណនេយ្យសេដ្ឋកិច្ចនៅឆ្នាំ ១៩៦៤ ផ្ដល់តួលេខជាភាគរយ៖

| | សហគ្រាសសាធារណៈ | ក្រុមហ៊ុនឯកជន និងសហគ្រាសសាធារណៈចម្រុះ | ឯកជនបុគ្គល |
|---|---|---|---|
| តម្លៃបន្ថែម | ២.២ | ៣២.៨ | ៦៥.០ =១០០០ |
| ការបែងចែកបៀវត្ស | ៥.១ | ៥៣.១ | ៤១.៨ = ១០០ |
| ពន្ធ និងតាក់ដែលបានបង់ | ២.៨ | ៨២.២ | ១៥.០ = ១០០ |
| ផលទុនថេរ | ០.៥ | ១៥.១ | ៨៤.៤ = ១០០ |

នៅឆ្នាំ ១៩៦៤ សារៈសំខាន់ នៃផ្នែកសាធារណៈបានចុះខ្សោយទាំងការរួមវិភាគទាន ដល់ផលទុនជាតិ ទាំងការរួមចំណែកដល់កេសររបស់រដ្ឋ។ ចាប់ពីពេលនោះមក ពេចក្រថ្មីៗទៀតក៏ត្រូវបានបង្កើត

ឡើង សារៈសំខាន់នៃផ្នែកសេដ្ឋកិច្ច មានការថយចុះនៅកម្ពុជា ក៏មានឧស្សាហកម្មដែលមានប្រភេទទុនឯកជន ផ្ទុយពីមតិដែលបានឃោសនាផ្សព្វផ្សាយថា មានតែការពង្រីកផ្នែករដ្ឋនោះ។

## ៨.៣.ឧស្សាហកម្មនានា

ពិនិត្យតាមសារៈសំខាន់ ឧស្សាហកម្មប្រទេស គិតជាភាគរយនៃតម្លៃបន្ថែម ប្រៀបនឹងផ្នែកទី ៤ នៃ វិស័យសេដ្ឋកិច្ចនាឆ្នាំ ១៩៦២ និង ១៩៦៣ ។

| | ១៩៦៣ | ១៩៦៤ | ១៩៦២ |
|---|---|---|---|
| សំណង់និងសាធារណៈការ | ៣៤ | ៣៤ | ២៩ |
| ឧស្សាហកម្មស្បៀង | ១៨ | ១៨ | ២៩ |
| ថាមពល និងទឹក | ១៧ | ១៦ | ៨ |
| បារី | ១០ | ១១ | ១៣ |
| ជួសជុលគ្រឿងយន្ត | ៦ | ៥ | ៦ |
| សម្ភារសំណង់ | ៥ | ៥ | ៤ |
| សម្ភារៈ និងឧបករណ៍នេសាទ | ៥ | ៤ | ៤ |
| រោងចក្រអារឈើ | ២ | ២ | ១ |
| ឧស្សាហកម្មផ្សេងៗ | ៣ | ៥ | ៧ |

ការចាត់ថ្នាក់បែបនេះ មានការកែប្រែច្រើនណាស់ក្នុងរយៈពេល ១៥ ឆ្នាំ ព្រោះសាខានានា នៃផ្នែកឧស្សាហកម្ម បានស្គាល់នូវអត្រាកំណើនខុសៗគ្នា។ ដោយឡែក វាទាមទារនូវការកែប្រែយ៉ាងឆាប់រហ័សនាឆ្នាំ បន្តទៀត ដោយហេតុនៃការកសាងរោងចក្រថ្មីៗថែមទៀត។

### ៨.៣.១.ឧស្សាហកម្មសំណង់ និងសាធារណៈការ

ជាឧស្សាហកម្មទីមួយនៃប្រទេស។ កាលពីឆ្នាំ ១៩៥២ ផ្នែកនេះឈរនៅជួរទី ៤ ប៉ុន្តែអត្រាកំណើនរហ័សពេក ធ្វើឱ្យគេឈរនៅជួរទី ១ វិញ។ នៅឆ្នាំ ១៩៦៤ ការរីកចម្រើន នៃវិស័យនេះ បែរជាទ្រឹងហើយថយចុះ គួរឱ្យកត់សម្គាល់។ នៅឆ្នាំក្រោយៗមក វិស័យនេះថយចុះខ្លាំង រហូតដល់ក្នុងសង្គ្រាម។ នៅពេលបើកចំហសេដ្ឋកិច្ចទីផ្សារនាឆ្នាំ ១៩៩០ វិស័យនេះមានអត្រាខ្ពស់ឡើងវិញ។

សាខានេះ ដោយសារធម្មជាតិ គឺជាការ បង្កើនទុន គឺមានន័យថា ផលិតកម្មរបស់វារួមវិភាគទានដល់ការវិនិយោគ។ ពួកអតិថិជននៃសាខានេះត្រូវបានគេបែងចែក ជាភាគរយ នៃផលិតផលសរុបដូចតទៅ ៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| គេហដ្ឋាន | ៥២ | ៤៥ | ៤៥ |
| សហគ្រាស | ៧ | ១២ | ៦ |
| រដ្ឋបាល | ៤១ | ៤៣ | ៤៩ |

ដើម្បីផលិត ១០០ រៀល នៃអាគារសំណង់ និងការងារសាធារណៈ គេត្រូវចំណាយនៅឆ្នាំ ១៩៦៣

- ៤ រៀល សម្រាប់ថាមពល
- ៤២ រៀល សម្រាប់វត្ថុធាតុដើម និងពាក់កណ្ដាលសម្រេច
- ៨ រៀល សម្រាប់ផលិតផលនៃឧស្សាហកម្មយន្តសាស្ត្រ
- ៨ រៀល សម្រាប់ផលិតផលឧស្សាហកម្មផ្សេងៗ

ផ្នែកសំណង់ មានសកម្មភាពសំខាន់ណាស់ នៅលើសាខានៃវត្ថុធាតុដើម និងពាក់កណ្ដាលសម្រេច ដូចជា ស៊ីម៉ង់ ដែក បេតុង ឥដ្ឋ ។ល។ ហើយបង្កើតបាននូវទីផ្សារ ៤០% ។ សំណង់មានតួនាទីជា ក្បាល ម៉ាស៊ីន នៃសេដ្ឋកិច្ចកម្ពុជា ។ ដូចនេះ បានជាសុភាសិតមួយថា បើសំណង់ដើរ អ្វីៗក៏ដើរដែរ ។ ឧស្សាហកម្មសំណង់ និងសាធារណៈ មានសារៈសំខាន់ផ្នែកឯកជន ពេលខ្លះមានសហគ្រាសសំណង់រដ្ឋដែរ។

### ៨.៣.២. ឧស្សាហកម្មស្បៀង

ស្ថិតក្នុងសេដ្ឋកិច្ចកសិកម្ម។ នៅចន្លោះឆ្នាំ ១៩៥២-១៩៦២ អត្រាកំណើន តិចជាង ២% ក្នុងមួយឆ្នាំ ប្រហែលអត្រាកំណើនផ្នែកកសិកម្មដែរ ដូចនេះមានន័យថា កសិផល បានត្រូវនាំចេញ ត្រង់តែម្ដងមិនសូវបានកែច្នៃមុនការនាំចេញទេ។ ឧស្សាហកម្មស្បៀងសម្រាប់ភ្ជាប់អ្វី ដែលដុះនៅចំការស្រែ និងតុហូបបាយ ប៉ុណ្ណោះ។

ឧស្សាហកម្មស្បៀងនៅកម្ពុជា គឺគិតជាភាគរយ នៃតម្លៃបន្ថែម៖

| | ១៩៦២ | ១៩៦៣ | ១៩៦៤ |
|---|---|---|---|
| ស្រូវ ឬអង្ករ | ៤៤ | ៥៤ | ៥៧ |
| អាល់កុល | ២២ | ១៧ | ១៣ |
| សាច់ជ្រូក | ១០ | ៧ | ៤ |
| ទឹកកក | ៣ | ៥ | ៦ |

| | | | |
|---|---|---|---|
| ភេសជ្ជៈ | ៣ | ៥ | ៦ |
| សាច់គោ | ២ | ២ | ២ |
| ផ្សេងៗ, | ១៦ | ១៥ | ១៨ |

នៅក្បែរម៉ាស៊ីនកិនស្រូវ សត្តឃាត ចម្រាញ់ប្រេង ឡដុតនំប៉័ង គេឃើញមានសហគ្រាសទំនើប សុរាគារកម្ពុជា បេសេអ៊ី បៀរអង្គរ កូកា ប៉េបស៊ី ជាដើម។ល។

### ៨.៣.៣. សាខា ថាមពល និងទឹក

ឈរនៅជួរបន្ទាប់ពីឧស្សាហកម្មស្បៀង។ ផ្នែកនោះ មានការលំបាកក្នុងការដាក់ឈ្មោះថា ឧស្សាហកម្ម លើចំណុចនៃការប្រើអុសដុតជាថាមពល បញ្ហាទឹក ដោះស្រាយបាននៅតាមទីក្រុង ឯជនបទប្រើទឹកអណ្តូង ទន្លេ មិនទាន់សម្បូរម៉ាស៊ីនបូមទឹក និងច្រោះទឹកស្អាត។ ១/៣ នៃថាមពល អគ្គិសនីប្រើដោយម៉ាស៊ីនភ្លើងតូចៗ។

ក្នុងសាខានេះ មានសហគ្រាសពីរធំៗ គឺ ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងរដ្ឋាករទឹក គឺសុទ្ធតែជាសហគ្រាសរដ្ឋ។

### ៨.៣.៤. ឧស្សាហកម្មថ្នាំជក់

មានសារៈសំខាន់ ព្រោះការផលិតបារី រួមវិភាគទានបានដល់ទៅ ១០នៃតម្លៃបន្ថែមក្នុងផ្នែក % ឧស្សាហកម្ម។ កម្មន្តសាលថ្នាំជក់ចំនួនបីកន្លែង ផលិតបារីចេញពីវត្ថុធាតុដើមថ្នាំជក់ក្នុងស្រុក ជា ក្រុមហ៊ុនចម្រុះ។ សព្វថ្ងៃ ក្រុមហ៊ុនឯកជន បានជួលកម្មន្តសាលនោះ ដោយចុះកិច្ចសន្យាអាជីវកម្ម តាមរយៈការដាក់ខ្សែផលិតកម្មថ្មី។

### ៨.៣.៥. វិស័យឧស្សាហកម្មផ្សេងៗទៀត

ជារបស់រដ្ឋ ដែលបានធ្វើអន្តរាគមន៍យ៉ាងសកម្ម ក្នុងការបង្កើនល្បឿនអភិវឌ្ឍន៍ឧស្សាហកម្ម។ សាខាសំខាន់ៗ មានដូចតទៅ៖

- ការជួសជុលរថយន្ត និងយន្តសាស្ត្រ ដែលជានាវ៉ាប់រងដោយរោងជាងតូចៗ។ គេរាប់ឃើញនៅក្នុងឆ្នាំ ១៩៦១ មានរោងជាង ២០០ កន្លែង ប្រើពលកម្មជា ៨០០ នាក់។
- សម្ភារសំណង់ មានភាពរុងរឿងស្របពេលនឹងឧស្សាហកម្មសំណង់៖ ឥដ្ឋ ក្បឿង ខ្សាច់ គ្រួស ការ៉ូ ក្តារបន្ទះ ថ្នាំពណ៌ និងចាប់ពីឆ្នាំ ១៩៦៤ ស៊ីម៉ង់ដែលផលិតដោយរោងចក្ររដ្ឋនៅចក្រីទីង ដែលមកដល់ឆ្នាំ ១៩៦៦ ការផ្គត់ផ្គង់សឹងតែពាក់កណ្តាលបរិមាណស៊ី ជាតម្រូវការក្នុងប្រទេស។ រោងចក្រអារឈើ ធ្វើឱ្យរស់ឡើងវិញនូវសហគ្រាសតូចៗ។

- សម្ភារ និងឧបករណ៍កសិកម្មៈ ជាសិប្បកម្មបោះរទេះ ជួសជុលនង្គ័ល កណ្តៀវ ចប រនាស់។ល។ មានសារៈសំខាន់ដល់ប្រទេសកសិកម្ម។ រោងចក្រដំឡើងត្រាក់ទ័រ កសាងនៅឆ្នាំ ១៩៦៤ នៅក្រុង ព្រះសីហនុ រហូតដល់ឆ្នាំ ១៩៦៧ ទើបដំណើរការផលិតកម្ម។
- រោងចក្រតម្បាញ ភាគច្រើននៅតែជាសិប្បកម្ម ប៉ុន្តែសហគ្រាសរដ្ឋ ធ្លេច និងតំបាញកប្បាសនៅ កំពង់ចាម ចាប់ផ្តើមផលិតនៅឆ្នាំ ១៩៦០។ រោងចក្រទី ២ របស់រដ្ឋនៅបាត់ដំបង បើកទ្វារតាំងពីឆ្នាំ ១៩៦៦ ដែរ។
- ឧស្សាហកម្មកៅស៊ូៈ កែច្នៃជ័រ នាំចេញដោយក្រុមហ៊ុនចំការកៅស៊ូខ្លួនឯងតែម្តង មានលក្ខណៈជា ឧស្សាហកម្ម។ ក្រៅពីផលិតជ័រក្រែបរោងចក្រមួយចំនួនផលិតកង់រថយន្ត ៩៦៦ រដ្ឋផលិតស្បែកជើង ទុយោ។
- ឧស្សាហកម្មក្រដាស ជារោងចក្ររដ្ឋ SONAPAP នៅឆ្លូង ចាប់ដំណើរការពីឆ្នាំ ១៩៦២។ នៅមាន រោងចក្រជាច្រើន ដែលផលិតក្រដាសពីម្សៅក្រដាស។
- អុកស៊ីសែន អាសេទីឡែន និងឧស្ម័នកាបូនិច ជាក្រុមហ៊ុនចម្រុះ។
- រោងចក្រផលិតសាប៊ូ ពីពិសោធន៍ផលិតឱសថ ដែកគោល និងផលិតវត្ថុពីប្លាស្ទិច។

ទិដ្ឋភាពខាងលើ បង្ហាញពីការរីកចម្រើនឧស្សាហូបនីយកម្មនៅកម្ពុជា។ ប៉ុន្តែក៏បានបង្ហាញចំណុចខ្វះខាតដែរ ពិសេសឧស្សាហកម្មគីមី ដែលមិនទាន់មានសោះនៅកម្ពុជា។ ការខ្វះរោងចក្រស្លដែកមិនគួរឱ្យភ្ញាក់ផ្អើលទេ ចំពោះប្រទេសកម្ពុជា។ ឧស្សាហកម្មវាយនភ័ណ្ឌ ឧស្សាហកម្មប្រពលវប្បកម្ម labo-intensiveនិងការសន្សំទុនមានតិចតួចណាស់។

## ៨.៤.លក្ខខ័ណ្ឌនានានៃអាជីវកម្មរបស់សហគ្រាស

ឧស្សាហកម្មនៅកម្ពុជា មិនទាន់មានការលើកទឹកចិត្តនៅឡើយ អំពីការជានាពីវត្ថុជាតុដើម។ ក្រៅពីនោះកត្តាផ្សេងទៀតសម្រាប់អាជីវកម្មរបស់សហគ្រាស មានភាពងាយស្រួល។

ពលកម្មសម្បូរ មានគុណភាព។ កម្រិតបៀវត្សនៅទាប ដែលមិនល្អត្រង់ចំណុចសង្គម ប៉ុន្តែជាចំណុចល្អចំពោះការអភិវឌ្ឍសេដ្ឋកិច្ច។

ថាមពលមុនឆ្នាំ ១៩៧០ មិនខ្វះទេ។ បច្ចុប្បន្នខ្វះខ្លាំងណាស់ ពិសេសថាមពលអគ្គិសនី គឺបញ្ហាប្រភពផង និងថ្លៃផង។ នៅគ្រប់សហគ្រាស និងគេហជន ménage ការប្រើម៉ាស៊ីនភ្លើងដោយខ្លួនផ្ទាល់ជាការចាំបាច់ បំផុត។ ក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្តល់បានតែ ២០% នៃថាមពល ជាប្រើប្រាស់របស់ឧស្សាហកម្មនៅភ្នំពេញ។ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី គ្មានជាប្រចាំទេ។ ទំនប់គិរីរម្យដែលផ្តល់ថាមពល កាលពីឆ្នាំ ១៩៦៨ ត្រូវខូចដោយសារសង្គ្រាម។ ទំនប់អគ្គិសនីព្រែកត្នោត និងកំចាយត្រូវបោះបង់ចោលគម្រោងសាងសង់ពាក់កណ្តាលការ ដោយ សារសង្គ្រាម។

ផ្នែកពន្ធអាករមានភាពស្មុគស្មាញ តែពន្ធធូជាងបើប្រៀបនឹងប្រទេសអន់ថយដូចគ្នា។ ពន្ធលើប្រាក់ចំណេញប៉ះពាល់ដល់ក្រុមហ៊ុន ២៥% ។ ពន្ធលើផលរបរ លើការលក់ដូរទំនិញ លើកទីមួយ ៥% ។

វាមានការលំបាក ក្នុងការខ្ចីទុនរយៈពេលវែង ដើម្បីវិនិយោគ អវត្តមានទីផ្សារហិរញ្ញវត្ថុ ឬធនាគារឱ្យខ្ចីរយៈពេលយូរ ។ ការខ្ចីប្រាក់រកស៊ីពាណិជ្ជកម្មរយៈពេលខ្លី និងមធ្យមក៏លំបាកដែរ។ អត្រាការប្រាក់មិនច្បាស់ លាស់ ប៉ុន្តែមិនខ្ពស់ទេ។

កម្ពុជានាទស្សវត្ស ១៩៦០ អនុវត្តន៍យោបាយការពារទំនិញ ដែលធ្វើឱ្យផលិតផលក្នុងស្រុកប្រជែងបាន នឹងទំនិញនាំចូល ធ្វើឱ្យឧស្សាហកម្មក្នុងស្រុករីកចម្រើន។ បច្ចុប្បន្នមិនទាន់មាននយោបាយនេះនៅឡើយទេ។

ទាំងសហគ្រាសឯកជន និងរដ្ឋ ជាទូទៅតែងជួបឧបសគ្គ ព្រោះការសិក្សាស៊ីជម្រៅតាំងពីការដាក់ទីតាំង និងការសិក្សាពីផលចំណេញដែលធ្វើឱ្យមានការជ្រើសរើសខុសក្នុងការវិនិយោគ។ ដើម្បីប្រើប្រាស់ទុន ដែលជាប្រភព ធនធានលំបាកក្នុងការរកបាននោះ គេត្រូវសិក្សាស៊ីជម្រៅ ក្នុងការប្រើប្រាស់ទុនឱ្យមានប្រសិទ្ធភាព។

## ៨.៥.រចនាសម្ព័ន្ធ និងការដឹកជញ្ជូន

ស្តីអំពីការដឹកជញ្ជូន គេត្រូវចែកឱ្យបានដាច់ពីគ្នា រវាងតម្លៃបន្ថែមនៃស្តុកជាទុន ដែលបម្រើឱ្យមានផលប្រយោជន៍។ ក្នុងទស្សនៈវិស័យថាមពល ន័យនៃពាក្យថា ទុន មានសារៈសំខាន់ជាងពាក្យថា Flux។ តម្លៃបន្ថែម ក្នុងផ្នែកដឹកជញ្ជូន កើតឡើងយឺតជាងផ្នែកឧស្សាហកម្ម។ ការត្បាញក្រណាត់មួយម៉ែត្រ កម្មករត្បាញក្នុងរយៈពេលខ្លី។ ឯការដឹកជញ្ជូន ត្រូវរងចាំដល់តំណាក់ការពេលវែង ទើបតម្លៃបន្ថែមបំពេញបាន។

**ក.** កម្ពុជាមានរចនាសម្ព័ន្ធដឹកជញ្ជូនល្អ។ ជាធម្មតា កម្ពុជាមានទន្លេ ស្ទឹង បឹង។ មេគង្គ អាចទទួលនាវា សមុទ្របាន ទន្លេសាបក៏អាចឱ្យនាវាទៅមកបាននៅរដូវវស្សា។ ពិសេសទិដ្ឋភាពកម្ពុជា មានភាពងាយស្រួលដល់ការកសាងផ្លូវថ្នល់ និងផ្លូវដែក។

ផ្លូវថ្នល់ មានសារៈសំខាន់ជាងផ្លូវដែក។ ពួកអាណានិគម បានកសាងផ្លូវនោះយ៉ាងមានប្រសិទ្ធភាព ទុកឱ្យរដ្ឋាភិបាលកម្ពុជាបន្តប្រើប្រាស់។ ផ្លូវគោកប្រវែង ២,០០០ គ.ម. ចាក់ជ័រកៅស៊ូ។ ក្រុមហ៊ុនរថយន្តដឹកជញ្ជូនមានសារៈសំខាន់ណាស់។

ផ្លូវដែក កសាងពីឆ្នាំ ១៩៣០ ដល់ ១៩៣២ ពីភ្នំពេញ ទៅព្រំដែនថៃ ប្រវែង ៣៨២ គ.ម.។ ការភ្ជាប់ផ្លូវ

ដែក រវាងភ្នំពេញ និងតំបន់កសិកម្មដ៏សំខាន់នៃខេត្តបាត់ដំបង មានសារៈសំខាន់ណាស់។ ផ្លូវដែក ១ ខ្សែទៀត ចាប់ដំណើរការនៅឆ្នាំ ១៩៦១ ពីភ្នំពេញ ទៅក្រុងព្រះសីហនុប្រវែង ២៧០ គ.ម.។ ការកសាងផ្លូវនេះ ឈរលើមូលដ្ឋាននៃសុធន្ទៈ និងការឱ្យខ្ចីពីប្រទេសបារាំង។

រចនាសម្ព័ន្ធកំពង់ផែ និងព្រលានយន្តហោះ ក៏មានការរីកចម្រើនក្នុងរយៈពេល ១០ ឆ្នាំ នៃទសវត្ស ១៩៦០ ដែរ។

ព្រលានយន្តហោះពោធិ៍ចិនតុង ជាជំនួយបារាំង មានផ្លូវហោះហើរ ៣,២០០ ម. ។ នៅសៀមរាប ក៏មានព្រលានយន្តហោះអន្តរជាតិ។ តាមខេត្តនានា មានព្រលានយន្តហោះតូចៗ អាចឱ្យយន្តហោះធុនស្រាលចុះចតបាន។

កំពង់ផែសមុទ្រក្រុងព្រះសីហនុ អាចទទួលនាវាសមុទ្រធំៗបាន។ កំពង់ផែភ្នំពេញមានការលំបាក ដោយសារទឹករាក់នៅរដូវក្តៅ។

វិស័យទូរគមនាគមន៍ ក៏មានការរីកចម្រើនដែរ។ បុស្តិ៍ទូរស័ព្ទកើនចំនួនរហូតដល់ទៅ ៥,០០០ គ្រឿង នាឆ្នាំ ១៩៦៧ ។ សព្វថ្ងៃ វិស័យនេះមានតិចណូឡូស៊ីថ្មី ដែលភ្ជាប់ដោយកាណាល់ផ្កាយរណប ទៅពាសពេញពិភពលោក។

**ខ.** រចនាសម្ព័ន្ធនេះ ផលិតនូវផលប្រយោជន៍ ៖ តម្លៃបន្ថែមនៃផ្នែកដឹកជញ្ជូន រួមចំណែកជាង ២% ដល់ផលទុនជាតិ។ ការវិវឌ្ឍថ្មី គឺការដឹកជញ្ជូន ផ្លូវអាកាស ផ្លូវដែក និងផ្លូវសមុទ្រ។

## ៨.៦.សេវាកម្មផ្សេងៗទៀត

សេវាកម្មផ្សេងៗរួមមាន ការសិក្សាស្រាវជ្រាវសណ្ឋាគារ ភោជនីយដ្ឋាន រោងភាពយន្ត សិក្សាធិការ ការជួសជុលអាគារ សេវាកម្មមេធាវី និងពាណិជ្ជកម្ម ធនាគារ និងរដ្ឋបាល មានតម្រូវការជាចាំបាច់នូវទុនជារូបិយ។

**ក.** ប្រជាជនសកម្មចំនួន ១៣% បម្រើក្នុងវិស័យ សេវាកម្ម ៤០ ហើយរួមវិភាគទានប្រហែល% នៃផលទុនជាតិ។

**ខ.** ផ្នែករដ្ឋបាលមានតែខ្មែរទេ ដែលជាអ្នកធ្វើកាងារនេះ។ ពួកចិន និងកូនកាត់ចិនគ្រប់គ្រងពាណិជ្ជ- កម្ម។

**គ.** រដ្ឋជាអ្នកសកម្មក្នុងកិច្ចការរដ្ឋបាល ហើយរួមចំណែក ៣៥% នៃតម្លៃបន្ថែមដោយសេវាកម្មផ្សេងៗ គឺស្មើនឹង ១៣% នៃផលទុនដុល។ រដ្ឋអន្តរាគមន៍លើវិស័យបី៖

- ឧស្សាហកម្មគ្មានផ្សែង សណ្ឋាគារ Sokha
- ធនាគារ និងធានារ៉ាប់រង ឱ្យបានធ្វើជាតូបនីយកម្ម នាឆ្នាំ ១៩៦៣
- ពាណិជ្ជកម្មក្រៅប្រទេស៖ បង្កើតឡើងនៅឆ្នាំ ១៩៦៣ ក្រុមហ៊ុនសេដ្ឋកិច្ចចម្រុះ ក្លាយជាក្រុមហ៊ុនរដ្ឋ។ ក្រុមហ៊ុននាំចេញ-ចូល SONEXIM SONAPRIM OROC,Magain d'Etat ធ្វើ ពាណិជ្ជកម្មធុំ។ ការលក់រាយស្ថិតនៅលើឯកជន។

សកម្មភាពរដ្ឋ លើសេវាកម្ម ស្ថិតក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ចទូទៅ។

# មេរៀនទី ៩
# ការបម្លែងកសិកម្ម និងអភិវឌ្ឍន៍ជនបទ
Agricultural Transformation and Rural Development

## ៩.១.ភាពចាំបាច់នៃការពង្រីកកសិកម្ម និង អភិវឌ្ឍន៍ជនបទ (The Imperative of agricultural progress and Rural Development)

យើងសង្កេតឃើញថា បើប្រជាពលរដ្ឋធ្វើការផ្លាស់មីលំនៅពីជនបទនៅទីក្រុង គឺជាដំណើរប្រវត្តិសាស្ត្រ ដែលធ្លាប់មានទីតាំងពីមុនមក ទោះយើងអាចពន្យល់បានថា មកពីភាពអាប់អួរនៃសេដ្ឋ កិច្ច នៅតំបន់ជនបទ។ អ្នកសេដ្ឋកិច្ចបានធ្វើការប៉ាន់ស្មានថា ប្រជាពលរដ្ឋជាកោដិនាក់ និងរប នៅតំបន់ជនបទ B1. 2 000 ដូច្នេះចំនួនកើតលឿងនៃប្រជាពលរដ្ឋកាន់តែច្រើន នៅតំបន់ជន ច, ពិសេសគឺប្រជាពលរដ្ឋក្រីក្រ ដែលប្រកបរបរសំខាន់របស់ពួកគេគឺ ធ្វើកសិកម្មគ្រាន់តែចិញ្ចឹម ជីវិត។ មូលដ្ឋានជនបទរបស់ពួកគេគឺការរស់នៅ ជីវិតត)ស៊ូប្រចាំថ្ងៃរបស់គេ គឺដើម្បីរស់។

បើការអភិវឌ្ឍន៍ អាចប្រព្រឹត្តទៅ ហើយអាចទ្រទ្រង់ជីវិតពួកគេដោយពួកគផ្ទាល់គឺ នឹងត្រូវចាប់ ផ្តើម នៅក្នុងតំបន់ជនបទជាពិសេសក្នុងតំបន់កសិកម្ម។ ខ្លឹមសារនៃបញ្ហាភាពក្រីក្រ គឺការរីកចម្រើន មិនស្មើភាព ប្រជាពលរដ្ឋកើនឡើងយ៉ាងលឿននិងការកើនឡើងភាពឥតការងារធ្វើនេះវាកើត មានស៊ើងដោយសារភាពអាប់អួរនៃជីវិត សេដ្ឋកិច្ចក្នុងជនបទ។

តួនាទីកសិកម្ម នៅក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ គឺមិនអាចជៀសផុតហើយត្រូវតែជួយនូបតម្កតាម។ ដូច្នេះយើងមានបទពិសោធន៍សេដ្ឋកិច្ចអភិវឌ្ឍន៍តំរូវអោយ រីកែប្រែចនាសម្ព័ន្ធសេដ្ឋកិច្ច ពីកសិកម្ម អន់ : ថយ អោយភៅdកសិកម្មជឿនលឿន →ឧស្សាហកម្ម និងសេវាកម្មសង្គម។ ប៉ុន្តែជាតិបូងកសិ កម្ម ត្រូវផ្តល់នូវសៀងអាហារដែលសិលទមអោយបាន កសិន នេះជាគំនិតយុទ្ធសាស្ត្រនៃការ អភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងតំបនណាតមុខ។

បច្ចុប្បន្ន ជួលជយើងបានឃើញហើយថា អ្នកសេដ្ឋកិច្ចអភិវឌ្ឍh (Development Econo mists) តានការនិងគួរបង្កើតបតយអំពីការដែលចង់បានយ៉ាងឆាប់រហ័សនូវ ស្សាហូបនីយ កម្ម។ ពួកគេតែងតែពិតយ៉ាងខ្លាំងដល់ពួនមីចាំបាកក្នុងការជួយāg (Supporting role) ទ្រក្នុងដំណើរនៃសេដ្ឋកិច្ចអភិវឌ្ឍន៍ តំ) ។ បើគ្មានកសិកម្មល្អគុណាស និង(បមកសិកម្ម និង សេដ្ឋកិច្ចជនប ជាបញ្ហានមអរបស់ សេដ្ឋកិច្ចអភិវឌ្ឍន៍អភិវឌ្ឍន៍សេដ្ឋកិច្ច, កុសុហកម្មអឹនអាចកប៉ ន តែបើកទទួលបានជោគជ័យ គឺឲបង្កើតភាពបានលិឌីយ៉ាងសាហាវក្នុងសេដ្ឋកិច្ច គឺជា បញ្ហាធ្វើអោយភាពក្រីក្រ កាតត្រីរីកដុះដលលឿង ភាពមិនស្មើភាពឥតការងារធ្វើការតែមើល )widespread poverty inequility and unemployment)

## ៩.២.ភាពមិនទៅមុខ និងភាពលូតលាស់របស់កសិកម្ម )Agrutural Stagnation and Growth ).

យើងឃើញប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើត តបទពិសោធន៍ក្នុងការt G.N.P. កើត ង ក្នុងសមស្សវ ន្លង់ កង-tamត និងធ្វើពាណិជ្ជកម្ម (%។10 អទិញ្ញវេល កើតឡើងប្រតព្ទ៨២)។ ផ្ទុយទៅវិញ ក្នុងទស្សវត្ត ន៍នដែលយើងឃើញថាមិកូលកសិ ៤ កើតឡើងយ៉ាងតិចបំផុត អោយផ្នែកវិទ្ធផលកសិកម្មក្នុង (កម្ម)K P. ថយចុះ។ ក្នុងយម ពិសោត ក៏ប្រវត្តិតរាស្ត្រ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍,ទោះបីជានៅក្នុងតំកសិកម្ម ខេត្រូវការ មនុស្សជាច្រើន ដើម្បីធ្វើការងារក៏ដោយ ក៏គេនៅតែទទួលយកទិន្នផល ។ ជាការពិត, នៅក្នុង ត តិយលោក ផលិតផលកសិកម្ម ពុំអាតទទួលបានផលច្រើតជាង 35% នៃផលិតផលជាតិសរុបទេ។

ពិនិត្យមើលតារាង

| ប្រទេសតតីយលោក នៃសាទ | កម្លាំងពលករក្នុងកសិកម្ម% | ទិន្នផលកសិកម្មនិង |
|---|---|---|
| អាស៊ីភាគខាងត្បូង | 72 | 30 |
| អាស៊ីភាគខាងកើត | 65 | 34 |
| ឡាទីន 33 | 18 | |
| អាហ្វ្រិក | 74 | 32 |

នៅចុងឆ្នាំ 1970, បណ្តាប្រទេសតតិយលោក មានការកើនលឿងខាងផ្នែក ផលិតផលសៀង និង ផលិតផលកសិកម្ម កប្បាស ), ក្រចៅ, ឡែន, កៅស៊ូ ក្នុងមួយកាពីជាតិចជាង (1% ក្នុងមួយឆ្នាំ(Food production Agricultural production: Food production, cotton, sisal, wool, rubber - - -)។ ការ ដែលមិនរីកចម្រើនទៅមុខនេះបណ្តាលមកពីមូលហេតុ ) ភាព រាំងស្ងួត :drought) ឌីអស់ជីវជាតិ )soil goes out) និងបញ្ហាសំខាន់ គឺមកពីការកើនលឿងចំ នួនប្រជាពលរដ្ឋ ច្រើនជាងការកើនលើងផលិតផល ជាតិសរុបដែលក្នុងនោះពលក គ្មានជំនាញឯកទេសទៀត –ផង នេះក៏ជាមូលហេតុធ្វើអោយតំរូវការស្បៀង កើនលឿង, ទៅអោយថ្លៃកើនលឿង, កំរិតជីវភាពប្រជាពលរដ្ឋកាន់តែយ៉ាប់យ៉ឺន និងបញ្ហាកាន់តែសំខាន់ ជាងនេះទៅទៀត គឺរដ្ឋាភិបាល ធ្វេសប្រហែស ក្នុងការអភិវឌ្ឍន៍ជនបទក្នុងការធ្វើអោយផលិតផលស្បៀង កើនឡើងសមស្របនឹងតំរូវ ការរបស់ប្រជាពលរដ្ឋ។ ដូច្នេះរដ្ឋាភិបាលត្រូវតែគិតតដល់ផ្នែកកសិកម្ម ដោយ បណ្តាក់ទុនអោយបាន ច្រើនជាងផ្នែកនានា ក្នុងចំណោមសេដ្ឋកិច្ច ហើយត្រូវស្វែងយល់ពីអ្វីដែលកសិកម្ម ត្រូវការសំខាន់ គឺ ត្រូវកែប្រែពីកសិកម្ម គ្រាន់តែចិញ្ចឹមជីវិតអោយទៅជាកសិកម្មពណិជ្ជកម្ម )The transition from subsistence to commercial agriculture)។

## ៩.៣.រចនាសម្ព័ន្ធនៃបណ្តាប្រទេសគពីយលោកដែលពឹងពាក់លើកសិកម្ម

( The structure of Third world Agrarian systems )

### ៩.៣.១.ទម្រង់ពីរបែបនៃកសិកម្មពិភពលោក ( Two kinds of world Agriculture )

នៅពេលដែលយើងក្រលេកមើលវិស័យកសិកម្មនៅក្នុងប្រទេសក្រីក្រមួយគួរ, យើងអ័ក ក ពោត ការងារជាក្រើកស្ថិតនៅចំកោនមុង។ ដើម្បីមើលយឃើញច្បាស់ក្នុងវិស័យនេះ យើងសូម ប្រៀបបៀប អាច ផលិតភាពកសិកម្ម ក្នុងប្រទេសអភិវឌ្ឍន៍ និងប្រទេសតមអភិវឌ្ឍន៍ )កសិកម្ម ពិភពលោកមានពីយ ...1 – ចំពោះប្រទេសអភិឌ្ឍន៏ មានសត្តភាព ក្នុងការធ្វើកសិក ) ប្រសិទ្ធិភាពកសិកបខ្ពស់ -មួយអស់លទ្ធភាព ហើយទទួលបានដល់ល្អកសិកម្មក់ៗទទួលបានទិន្នផល ក្នុង .( ប្រសចេះប្រើប្រាស់ជំពួកកសិករតិច ( Small Number of Farmers ) ចិញ្ចឹមប្រជាពលរដ្ឋបានទាំងមូល។

### ៩.៣.២.ចំពោះប្រទេសប្រទេសមិនទាន់អភិវឌ្ឍន៍

ប្រសិទ្ធិភាពកសិកម្ម ផលិតភាពទៅបផ្នែកលើយថាដល់ជីវិតខុសររបស់ពួកគេស្ថិតក្នុងកំរិតអប្បបរមា។

យើងសូមបង្ហាញនៅក្នុងតារាង 10.3.ពីការខុសស្រឡះក្នុងផលិតភាពពលករ។ ក្នុងឆ្នាំ.1960ប្រជាកសិករនៅប្រទេសអភិវឌ្ឍន៍ (The agricultural population of the developed countless) ក្នុងជប 115លាននាក់ បានក្នុងលុយសរុបគិតជាដុល្លា( $78 កោដ្ឋ ប្រជាកសិករម្នាក់ៗទទួលមានប្រហែល $680 ។ ផ្ទុយទៅវិញប្រជាកសិករនៅក្នុងប្រទេសមិនអភិវឌ្ឍន៍ )ក្នុងឆ្នាំ1960) $52 ប៉ុណ្ណោះ។ ដូច្នេះយើងឃើញពីផលិតភាពកម្មករប្រទេសអភិវឌ្ឍន៍ ច្រើនជាង13ដង ឲ្យប្រជាកសិករនៅក្នុងប្រទេសមិនទាន់អភិវឌ្ឍន៍។

ពិនិត្យមើលតារាង

Agricultural population and production in DC, and LDC, 1960.1980 and 2000

| | 1960 | | 1980 | | 2000 | |
|---|---|---|---|---|---|---|
| | $LDC_S$ | $DC_S$ | $LDC_S$ | $DC_S$ | $LDC_S$ | $DC_S$ |
| Agricultural population ( millions ) | 115 | 850 | 75 | 1230 | 50 | 1480 |
| Agricultural production total ( $billions | 78 | 43 | 125 | 77 | 186 | 125 |
| Per Capita | 680 | 52 | 1660 | 63 | 3720 | 91 |

agricultural
production ($)

កសិកម្មទំនើបនៅក្នុងទីផ្សារចម្រុះ(Mixed Market)គឺជាដំណើរកែប្រែការធ្វើកសិកម្ម គ្រប់គ្រាន់តែចិញ្ចឹមជីវិត អោយទៅជាការផលិតផលកសិកម្មច្រើនមុខ និងមានឯកទេស ផលិតកម្មខ្ពស់។ ប៉ុន្តែការកែប្រែនេះវាមានការទាក់ទិនយ៉ាងច្រើនទៅនឹងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកសិកម្ម និងអនុវត្តន៍នូវបច្ចេកទេសកសិកម្មថ្មីៗរដ្ឋាភិបាលនៃប្រទេសនានា ដែលមានបំណងចង់កែទម្រង់ប្រពៃណីកសិកម្ម ដើម្បីអោយបានសម្រេច នូវការបង្កើនផលិតផល ត្រូវតែ ទទួលស្គាល់ គឺនសរបទៅនឹងការផ្លាស់ប្តូរសង្គមទាំងមូល, នយោបាយស្ថាប័ននានាក្នុងជនបទអោយ បានត្រឹមត្រូវ។ បើមិនគិតគួរដល់ការផ្លាស់ប្តូរនោះទេនោះយើងមិនអាចមើលឃើញច្បាស់ថាតើប្រាក់ចំណូលឬ) ផលិតផលមធ្យ (ដែលប្រជាកសិករម្នាក់ៗទទួលបានប៉ុន្មាននោះទេ ទោះបីជាផលិតផល កសិកម្មត្រូវកើនឡើងក៏ដោយ- គឺវាធ្វើជាម្ចាស់ដីធំៗ រឺក៏អ្នកមាន កាត់តែតឡើង ចំណែកឯអ្នក ជួលដី(tenant farmers) ឬអ្នកតូចតាចគ្មានដីធ្លីនេងគេ (landless laborers) កាន់តែក្រទៅៗ។

ដូច្នេះយើងស្វែងយល់ពីរបៀបដែលប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន បានឈានពីការធ្វើការកសិកម្ម គ្រាន់តែចិញ្ចឹមជីវិតអោយតែរស់ទៅជាផលិតផលច្រើនមុខច្រើនបែប ហើយឆ្ពោះទៅរក ការពង្រីកផលិតផល នៅលើសហគ្រាសពាណិជ្ជកម្ម ក្នុងទ្រង់ទ្រាយធំ ) large - scale commercial enterprises)។

### ជំហានទី១៖របរកសិកម្ម គ្រាន់តែចិញ្ចឹមជីវិត (Subsistence Farming)

ការធ្វើស្រែចំការ ដើម្បីបំពេញតំរូវអេប្បបរិមានោះ គឺជាការផលិតនូវផលិតផលកសិកម្ម សំរាប់តែការប្រើប្រាស់ខ្លួនគេផ្ទាល់តែម្តង ដូចជា ស្រូវអង្ករ ពោតសណ្តែក បន្លែប្រភពចំបងនៃតំរូវការរបស់គេ។ ទិន្នផលនឹងផលិតភាពដែលគេបានទទួលនៅមានកំរិតទាប ដោយពួកគេប្រើប្រាស់ឧបករណ៍កសិកម្មអន់ថយ។ ការបណ្តក់ទុនទៅលើវិស័យ កសិកម្មតិច ប៉ុន្តែដី ពលកដីកត្តាផលិតកម្មដ៏សំខាន់ (Land - labor are the principal factors of production ) ។ ក្នុងនោះបើយើងពិនិត្យ មើលច្បាប់មួយ គេនិយាយថាបើយើងមានពលករច្រើន អនុវត្តន៍នៅលើដីមួយហិកតានោះទិន្នផល រឺ ក៏ផលិតភាព ដែលយើងទទួលបានមកវិញគឺ ទាបបំផុត ច្បាប់នេះ ហៅថាច្បាប់ត្រលប់ថយចុះ(The law of diminishing returns) ។ ការប្រកបរបរកសិកម្មបែបនេះ ច្រើនពឹងផ្អែកលើទឹក ភ្លៀង, លើសណ្ឋានដី ដែលជាលក្ខណៈធម្មជាតិផ្តល់អោយ ដោយគេពុំគិតពីការថែបំប៉នដាក់ជី នៅលើដីស្រែ។ ប្រជាកសិករ មួយភាគធំត្រូវរវល់ការងារច្រើនតែក្នុងរដូវដាំដុះ និងច្រូតកាត់ (Seasonal peak periods such as planting and harvesting)។ ក្រៅពីនេះគេមានពេលទំនេរច្រើន ដែលជាហេតុអោយពួកគេបាត់បង់នូវមាសប្រាក់ ប្រជាកសិករច្រើនតែធ្វើការងារនៅ លើដីស្រែមួយចំនួនដែលគេគិតថាអាចចិញ្ចឹមគ្រួសារគេបានដោយមិនចបាច់ជួលកសិករផ្សេងទៀត

ឡើយ (landless laborers = កសិកគ្មានដីស្រែ)។បរិដ្ឋានហួតហែង ខ្សោះកក្រោះ។ បច្ចេកទេសទាបស្ថាប័នសង្គមមិនរស់រវើក ទីផ្សារ និងបណ្តាញ ទូរគមនាគមន៍ រវាងជននិង ទីក្រុង-មិនសុីនសុីចង្វាក់គ្នា ធ្វើអោយកសិករ ខូចទឹកចិត្តក្នុងការខិតខំបង្កើតផលិតផល។

## ជំហានទី2 ៖ ការកែប្រែអោយទៅជាយកសិកម្មចំរុះ និង ផលិតផលច្រើនមុខ

(The Transition to Mixed and Diversified Farming)

ជាទូទៅ ចំណង់ចំណូលចិត្តរបស់ប្រជាពលរដ្ឋ របស់ប្រទេសមួយក៏ដូចជាប្រជាពលរដ្ឋ ពិភពលោកទាំងមូលតែងតែគិតគូចង់កែប្រែប្រព័ន្ធកសិកម្មដែលពឹងផ្អែកទៅលើធម្មជាតិ អោយទៅជា ប្រព័ន្ធកសិកម្មដែលមានលក្ខណៈឯកទេសខ្ពស់ផ្អែកពាណិជ្ជកម្ម។ មានន័យថា យើងនឹងប្រកប កសិកម្មដែលមានលក្ខណៈ ដូរដោះ រឺ ទិញ លក់ទំនិញ និង សេវាកម្មតាមរៀបជំនួញ )The specialized commercial farming system)របរកសិកម្មចំរុះ គឺជាការធ្វើអោយមានផលិតផលកក្រើកមុន (Mixed and Diversified far farming) គឺជា ជំហានកែប្រែ ពីរបៀបធ្វើកសិកម្មគ្រប់គ្រានតែចិញ្ចឹមជីវិត អោយទៅជផលិតកម្មឯក ឯកទេសមកកម្ម(Specialized production)។ នេះគឺជាសេចក្តីប៉ងប្រាថ្នា របស់ប្រជាពលករ ជនបទ ភាគច្រើនលើសលុប នៅក្នុងប្រទេសតតិយលោក ដែលពួកគេចង់បាន ហើយក៏ធ្វើអោយការប្រើប្រាស់ពលករកាន់តែមានប្រសិទ្ធិភាព។

ឧទាហរណ៍ យើងត្រូវដាំដំណាំចាំបាច់ ហើយសំខានជាងគេ )Staple crop) នៅគ្រប់រដូវ មិនត្រូវទុកអោយដីដាំដំណាំទំនេរចោល)idle-land) Staple crops ដូចជា ស្រូវសាលី, ពោត, អង្ករ និង cash crops ដូចជាដំណាំឈើសុីផ្លែ, បន្លែ កាហ្វេ, តែ កប្បាស មន ដែលដលដំណាសំរាប់ធ្វើជាវត្ថុធាតុដើម ឧស្សាហកម្មទៀតផង។ ដូច្នេះការប្រើប្រាស់គ្រាប់ពូជ ល្អៗ) Good seeds), ជី ថ្នាំសម្លាប់សត្វល្អិតប្រព័ន្ធសាស្រ្តរួមផ្សំ ជាមួយ ឧបករណ៍បច្ចេកទេស តាកទីរ ម៉ាសុីនច្រូតកាត់ ភ្ជួរ រាស់ ព្រមជាមួយនឹង កសិករមានជំនាញឯកទេសទៀតនោះ ធ្វើអោយទិន្នផលកសិផលកើនឡើងដែលលទ្ធផលដ៏ប្រសើរក្នុងការផ្គត់ផ្គង់ស្បៀងអាហារបានគ្រប់គ្រាន់ដល់កសិករ)Adequate are supply of the staple food)ហើយថែមទៀតមានលទ្ធភាព យកផលិតផលរបស់ខ្លួន ទៅលក់លើទីផ្សារ ទៀតផង។ទាំងនេះជាជំហាន ក្នុងការបង្កើនកំរិតជីវភាពគ្រួសារ និងបណ្តាក់ទុនបន្ថែមទៅលើរបរកសិកម្មអោយការប្រសើរឡើង។

(to raise his family's consumption standards and/ or invest in farm improvements) ការទទួលបានជោគជ័យ និងបរាជ័យ គឺ វាមិនឲ្យល់តែអាស្រ័យទៅលើលទ្ធភាព នុងជំនាញកសិករប៉ុណ្ណោះទេ គឺវាអាស្រ័យផងដែរនៅ សង្គម លក្ខខណ្ឌពាណិជ្ជកម្ម និងស្ថានប័ននានា បាដែលត្រូវពាក់ព័ន្ធ។ សំខាន់ជាងគេគឺរដ្ឋាភិបាលត្រូវគិតគូរ និងយកចិត្តទុកដាក់ដល់ប្រជាកសិករក្នុង លើកទឹកចិត្តដល់ពួកគេដែលខិតខំបង្កើនទិន្នផលតាមរយៈអោយតម្លៃដោយយុត្តិធម៌នៅលើទីផ្សារ (a fair market price) រឺក៏ តំលៃលើកទឹកចិត្ត (price incentives)។

## ជំហានទី3: របរពាណិជ្ជកម្ម កសិកម្មទំនើប )Modern Commercial Farming)

ជាទូទៅ, ការកើនលឿងនៃក៏តជីវភាព, ការរីកចម្រើននៃជីវភាព និង កច្ចេកទេស )Bio - logical and technical progress),ការរីកលូតលាស់លើងនៃទីផ្សាជាតិ និងអន្តរជាតិ បាន ផ្តល់នូវសន្ទុះនៃការរីកចម្រើនយ៉ាងខ្លាំង។

ចំពោះកសិកម្មដែលមានលក្ខណៈពិសេស ពី ផ្តល់ស្បៀងអោយបានគ្រប់គ្រាន់ ដល់ គ្រួសារនិមួយៗ បន្ទាប់មកគឺត្រូវផលិតអោយបានច្រើន ដើម្បីបំពេញសំណូមពរសង្គម ក្នុងនោះ គោលបំណងចំបង គឺ ប្រាក់ចំណេញ )The basic goal is profit) ដូច្នេះ ការប្រើប្រាស់ ជីថ្នាំសំលាប់សត្វល្អិតពូជ ជាពិសេសធារាសាស្ត្រ និងធនធានធម្មជាតិក្លាយជាជាកម្មវត្ថុដ៏ចំបង ចំពោះរបរកសិកម្ម ដែលធ្វើអោយយើងអាចទទួលបាន នូវទិន្នផលអតិបរិមា ក្នុងមួយហិកតា។ បើយើងនិយាយពី ផលិតផល គឺ យើងនិយាយសរុបផលិតផលអស់ សម្រាប់ដាក់លក់នៅលើទីផ្សារ កាលណាគេនិយាយពីសេដ្ឋកិច្ច គេច្រើនតែគិតដល់ពីចំណាយថេរ និងកំណាយប្រែប្រួល) ,fixed and variable costs) ការសន្សំ ការបណ្តាក់ទុន អត្រាប្រាក់ចំណូល ថ្លៃទីផ្សារ និងថ្លៃសម្រាប់ជម្រុញអោយ បានល្អនូវបរិមាណ និងគុណភាពផលិតផល។ ដូច្នេះដើម្បីជំរុញទាំងគុណភាព និងបរិមាណផលិ ផលអោយមានកំរិតកើនឡើង លុះតាតែយើងបង្កបង្កើតទុន( capital formation) ពង្រីកបច្ចេកទេសជ្រាវវិទ្យាសាស្ត្រ មិនតែប៉ុណ្ណោះ អ្នកសេដ្ឋកិច្ច ត្រូវមានផែនការ និងព្យាករណ៍ទុកជាមុននូវតំរូវការក្នុងស្រុក និងក្រៅស្រុក ដើម្បីអោយប្រទេសរបស់ខ្លួនមានលទ្ធភាពនាំចេញចេញនូវផលិតផលនៅលក់នៅក្រៅប្រទេស។

យើងអាចសន្និដ្ឋានថា ការដែលធ្វើអោយប្រសើរឡើងនូវរបរកសិកម្មចំរុះ គឺវាមិនគ្រាន់តែបង្កើនប្រាក់ចំណូល អោយកសិករប៉ុណ្ណោះទេ ថែមទាំងបានស្រូបយកពលករអោយមានការងារធ្វើទៀត )ផង។

ដូច្នេះរដ្ឋាភិបាល ត្រូវតែជំរុញ លើកទឹកចិត្តដល់ប្រជាកសិករអោយប្រកប ការងារកសិកម្មអោយបានខ្លាំងខ្លា ជាពិសេសត្រូវតែជំរុញ និងព្យាករណ៍ទុកជាមុន នូវផលិតផលណាដែលជាតំរូវការចាំបាច់ត្រូវនាំចេញ មានគោលនយោបាយថ្លៃ និង មានគោលនយោបាយថ្លៃ និងតម្លៃលើកទឹកចិត្ត ដល់កសិករ។

យើងពិនិត្យមើលយុទ្ធសាស្ត្រមួយនៃការអភិវឌ្ឍន៍ កសិកម្មនិងជនបទ បើគោលដៅចំបងនៃការអភិវឌ្ឍន៍កសិកម្ម និជនបទនៅប្រទេសតតិយលោក គឺជាការធ្វើអោយប្រសើរឡើងនូវកំរិតជីវភាព របស់ប្រជាពលរដ្ឋជនបទ បានបង្កើនប្រាក់ចំណូល ទិន្នផល ផលិតភាព នោះគឺជាការដ៏ ខាន់ណាស់ ក្នុងការបង្ហាញប្រភពសំខាន់ៗ នៃការរីកចម្រើនកសិកម្មនឹងមូលដ្ឋានក្នុងការធ្វើអោយសម្រេចគោលដៅនោះ។

**⁕បច្ចេកទេស និងការរកឃើញអ្វីដែលថ្មី** (Technology and innovation)

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន បានអនុវត្ត បច្ចេកទេសកសិកម្មថ្មី និងការរកឃើញអ្វីដែលថ្មីដែលជាមូលដ្ឋានដំបូងក្នុងការជួយធ្វើអោយប្រសើរឡើងខ្ពស់ថែមទៀត នូវទិន្នផល និង ផលិតភាព។ នៅក្នុង

ប្រទេសមួយចំនួនទៀត គេបានពង្រៀកដីដាំដុះ គេត្រូវធ្វើស្រែចំការលើដី ដែលពុំទាន់បានធ្វើពីមុនហើយ មិនបានអនុវត្តបច្ចេកទេសកសិកម្ម (without the need for new technology)។

ប្រភពចំបងពីរ អ្នក ថ្មីដែលអាចបង្កើនទិញកសិកម្ម។ ដូចជាត្រាក់ទ័រ អាច ដើម្បីឲ្យកើនផល កសិកម្ម និងចំនួនពលករ ឧទាហរណ៍ ពលករម្នាក់អាចដំណើរការ ម៉ាស៊ីនកាត់ បានផលក្នុងមួយ នឹងតម្រូវការរាប់រយនាក់ តែធ្វើការតាមរបៀបបុរាណ។ ប៉ុន្តែចំពោះប្រទេសដែលមានដីតូច ទុនតិច, មកច្រើនលឃើញប្រកាសថ្មី នេះមិនជវតែធ្វើអោយខូចដ្ឋានស្រែចំការប៉ុណ្ណោះទេ ថែមទាំងបង្កើតភាពឥតការងារធ្វើរបស់ប្រជាពលរដ្ឋជនបទជាច្រើនទៀតផង។ការនាំចូលនូវម៉ាស៊ីនទំនើប បច្ចេកទេសខ្ពស់បែបនេះ គឺជាការប្រឆាំងនឹងការអភិឌ្ឍន៍(Antidevelopmental)។ ដូច្នេះប្រភពដ៏សំខាន់ក្នុងការអភិវឌ្ឍន៍កសិកម្ម។

អ្នកសេដ្ឋកិច្ច នៃប្រទេសនិមួយៗ តែងតែគិតថា បើគេចង់បង្កើន ផលិតផលកសិកម្ម តាមរយៈបច្ចេកទេសថ្មី បដិវត្តន៍ខៀវ (new Green Revolutions technologies) គេត្រូវតែកែសំរួលថ្លៃ ទីផ្សារអោយសមស្របថ្លៃផលិតផលរបស់កសិករ ថែមទាំងផ្តល់នូវការលើកទឹកចិត្តចំពោះកសិករតូចតាច មធ្យម ដោយបង្កើតនយោបាយថ្លៃ ដែលឆ្លុះបញ្ចាំងការពិតនូវលក្ខខ័ណ្ឌទីផ្សារក្នុង ប្រទេស។ តំរូវការ ការផ្គត់ផ្គង់ ការគាំទ្រគោលនយោបាយ (Supportive policies)ចំពោះបញ្ហា គោលនយោបាយថ្លៃដែលរដ្ឋាភិបាលបានដាក់ចុះត្រូវតែមានការគាំទ្រពីរដ្ឋាភិបាលខ្លួនឯង ហើយអនុវត្តន៍អោយបានមឹុងម៉ាត់ លើកទឹកចិត្តដល់ប្រជាកសិករ ធ្វើយ៉ាងណាអោយ ប្រជាកសិករមានទំនុកចិត្តជឿជាក់លើគោលនយោបាយ ដើម្បីអោយប្រជាពលរដ្ឋទាំងមូលចូលរួមជួយគាំទ្រផង (Activate Windows) ។

### ❋ភាពចាំបាច់នៃការពង្រីកកសិកម្ម និងការអភិវឌ្ឍន៍ជនបទ

- Pollution growth rapidly
- Unemployment
- Low income

ហេតុអ្វីបានជាត្រូវអភិវឌ្ឍន៍កសិកម្មនៅជនបទ?

- ឲ្យអត្ថន័យ(អភិវឌ្ឍន៍)
- ប្រជាពលករភាគច្រើនជាកសិករ
- ផ្តល់វត្ថុធាតុដើមដល់ឧស្សាហកម្ម។

# មេរៀនទី ១០
# ការអប់រំ និងការអភិវឌ្ឍន៍ ( Education and Development )

## ១០.១.ការអប់រំ និងធនធានមនុស្ស ( Education and human resource )

អ្នកសេដ្ឋកិច្ចភាគច្រើនបានយល់ឃើញថា ធនធានមនុស្សគឺជាការកំណត់យ៉ាងសំខាន់នូវលក្ខណៈអត្តចរិក សេដ្ឋកិច្ច និងសង្គមរបស់ប្រទេសមួយ ដើម្បីអោយឈានទៅរកការអភិវឌ្ឍន៍រីកចម្រើន ។ លោកសាស្ត្រាចារ្យ Frederick Harbison ដែលបង្រៀននៅសាកលវិទ្យាល័យ Princeton បានអះអាងថា ធនធានមនុស្សគឺជាមូលដ្ឋានកំណត់យ៉ាងខ្ពស់បំផុតនូវទ្រព្យសម្បត្តិរបស់ ជាតិមួយ,

មនុស្សរស់នៅត្រូវតែសកម្មក្នុងការអភិវឌ្ឍន៍ជាតិរបស់ខ្លួនដូចជា បង្វែរទុនយកផលប្រយោជន៍ជាតិ (exploit natural Resources កសាងសង្គម និងសេដ្ឋកិច្ច និងអង្គការនយោបាយ)Build social economic, and political organizations)។ ជាការច្បាស់ណាស់ថាប្រទេសមួយដែលមិន អាចបង្កើនជំនាញ និងចំណេះដឹងដល់ប្រជាពលរដ្ឋរបស់ខ្លួន និងប្រើប្រាស់ពួកគេអោយមានប្រសិទ្ធ ភាព ក្នុងសេដ្ឋកិច្ចជាតិ នោះថានឹងមិនអាចអភិវឌ្ឍន៍អ្វីផ្សេងទៀតបានឡើយ ។

Human resources constitute the ultimate basis for wealth of nation Human being are the active agents who accumulate capital, exploit natural resources. Build social, economic and political organizations and carry forward national development. Clearly, a country which is unable to develop skills and Knowledge of its people and to utilize them effectively in the national economy will be unable to develop anything else.

គ្រឹះស្ថានអប់រំ សិក្សាបណ្ដុះបណ្ដាលជំនាញ និងចំណេះដឹងជាប្រព័ន្ធអប់រំយ៉ាងត្រឹមត្រូវបំផុត ។ប្រជាជាតិនៅតតិយលោកភាគច្រើនបានជឿជាក់ថា ការពង្រីកបរិយៈអប់រំ គឺជាកូនសោរ ដ៏សំខាន់ ក្នុងការអភិវឌ្ឍន៍ជាតិមួយ ការអប់រំកាន់តែពង្រីក, ការអភិវឌ្ឍន៍កាន់តែឆាប់រហ័ស (the more education, the more rapid the development) សេដ្ឋកិច្ចនៃការអប់រំ (The economics of education) គឺជាធាតុមួយដែលគ្មានរូបរាងយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចអភិវឌ្ឍន៍ ។

នៅពេលដែលយើងទទួលស្គាល់នូវគោលការណ៍ជុំវិញ រីតំរូវការនៃការអប់រំចំណេះដឹងក្នុង បណ្ដាប្រទេសតតិយលោកគឺជាសេចក្ដីប៉ងប្រាថ្នាក្នុងការធ្វើអោយសេដ្ឋកិច្ច កាន់តែមានលក្ខណៈ ប្រសើរឡើងដោយប្រើមធ្យោបាយបង់ថ្លៃលើការងារអោយបានច្រើនជាងមុន ចំពោះបុគ្គលិក ពលករ ដែកមានជំនាញ និងឯកទេសមុខ ។

លើបញ្ហានេះ យើងសង្កត់ធ្ងន់លើការចំណាយសាធារណៈ, សមាមាឌនៃអ្នកដែលមកចុះ ឈ្មោះធៀបនឹងអ្នកដែលមិនមកចុះឈ្មោះរៀន, កំរិតអ្នកដែលចេះអាន ចេះសរសេរ (Literacy levels), អត្រាអ្នកដែលដកខ្លួនចេញពីការសិក្សា (dropout rate)។

ពេលនេះ យើងនឹងរំលឹកឡើងវិញនូវបញ្ញាតិជាមូលដ្ឋានខ្លះ ក្នុងសេដ្ឋកិច្ចនៃការអប់រំសេដ្ឋកិច្ចនៃ) ការអប់រំ គឺជាការអប់រំបណ្តុះបណ្តាលជំនាញ ឯកទេសដល់ប្រជាពលរដ្ឋក្នុងទិសដៅ អភិវឌ្ឍន៍សេដ្ឋកិច្ចរួម ជាមួយនឹងការកំណត់ តំរូវការនិងការផ្គត់ផ្គង់សាលារៀន និងភាពខុសគ្នារវាង ផលប្រយោជន៍ឯកជន និង សង្គម )The distinction between private and social benefits) សំខាន់ជាងនេះទៀតគឺ ការ ចំណាយលើការបណ្តាក់ទុនក្នុងវិស័យអប់រំ ។

## ១០.២.អប់រំ ក្នុងតំបន់អភិវឌ្ឍន៍ ( A Profile of Education in developing regions )

### ១០.២.១.ចំណាយសាធារណៈលើវិស័យអប់រំ ( Public Education Expenditure )

នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន វិស័យអប់រំជាវិស័យមួយដ៏សំខាន់ ហើយមានការបើ ប្រាស់ ទុនយ៉ាងច្រើន ។ មានហេតុផលជាច្រើនក្នុងការប្រើប្រាស់ទុនក្នុងវិស័យអប់រំនេះ ដូចជាចំណាយ លើការ សាងសង់សាលារៀន ឧបគរ សិក្សា ចំណាយលើការបង្ហាត់បង្រៀនអ្នកដែពុំទាន់ចេះ អាន ចេះសរសេរ ចំណាយលើការបណ្តុះបណ្តាលសិស្ស និស្សិត ថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ ឧត្តមសិក្សា និងជាពិសេស បណ្តុះបណ្តាលជំនាញ ឯកទេសអោយសមស្របទៅតាមការរីកចម្រើនបច្ចេក ទេស និង ស្ថានភាពរបស់ ប្រទេសខ្លួន ។ ឧទាហរណ៍ កសិករដែលចេះអាន ចេះសរសេរ (Literate farmers) ការអប់រំដឹងត្រូវបាន គេគិតថាមានផលប្រយោជន៍ និងមានភាពទទួលខុសត្រូវ លើ បច្ចេកទេសកសិកម្មថ្មី ច្រើនជាងកសិករ ដែលមិនចេះអានចេះសរសេរ (illiterate farmers)។

យើងត្រូវបណ្តុះបណ្តាល សិប្ប អ្នកបច្ចេកទេស បន្ថែមទាំងបរិមាណ និងគុណភាព និងត្រូវ បង្កើត ការិយាល័យទទួលបន្ទុកផ្នែកបច្ចេកទេស និងរដ្ឋបាល, ផ្នែកវិជ្ជាជីវៈ និងគ្រប់គ្រងនៅ តំបន់ដែលទំនើប។ ។

នៅក្នុងប្រទេសដែលពុំទាន់មានការរីកចម្រើន) LDC) ការចំណាយលើវិស័យអប់រំ កើនឡើង យ៉ាងខ្លាំង ។ នៅអាស៊ី ការចំណាយលើវិស័យអប់រំ ក្នុងឆ្នាំ ១៩៦០ នៅឆ្នាំ ១៩៧០ កើនឡើងបីដង ។ នៅអាហ្វ្រិក និង អាមេរិកឡាទីន កើនឡើងពីរដង ។

### ១០.២.២. ការចុះឈ្មោះចូលរៀន( The Enrollment )

រវាងឆ្នាំ ១៩៦០ និងឆ្នាំ ១៩៨៥ ចំនួនមនុស្សសរុបដែលបានចុះឈ្មោះចូលរៀន នៅកំរិតទី១ ទី ៦ និងទី ៣ ។

នៅក្នុងប្រទេស Africa, Asia, Middle East និង Latin America កើនឡើងពី ១៦៣លាន ទៅ ៤៥៥លាន។ ប៉ុន្តែគេសង្កេតឃើញថា នៅកំរិតទី ៣ មានការកើនឡើងត្រឹមតែ ១២៧១៨ %, ៥ក្នុងមួយឆ្នាំ % ធៀបទៅនឹងការកើនឡើងសរុបទាំងកំរិតទី ១, ទី២, secondary and tertiary levels ទន្ទឹមនឹងការ ទី ៣ primary , ចុះឈ្មោះចូលរៀនមាការកើនឡើងពិតមែន តែក៏មានអ្នកចាកចេញពី សាលាមុនបញ្ចប់ការ

សិក្សាដែរ )Many students drop out before completion)មានប្រទេសមួយចំនួនដូចជា Africa Asia Latin American_ចំនួនដែលចាកចោល សាលាមានសពីពាក់កណ្ដាលនៃចំនួនដែលចុះឈ្មោះចូលរៀនផង ។ បញ្ហានេះគបានកត់សំគាល់ថា មកពីបញ្ហាប្រាក់ចំណូល ។

### ១០.២.៣. ការចេះអានសរសេរ (Literacy)

យុវវ័យចាប់ពីអាយុ ១៥ឆ្នាំ ឡើងទៅ ភាគរយនៃអ្នកដែលមិនចេះអក្សរនៅក្នុងឆ្នាំ ១៩៦០ បានធ្លាក់ចុះពី ៦០%៥១ ទៅ %នៅប្រទេសដែលកំពុងអភិវឌ្ឍន៍ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ យើងឃើញថា ចំនួនយុវវ័យដែលពុំទាន់ចេះអាន ចេះសរសេរកើតលើងជាង ៧០លាននាក់ ពីព្រោះបើ ប្រៀបធៀបចំនួនប្រជាពលរដ្ឋកើនឡើងក្នុងឆ្នាំ ១៩៨៥ រហូត ៩០០ លាននាក់ ។ ដោយសារតែចំនួន ប្រជាពលរដ្ឋកើនឡើងលឿនយ៉ាងនេះ នាំអោយប្រទេសនោះ បណ្ដុះបណ្ដាលអ្នកបច្ចេកទេស បាន ចំនួនមួយតិចបំផុត ធ្វើអោយផលិតភាពពលកម្មមានកំរិតទាបហើយជីវភាពប្រជាពលរដ្ឋធ្លាក់ចុះ ដែល ធ្វើអោយយុវវ័យមួយចំនួនលទ្ធភាពទៅក្រេបយកចំណេះដឹង ហើយមួយចំនួនទៀតបានចាកចោល សាលាមុនពេលបញ្ចប់ការសិក្សា ។

ការអប់រំ និងភាពជានការងារធ្វើ )Education and Employment) នៅក្នុងបណ្ដាប្រទេសមួយចំនួនបានធ្វើការពិភាក្សាគលើបញ្ហាការអប់រំ និងសេដ្ឋកិច្ចអភិវឌ្ឍន៍ និយាយជារួម、 និងភាពមានការងារធ្វើក្នុងកំរិតមួយនៃការអប់រំ និយាយដោយលែក នាំអោយគេបាន រកឃើញនូវមូលដ្ឋានពីរជាចំបង ។
១ទំនាក់ទំនងទៅវិញទៅមករវាងតំរូវការ និងនយោបាយទទួលខុសត្រូវក្នុងការផ្គត់ផ្គង ., តើ យើងត្រូវកំណត់ទីកន្លែងដើម្បីបង្កើតសាលារៀនប៉ុន្មាន, ហើយអ្នកណាចូលរៀននៅទីនោះ និងថា ពួក គេនឹងទទួលបាននូវចំណេះដឹងអី ។

២ ការចែកដាច់ពីគ្នា រវាង -«សង្គម» «ឯកជន» «ចំណូល» «ចំណាយ ក្នុងកំរិតខុសគ្នាន ចំណេះដឹង ហើយនឹងយុទ្ធសាស្ត្រនៃការបណ្ដាក់ទុនលើវិស័យអប់រំខុសៗគ្នា តាមវិធីណា ។
(ទំនាក់ទំនងភាពមានការងារធ្វើ និងចំណេះដឹង) ការផ្គត់ផ្គង់ និងគំរវការលើវិស័យអប់រំ -
Educational supply and demand (the relationship between employment and Education)
ចំនួនសិស្ស និស្សិតដែលបានចូលសាលារៀន គឺអាចកំណត់នូវតំរូវការ និងការផ្គត់ផ្គង់ដូច ទំនិញ និងសេវាកម្មដទៃទៀតដែរ វិស័យអប់រំបណ្ដុះបណ្ដាលក្នុងបណ្ដាប្រទេសពុំទាន់អភិវឌ្ឍន៍ )LDC) ការកំណត់តំរូវការមានសារសំខាន់ច្រើនជាងការកំណត់នូវការផ្គង់ផ្គង់ ។

បើយើងពិនិត្យ វិភាគ ផ្នែកតំរូវការ យើងឃើញមានបញ្ហាពីរចំបងៗ -
– (១)នៅពេលដែលនិស្សិតរៀនចប់មហាវិទ្យាល័យ សកលវិទ្យាល័យ ពួកគេសង្ឃឹមថា នឹង រកបានប្រាក់ចំណូលខ្ពស់ នៅពេលដែលគេទទួលបានការងារធ្វើ ។

–(២)ក្នុងការចំណាយលើវិស័យអប់រំបណ្តុះបណ្តាល ដោយប្រយោលក្តី ដោយផ្ទាល់ក្តី ពួកគេរឺ ឪពុកម្តាយគ្រួសារគេត្រូវតែអត់ធ្មត់ ក្នុងការចំណាយនេះ ដើម្បីខ្លួនគេ រឺកូនចៅគេទទួលបាន ចំណេះដឹងខ្ពស់ ។ ព្រោះតំរូវការនៃចំណេះដឹង ជំនាញឯកទេស គឺជាតំរូវការយ៉ាងចបាច់ចំពោះតំបន់ ឧស្សាហកម្មទំនើបដែលពួកនិស្សិតទាំងនោះ អាចទទួលបានប្រាក់ឈ្នួលពលកម្មខ្ពស់ ។ ដូច្នេះ គេអាច ទាញយកផលប្រយោជន៍បានមកវិញ ក្រោយពីគេទទួលបានការងារធ្វើ ដើម្បីយកទៅទប់ទល់នឹងការ ចំណាយរបស់គេ លើវិស័យអប់រំ បណ្តុះបណ្តាលកន្លងមក ។

ផ្នែកផ្គត់ផ្គង់ បរិមាណសាលារៀនតាំងពីថ្នាក់បឋម មធ្យម រហូតដល់ថ្នាក់សកលវិទ្យាល័យ គឺកំណត់ដោយនយោបាយរបស់រដ្ឋាភិបាលមួយ ដែលមិនទាក់ទងដល់លក្ខណៈវិនិច្ឆ័យ សេដ្ឋកិច្ចឡើយ )Economic criteria) នយោបាយនៅក្នុងប្រទេសតតីយលោក គឺ ទាមទារចំនួនសាលារៀនយ៉ាង ច្រើន តែការផ្គត់ផ្គងនេះ វាកំណត់ដោយកំរិតចំណាយលើវិស័យអប់រំ របស់រដ្ឋាភិបាល )the level of government educational expenditures) និងការប្រមូលផ្តុំពួកឯកជន ដើម្បីបំពេញការផ្គត់ផ្គង់លើ វិស័យអប់រំនេះ ។

យើងក្រឡេកមើលទិសដៅដំបូងក្នុងការស្វែងរកការងារធ្វើ )Employment -oriented) ។ ចំណេះដឹងជំនាញ ឯកទេសរបស់បុគ្គលម្នាក់ៗ ត្រូវតែសមស្របទៅនឹងការងារ`` និងទីកន្លែងដែលគ បាន ធ្វើការ មានបួនចំណុចដែលយើងត្រូវវិភាគ ។ :

ការខុសគ្នារវាងប្រាក់ឈ្នួលពលកម្ម រឺ ប្រាក់ចំណូល (The wage or income differential) នៅតំបន់ទំនើប )The modem sector) និងតំបន់ធ្វើការតាមរបៀបប្រពៃណីបូរាណ The traditional) តែងតែទទួលប្រាក់ឈ្នួលពលកម្មខុសគ្ន ទោះបីជាគេមានការងារដូចគ្នាក៏ដោយ ។ ការបំពេញការងារនៅតំបន់ទំនើប គឺថាអាស្រ័យទៅលើកំរិតនៃការយល់ដឹង ជំនាញនិងបទពិសោធន៍ តែវាផ្ទុយទៅវិញចំពោះតំបន់ដែលធ្វើការតាមរបៀបបុរាណ ។ កាលណាតំបន់កាន់តែទំនើប រីកចម្រើន ប្រាក់ឈ្នួលពលកម្ម រឺ ប្រាក់ចំណូលកាន់តែខុសគ្នា ហើ តំរូវការចំណេះដឹង ជំនាញឯកទេស ភាពប៉ិន ប្រសប់ និងបទពិសោធន៍កាន់តែស៊ីជំរៅខ្លាំងឡើងៗ ។ ដូច្នេះ ក្រោយពីការសិក្សាដោយបទពិសោធន៍ មក យើងឃើញថា ចំពោះតំបន់ទំនើបបានផ្តល់ប្រាក់ឈ្នួលពលកម្មដល់ពលករខុសៗគ្នា អាស្រ័យតាមកំរិតនចំណេះដឹង ។

លទ្ធភាពដែលអាចកើតមានឡើងក្នុងការស្វែងរកការងារនៅតំបន់ទំនើប (the probability of success in finding modern sector employment) រឺ ពលករម្នាក់ៗ ដែលបានបញ្ចប់ការសិក្សាមហាវិទ្យាល័យ សាលាឯកទេស គឺមានប្រៀបសុំចូលប្រកួត ប្រជែងក្នុងទីផ្សារពលករ (Labor market) ដើម្បីស្វែងរកការងារធ្វើជាងអ្នកដែលពុំទាន់បានបញ្ចប់ការ សិក្សានៅមហាវិទ្យាល័យ សាលាឯកទេស បើអត្រាប្រាក់អាជីពក្នុងចំណោមអ្នកចេះដឹងនៅតំបន់ (urban unemployment rates among the educated are growing) :81ពលកម្មដែលត្រូវកំណត់អោយពលករវាទាក់ទងទៅនឹងអត្រាប្រាក់អាជីព ។ ដូច្នេះអ្នក

ដែលបានបញ្ចប់ ការសិក្សានៅមហាវិទ្យាល័យ និងឯកទេសជាន់ខ្ពស់ គឺថាក្រដាសទៅនឹងអ្នកដែលបានបញ្ចប់ការសិក្សា ត្រឹមមធ្យមសិក្សា ។

ការចំណាយឯកជនផ្ទាល់លើវិស័យអប់រំ (The direct private costs of education) ក្នុងន័យនេះ យើងចង់និយាយពីការចំណាយលុយពីហោប៉ៅ ដើម្បីបណ្តុះបណ្តាលចំណេះដឹង ដល់កូនចៅ ការចំណាយទាំងនេះរួមមាន ការបង់ថ្លៃសាលា ចំណាយលើសៀវភៅសិក្សា ..., សម្លៀកបំពាក់ និងការចំណាយផ្សេងៗទៀតដែលទាក់ទិននឹងការសិក្សា ប៉ុន្តែតំរូវការចំណេះដឹង វាផ្ទុយពីការចំណាយផ្ទាល់ បានន័យថា កាលណាការបង់ថ្លៃសាលាកាន់តែខ្ពស់នោះតំរូវការចំណេះ នឹង ឯកជន កាន់តទាប, អហរណ៍ប្រជាពលរដ្ឋក្រីក្រ ។

## ១០.៣. ការអប់រំសង្គម និងការអភិវឌ្ឍន៍ (Education Society and Development)

យើងមិនអាចនិយាយពីទំនាក់ទំនងរវាងការអប់រំ និងការអភិវឌ្ឍន៍ដោយគ្មានផ្សារភ្ជាប់ រវាង ប្រព័ន្ធអប់រំទៅនឹងសេដ្ឋកិច្ច និងលក្ខណះសង្គមបានឡើយ ។ ប្រព័ន្ធអប់រំគឺវាមិនតែងតែឆ្លុះបញ្ចាំង ធម្មជាតិនៃសង្គមទាំងស្រុងនោះទេ ។ ឧទាហរណ៍ បើសង្គមមួយគ្មានសមភាពរវាងសេដ្ឋកិច្ច និងរចនា សម្ព័ន្ធសង្គមនោះ ប្រព័ន្ធអប់រំនឹងឆ្លុះបញ្ចាំងនូវភាពលំអៀងទៅនឹងអ្នកដែលមានកំរិតជីវភាព និង វណ្ណៈខ្ពស់ ទន្ទឹមនឹងនោះ ការអប់រំ និងការអភិវឌ្ឍន៍អាចមានឥទ្ធិពលនៅពេលអនាគ និងទិសដៅ សង្គមតាមវិធីពីរ។ ទី១ ដោយការជះឥទ្ធិពលនៅលើប្រព័ន្ធសេដ្ឋកិច្ច ក្នុងសង្គមជាច្រើន វិសមភាពប្រព័ន្ធអប់រំមាននិន្នាការឥតឈប់ឈរ ក្នុងការពង្រឹង និងផលិតឡើងវិញនូវ សេដ្ឋកិច្ច និងប្រព័ន្ធសង្គមទាំងមាន socioeconomic structures) ម្យ៉ាងទៀត ការកែទំរង់ការអប់រំ គឺជាសក្តានុពលដ៏ធំធេងក្នុងការជំរុញទំនាក់ទំនងសង្គម និងកែទំរង់សេដ្ឋកិច្ចជាតិទាំងមូល ។

យើងនិងពិនិត្យ និងសិក្សាពីលក្ខណៈ ៦យ៉ាង នៃសេដ្ឋកិច្ចក្នុងការអភិវឌ្ឍន៍ ដើម្បីអោយដឹងថា អ្វីនៅដែលវាមានឥទ្ធិពលលើ រឺរងឥទ្ធិពលដោយប្រព័ន្ធអប់រំរបស់ប្រទេសមិនខានអភិវឌ្ឍន៍ ការ ពិនិត្យនេះនឹងបង្ហាញពីការទំនាក់ទំនងសំខាន់ៗរវាងការអប់រំ និងការអភិវឌ្ឍន៍ ។

### ១០.៣.១.ការអប់រំ និងការរីកចម្រើននៃសេដ្ឋកិច្ច (Education and Economic Growth)

នៅក្នុងបណ្តាប្រទេសតតិយលោក ការពងជំនាញថ្នាក់មធ្យមនឹង ឧត្តមមិនបានដែលធ្វើអោយគេអាចសន្និដ្ឋានថានៅក្នុងតំបន់សាធារណៈការបង្កើតប្រព័ន្ធអប់រំជាផ្លូវការនិងឯកជននៅមានការខ្វះខាតនិងការកំណត់ការរីកចម្រើនGNPគ្រប់គ្រាន់និងការពង្រីកវពងីកនាំហើយសំណើសុំជាច្រើនឆ្នាំក្នុងការពង្រីកការ អបរំក៏នៅតែមានបញ្ហា ។

មានប្រទេសមួយចំនួនបង្ហាញអោយថា គេមានការរីកចម្រើនខាងទុកមនុស្ស (human capital) តមានការខ្វះខាតខាងខុនរូប (physical capital) បញ្ហាពីនេះ ជាប្រភពយ៉ាងសំខាន់ក្នុងការធ្វើអោយ

សេដ្ឋកិច្ចរីកចម្រើន។ ជាក់ស្តែងនៅក្នុង Atica Asia គឺ ពួកគេចាំបាច់ត្រូវកសាងទងទុនមនុស្ស និងខុនរូប ដែលជាការងារចំបងក្នុងទិសដៅអភិវឌ្ឍន៍ ។ ដូច្នេះ ដើម្បីពង្រីកការអប់រំគ្រប់កំរិតខងអស់ ក្នុងគោលបំណងប្រមូលផ្តុំអោយរីកចម្រើនផ្នែកសេដ្ឋកិច្ច គឺ :

១.បង្កើតផលិតភាពកំលាំងពលករ និងបង្កើនចំណេះដឹងជំនាញ (Creating a productive labor force and increasing know ledge and skills)

២.ផ្តល់ភាពមានការងារធ្វើយ៉ាងទូលាយ និងប្រាក់ចំណូលដល់គ្រូបង្រៀន កម្មករសំណង់ ខ. អ្នកបោះពុម្ភសៀវភៅ សិក្សានិងក្រដាស និងអ្នកផលិតសម្លៀកបំពាក់ឯកសណ្ឋានសាលា ។ (providing widespread employment and income earning for teachers, and construction workers, textbook and paper printer, school uniform manufacturers.

៣.បង្កើតថ្នាក់រៀនសំរាប់អ្នកដឹកនាំចេះដឹង ដើម្បីបំពេញកន្លែងទំនេរដែលទុកចោលដោយ (creating classes of educated leaders to fill vacancies left by departing expatriates)

៤.បណ្តុះបណ្តាលជំនាញវិស្វករ អ្នកសេដ្ឋកិច្ច ដែលជាមូលដ្ឋានចំបងៗក្នុងការធ្វើអោយ សេដ្ឋកិច្ចរីកចម្រើន ។ ការអប់រំចំណេះដឹង អាចបង្កើតបានជាការប្រមូលផ្តុំការរីកចម្រើនផ្នែកសេដ្ឋកិច្ច ។ ចំណេះដឹង និងជំនាញរបស់កំលាំងកម្មករ គឺជាលក្ខខ័ណ្ឌចាំបាច់ក្នុងការទ្រទ្រង់សេដ្ឋកិច្ចអោយរីកចម្រើន មិនអាចប្រកែកបាន។

## ១០.៣.២.ការអប់រំ ភាពមិនស្មើភាព និងភាពក្រីក្រ (Education, inequality, and Poverty)

**ប្រេងនិងឧស្ម័ន** : លទ្ធភាពខ្ពស់ក្នុងការរុករកធនធានប្រេងនិងឧស្ម័នក្នុងសមុទ្រនៅក្នុងប្រទេស និងផ្តល់នូវការលើកស្ទួយដល់សេដ្ឋកិច្ចជាតិ។ បញ្ហាប្រឈមចំពោះមុខ គឺត្រូវរៀបចំផែនការពីពេលបច្ចុប្បន្ននេះទៅដើម្បីប្រើប្រាស់ប្រភពថាមពលនេះ និងប្រើប្រាស់ចំណូលដែលទទួលបានពីប្រភពធនធាននេះ៖ តាមរ ល្អបំផុត សំដៅទាញយកផលប្រយោជន៍សម្រាប់ប្រទេសជាតិនិងប្រជាពលរដ្ឋ ក្នុងរយៈពេលមធ្យម និង វែង។ រាជរដ្ឋាភិបាលកម្ពុជានឹងចាប់ផ្តើមធ្វើការសិក្សាស្រាវជ្រាវក្នុងពេលឆាប់ៗនេះ៖ ដើម្បីជ្រើសពិសោធន៍ល្អ១ និងចៀសវាងគ្រោះថ្នាក់ ទាំងឡាយដែលធ្លាប់បានកើតឡើងនៅតាមបណ្តាប្រទេសជពិន .. ឧស្ម័នដែលបានពីអណ្តូងប្រេងក្នុងសមុទ្រ) បើមិនដូច្នោះទេឧស្ម័នទាំងនោះនឹងឆេះចោលនៅកន្លែង ត្រូវបានយកមកប្រើប្រាស់ក្នុងរូបភាពផ្សេងៗដែលមានប្រយោជន៍សម្រាប់ផលិតកម្ម នៅលើដីគោក » មកប្រើប្រាស់សម្រាប់ផលិតកម្មដី សម្រាប់ការផលិតថាមពល សម្រាប់ធ្វើជាប្រភពថាមពលតាម ឧស្សាហកម្មជាច្រើនប្រភេទ។ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើការសិក្សាស្រាវជ្រាវ និងខិតខំប្រឹងប្រែង ..ដំណើរការហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីឱ្យធនធានប្រេងនិងឧស្ម័នដ៏មានតម្លៃ) រាប់បញ្ចូលទាំងឧស្ម័នដែលគេ ពីអណ្តូងប្រេង (ត្រូវបានយកទៅប្រើប្រាស់ ដោយមានសារប្រយោជន៍ទៅតាមលទ្ធភាពដែលអាចធ្វើបាន។

**បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍** : ចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍ គឺត្រូវអភិវឌ្ឍប្រព័ន្ធទូរគមនាគមន៍និងប្រៃសណីយ៍មួយដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចនិងមានគុណភាពកម្រិតពិភពលោក ដែលត្រូវ គ្របដណ្តប់ទូទាំងប្រទេស។ ការសម្រេចបានចក្ខុវិស័យនេះ ទាមទារឱ្យមានការវិនិយោគខ្ពស់ ដើម្បីកសាង មូលដ្ឋាននៃហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធទូរគមនាគមន៍ទាំងឡាយ ជាពិសេស ខ្សែកាបអុបទិច ដែលអាចប្រើប្រាស់ល្បឿនខ្ពស់ ដើម្បីរៀបចំប្រព័ន្ធទូរគមនាគមន៍ទាំងឡាយនៅជនបទ។ បញ្ហាប្រឈមបន្ទាន់ចំពោះ មុខ គឺការ បញ្ចុះតម្លៃសេវាទូរគមនាគមន៍ ដែលជាជំនួយដល់អាជីវកម្មនិងប្រជាជនជាទូទៅ។ វិស័យទូរគមនាគមន៍និង ព័ត៌មានវិទ្យា ត្រូវដាក់ឱ្យដំណើរការសម្រាប់ធ្វើឱ្យប្រសើរឡើងនៃស្ថានភាពរស់នៅរបស់អ្នកក្រ។ អាទិភាពទាំង ឡាយសម្រាប់ដំណាក់កាល ផយអជ) ២០០៦-២០១០ (គឺ:

- បន្ទាបតម្លៃខ្ពស់របស់សេវាកម្មទូរគមនាគមន៍ ឱ្យបានឆាប់រហ័ស។
- ពង្រីកបណ្តាញទូរគមនាគមន៍ទាំងឡាយនៅក្នុងតំបន់ទីប្រជុំជន និងពង្រីកបណ្តាញទាំងនោះទៅដល់ទីប្រជុំតូចៗ និងតំបន់ជនបទ។

- ពង្រីកសេវាប្រៃសណីយ៍ពីតំបន់ទីក្រុង-ទីប្រជុំជន ដល់តំបន់ជនបទប្រកបដោយគុណភាព មានតម្លៃថោកសមរម្យ និងពង្រឹងសមត្ថភាពស្ថាប័នគ្រប់គ្រង។
- ពង្រីកនិងធ្វើឱ្យប្រសើរឡើងនូវវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃបណ្តាញផ្សព្វផ្សាយរបស់
- វិទ្យុ ទូរទស្សន៍ និងទីភ្នាក់ងារសារព័ត៌មាន។
- បន្តអនុវត្តគោលនយោបាយបើកទូលាយក្នុងការជំរុញការចូលរួមរបស់ផ្នែកឯកជន។

ការផ្តោតការយកចិត្តទុកដាក់នឹងនៅតែបន្ត ទៅលើការជំរុញការប្រើប្រាស់យ៉ាងទូលំទូលាយនូវបច្ចេកវិទ្យា មាន នៅក្នុងគ្រប់រាល់រូបភាពនៃការគ្រប់គ្រងក្នុងរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរក្សាប្រកបដោយ សិទ្ធភាពនូវឯកសារនានា ទិន្នន័យមូលដ្ឋាន និងគេហទំព័រ ដែលនឹងផ្តល់ភាពងាយស្រួលប្រើប្រាស់ដល់ជនទាំងឡាយ លើគ្រប់រូបភាពនៃសេចក្តីត្រូវការ។ ក្រសួង-ស្ថាប័ននីមួយ១ នឹងបង្កើតគេហទំព័រផ្ទាល់ ng ហើយកែលម្អវាឱ្យទាន់ពេលវេលាក្នុងរាល់៦ខែម្តង ឬញឹកញាប់ជាងនេះទៅតាមតម្រូវការចាំបាច់។ គេហទំព័រទាំងនេះ៖ នឹងមានផ្ទុកនូវទិន្នន័យនិងព័ត៌មានទាំងអស់ ដែលមានការទាក់ទងទៅនឹងក្រសួង-ស្ថាប័ន។

## ១២.៩.ការអភិវឌ្ឍផ្នែកឯកជននិងការបង្កើតការងារ

មុំទាំងបួននៃចតុកោណនេះគឺ) : ក (ការពង្រឹងផ្នែកឯកជន និងការទាក់ទាញការវិនិយោគ) ខ ( ការ លើកសយសហគ្រាសធុនតូចនិងមធ្យម) គ (ការបង្កើតការងារ និងធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករ និងនិយោជិត និង) ឃ (ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម។

ការពង្រឹងផ្នែកឯកជន : ផ្នែកឯកជន ត្រូវបានចាត់ទុកជាកម្លាំងជំរុញចម្បងនៃកំណើនសេដ្ឋកិច្ចទន្ទឹមគ្នានឹងពេលដែលរដ្ឋាភិបាលដើរតួយ៉ាងសំខាន់ជាអ្នករៀបចំយុទ្ធសាស្ត្រ មគ្គទេសក៍ និងអ្នកគ្រប់គ្រងដំណើរ ការអភិវឌ្ឍ ហើយជាអ្នកសម្រាលក្នុងការបង្កើតឱ្យមាននូវបរិយាកាសល្អប្រសើរសម្រាប់ការវិនិយោគឯកជននិង សហគ្រាស។ ដើម្បីដោះស្រាយបញ្ហាសំខាន់ទាំងឡាយដែលបង្អាក់ដល់ការអភិវឌ្ឍផ្នែកឯកជននៅកម្ពុជា "ផែនការ ១២ ចំណុច ដែលលើកឡើងពីការប្តេជ្ញាចិត្តទាំងឡាយរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើឱ្យប្រសើរឡើងបរិយាកាសវិនិ យោគ និងសម្រួលដល់ពាណិជ្ជកម្ម ត្រូវបានអនុម័ត។

រាជរដ្ឋាភិបាលនឹងបន្តជំរុញ រក្សា និងលើកកម្ពស់បរិយាកាសអំណោយផលនេះ៖ តាមរយៈ:

- ការបង្កើនសមាហរណកម្មសេដ្ឋកិច្ចកម្ពុជានៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។
- ការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័ដែលចាំបាច់ និងការធ្វើឱ្យមានកម្លាំងពលករជំនាញ (តាមរយៈការអប់រំ បណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនិងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗទៀត)។
- បង្កើត និងអនុវត្តតំបន់សេដ្ឋកិច្ចពិសេស ដើម្បីទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងបង្កើតការងារ ជូនប្រជាជន។

- ការពង្រឹងជាបន្តទៀតនូវក្របខណ្ឌច្បាប់សម្រាប់សហគ្រាស រួមមានច្បាប់ លិខិតបទដ្ឋាន និងសមត្ថភាព ស្ថាប័នដែលសម្រួលដល់ការធ្វើអាជីវកម្មជំនួញ និងការវិនិយោគឯកជន ក្នុងបរិយាកាសមួយដែល មានការប្រកួតប្រជែងដោយស្មើភាពគ្នា តម្លាភាព គណនេយ្យភាព និងភាពអាចព្យាករណ៍បាន។
- ការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាពនិងយ៉ាងឆាប់រហ័ស នូវកត្តាចម្បងៗទាំងឡាយដែលកំណើនផ្នែកឯកជន ដែលបានកំណត់ក្នុងការអង្កេតបរិយាកាសវិនិយោគ១ ដូចជា អភិបាលកិច្ចបន្ទុកផ្នែកទិដ្ឋភាពច្បាប់ ភាពខ្សោយនៅក្នុងបរិយាកាសតុលាការនិងច្បាប់។
- ការលុបបំបាត់នូវភាពមិនប្រាកដប្រជានិងភាពមិនអាចព្យាករណ៍បានដែលមាននាពេលបច្ចុប្បន្ន »...ឡើងដោយកត្តាដូចបានពោលខាងលើ ដែលធ្វើឱ្យអ្នកវិនិយោគពិតប្រាកដនិងសម្រាប់រយៈពេល ចៀសចេញពីកម្ពុជា ដោយធ្វើឱ្យគេអាចយល់បានថា អ្នកវិនិយោគទាំងឡាយណាដែលនៅកម . អ្នកចង់ទាញយកផលចំណេញភ្លាមៗ និងឆ្លៀតឱកាសរកចំណេញ ឬក៏ធ្វើអាជីវកម្មនៅក្នុងផ្នែកមិនជកា ដើម្បីគេចពន្ធ ហើយជាមួយនេះៈ ដើម្បីរកផលចំណេញឱ្យបានច្រើនបំផុត។
- ការដាក់ឱ្យដំណើរការី ប្រកចេញចូលតែមួយ " ជាយន្តការសម្របសម្រួលមួយដ៏ឆាប់រហ័សរបស់ ភិបាល សម្រាប់ពាណិជ្ជកម្ម និងអ្នកវិនិយោគទាំងអស់។
- ការបន្តការពិភាក្សាដោយចំហជាមួយផ្នែកឯកជន តាមរយៈវេទិកាផ្នែកឯកជន និងគណៈកម្មាធិការសម្រាប់អភិវឌ្ឍន៍ផ្នែកឯកជន ដើម្បីដោះស្រាយការព្រួយបារម្ភទាំងឡាយរបស់ផ្នែកឯកជន។

ដើម្បីលើកកម្ពស់កំណើនដែលនាំមុខដោយការនាំចេញ និងកំណើនដើម្បីគាំទ្រអ្នកក្រ តាមរយៈការ ធ្វើពិពិធកម្ម រាជរដ្ឋាភិបាលនឹងបន្តលើកទឹកចិត្ត សម្រួល និងផ្តល់ការគាំទ្រដល់ការវិនិយោគផ្នែកឯកជន ក្នុងវិស័យមួយចំនួន និងក្នុងវិស័យអាទិភាព ដូចខាងក្រោម:

- កសិកម្ម និងកសិ-ឧស្សាហកម្ម រួមទាំង ជាវសាស្ត្រ ដោយសារវិស័យទាំងនេះមានសក្តានុពលខ្ពស់សម្រាប់កំណើនខ្លាំង និងមានផលប៉ះពាល់ខ្លាំងលើសេដ្ឋកិច្ច តាមរយៈការបង្កើនចំណូលក្នុងតំបន់ជនបទ និងបង្កើនតម្រូវការ។
- ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងទូរគមនាគមន៍។ • ការផលិតនិងការចែកចាយថាមពលអគ្គិសនី។
- ឧស្សាហកម្មដែលត្រូវការកម្លាំងពលកម្មច្រើន និងកម្មន្តសាលកែច្នៃសម្រាប់ការនាំចេញ។
- ទេសចរណ៍ និងវិស័យពាក់ព័ន្ធ។
- ការអភិវឌ្ឍធនធានមនុស្ស។

**ពាណិជ្ជកម្ម** : ដោយផ្សារភ្ជាប់ផលិតកម្មទៅនឹងការប្រើប្រាស់ឬអ្នកផលិតទៅនឹងអ្នក ពាណិជ្ជកម្មគឺជាមធ្យោបាយដ៏សំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច។ ការជំរុញលើកទឹង ពាណិជ្ជកម្មសម្រាប់ផលិតផលកម្ពុជា គឺជាអាទិភាពខ្ពស់ក្នុងចំណោមអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាល។

ប្រសិនបើមានការលក់ដូរនៅទីផ្សារ ការវិនិយោគអាចនឹងហូរចូល ដើម្បីលើកទឹកចិត្តនិងលើកកម្ពស់ផលិតកម្មទំនិញ និងសេវាកម្ម ដោយប្រើប្រាស់ភាពខ្លាំងពិតប្រាកដរបស់កម្ពុជា ដូចដែលធ្លាប់បានកើតមានឡើងក្នុងឧស្សាហកម្មកាត់ដេរ ហើយអាចនឹងសម្រេចបានក្នុងវិស័យកសិកម្ម ការកែច្នៃកសិកម្ម សិប្បកម្ម និងផ្នែកផ្សេងទៀត។

តាំងពីឆ្នាំ២០០១ ក្របខណ្ឌគោលនយោបាយពាណិជ្ជកម្មមួយសម្រាប់ជំរុញការអភិវឌ្ឍវិស័យពាណិជ្ជកម្ម «សនិងក្រៅប្រទេស ត្រូវបានដាក់ឲ្យដំណើរការ ដែលជាមធ្យោបាយមួយដើម្បីជំរុញកំណើន និងចូលរួមក្នុងការបន្ថយភាពក្រីក្រ។ គំនិតផ្តួចផ្តើមនានានិងវិធានការកែទម្រង់ ទាំងឡាយដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីអនុវត្តក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មឱ្យបានពេញលេញ ក្នុងការនាំចេញយ៉ាងសកម្មនិងការធ្វើ សមាហរណកម្មប្រទេសទៅក្នុងតំបន់ និងការចូលរួមទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០៤។ រាជរដ្ឋាភិបាលក៏បានចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនិង/ឬពាណិជ្ជកម្ម អនុគ្រោះជាមួយប្រទេសជាច្រើន ប្រកបដោយជោគជ័យ។ ទោះជាដូចនេះក្តី នៅមានការរាំងស្ទះជាច្រើនទៀត ដែលមានលក្ខណៈប្រហាក់ ប្រហែលទៅនឹងការរាំងស្ទះនៅក្នុងការវិនិយោគឯកជនក្នុងវិស័យឧស្សាហកម្ម ដែលជាឧបសគ្គនៃកំណើនក្នុង វិស័យពាណិជ្ជកម្ម។ អភិក្រមគ្រប់គ្រងទូទាំងវិស័យ មួយសម្រាប់ផ្នែកពាណិជ្ជកម្មកំពុងត្រូវបានរៀបចំ។ បញ្ហា ប្រឈមបន្ទាន់ចំពោះមុខទាំងឡាយ គឺត្រូវធានាថាកិច្ចព្រមព្រៀងពាណិជ្ជកម្មអនុគ្រោះ៖ ទាំងឡាយដែលបានចុះ៖ ហត្ថលេខារួចហើយ ត្រូវបានទទួលឧត្តមភាពតាមរយៈពាណិជ្ជកម្មឯកជន ក្នុងការនាំផលិតផលកម្ពុជាទៅកាន់ ទីផ្សារបរទេស ដើម្បីការនាំចេញទាំងឡាយអាចមានលក្ខណៈចម្រុះនិងទូលំទូលាយ ដោយជួយឱ្យការនាំចេញ លែងមានការពឹងផ្អែកទៅលើឧស្សាហកម្មកាត់ដេរតែមួយមុខ។

កំណែទម្រង់នានាដែលរាជរដ្ឋាភិបាលកម្ពុជានឹងបន្តក្នុងអភិបាលកិច្ច វិស័យតុលាការនិងច្បាប់ និងរដ្ឋបាល សាធារណៈ ក៏ដូចជា ក្នុងការស្តារហេដ្ឋាចរនាសម្ព័ន្ធមូលដ្ឋាន នឹងពិតជារួមចំណែកក្នុងការធ្វើឱ្យមានបរិយាកាសល្អ ប្រសើរជាងមុខ សម្រាប់ពាណិជ្ជកម្មនិងការវិនិយោគដោយផ្នែកឯកជន។ បន្ថែមពីលើការដោះស្រាយឧបសគ្គ ទាំងឡាយក្នុងផ្នែកឧស្សាហកម្ម កម្មន្តសាលនិងឧស្សាហកម្មកែច្នៃ ក៏ដូចជា ក្នុងផ្នែកពាណិជ្ជកម្ម រាជរដ្ឋាភិបាល កម្ពុជានឹង :

- ជំរុញលើកទឹកចិត្តយ៉ាងសកម្មឱ្យមានលទ្ធភាពចូលទៅក្នុងទីផ្សារក្រៅប្រទេសនានា របស់ផលិតផល ពិសេសនិងមានគុណភាពខ្ពស់របស់កម្ពុជា ដែលរាប់បញ្ចូលទាំងផលិតផលកសិកម្ម (ជាពិសេស ផលិតផលដែលបានកែច្នៃរួចហើយ) ផលិតផលកែច្នៃពីត្រី និងសេវាកម្មកម្លាំងពលកម្ម។
- ជំរុញផលិតផលកម្ពុជានៅទីផ្សារបរទេស។
- ជំរុញលើកទឹកចិត្តឱ្យមានការបង្កើតសមាគមសម្រាប់សមាជិកភាពនៃធុរៈកិច្ច និងពង្រឹងសមត្ថភាពផ្សាយរបស់សមាគមទាំងនោះ។

- កាត់បន្ថយឧបសគ្គដែលបណ្ដាលមកពីគោលនយោបាយ ចំពោះអន្តរកម្មធុរៈកិច្ចប្រកបដោយប្រសិទ្ធភាព។
- រៀបចំឱ្យមានប្រសិទ្ធភាពនូវអធិការកិច្ចគយ ដើម្បីធ្វើឱ្យការងារនេះ៖_មានភាពងាយស្រួលជា. សម្រាប់អតិថិជន និងមិនមានការពន្យារនិងការចំណាយដែលផ្សារភ្ជាប់នឹងស្ថានភាពនេះ រួមទាំងការរៀបចំ និងការអនុវត្តច្បាប់គយនិងរដ្ឋករ ដែលបានកែសម្រួលរួចហើយ។
- កាត់បន្ថយឧបសគ្គនៃការនាំចូល ដូចជាតម្លៃខ្ពស់នៃការចុះបញ្ជីនិងតម្លៃនៃការចេញអាជ្ញាប័ណ្ណ។
- ជួយសម្រួលដល់ការបង្កើតតំបន់កែច្នៃសម្រាប់ការនាំចេញ ដើម្បីជំរុញឧស្សាហកម្មកែច្នៃនិងសម្រាប់បម្រើឱ្យការនាំចេញ។

**ទេសចរណ៍** : ការកើនឡើងយ៉ាងឆាប់រហ័ស បានជំរុញឱ្យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធកាយ ជាវិស័យទីពីរបន្ទាប់ពីឧស្សាហកម្មកាត់ដេរ និងមានតួនាទីក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងការផ្ដល់ឱកាសការងារ ជូនប្រជាពលរដ្ឋកម្ពុជាមួយចំនួនធំ ទាក់ទងនឹងផ្នែកមួយចំនួនដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ការដឹកជញ្ជូន និង សេវាកម្មផ្សេងៗទៀត។ គោលនយោបាយសម្រាប់អភិវឌ្ឍវិស័យទេសចរណ៍ត្រូវបានផ្អែកលើគោលការណ៍ជា មូលដ្ឋានបី) ក (ការអភិវឌ្ឍត្រូវមានលក្ខណៈចីរភាព ពឹងផ្អែកលើកេរដំណែលវប្បធម៌ដ៏ស្តុកស្តម្ភ ប្រវត្តិសាស្ត្រ និងធម្មជាតិដ៏ល្អត្រកាលនៃទឹកដីកម្ពុជា។ សំខាន់ជាងនេះទៀតគឺការអភិវឌ្ឍដែលរួមចំណែកក្នុងការកាត់បន្ថយ ភាពក្រីក្រ) ខ (ការផ្សព្វផ្សាយយ៉ាងសកម្មនិងមានលក្ខណៈច្នៃប្រឌិតអំពីវិស័យទេសចរណ៍ ដើម្បីធ្វើឱ្យកម្ពុជា ក្លាយទៅជាគោលដៅទេសចរណ៍ វប្បធម៌និងធម្មជាតិ៉ មួយក៏គួរជាទីទាក់ទាញដែលមានលក្ខណៈប្រកួតប្រជែង នៅក្នុងតំបន់ និងអន្តរជាតិ) គ (ក្រៅពីការកើនឡើងនៃចំនួនភ្ញៀវទេសចរដែលបានមកដល់ ត្រូវបង្កើនចំនួនថ្ងៃ ដែលអ្នកទេសចរស្នាក់នៅក្នុងប្រទេស និងការចំណាយរបស់ភ្ញៀវទេសចរ ព្រមទាំងធ្វើឱ្យមានគោលដៅទេសចរណ៍ ច្រើនប្រភេទ និងច្រើនកន្លែង។ លើសពីនេះទៀត ការខិតខំប្រឹងប្រែងនឹងត្រូវធ្វើឡើង ដើម្បីធានាថាផលប្រយោជន៍សមស្របនៃវិស័យទេសចរណ៍ នឹងជួយដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅ ជុំវិញតំបន់ទេសចរណ៍ ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ការផ្ដួចផ្ដើមគំនិតសំខាន់ៗដែលនឹងត្រូវបន្តធ្វើឱ្យមានប្រសិទ្ធភាព។ទៀត ជាអាទិ៍:

- គោលនយោបាយបើកចំហជើងមេឃ។
- ធ្វើឱ្យមានភាពងាយស្រួលក្នុងការទទួលទិដ្ឋាការ និងការទស្សនា។
- កិច្ចព្រមព្រៀងទេសចរណ៍អាស៊ាន និងកិច្ចព្រមព្រៀងផ្សេងៗទៀត ដូចជាការពង្រឹងទេសចរណ៍ក្នុង តំបន់ជាដើម។
- ពង្រឹងសមត្ថភាព និងយន្តការប្រឆាំងបទល្មើសពាក់ព័ន្ធនឹងទេសចរណ៍ផ្លូវភេទរាល់រូបភាពនៃអាជីវកម្មលើកុមារ។

រាជរដ្ឋាភិបាលបានបន្តការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត) ផ្លូវគោក អាកាសយានដ្ឋាន កំពង់ផែ ប្រព័ន្ធទឹកស្អាត អគ្គិសនី (ក៏ដូចជាការផ្តល់នូវបរិយាកាសសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមនិងបង្កលក្ខណៈងាយស្រួលឱ្យមានការកើនឡើងនៃភ្ញៀវទេសចរ ការស្នាក់នៅ និងការទស្សនា។ ដោយមានការ កើនឡើងជាបន្តបន្ទាប់ក្នុងល្បឿនលឿន ចំនួនភ្ញៀវទេសចរមកដល់ប្រចាំឆ្នាំ ត្រូវបានរំពឹងថា នឹងកើនដល់ប្រមាណ៣លាននាក់នៅឆ្នាំ២០១០ ចំណូលទេសចរណ៍នឹងកើនឡើងដល់ប្រមាណ ១.៥០០លានដុល្លារ និងផ្តល់ការងារដល់ប្រជាពលរដ្ឋប្រមាណ ៤០០.០០០នាក់។ សម្រាប់គោលបំណងនេះ៖ រាជរដ្ឋាភិបាលត្រូវអនុវត្ត វិធានការគាំទ្រជាច្រើនដូចខាងក្រោមៈ

- ការបង្កើតឡើងនូវក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយវិស័យទេសចរណ៍ ដើម្បីបង្កលក្ខណៈអោយផ្នែកសាធារណៈ និងឯកជនចូលរួមសហការគ្នាក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។
- ការបង្កើតការិយាល័យ ឬបញ្ជារព័ត៌មានទេសចរណ៍នៅតាមច្រកទ្វារព្រំដែនអន្តរជាតិ។
- លើកទឹកចិត្តឱ្យមានការផ្តល់សេវាព័ត៌មាន ដូចជា សណ្ឋាគារឬផ្ទះសំណាក់ មគ្គុទេសក៏ទេសចរ អាក (សចរណ៍និងសេវាដែលមានការពាក់ព័ន្ធ ភោជនីយដ្ឋាន គមនាគមន៍។ ល។
- កែលម្អ និងអភិវឌ្ឍបន្ថែមទៀតនូវផលិតផលទេសចរណ៍ ដោយផ្តោតទៅលើតំបន់អាទិភាពទាំងបួន (តំបន់សៀមរាប-អង្គរ ភ្នំពេញ និងតំបន់ជុំវិញតំបន់ឆ្នេរ និងតំបន់ភូមិភាគឥសាន្ត) និងពង្រីកទៅកាន់ តំបន់ផ្សេងៗ ទៀតនៅទូទាំងប្រទេស។

**សហគ្រាសតូចនិងមធ្យម** : សហគ្រាសតូចនិងមធ្យមជាធម្មតាស្ថិតនៅជាប់ប្រជាជនសាមញ្ញ និងផ្តល់ ផលប្រយោជន៍ដល់សហគមន៍ជនបទក្នុងការកែច្នៃ និងតម្លៃបន្ថែមទៅលើផលិតផល ក៏ដូចជាការបង្កើតការងារ។ សហគ្រាសតូចនិងមធ្យមផ្តល់ផងដែរនូវការតភ្ជាប់យ៉ាងសំខាន់ទៅនឹងវិស័យពាណិជ្ជកម្ម ក៏ដូចជា ទៅនឹងសហគ្រាស។ ដើម្បីជំរុញល្បឿននិងសម្រួលដល់សហគ្រាសតូចនិងមធ្យម រាជរដ្ឋាភិបាលនឹងអនុវត្តវិធានការដូចខាង ក្រោមៈ

- ដាក់ឱ្យមាននូវវិធានការទាំងឡាយ ដើម្បីឱ្យសហគ្រាសធុនតូចនិងមធ្យម និងមីក្រូសហគ្រាសដំណើរ ការក្នុងបរិស្ថានធុរៈកិច្ចមួយមានផលចំណេញ និងបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរយៈពេលមធ្យម និងវែង។
- បង្កើតប្រព័ន្ធពិសេស១ដើម្បីគាំទ្រស្ត្រីក្នុងធុរៈកិច្ច និងបង្កលក្ខណៈងាយស្រួលដល់ស្ត្រី ឱ្យអាចប្រើប្រាស់ សេវាកម្មនិងកម្មវិធីនានានៃការអភិវឌ្ឍសហគ្រាសតូចនិងមធ្យម។
- កាត់បន្ថយនីតិវិធីការចុះបញ្ជីក្រុមហ៊ុន និងជួយក្នុងដំណើរការនៃការចាប់ផ្តើមរបស់សហមធ្យម។
- បង្កើតស្ថាប័នស្តង់ដារជាតិនិងស្ថាប័នផលិតភាព ដើម្បីជួយធានាគុណភាពនៃផលិតផលក្នុងស្រុក ផលិតភាព។

- ជំរុញគាំទ្រសេវាប្រឹក្សាដល់សហគ្រាសតូចនិងមធ្យម ដើម្បីជួយអភិវឌ្ឍបច្ចេកវិទ្យាទំនើបនៅកម្ម ការកែលម្អគុណភាពផលិតផល ការគ្រប់គ្រងនិងការស្វែងរកទីផ្សារ។
- ជំរុញការបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងក្នុងស្រុកនិងក្រៅស្រុក។
- ពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតច្បាប់នានាដែលពាក់ព័ន្ធនឹងរោងចក្រ តំបន់ឧស្សាហកម្ម ។ល។ ការបង្កើតមុខទំនិញថ្មីៗ ខ្នាតនិងរង្វាស់រង្វាល់ និងសុវត្ថិភាពឧស្សាហកម្ម។
- លើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការជំរុញសហគ្រាសតូចនិងមធ្យម។

ឥណទានជនបទ គឺជាកត្តាមួយសំខាន់សម្រាប់ការពង្រីកសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលំទូលាយ សម្រាប់ ការអភិវឌ្ឍជនបទ និងសម្រាប់ការកាត់បន្ថយភាពក្រីក្រ តាមរយៈការគាំទ្រផលិតកម្មកសិកម្ម និងការបង្កើត និងការពង្រីកធុរៈកិច្ច) ជាពិសេសសហគ្រាសតូចនិងមធ្យម (តាមរយៈការបង្កើនផលិតភាព ការបង្កើតចំណូល ព្រមទាំងសម្រាប់ការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។ មូលនិធិជាច្រើនថែមទៀត គឺជាតម្រូវ ការចាំបាច់សម្រាប់ជួយបំពេញមួយផ្នែកលើតម្រូវការដ៏ធំក្នុងឥណទានជនបទ។ បញ្ហាប្រឈមដ៏ចម្បងបំផុត គឺត្រូវស្វែងរកដំណោះស្រាយនិងមធ្យោបាយនានា ដែលតាមរយៈនេះ ឥណទានជនបទ អាចមានសម្រាប់ការ ប្រើប្រាស់ក្នុងអត្រាការប្រាក់មួយទាបច្រើនជាងអត្រាដែលមានបច្ចុប្បន្ន )៤៨ភាគរយក្នុងមួយឆ្នាំ(។ ដើម្បីធានា ឱ្យមានលទ្ធភាពច្រើនជាងមុននិងមានលក្ខណៈងាយស្រួលដល់អ្នកក្រ ក្នុងការទទួលបានឥណទាន ជាពិសេស សម្រាប់គោលបំណងធ្វើផលិតកម្ម រាជរដ្ឋាភិបាលនឹងចាត់វិធានការដើម្បីពង្រីកនិងបន្ថយចំណាយខ្ពស់សម្រាប់ ឥណទានជនបទ តាមរយៈ:

- ការពិនិត្យពិចារណានិងការជំរុញលើកទឹកចិត្តឱ្យមានការបង្កើតស្ថាបន័ ដូចជាសហករណ៍អ្នកប្រើប្រាស់ដែលមាននៅក្នុងតំបន់មួយចំនួននៃទ្វីបអាស៊ី។
- ការបង្វែរអង្គការក្រៅរដ្ឋាភិបាលដែលកំពុងដំណើរការការងារនេះ ឱ្យក្លាយជាប្រតិបត្តិការហិរញ្ញវត្ថុ។
- មានការចុះបញ្ជីឈ្មោះត្រឹមត្រូវ (ដំណើរការនេះ បានចាប់ផ្តើមរួចមកហើយ ហើយអង្គការភិបាលជាច្រើនត្រូវបានផ្តល់អាជ្ញាប័ណ្ណរួចហើយ)។
- ការធ្វើឱ្យប្រសើរឡើងការត្រួតពិនិត្យស្ថាប័នទាំងនេះ ដើម្បីធានាថា ស្ថាប័នទាំងនេះពិតជាដំណើរសមស្របទៅតាមគោលការណ៍។
- ការកាត់បន្ថយអត្រាការប្រាក់ដែលមានជាទូទៅ តាមរយៈបទពិសោធន៍ដ៏ល្អប្រសើរដែលធ្លាប់មានមកហើយ។

ការបង្កើតការងារនិងលក្ខខណ្ឌការងារល្អប្រសើរជាងមុន : ទិសដៅសំខាន់ៗក្នុងការងារនេះ៖ គឺការបង្កើតកាលានុវត្តភាពការងារដែលមានសារៈប្រយោជន៍ ទាំងក្នុងផ្នែករៀបរយនិងទាំងក្នុងផ្នែកមិនរៀបរយ ការធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់ពលករមានគុណភាព និងការលុបបំបាត់រូបភាពអាក្រក់បំផុត

នៃពលកម្មកុមារ។ ឧស្សាហកម្មកាត់ដេរដែលកើនឡើងយ៉ាងឆាប់រហ័ស បានធ្វើឱ្យមានការប្រែប្រួលនៃស្ថានភាពការងារនៅទីប្រជុំជនតាមរយៈការបង្កើតនិងការធ្វើឱ្យមានស្ថេរភាពការងារដែលប្រើកម្លាំងពលកម្មច្រើន ជាពិសេស សម្រាប់ស្ត្រី . ក៏ដូចនៅក្នុងវិស័យផ្សេងៗទៀតដែរ គោលនយោបាយមួយដែលមានលក្ខណៈជាប្រព័ន្ធកំពុងត្រូវបាន កមកអនុវត្ត ដើម្បីបង្កើតការងារឱ្យបានច្រើនជាងមុន ជាពិសេស សម្រាប់ប្រជាជនក្មេងៗដែលកំពុងចូលខ្លួន. ៥២ពលកម្ម និងសម្រាប់ពលរដ្ឋកម្ពុជាទាំងអស់តាមរយៈវិធានការទាំងឡាយ ដូចខាងក្រោមៈ

- បង្កើនផលិតភាពកសិកម្ម ដើម្បីបង្កើតកាលានុវត្តភាពការងារនៅជនបទឱ្យបានច្រើនជាងមុន ដែលនឹង មានឥទ្ធិពលខ្លាំងទៅលើវិស័យជាច្រើន រួមបញ្ចូលទាំង តាមរយៈការបង្កើនតម្រូវការទំនិញនិងសេវា កម្មផ្សេងៗ។
- លើកទឹកចិត្តការវិនិយោគផ្ទាល់ពីបរទេសនិងការវិនិយោគក្នុងស្រុកនៅក្នុងវិស័យអាទិភាព ជាពិសេស វិស័យកសិកម្ម កសិ-ឧស្សាហកម្ម ឧស្សាហកម្មនិងគម្រោងដែលប្រើប្រាស់ពលកម្មច្រើន ព្រមទាំងវិស័យទេសចរណ៍។
- បង្កើតបណ្តាញអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងជំនាញផ្សេងៗ ដើម្បីបម្រើដោយស្មើភាពគ្នា ទាំងបុរសនិងទាំងស្ត្រី ជាពិសេសជនក្រីក្រ ជនពិការ និងក្រុមជនដែលងាយរងគ្រោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ សម្រាប់រយៈពេលខ្លីនិងវែង។
- រៀបចំបង្កើតមូលដ្ឋានទិន្នន័យកម្លាំងពលកម្មមួយ និងប្រព័ន្ធស្ថិតិមួយ ដោយមានទិន្នន័យដែលបំបែកលម្អិតជាច្រើនប្រភេទ ដូចជា តាមយេនឌ័រ ពិការភាព និងកត្តាផ្សេងៗទៀតដែលទាក់ទងនឹងសង្គមកិច្ច។
- ជួយពលករកម្ពុជាក្នុងការស្វែងរកការងារនៅបណ្តាប្រទេសផ្សេងៗទៀត។

ការធានាឱ្យមានលក្ខខណ្ឌនៃកន្លែងធ្វើការដែលមានសុវត្ថិភាព ត្រឹមត្រូវ និងមានអនាម័យល្អ និងលក្ខខណ្ឌ កិច្ចសន្យាដែលត្រឹមត្រូវនិងយុត្តិធម៌សម្រាប់កម្លាំងពលកម្មគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការងារហើយក៏ជាផ្នែកមួយដ៏សំខាន់នៃការងារផងដែរ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងដោះស្រាយជាប្រចាំ នូវបញ្ហាទាំង មនេះ រួមមាន ការកម្រិតអប្បបរមានៃប្រាក់ឈ្នួលប្រចាំខែនិងថ្ងៃឈប់សម្រាក ការកាត់បន្ថយវិសមភាពក្នុងប្រាក់ឈ្នួលរវាងបុរសនិងស្ត្រីដំណោះស្រាយជម្លោះនិងការមិនឯកភាពគ្នាតាមសន្តិវិធី ដោយមិនបង្កឡើងនូវការអាក់ខានដល់សង្វាក់ផលិតកម្ម និងការបាត់បង់ប្រាក់ឈ្នួលរបស់និយោជិក។ អាទិភាពទាំងទាញ នេះគឺៈ

- ពង្រឹងយ៉ាងខ្លាំងក្លានូវការអនុវត្តច្បាប់ស្តីពីការងារនិងអនុសញ្ញាអន្តរជាតិ ដែលទាក់ទងទៅសហជីពកម្មករ ដើម្បីការពារសិទ្ធិនិងកាតព្វកិច្ចរបស់កម្មករ និយោជិត និងនិយោជក។
- ធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករនិងនិយោជិត រួមបញ្ចូលទាំងកម្មករនៅទាំងក្នុងនិងក្រៅប្រទេស និងកម្មករមានផ្ទៃពោះ។

- បន្តនិងពង្រឹងការខិតខំប្រឹងប្រែងដើម្បីកាត់បន្ថយសមាមាត្រនៃកុមារធ្វើការងារ (ពលកម្មកុមារ ,
- ពង្រឹងការអនុវត្តច្បាប់ស្តីពីសន្តិសុខសង្គម។
- បង្កើត " បេឡាជាតិសន្តិសុខសង្គមមួយ"។
- ពិនិត្យជម្រើសដែលអាចធ្វើបាន សម្រាប់ការបង្កើតបេឡាសោធន ជាពិសេស សម្រាប់ជនពិការ ,អ្នកនៅក្នុងបន្ទុក និងការធានារ៉ាប់រងសម្រាប់គ្រោះថ្នាក់ការងារ ដូចមានចែងក្នុងច្បាប់ការងារ។

បណ្តាញសុវត្ថិភាពសង្គម : រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តផ្តល់នូវអន្តរាគមន៍សម្រាប់វិស័យសង្គមកិច្ច ដែលក្នុងនោះរួមមាន) ក (ការកាត់បន្ថយភាពងាយរងគ្រោះនរបស់អ្នកក្រ) ខ (វិធានការដើម្បីសម្រាលផល ប៉ះពាល់នៃគ្រោះធម្មជាតិ) គ (ការជួយជនរងគ្រោះដោយសារបាតុភូតទាំងនោះ) ឃ (ការពង្រីកកម្មវិធីនីតិ សម្បទានិងកម្មវិធីសមាហរណកម្មឡើងវិញសម្រាប់ជនពិការ សម្រាប់ជនដែលរងគ្រោះដោយគ្រឿងញៀន សម្រាប់ ជនរងគ្រោះដោយសារការជួញដូរនិងកុមារដែលប្រព្រឹត្តខុសច្បាប់ ក៏ដូចជាការពង្រីកកម្មវិធីសុខុមាលភាពសម្រាប់ ជនចាស់ជរា កុមារកំព្រា មេម៉ាយនិងពោះម៉ាយក្រីក្រ គ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ ស្ត្រីរងគ្រោះ ជនគ្មានទីលំនៅដ្ឋាន និងអតីតយុទ្ធជននិងគ្រួសាររបស់ពួកគេ )ង (ការទប់ស្កាត់បទល្មើសនិងការការពារសុវត្ថិភាព សហគមន៍នៅថ្នាក់ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុង និងថ្នាក់ជាតិ ដោយសហការក្នុងភាពជាដៃគូអភិវឌ្ឍន៍ និងអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗទៀត។ យុទ្ធសាស្ត្រនិងសកម្មភាពជាអាទិភាពទាំងឡាយដែលត្រូវអនុវត្ត រួមមាន ការអនុម័តយកនិងការពង្រឹងការអនុវត្តច្បាប់សំខាន់ៗ និងការបង្កើតមជ្ឈមណ្ឌលនីតិសម្បទាំសប្រម កុមារកំព្រា ជនអនាថាតាមផ្លូវ ជនពិការ ជនចាស់ជរា ព្រមទាំងស្ត្រីនិងកុមាររងគ្រោះដោយការជួញដូរ ដោយសារបច្ចុប្បន្ននេះ៖ បញ្ហាគ្រឿងញៀនបានក្លាយជាកង្វល់ដ៏ធំមួយសម្រាប់សន្តិសុខ និងសុខុមាលា សង្គមជាតិទាំងមូល វិធានការដើម្បីទប់ស្កាត់ ការផលិត ការហូរចូល ការលក់ដូរ និងការប្រើប្រាស់។ នឹងត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់ដោយអាជ្ញាធរពាក់ព័ន្ធ។

## ១២.១០.ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

ផ្នែកនេះបង្ហាញពីចតុកោណទី៤ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលភាគច្រើនគ្រប់ លើផ្នែកសង្គមកិច្ច ក្នុងនោះរួមមាន អប់រំ សុខាភិបាល សមភាពយេនឌ័រ និងបញ្ហាប្រជាជន។

ការអប់រំ ការអប់រំត្រូវបានទទួលយកជាសកល ថាជាមូលដ្ឋានសិទ្ធិមនុស្សមួយដ៏សំខាន់។ ការអប់រំ ប៏ជាកត្តាមួយចម្បងផងដែរ ដែលផ្តល់វិភាគទានដល់ការកាត់បន្ថយភាពក្រីក្រ។ ទិសដៅរយៈពេលវែង គឺដើម្បីធានាថាកុមារនិងយុវជនកម្ពុជាទាំងអស់មានឱកាសស្មើៗគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាព បព៌គិតពីឋានៈក្នុងសង្គម តំបន់ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ ឬភាពពិការឡើយ។ ការអប់រំ បង្កើតឱ្យមានមោទនភាពចំពោះជាតិនិងចំពោះខ្លួនឯងក្នុងឋានៈជាពលរដ្ឋម្នាក់ មានកម្រិតសីលធម៌និងសុទិដ្ឋិនិយមខ្ពស់ដូចជា មានការទទួលខុសត្រូវចំពោះប្រទេសជាតិនិងប្រជាជន។ តួនាទីនៃការ

អប់រំ គឺដើម្បីលើក ឧស់គណភាពសិស្ស-និស្សិត ដើម្បីក្លាយខ្លួនជាអ្នកមានផលប្រយោជន៍ និងការរស់នៅប្រកបដោយភាពសុខដុមរមនានៅក្នុងសង្គមមួយដែលស្ថិតនៅក្នុងបរិបទនៃសកលភាវូបនីយកម្ម។

វិស័យអប់រំគឺជាវិស័យមួយដែលត្រូវបានទទួលស្គាល់ថាសម្រេចបានជោគជ័យនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់កម្ពុជា ទាំងនៅក្នុងការងារកំណែទម្រង់ ទាំងនៅក្នុងការសម្រេចបាននូវសមិទ្ធផលទាំងឡាយ។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាប្រឈមជាច្រើននៅតែកើតមានឡើងនៅឡើយ ហើយនៅក្នុងចំណោមបញ្ហា ប្រឈមទាំងនោះ មានជាអាទិ៍ ភាពចាំបាច់និងបន្ទាន់ក្នុងការលើកកម្ពស់គុណភាពនៃការអប់រំ។ កិច្ចសហប្រតិ បត្តិការក្នុងចំណោមភាគីដែលមានចំណែកពាក់ពន្ធ័នានា មានការរីកចម្រើនច្រើនក្នុងរយៈពេលថ្មីៗកន្លងទៅនេះ។ តាមរយៈបទពិសោធន៍ដែលទទួលបានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០១-២០០៥ ផែនការ យុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ មួយទៀត ត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាង ទូលំទូលាយជាមួយអ្នកមានចំណែកពាក់ពន្ធ័ទាំងអស់ ហើយផែនការនេះបានបញ្ចូលនូវគោលដៅទាំងឡាយនៃ ផនការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០០៣-២០១៥។ ផែនការនេះ គឺជាក្របខ័ណ្ឌលនយោបាយនិងការ ** ដលខានមួយ សម្រាប់ការកែលមសានភាពរស់នៅរបស់អ្នកក្រ ដោយប្រើប្រាស់ការអប់រំជាកត្តាសំខាន់ការលើកកម្ពស់ការអភិវឌ្ឍសង្គមនិងកំណើនសេដ្ឋកិច្ច។ ការផ្តោតការយកចិត្តទុកដាក់ ត្រូវធ្វើឡើងនៅក្នុង លម្អគុណភាពអប់រំនៅគ្រប់កម្រិតទាំងនៅកម្រិតមតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ ផ្នែកនេះ៖ គូសបញ្ជាក់ពីចំណុចសំខាន់ៗនៃ ផែនការយុទ្ធសាស្ត្រវិស័យ អប់រំឆ្នាំ២០០៦-២០១០ ដែលផ្តល់ព័ត៌មានលម្អិតជាងនេះ។

បង្អែករឹងមាំរបស់ប្រទេសជាតិមួយ គឺជា " សំណុំដ៏សំខាន់ៗ នៃធនធានមនុស្សដែលមានការអប់.. ជំនាញ មានទេពកោសល្យ និងមានសមត្ថភាព នៅក្នុងវិស័យនានានៃផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច។ បច្ចុប្បន្ននេះ ការផ្តល់សេវាអប់រំនៅកម្រិតឧត្តមសិក្សា ជាពិសេស ការផ្តល់ដោយផ្នែកឯកជន ហាក់ដូចជាមិន មានតុល្យភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការរយៈពេលខ្លីនៃទីផ្សារ ដូចជាតម្រូវការបន្ទាន់នូវបុគ្គលិកថ្នាក់ទាបនិងថ្នាក់មធ្យម។ ការបន្សាគ្នាមិនត្រឹមត្រូវរវាងទិដ្ឋភាពការងាររយៈពេលវែងនិងការសិក្សា កំពងនៅកើតមានឡើង។ ដើម្បីឱ្យមានការរីកចម្រើននិងរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រូបនេះ ជាតិត្រូវការមុខជំនាញជាច្រើន ដូចជា អ្នកវិទ្យាសាស្ត្រ វិស្វករ អ្នកស្រាវជ្រាវ និងអ្នកឯកទេស នៅតាមផ្នែកនានានៃសេដ្ឋកិច្ច-សង្គមកិច្ច។ បញ្ហាប្រឈមនៅក្នុងវិស័យអប់រំ គឺត្រូវផ្តល់សេវាកម្មនានាសម្រាប់ការអប់ ចាំបាច់ប្រកបដោយគុណភាពខ្ពស់នៅក្នុងគ្រប់វិស័យ តាមរយៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេទេស និងការ អប់រំកម្រិតឧត្តមសិក្សា ហើយត្រូវមានសមត្ថភាពទាក់ទាញនិស្សិតឱ្យមកចូលរួមក្នុងវគ្គសិក្សាទាំងនេះ៖។ ចំពោះ បញ្ហានេះ តួនាទីរបស់ គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា គឺមានសារៈសំខាន់ក្នុងការវាយតម្លៃនិង ទទួលស្គាល់គុណភាពតែចំពោះមហាវិទ្យាល័យទាំងឡាយណា

ដែលមានលក្ខណៈវិនិច្ឆ័យផ្នែកគុណភាពជាអប្បបរមា និងមានសារៈសំខាន់សម្រាប់ការរៀបចំបង្កើតឡើង នូវ យុទ្ធសាស្ត្រអប់រំឧត្តមសិក្សាដ៏ទូលំទូលាយមួយ។

នៅក្នុងចំណោមអាទិភាពទាំងឡាយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០ និង គោល នយោបាយសំខាន់ៗ ការងារដែលត្រូវធ្វើ ជាអាទិ៍មាន

- ការធានាឱ្យមានលទ្ធភាពចូលរៀនប្រកបដោយភាពងាយស្រួលនិងសមធម៌ ជាពិសេស សម្រាប់អ្នកក្រ ក្មេងស្រី ជនជាតិភាគតិច និងកុមារក្រីក្រ ក៏ដូចជា ប្រជាជនរស់នៅក្នុងតំបន់ដែលអត្រាភាពក្រីក្រខ្ពស់។
- សកលកម្មនៃការអប់រំមូលដ្ឋាន ៩ឆ្នាំ និងលើកកម្ពស់កាលានុវត្តភាពជីវិតរស់នៅ។
- ការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាអប់រំ ដោយរាប់បញ្ចូលទាំង តាមរយៈការធ្វើ ទំនើបកម្ម និងកំណែទម្រង់ប្រកបដោយប្រសិទ្ធភាព។
- ការផ្សារភ្ជាប់ការអប់រំនិងការបណ្តុះបណ្តាលទៅនឹងទីផ្សារពលកម្មរយៈពេលវែងនិងមធ្យម និងទៅ នឹងសង្គម រួមបញ្ចូលទាំង ការអប់រំឱ្យមានជំនាញសម្រាប់ការរស់នៅនិងសុខភាពល្អ និងការអបរមេតា
- ការពារមេរោគហ៊ីវ /ជម្ងឺអេដស៍។
- ការអភិវឌ្ឍបន្ថែមទៀតក្នុងវិស័យយុវជននិងកីឡា ដោយបង្កើនការយកចិត្តទុកដាក់ចំពោះ យុវជនក្នុងគ្រប់មុខជំនាញ។
- ការអភិវឌ្ឍនិងការកសាងសមត្ថភាពស្ថាប័ន សម្រាប់ការងារវិមជ្ឈការ។

ក្នុងពេលថ្មីៗនេះ៖ វឌ្ឍនភាពសំខាន់ៗមួយចំនួនត្រូវបានធ្វើឱ្យសម្រេចឡើង ក្នុងការបង្កើនកម្រិត ចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ) បញ្ចប់ការសិក្សាជាមូលដ្ឋាន ៩ឆ្នាំ) ប៉ុន្តែទោះជា ដូចនេះក្តី គម្លាតធំចំពោះអ្នកក្រខ្លាំង និងនៅតំបន់ដាច់ស្រយាល នៅតែមាននៅឡើយ។ នៅពេលដែលកម្រិតនៃ បេននិងផលធៀបយេនឌ័រនៅកម្រិតបឋមសិក្សា អាចសម្រេចបាន ១០០ភាគរយ នៃ គោលដៅនៅមុនឆ្នាំ២០១៥កម្រិតនៃការចុះឈ្មោះចូលរៀន និងផលធៀបយេនឌ័រនៅកម្រិតបធ្យមសិក្សា និងមិនអាចសម្រេចបាន ១០០ភាគរយតាមចំណុចដៅ បើមិនមានការខិតខំប្រឹងប្រែងរួមគ្នានោះទេ។ គោលដៅសំខាន់ៗ ចំពោះ មុខរបស់វិស័យអប់រំរួមមានៈ

- ការកាត់បន្ថយចំងាយផ្លូវ ដែលកុមារធ្វើដំណើរពីផ្ទះមកកាន់សាលាបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ តាមរយៈការសាងសង់និងបើកសាលារៀននៅជិតភូមិដែលកុមាររស់នៅ ជាពិសេសនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- បង្កលក្ខណៈងាយស្រួល ដើម្បីឱ្យកុមារីបានចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិនិង កម្រិតសិក្សាខ្ពស់ជាង។

- កាត់បន្ថយការចំណាយរបស់ឪពុកម្តាយសិស្សក្នុងការចុះឈ្មោះចូលរៀន និងធានាឱ្យមានការចូលរៀននិងការសិក្សារបស់កុមារក្រីក្រ ហើយតាមរយៈនេះ៖ នឹងធានាឱ្យមានការកាត់បន្ថយកម្លាំងពលកម្មកុមារផងដែរ។
- បង្កើនគុណភាពអប់រំឱ្យដល់និងក្រោយកម្រិតអប់រំមូលដ្ឋាន _ រាប់បញ្ចូលទាំងការកែសម្រួលកម្មវិធីសិក្សានិងការដាក់បញ្ចូលស្តង់ដារអប្បបរមានៃលទ្ធផលនៃការសិក្សារបស់សិស្ស និងប្រព័ន្ធវាយតម្លៃការសិក្សា របស់សិស្ស សម្រាប់ថ្នាក់ទី៣ ថ្នាក់ទី៦ និងថ្នាក់ទី៩។ ការអភិវឌ្ឍគ្រូបង្រៀន និងការកំណត់ប៉ុស្តិ៍បំពេញការងារគ្រូ ការធានាគុណភាព និងប្រព័ន្ធវាយតម្លៃនិងទទួលស្គាល់គុណភាព។

ទន្ទឹមនឹងពេលដែលយុទ្ធសាស្ត្ររយៈពេលវែងមួយត្រូវបានរៀបចំឡើង ហើយការវិនិយោគត្រូវបន្តធ្វើ សម្រាប់វឌ្ឍនភាពនៅកម្រិតមធ្យមសិក្សា ឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងដំណាក់កាលជ័យអន គោលដៅនិងចំណុចដៅសំខាន់ៗ ជាអាទិ៍មាន: table4

យុទ្ធសាស្ត្រចំបង១និងសកម្មភាពសំខាន់ៗរបស់វិស័យអប់រំ ដើម្បីសម្រេចគោលដៅទាំងនេះ និងនៅ ផ្សេងៗទៀត រួមមាន:

- បង្កើនចំនួនកុមារថ្នាក់មត្តេយ្យសិក្សា ដែលចូលរៀនក្នុងកម្មវិធីអប់រំសម្រាប់កុមារតូច១ ដែលបានរៀបចំឡើងនៅក្នុងសាលា សហគមន៍ និងតាមផ្ទះ។
- បង្កើនចំនួនសាលាបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ ជាពិសេស នៅតំបន់ដាច់ស្រយាល និងតំបន់ដែលទទួលសេវាកម្មមិនគ្រប់គ្រាន់។
- បង្កើនចំនួនគ្រូបង្រៀន ទាំងគ្រូប្រុសនិងគ្រូស្រីនៅគ្រប់កម្រិតសិក្សាទាំងនោះ៖ ដើម្បីលើកកម្ពស់ផលធៀបសិស្ស-គ្រូ និងសមាមាត្របុគ្គលិកសិក្សាស្រី ជាពិសេស ការផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ការបំពេញ ការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។
- លើកកម្ពស់គុណភាពគ្រូបង្រៀន តាមរយៈការអភិវឌ្ឍមុខរបរវិជ្ជាជីវៈ ដែលផ្សារភ្ជាប់ទៅនឹងការផ្តល់
- ប្រាក់លើកទឹកចិត្ត សម្រាប់ការបំពេញការងារ។
- យកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើនប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន (បាននឹងកំពុងដំណើរការ) និងបើកប្រាក់បៀវត្សរ៍ឱ្យទាន់ពេលវេលា។
- ធានាគុណភាពអប់រំ តាមរយៈការកែលម្អការផ្តល់នូវសៀវភៅសិក្សា សម្ភារៈសិក្សា បរក្សា។ បណ្ណាល័យ និងបន្ទប់ពិសោធន៍។
- រៀបចំឱ្យមានស្តង់ដារគុណភាពសម្រាប់គ្រប់កម្រិត និងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិមួយសម្រាប។
- មូលដ្ឋាន។

- បង្កើនចំនួនអន្តេវាសិកដ្ឋានដែលមានសវត្តិភាពសម្រាប់សិស្សស្រីដែលមកពីតំបន់ឆ្ងាយៗ ដើម្បីមករៀន នៅសាលាមធ្យមសិក្សាបឋមភូមិដែលជិតបំផុត នៅលើមូលដ្ឋាននៃគម្រោងសាកល្បងជាគំរូ ដែលបាននិងកំពុងដំណើរការរួចហើយ។
- កាត់បន្ថយបន្ទុកចំណាយរបស់សិស្សក្រីក្រ ជាពិសេសសិស្សស្រី តាមរយៈការផ្តល់អាហារូបករណ៍ (នៅ បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា) និងការលុបបំបាត់ការបង់ប្រាក់ក្រៅ
- ផ្លូវការគ្រប់ប្រភេទទៅឱ្យគ្រូ។
- ពង្រីកនិងកំណត់មុខសញ្ញាឱ្យបានល្អជាងមុនសម្រាប់កម្មវិធីផ្តល់អាហារសម្រន់នៅបឋមសិក្សា និងកម្មវិធី លើកទឹកចិត្តសម្រាប់សិស្សថ្នាក់ទី៧ ដល់ទី៩។
- បន្តជានាឱ្យមានការវិភាជន៍ឱ្យបានគ្រប់គ្រាន់និងការផ្តល់ឱ្យបានទាន់ពេលវេលានូវថវិកាចរន្តសម្រាប់ វិស័យអប់រំ ជាពិសេស សម្រាប់ការអប់រំមូលដ្ឋាន។
- បង្កើននិងកែលម្អកម្មវិធីអក្ខរកម្មសម្រាប់ប្រជាជនពេញវ័យ ជាពិសេស សម្រាប់ស្ត្រី។

**សុខាភិបាល** : ការលើកកម្ពស់ស្ថានភាពសុខភាពរបស់ប្រជាជនគឺជាអាទិភាពមួយខ្ពស់បំផុត។ ការលើក កម្ពស់ស្ថានភាពអាហារូបត្ថម្ភ ក៏ដូចជា សុខភាពបន្តពូជ សុខភាពមាតានិងកុមារ ការលុបបំបាត់មូលហេតុបណ្តាល នៃជម្ងឺ ការចាត់វិធានការបង្ការ និងការផ្តល់ការព្យាបាលដែលចាំបាច់ គឺមានសារៈសំខាន់ ក្នុងការលើកកម្ពស់ស្ថាន ភាពសុខភាពនៃប្រជាជនជាទូទៅ ជាពិសេស ជនងាយរងគ្រោះដែលគ្មានមធ្យោបាយ ដើម្បីទទួលបានសេវាទាំងនោះ។ កត្តាអន្តរវិស័យនិងកត្តាផ្សេងទៀតជាច្រើនដែលប៉ះពាល់ដល់ស្ថានភាពសុខភាពរបស់ប្រជាជន មានជាអាទិ៍) ក (ភាពក្រីក្រជាមូលហេតុនិងបច្ច័យអាក្រក់នៃសុខភាពមិនល្អ) ខ (ការលំបាកផ្នែកហិរញ្ញវត្ថុរបស់អ្នកក្រ ដែលរារាំង មិនឱ្យពួកគាត់មានលទ្ធភាពទទួលសេវាសុខាភិបាលសាធារណៈ) គ (ការកែលម្អគុណភាពទឹកនិងសេវាអនាម័យ) ឃ (ការអប់រំប្រសើរជាងមុននិងកម្រិតអក្ខរកម្មខ្ពស់ជាងមុន ក៏ដូចជាលទ្ធភាពទទួលបានព័ត៌មាន និងការយល់ដឹងច្រើនជាងមុន )ង (សមធម៌យេនឌ័រ) ច (បណ្តាញសុវត្ថិភាពសង្គមសម្រាប់អ្នកក្រនិងអ្នកងាយរងគ្រោះ) ឆ (ការផ្តល់អាហារូបត្ថម្ភល្អជាងមុន តាមរយៈ ការធ្វើអន្តរាគមន៍សមស្រប។ ល។

ផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាលឆ្នាំ២០០៣-២០០៧ ដែលនឹងត្រូវបន្តរហូតដល់ឆ្នាំ២០១០ បន្ទាប់ពីការត្រួតពិនិត្យឡើងវិញនៅឆ្នាំ២០០៦) នៅពេលដែលមានទិន្នន័យការកែសម្រួលរួចតាមរយៈ អង្កេត ប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា (ផ្តល់នូវក្របខ័ណ្ឌសកម្មភាពដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចបាននូវ អាទិភាពនានាដែលក្នុងនោះរួមមាន) ក (ការផ្តល់សេវាសុខាភិបាល) ខ (ការផ្លាស់ប្តូរឥរិយាបទ) គ (ការកែលម្អគុណភាព) ឃ (ការអភិវឌ្ឍធនធានមនុស្ស) ង(ហិរញ្ញប្បទានសុខាភិបាល )ច (ការអភិវឌ្ឍស្ថាប័ន។ ផែនការ យុទ្ធសាស្ត្រសុខាភិបាល គឺជាក្របខ័ណ្ឌនៃការណែនាំតម្រង់ទិសសម្រាប់គ្រប់សកម្មភាពទាំងអស់ក្នុងវិស័យសុខាភិបាល ការរៀបរាប់ខាងក្រោមនេះ៖) រួមបញ្ចូលទាំងសូច

នាករនៅក្នុងតារាង ៤.៥ (គឺគ្រាន់តែ បង្ហាញបញ្ហាសំខាន់ៗមួយចំនួនតែប៉ុណ្ណោះ ពុំបានធ្វើការបញ្ជាក់លម្អិតនោះទេ។

សុខាភិបាល គឺជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំងបួនរបស់ កម្មវិធីសកម្មភាព ដែលធានាបាននូវការធ្វើវិភាជន៍និងការផ្តល់ថវិកាទាន់ពេលវេលាទាំងចំណាយចរន្តនិងមូលធន ដូចនេះក្តី នៅក្នុងការប្រើប្រាស់ថវិកាជាក់ស្តែងថ្នាក់ជាតិហាក់ដូចជាប្រើប្រាស់ចំណែកមួយធំជាងទៅ ..និងថ្នាក់ក្រោមបន្តបន្ទាប់។ ដោយសារអ្នកផ្តល់សេវាច្រើន ទាំងផ្នែករដ្ឋនិងទាំងផ្នែកឯកជន ហើយការ ដែលកើតមានដោយបុគ្គលម្នាក់ៗ ដែលពួកគេភាគច្រើនជាអ្នកក្រីក្របំផុត ធ្វើឱ្យមានការពិបាកណាស់ កែតម្រូវការប៉ាន់ប្រមាណចំណាយឱ្យបានត្រឹមត្រូវលើការថែទាំសុខភាពនៅកម្ពុជា ប៉ុន្តែផ្នែកលើមូលដ្ឋាន ចំនួនការចំណាយនៅតែមានកម្រិតទាបនៅឡើយ ប្រហែល ៣៣ដុល្លារអាមេរិកក្នុងប្រជាជនម្នាក់។ "មូលនិធិសមធម៌" ត្រូវបានចាប់ផ្តើមអនុវត្ត ដើម្បីបំពេញបន្ថែមពីលើប្រព័ន្ធមិនទូទាត់ថ្លៃព្យាបាលជម្ងឺដែលមានស្រាប់។ ដើម្បីកែលម្អលទ្ធភាពប្រើប្រាស់នូវប្រព័ន្ធថែទាំសុខភាព។ គម្រោងសាកល្បងចំនួន ១៧ កំពុងដំណើរការក្នុង ចំណោមខេត្ត-ក្រុងចំនួន ១៣ ហើយ មូលនិធិសមធម៌ នឹងត្រូវបង្កើនកម្រិត នៅក្នុងពេលដ៏ខ្លីខាងមុខ។ ទោះបីជា ដូចនេះក្តី វិធីសាស្រ្តជាច្រើនទៀតប្រកបដោយចីរភាពជាង សម្រាប់ជួយអ្នកក្រនៅក្នុងរយៈពេលវែង ត្រូវតែបានយក មកគិតគួរពិចារណា។ ដើម្បីឈានទៅសម្រេចបាននូវការកែលម្អគុណភាព ការការពារនិងការថែរក្សាសុខភាព គម្រោង សំណុំសកម្មភាពអប្បបរមា និង គម្រោងសំណុំសកម្មភាពបង្កប់ ត្រូវបាននិងកំពុងដាក់ឱ្យដំណើរការ។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន បាននឹងកំពុងអនុវត្តកិច្ចសន្យាគម្រោងសាកល្បងនៅក្នុងស្រុកប្រតិបត្តិចំនួន ១១ ដើម្បីធានាផ្តល់ឱ្យបានសមរម្យនូវការថែទាំសុខភាព ជាពិសេស នៅតំបន់អ្នកក្រីក្រនិងអ្នករស់នៅតំបន់ដាច់ស្រយាល ដើម្បីឱ្យបានដល់ដៃជនងាយរងគ្រោះនៅតំបន់នោះ។ គម្រោងទាំងអស់នេះ នឹងត្រូវពង្រីកទៅកាន់តំបន់ផ្សេងៗ ទៀត។ table5

## ១២.១១.សកម្មភាពនិងយុទ្ធសាស្រ្ត

សកម្មភាពនិងយុទ្ធសាស្រ្តជាអាទិភាព ដើម្បីអនុវត្តនៅក្នុងវិស័យសុខាភិបាល រួមមាន . :

- បង្កើនល្បឿនកំណែទម្រង់នៅគ្រប់ផ្នែកទាំងអស់។
- ព្យាយាមនិងសម្រេចការសម្របសម្រួលប្រសិទ្ធភាពចំណាយ ឱ្យបានប្រសើរនៅក្នុងកម្មវិធីត្រួតពិនិត្យ ជម្ងឺតាមរយៈខ្សែបណ្តោយនិងយន្តការបែងចែកសេវាសុខាភិបាល។
- លើសពីនេះទៀត ពង្រីកនិងពង្រឹងមូលនិធិសមធម៌សុខាភិបាល ដើម្បីជួយអ្នកក្រីក្រឱ្យអាចប្រើប្រាស់ សេវាសុខភាពសាធារណៈបានស្រាវជ្រាវដើម្បីស្វែងរកមធ្យោបាយនានាប្រកបដោយចីរភាពក្នុងការជួយ អ្នកក្រីក្រ ដើម្បីមានភាពងាយស្រួលក្នុងការទទួលបាននូវប្រព័ន្ធថែទាំសុខភាព ដោយមិនបាច់បង់ថ្លៃ ព្យាបាល ឬតាមរយៈនៃជំនួយរូបិយវត្ថុដែលមានគោលដៅច្បាស់លាស់។
- ជាទូទៅ ធ្វើសនិទានកម្មប្រព័ន្ធស្តារចំណាយឡើងវិញ ដើម្បីធានាឱ្យមានការអនុវត្តល្អប្រសើរបំផុត។

- ស្វែងរកវិធីនិងមធ្យោបាយនានា ដើម្បីកែលម្អឱ្យបានប្រសើរឡើងនូវហិរញ្ញប្បទានសម្រាប់មន្ទីរពេទ្យ។
- បង្កើនការជ្រើសរើសនិងការបណ្តុះបណ្តាលធ្ម និងជានាការបែងចែកពួកគេឱ្យទៅបម្រើការងារនៅតំបន់ដែលមានតម្រូវការ។
- បង្កើនសមាមាត្រនៃការសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលមានជំនាញ និងលើកកម្ពស់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្រាលកូនដោយការវះកាត់។
- កែលម្អសុខភាពកុមារ តាមរយៈការគ្របដណ្តប់ជាទូទៅ នៃអន្តរាគមន៍របស់កម្មវិធី ប័ណ្ណពិនសម្រាប់ ការគង់វង្សនៃកុមារ រួមបញ្ចូលទាំង អន្តរាគមន៍ផ្នែកអាហារូបត្ថម្ភ និងកម្មវិធី ការគ្រប់គ្រងចម្រើននៃ ជម្ងឺរ៉ៃកុមារ។
- កែលម្អសេវានិងព័ត៌មានពីសុខភាពបន្តពូជ រួមទាំងការពន្យារកំណើត និងដោះស្រាយបញ្ហានិងសេវា
- សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ របស់យុវជន។
- ពិនិត្យស្វែងរកលទ្ធភាពក្នុងការពង្រីកកម្មវិធីអ្នកស្ម័គ្រចិត្តតាមភូមិដែលមានបច្ចុប្បន្នសម្រាប់ការថែទាំសុខភាពទាក់ទងនឹងជម្ងឺគ្រុនចាញ់ ដើម្បីផ្តល់ការការពារនិងថែរក្សាសុខភាព តាមរយៈបុគ្គលិកសុខាភិបាលតាមភូមិដែលមានតម្លៃពលកម្មទាប ដែលត្រូវបានជ្រើសរើសដោយសហគមន៍ និងចែករំលែក ចំណេះដឹងអប្បបរមាស្តីពីការថែទាំសុខភាព។
- សាងសង់ឬស្តារឡើងវិញ និងកែសម្រួលមណ្ឌលសុខភាពបន្ថែមទៀត ( ថ្នាក់ស្រុកនិងឃុំ) និងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ជាពិសេស នៅតំបន់ក្រីក្របំផុត។
- លើកកម្ពស់ការអប់រំ និងសេវាសង្គ្រោះបន្ទាន់។
- ពង្រឹងជាការអនុវត្តបទបញ្ញត្តិនិងច្បាប់សុខាភិបាល ដែលទាក់ទងនឹងវេជ្ជសាស្ត្រនិងឱសថព្រមទាំងសុវត្ថិភាពចំណីអាហារផងដែរ។
- ជានាផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់វិស័យសុខាភិបាល។
- បង្កលក្ខណៈងាយស្រួលនិងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ក្នុងការថែទាំងនៅទីប្រជុំជន និងទាំងនៅទីជនបទ។

**មេរោគហ៊ីវ/ជម្ងឺអេដស៍** : ការការពារ ការព្យាបាល ការថែទាំ និងការខិតខំកាត់បនេះ មេរោគហ៊ីវ/ ជម្ងឺអេដស៍ គឺជាកត្តាសំខាន់រួមចំណែកដល់គោលដៅរួមនៃ ផយអជ ក្នុងការការ និងកំណើនសេដ្ឋកិច្ច។ កិច្ចប្រឹងប្រែងរួមគ្នា បានធ្វើឱ្យមានការថយចុះប្រេវ៉ាឡង់បន្ទាប់ពីមានការ ចាប់តាំងពីឆ្នាំ១៩៩៧ ការពង្រីកសេវាកម្មយ៉ាងឆាប់រហ័សសម្រាប់ប្រជាជនដែលមានផ្ទុកមេរោគ បន្តការថែទាំ បង្កើនកម្រិតយល់ដឹងអំពីមេរោគហ៊ីវដល់ប្រជាជនទាំងអស់ និងការផ្លាស់ប្តូរបរិយាកា នយោបាយ ដូចជា ការអនុម័តិច្បាប់ស្តីពីការការពារ និងការត្រួតពិនិត្យមេរោគហ៊ីវ/ ជម្ងឺអេដស៍។ ការប្រែប្រួលនៃជម្ងឺរាតត្បាត ប្រមូលផ្តុំលើក្រុមដែលមានហានិ

ភ័យខ្ពស់ ដែលរាលដាលក្នុងចំណោមប្រជាជន ១ ចាំបាច់ត្រូវពង្រឹងបន្ថែមទៀតនូវការទទួលខុសត្រូវនៅថ្នាក់ជាតិចំពោះមេរោគហ៊ីវ/ ជម្ងឺអេដស៍។ រាជរដ្ឋាន កម្ពុជា ប្តេជ្ញាដើម្បីធ្វើការឆ្លើយតបទៅនឹងបញ្ហាពហុវិស័យ ដែលបានណែនាំតាមរយៈ ផយអជ សម្រាប់ ឆ្លើយតបយ៉ាងទូលំទូលាយលើមេរោគហ៊ីវ/ជម្ងឺអេដស៍ ឆ្នាំ ២០០៦-២០១០ ជាមួយនឹងការឆ្លើយតបយ៉ាងខ្លាំងកា តាមលក្ខណៈវិមជ្ឈការ។ អាទិភាពសំខាន់ៗ រួមមានៈ

- ជំរុញកម្មវិធីលើកទឹកចិត្តឱ្យបានទូលំទូលាយ ចំពោះបុរស ស្ត្រីក្នុងការប្រើប្រាស់ស្រោមអនាម័យ និងជំរុញសកម្មភាពប្រើប្រាស់ស្រោមអនាម័យសម្រាប់ប្រជាជនទូទៅ ដែលធ្វើសកម្មភាពផ្លូវភេទរួមមាន ស្ត្រី មនុស្សពេញវ័យ និងយុវវ័យ។
- ទប់ស្កាត់ការឆ្លងនៃមេរោគហ៊ីវ ជំងឺអេដស៍ទៅលើគ្រួសារ តាមរយៈកម្មវិធីព័ត៌មាន ការអប់រំ ការប្រាស្រ័យទាក់ទង និងការពិគ្រោះយោបល់ជាលក្ខណៈបុគ្គល។
- បង្កើននិងកែលម្អសេវាគាំទ្រ និងសេវាថៃទាំសុខភាព ដែលមានផលប៉ះពាល់ដោយមេរោគហ៊ីវ ជម្ងឺអេដស៍។

**សមភាពយេនឌ័រ** ៖ រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកស្ត្រីមានតួនាទីសំខាន់នៅក្នុងសេដ្ឋកិច្ច និងសង្គមក។ ផែនការយុទ្ធសាស្ត្រសម្រាប់ស្ត្រី "នារីរតនៈ ឬ ស្ត្រីគឺជាត្បូងមានតម្លៃ" នឹងបន្តនូវភាពខ្លាំងក្លាក្នុងគោលប ផ្តល់ជូនស្ត្រីកម្ពុជានូវតម្លៃនិងក្តីសង្ឃឹមក្នុងជីវិត តាមរយៈ ការបញ្ជ្រាបយេនឌ័រនៅគ្រប់សកម្មភាពទាំង រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពខ្ពស់លើការលើកទឹកចិត្ត និងការលើកកម្ពស់ស្ថានភាពសង្គមរបប ដោយផ្តោតការយកចិត្តទុកដាក់លើការអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ការកសាងសមត្ថភាពស្ត្រីលើគ្រប់វិស័យការផ្លាស់ប្តូរឥរិយាបទសង្គមដែលមានការរើសអើងប្រឆាំងនឹងស្ត្រី និងការធានានូវសិទ្ធិរបស់ស្រីឱ្យមលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងការកសាងប្រទេសជាតិ។

បញ្ហាសំខាន់បំផុតដើម្បីកាត់បន្ថយភាពក្រីក្រគឺការលុបបំបាត់យ៉ាងឆាប់នូវរាល់ឧបសគ្គចំពោះមុខ និងដែលជាប់ពាក់ព័ន្ធវិសមភាពយេនឌ័រ ដូចជា វិសមភាពក្នុងការទទួលបានការអប់រំ ថ្លៃឈ្នួលការងារភាពជា «សិទឹកងការកាន់កាប់ដីធ្លី ការថែរក្សាសុខភាពបន្តពូជរបស់ពួកគេ ភាពងាយទទួលរងគ្រោះដោយសារ រោគហ៊ីវ ជម្ងឺអេដស៍ និងការជួញដូរស្ត្រី និងការធ្វើការងារដែលមិនទទួលបានផលប្រយោជន៍ជាទូទៅ ទាំងក្នុង គេសារនិងសង្គម នៅពេលជាមួយគ្នានេះដែរ ការទទួលបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការចិញ្ចឹមបីបាច់គ្រួសារ។ ខណៈពេល ដែលស្ត្រីជាច្រើនជាកម្លាំងពលកម្មនៅក្នុងវិស័យឧស្សាហកម្ម ដោយសារបច្ចុប្បន្នវិស័យកាត់ដេររីកចម្រើនយ៉ាង ឆាប់រហ័ស ទោះបីជាស្ត្រីដ៏ច្រើនលើសលប់ជាកម្លាំងពលកម្មដែលមានកម្រិតទាប ក៏តំណាងរបស់ស្ត្រីនៅក្នុងកម្រិត អ្នកតាក់តែងគោលនយោបាយនិងការធ្វើសេចក្តីសម្រេចចិត្ត រួមមានរដ្ឋសភាជាតិ និងស្ថាប័នប្រជាធិបតេយ្យ ផ្សេងៗ មន្ត្រីរាជការ និងផ្នែកផ្សេងៗទៀតនៅមានកម្រិតទាបនៅឡើយ ហើយត្រូវទាមទារធ្វើការកែលម្អដោយ យកចិត្តទុកដាក់។ ៤.៩៩ ដោយសារយេនឌ័រជាបញ្ហាអន្តរវិស័យ និងជាការទទួលខុសត្រូវរបស់គ្រប់ស្ថាបន៍ទាំងអស់ បញ្ហានិង យុទ្ធសាស្ត្រដើម្បីដោះស្រាយ

វិសមភាពយេនឌ័រត្រូវបានបង្ហាញ រួចមកហើយនៅក្នុងវិស័យផ្សេងៗដូចជា កសិកម្ម ការងារ អប់រំ សុខាភិបាល និងផ្នែកផ្សេងៗទៀតនៅផ្នែកខាងដើមនៃជំពូកនេះ។ ចំនួនដ៏ច្រើននិងទិដ្ឋភាពផ្សេងៗការបញ្ជ្រាបយេនឌ័រនៅក្នុងប្រទេស ត្រូវមានការចូលរួមយ៉ាងខ្លាំងក្លា។ នៅថ្នាក់ជាតិ ក៏ដូចជាថ្នាក់ក្រោម ជាតិ និងការចូលរួមនៅថ្នាក់មូលដ្ឋាន គឺផ្តោតទៅលើ:

- ការប្តេជ្ញាចិត្តកសាងសមត្ថភាពនៅគ្រប់កម្រិតទាំងអស់ រួមមាន ទាំងអ្នកធ្វើគោលនយោបាយ និងកម្មវិធី នានា ដែលទាក់ទងនឹងយេនឌ័រ និងការបញ្ជ្រាបយេនឌ័រ។
- ជំរុញការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី។
- លើកកម្ពស់ការការពារខាងផ្លូវច្បាប់ចំពោះស្ត្រី។

ផយអជ នឹងផ្តោតលើផ្នែកសំខាន់ៗមួយចំនួន តាមរយៈការផ្សព្វផ្សាយតាមរយៈការផ្សព្វផ្សាយចំណេះដឹង និងសកម្មភាពសំខាន់នានា រួមមាន:

- បញ្ជ្រាបយេនឌ័រទៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជាទាំងមូល រួមមាន នៅក្នុង ថ្នាក់រដ្ឋាភិបាលទាំងអស់និងនៅក្នុងដំណើរការផ្តល់ថវិកា។
- ណែនាំ ដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី (តាមរយៈការលុបបំបាត់អំពើពុករលួយនិងការពង្រឹងច្បាប់ឱ្យបានម៉ឺងម៉ាត់) និងទំនៀមទំលាប់វប្បធម៌ ដែលទ្រទ្រង់ វិសមភាពយេនឌ័រនៅក្នុងគ្រួសារ និងសង្គម។
- បង្កើនលទ្ធភាពរបស់ស្ត្រីក្នុងការទទួលបានផលិតភាពទ្រព្យសកម្មដូចជា មូលធនហិរញ្ញវត្ថុ ការកាត់ បន្ថយការរើសអើងដែលទាក់ទងនឹងយេនឌ័រនៅលើទីផ្សារពលកម្ម និងផ្តល់បរិយាកាសដ៏ល្អប្រសើរដើរ ឱ្យស្ត្រីអាចចូលរួមបានច្រើនជាងមុននៅក្នុងការងារដែលមានគុណភាពខ្ពស់។
- ដោះស្រាយបញ្ហាផ្សេងៗដូចជាការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងរចនាសម្ពន្ធ័នៃសេចក្តីសម្រេច នានា ទាំងក្នុងនិងក្រៅផ្លូវការ ជំរុញឱ្យស្ត្រីទទួលបាននូវកម្រិតឋានៈនិងតួនាទីខ្ពស់នៅក្នុងរដ្ឋបាលសាធារណៈ តាមរយៈគោលនយោបាយនិងច្បាប់។ បង្កើនល្បឿននិងជំរុញឱ្យមានការអនុវត្តច្បាប់រដ្ឋប្បវេណីឱ្យបាន ម៉ឺងម៉ាត់ក្នុងការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ជំរុញឱ្យមានការអនុម័តច្បាប់ជួញដូរមនុស្ស និងការ អនុវត្តផែនការសកម្មភាពជាតិ ដើម្បីការពារជនរងគ្រោះដោយអំពើហិង្សា។

គោលនយោបាយប្រជាជន : គោលនយោបាយនេះក៏ជាបញ្ហាអន្តរវិស័យមួយយ៉ាងទូលំទូលាយដែលមាន ការពាក់ព័ន្ធនឹងវិស័យផ្សេងៗទៀតជាច្រើន ដូចជា សុខាភិបាល អប់រំ បរិស្ថាន ម៉ាក្រូសេដ្ឋកិច្ច សមភាពយេនឌ័រ បញ្ហាគ្រឿងញៀន និងវិស័យផ្សេងៗទៀត។ បច្ចុប្បន្នអត្រាកំណើនប្រជាជនប្រចាំឆ្នាំគឺ ១,៨ភាគរយ ជាបន្ទុកដ៏ ធ្ងន់ធ្ងរមួយទៅលើសេវាសាធារណៈនិងធនធាន និងជាកត្តាមួយរួមចំណែកឱ្យកើតមានភាពក្រីក្រ។ ដំណោះ៖ ស្រាយជាអាទិភាពរួមមាន:

- គាំទ្រដល់គូស្វាមីភរិយានិងបុគ្គលម្នាក់ៗឱ្យធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវលើ ចំនួនកូន និងការពន្យារកំណើត ហើយឱ្យទទួលបាននូវ ព័ត៌មាន ការអប់រំ សេវាកម្មនានា និងមធ្យោបាយដើម្បីអនុវត្តការសម្រេចចិត្តខាងលើ។
- កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃការផ្លាស់ប្តូរទីលំនៅ ទៅលើទីប្រជុំជននិងជនបទ។
- បញ្ចូលអថេរប្រជាជន រួមទាំង បញ្ហាមនុស្សចាស់និងការផ្លាស់ទីលំនៅ ទៅក្នុងគោលនយោបាយ សេដ្ឋកិច្ចនិងសង្គមកិច្ច នៅគ្រប់កម្រិតទាំងអស់នៃផែនការ និងកម្មវិធីនានា។

ចំណាយ ធនធាន និងការរៀបចំកម្មវិធី : ការសម្រេចបាននូវគោលដៅនិងចំណុចដៅទាំងអស់នៅក្នុងកំឡុងពេលអនុវត្ត ផយអជ ២០០៦-២០១០ នឹងពាក់ព័ន្ធទៅនឹងចំនួនដ៏ច្រើននៃធនធានហិរញ្ញវត្ថុ " បច្ចេកទេស ទាំងផ្នែកសាធារណៈនិងទាំងផ្នែកឯកជន។ ការលើកឡើងនៅក្នុងជំពូកបន្ទាប់) ជទូក។ មួយចំនួនធនធានដែលអាចរកបាននិងការរៀបចំកម្មវិធីកៀរគរជំនួយ តាមរយៈកម្មវិធីវិនិយោគសាធារណៈ និងថវិកាប្រចាំឆ្នាំ។

## ១២.១២.ទិសាគគោលនយោបាយកសិកម្ម




ក្រាភិច ១២.១

## ១២.១៣.គ្រោះថ្នាក់នៃការផ្លាស់ប្តូរតម្លៃនៅក្នុងទីផ្សារ

ប្រសិនបើតម្លៃនៅលើទីផ្សារត្រូវបានដាក់បញ្ចូលដូចជាកំនើនប្រាក់ឈ្នួលតើនេះគឺជាលទ្ធផលដែលធ្វើឱ្យថ្លៃលក់រាយ ហើយវាជាផលិតផលរបស់កសិដ្ឋាន ?ជាទូទៅចំលើយទាំងពីរគឺថាកសិដ្ឋានហើយនឹងការលក់រាយវាប៉ះពាល់ដល់ទំហំផលធៀបអាស្រ័យលើចំណោតមេគុណពិតប្រាកនៃតម្រូវការនឹងបំពេញមុខតម្លៃផ្គត់ផ្គង។ សម្រាប់ភាពសាមញ្ញយើងត្រូវគិតថាទី១ វាខ្ចីតាំងនៅផ្លូវទាបបរិយាយក្នុងរូប ១២២.។ ក្នុងនេះគឺកញ្ចប់ទំនិញកំណត់បរិមាណផ្គត់ផ្គង់ )Qគឺថេរជាមុខងារនៃការលក់( រាយ។ កំនើននៅក្នុងទីផ្សារកញ្ចប់ទំនិញនិងមូលហេតុនៅក្នុងកសិដ្ឋានទទួលបានមកពីតម្រូវការពីការ ផ្លាស់ប្តូរមិនទានគេ។ ដូចនេះគឺផ្តលសិទ្ធិនៅក្នុងផ្លូវទាបបំផុតនៃកម្រិតខុសគ្នា គឺបង្ហាញនូវការបញ្ចុះ ថ្លៃកសិដ្ឋានវាមិនប៉ះពាល់ទៅនឹងការលក់រាយទេ។

ជាមួយនៃការអនុម័តនៃពេលវាលាទោះជាយ៉ាងដូចនេះក្តីតម្លៃកសិដ្ឋាននឹងបន្តយការវាយតម្លៃ ជាបរិមាណផ្គត់ផ្គង់ការផ្គត់ផ្គង់ទាបបន្ទាត់កោងបានទ្រេតវិជ្ជមាន។ ការផ្គត់ផ្គង់តិចតួចនិងមាន កំនើនកសិដ្ឋាននិងការលក់រាយ។ ដូចនេះជាចុងក្រោយការលក់រាយនិង កែសម្រួលឡើងវិញ។ ដំបូងកំនើននៅក្នុងតម្លៃនៃទីផ្សារផលិតផលនិងធ្វើឱ្យកើតមានឡើងជាប់នៅការប្រគួតប្រជែថា លទ្ធផលនៅក្នុងការបញ្ចុះតម្លៃកសិដ្ឋាននិងតម្លៃលក់រាយខ្ពស់។ នេះគឺជាការបរិយាយដែលគេមិន ទានបានផ្លាស់ប្តូរក្នុងការទទួលបានមកពីការផ្គត់ផ្គង់ហើយមុខងារតម្រូវការខណៈពេលដែលទទួលយក សំខាន់ការផ្គត់ផ្គត់និងមុខងារតម្រូវការគឺមិនផ្លាស់ប្តូល។




ក្រាភិច ១២. ២

Figure ១២២. ជួយដល់ការនឹកគិតក្នុងចិត្តថាទ្រទ្រង់ខុសពីគេបើការផ្គត់ផ្គង់និងតម្រូវការតែងតែទទួលផលខុសគ្នាក្នុងការកើតមានឡើងនៃកសិដ្ឋាននឹងតម្លៃលក់រាយ។ គុណសម្បត្តិនៃការវែក ញែកខាងមុខ។ ទីមួយគឺផ្លាស់ប្តូរតម្លៃនៃការផ្តល់ឱ្យមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់។ យើងអាចដដែកគ្នាពីការផ្លាស់ប្តូរតម្លៃក្នុងសហការីជាមួយនិងអត្តប្រយោជន៍ថ្មី។ បើការផ្លាស់ប្តូរ ពេលនេះគួរតែបរិយាពីមុខងារតម្រូវការចំៗពីផលិតផល។

ការវែកញែកទីពីរបង្ហាញនៅក្នុងFigure6-3គឺឧទាហរណ៏នៃលំនឹងទ្រឹស្តីហើយលំនឹងស្ថាន ការណ៏តែមួយសំរាបផលិតផលគឺបង្ហាញពីការផ្លាស់ប្តូរកត្តាទាំងអស់ចំណាប់ឥតឈប់ឈរ។ ទោះបីមានប្រយោជន៏សម្រាប់ការពន្យល់ជាទូទៅធម្មជាតិនៃការផ្លាស់ប្តូរក្នុងកម្រិតខុសគ្នាទៅលើកសិដ្ឋានហើយនិងតម្លៃលក់រាយវាអាចនាំឱ្យយល់ខុសពោលអនុវត្តតែងតែពិតគ្រប់ស្ថានភាពកត្តាទាំងនោះគឺឥតឈប់ឈរ។ សម្រាប់ឧទាហរណ៏តូចតម្លៃសម្រាប់ផ្លែប៉ោមមួយផ្លែនៅក្នុងWashington Stateតែងតែទទួលលទ្ធលខ្ពស់សម្រាប់Washingtonហើយធ្វើឱ្យថោកនៅតម្លៃលក់រាយសម្រាប់អតិថិជន។ យ៉ាងណាក៏ដោយការវែកញែកនេះតែងតែមិនពេញលេញវាយកបញ្ជីប្រាក់ចេញពីន្លោះ ការដាំដុះហើយការលូតលាស់របស់ថ្លៃប៉ោម។

ដើឱ្យតម្លៃលក់រាយសម្រាប់ផ្លែប៉ោមនឹងលទ្ធផលថយចុះតម្លៃសម្រាប់ជំនួស។ អញ្ចឹងប្រព័ន្ធដែលជះឥទ្ធិពលទៅលើតម្លៃប៉ុន្តែវាមិនធំទេនៅពេលដែលឥទ្ធិពលទីពីរដែលយកមកពិនិត្យ។

នៅខាងមុខគេតែងតែមានគំនិតវិភាគដែរសន្មតថាការផ្លាស់ប្តូរតម្លៃប្រព័ន្ធភ្លាមៗទាំងអស់ប៉ុន្តែនេះគឺមិនមែនជាហេតុផលទេ។

## ការផ្ទេរតម្លៃ

ពត៌មានថ្មីថាឥទ្ធិពលតម្លៃអាចបង្កើតបានសម្រាប់អ្នកប្រើប្រាស់ផ្លាស់ប្តូរក្នុងតម្រូវការខាងដើម (ផ្លាស់ប្តូរទំនាក់ទំនងទីផ្សារនាំចូល)ឬសម្រាប់ផ្នែកទីផ្សារ(ផ្លាស់ប្តូរក្នុងការផ្គត់ផ្គង់)សម្រាប់ថ្នាក់កសិដ្ឋាន។ ដែលចូលចិត្តប្រគួតក្នុងទីផ្សារយ៉ាងសុក្រិតតម្លៃតែងតែផ្លាស់ប្តូរភ្លាមៗ ហើយពិនិត្យពីពត៌មានថ្មី ប៉ុន្តែបើតាមការពិតទីផ្សារគឺមិនសុក្រិត។

ប្រធាននៃថ្លៃត្រូវបានប្រគល់ឱ្យធ្វើជាមួយប្រភេទនៃថ្លៃកែប្រែឱ្យសមរម្យក្នុងប្រព័ន្ធនៃ ទីផ្សារ។ ទីផ្សារវិគាគថាគួរឱ្យចាប់អារម្មណ៍ដូចគ្នានិងសំនួរដែលសួរបន្តបន្ទាប់ តើធ្វើដូចម្តេច ឱ្យតម្លៃសមរម្យ ?

គេច្រើនវិភាគសំអាងទៅលើការពិសោធន៍ហើយបានប្រមូលផ្តុំលើ ទំនាកទំនងចន្លោះកសិដ្ឋាននិងតម្លៃលក់រាយ។ ការវិភាគទាំងឡាយនេះគឺលំអៀងតំបូងគឺសមហេតុផលធម្មតាការរត់មកផ្លាស់ប្តូរ នៅក្នុងតម្លៃកសិដ្ឋានទៅផ្លាស់ប្តូរក្នុងតម្លៃលក់រាយ។ វាគឺចម្លែកស្វែរកតម្លៃការលក់នៅសល់មួយ ដែលកើតឡើងណាលគ្នា។ ក្រោយពេលពីរខែក្នុងរយះពេលស្មើគ្នាដែលអាចខូចរលួយដូច ដឹកដោះគោសាច់និងផ្លែឈើ

ស្រស់ហើយនិងបន្លែ។ តម្លៃលក់រាយមួយភាគបីហាក់ដូចជាធ្លើតបជាមួយការថ្លឹងថ្លែងខុសប្លែពី គ្នាពីការបង្កើតតម្លៃក្នុង កសិដ្ឋានភ្ជាប់ពីចំនួនចុះអន់ថយក្នុងតម្លៃកសិដ្ឋាន។

សិក្សាពីតម្រូវការខាងដើមក្នុងលេខ6-1គឺយើងប្រើចំនុចនៃការចាកចេញ។ នៅក្នុងគម្រូដើមនេះ គឺគេទុកចិត្តលើតម្លៃទីផ្សារការនាំចូលនិងបរិមាណនៅលើទីផ្សារជាទូទៅប្រសិនបើតម្លៃខុសគ្នានៅលើទីផ្សារ) (ត្រូវផ្លាស់ប្តូរជាមួយបរិមាណនៅលើទីផ្សារ។ ចាប់តាំងពីមានសម្ថភាពចែកចាយតម្លៃលក់ រាយលើសពីថ្លៃកសិដ្ឋានចំនុចដែលអាចលក់រាយគឺមុខងារនៃតម្លៃកសិដ្ឋានបរិមាណដែលនាំចូលមក ក្នុងទីផ្សារ។

# បណ្ណាល័យសាស្ត្រ )Bibliography(

**ជាភាសាជាតិ៖**


ឆាយ គង្គា ២០០១ *ការព្យាករណ៍តម្រូវការ ផ្គត់ផ្គង់ និងយុទ្ធសាស្ត្រនៃការជំរុញវិស័យដំណាំស្រូវនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាលាក្រោយឧត្តម សាកលវិទ្យាល័យជាតិធុនណាំ ពោងពុម្ពទស្សនាវដ្ដីវិទ្យាសាស្ត្រកសិកម្មខាងជូ ទីក្រុងខាងជូ សាធារណៈរដ្ឋកូរ៉េ ប្រទេសកូរ៉េខាង )ត្បូង( (ភាសាអង់គ្លេស)

ឆាយ គង្គា ២០០២ *ស្ថានភាពបច្ចុប្បន្ននៃទីផ្សារដំណាំស្រូវនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សាលាក្រោយឧត្តម សាកលវិទ្យាល័យជាតិធុនណាំ សាធារណៈរដ្ឋកូរ៉េ ពោងពុម្ពទស្សនាវដ្ដីវិទ្យាសាស្ត្រធុនណាំ ទីក្រុងខាងជូ ប្រទេសកូរ៉េខាង) (ភាសាអង់គ្លេស) (ត្បូង

ឆាយ គង្គា ២០០៤ *ទីផ្សារនៃផលិតផលកសិកម្មនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត ពោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ ទីក្រុងខាងជូ សាធារណៈរដ្ឋកូរ៉េ(ភាសាអង់គ្លេស)(ប្រទេសកូរ៉េខាងត្បូង)

ឆាយ គង្គា ២០០៥ *ការវិភាគថ្លៃនៃផលិតផលកសិកម្មនៅកម្ពុជា* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត ពោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ រដ្ឋធានីសេអ៊ូល សាធារណៈរដ្ឋកូរ៉េ(ភាសាអង់គ្លេស)(ប្រទេសកូរ៉េខាងត្បូង)

ឆាយ គង្គា ២០០៥ *មីក្រូសេដ្ឋកិច្ច ភាគ១ បោះពុម្ពលើកទី ៧ សាកលវិទ្យាល័យបៀលប្រាយ*

ឆាយ គង្គា ២០០៥*ពាណិជ្ជកម្មគ្រាប់ធញ្ញជាតិក្រោមគោលនយោបាយអង្គការពាណិជ្ជកម្មពិភពលោក* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត ពោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិ ទីក្រុងខាងជូ សាធារណៈរដ្ឋកូរ៉េ (ប្រទេសកូរ៉េខាងត្បូង) ភាសា) (អង់គ្លេស

ឆាយ គង្គា ២០០៦ *ការព្យាករណ៍ការផ្គត់ផ្គង់ដំណាំស្រូវ* អត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រ សម្រាប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត ពោងពុម្ពទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្មអន្តរជាតិសង្គមកូរ៉េ រដ្ឋធានីសេអ៊ូល សាធារណៈរដ្ឋកូរ៉េ (ប្រទេសកូរ៉េខាងត្បូង) (ភាសាអង់គ្លេស)

ឆាយ គង្គា ២០០៦ *ប្រវត្តិនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា* បោះពុម្ពលើកទី១ រោងពុម្ព មហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម (ភាសាខ្មែរ)

ឈាង នរិន្ទ ២០២០ *ប្រសិទ្ធភាពសេដ្ឋកិច្ចដំណាំស្រូវនៅកម្ពុជា៖ករណីសិក្សាខេត្តបាត់ដំបង តាកែវ ស្វាយរៀង* និក្ខេបបទបញ្ចប់កាសិក្សាកម្រិតថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ ព្រះរាជាណាចក្រកម្ពុជា

ឌុយ ចាន់ឌីណា ១៩៩៤ *សេដ្ឋកិច្ចអភិវឌ្ឍន៍* វិទ្យាស្ថានវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រះរាជាណាចក្រកម្ពុជា

វង្ស ឌីណា ២០១៧ *ការគ្រប់គ្រង និងការប្រមូលពន្ធលើប្រាក់ចំណេញរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦* និក្ខេបបទបញ្ចប់ការសិក្សាកម្រិតថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ

វ៉ាន់ ប៊ុនថេត ១៩៩៥ *សេដ្ឋកិច្ចកម្ពុជា* សាលាភូមិន្ទរដ្ឋបាល ព្រះរាជាណាចក្រកម្ពុជា

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ព្រះរាជាណាចក្រកម្ពុជា

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ *សៀវភៅកម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ២០១៨* រោងពុម្ព

សីន សុទ្ធ ២០២០ *ស្ថិរភាពសេដ្ឋកិច្ចកម្ពុជាតាមរយៈការគ្រប់គ្រងចំណូល និងចំណាយសាធារណៈ* និក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សាកលវិទ្យាល័យខេមរៈ

## ជាភាសាបរទេស៖

Alain de Janvry, Elisabeth Sadoulet, 2006, *Development Economics: Theory and Practice,* Routledge, Taylors & Francis Group.

Bishop C.E., and W. D. Toussaint, *Introduction to Agricultural Economic Analysis*, 2nd Edition, John Wiley & Sons, Inc., 1962.

CHHAY Kongkea, 2003, *Rice-Supply-Demand and Improvement Strategy on Rice Industry in Cambodia*, Thesis Presented for the Master's Degree, Department of Agricultural Economics, Graduate School, Chonnam National University, Gwangjy 500-757, Gwangju City, Republic of Korea (South Korea).

CHHAY Kongkea, 2006, *Agricultural Development Strategy in Cambodia*, Dissertation Presented for the Ph.D. Degree, Department of Agricultural Economics, Graduate School, Chonnam National University, Gwangjy 500-757, Gwangju City, Republic of Korea (South Korea).

David Colman and Trevor Young, 1997, *Principle of Agricultural Economics: Market and Prices in Less Developed Countries*, Cambridge University Press.

Debertin David L., 2012, *Agricultural Production Economics*, 2nd Edition, Macmillan Publishing Company, a division of Macmillan Inc.

Don Bellante and Mark Jackson, 1983, *Labor Economics Choice in Labor Markets*, 2nd Edition, McGraw-Hill Book Company.

Drummond H. Evan, and John W. Goodwin, 2004, *Agricultural Economics*, 2nd Edition, Prentice Hall, Inc.

Dwight H. Perkins, Steven Radelet, David L. Lindauer, Steven A. Block, 2015, *Economics of Develoment*, 7th Edition, W.W. Norton & Compsny, Inc.

Dwight H. Perkins, Steven Radelet, Donalet R. Snodgrass, Malcom Gillis and Michael Roemer, 2001, *Economics of Develoment*, 5th Edition, W.W. Norton & Compsny, Inc.

F. Bailey Norwood and Jayson L. Lusk, *Agricultural Marketing and Price Analysis*, Pearson Prentice Hall, Pearson Education, Inc., 2008.

Fajardo Feliciano R., 1990, *Agricultural Economics*, 4th Edition, Rex Printing Company, Inc., Manila, Phnilippines.

Fred C. Armstrong, 1986, *The Business of Economics*, West Publishing Company.

Freddies Barnard, Jay Akridge, Frank Dooley, and John Foltz, *Agribusiness Management*, 4th Edition, Routledge, 2012.

Gail L. Cramer and Clearence W. Jensen, 1994, *Agricultural Economics and Agribusiness*, 6th Edition, John Wiley & Sons, Inc.

Joseph A. Schumpeter, 1983, *The Theory of Economic Development*, John E. Elliott, Transaction Publishers. New Brunswick, New Jersey.

Julie Schaffner, 2014, *Development Economics; Theory, Empirical Research, and Policy Analysis*, John Wiley & Sons, Inc.

M. L. Jhingan, 2011, *The Economics of Development and Planning*, 40th Edition, Vrinda Publications(P), LTD.

Mans Soderbom, Francis Teal, Markus Eberhardt, Simon Quinn, Andrew Zeitlin, 2015, *Emperical Development Economics*, Routled, Taylors & Francis, London & New York.

Michael P. Tadaro and Stephen C. Smith, 2015, *Economics Development*, 12th edition, Pearson.

Norton George W., and Jeffrey Alwang, 1993, *Introduction to Economics of Agricultural Development*, McGraw-Hill, Inc.

Olivier Blanchard, 2003, *Macroeconomics*, 3rd Edition, Prentice Hall.

P. N. (Raja) Junankar, 2016, Development Economics: The Role of Agricultural in Development, Palgrave Mcmillian.

Peter G. Helmberger and Jean-Paul Chavas, *The Economics of Agricultural Prices*, Prentice Hall, Inc., 1996.

Peter L. Nuthall, *Farm Business Management: Analysis of Farming System*, CAB International, 2011.

Peter L. Nuthall, *Farm Business Management: The Human factor*, 2nd edition, CAB International, 2019.

Pranav K. Desai, 2010, *Agricultural Economics*, Biotech Books, Delhi-110035.

Robert D. Histrich, Michael P. Peters, and Dean A. Shepherd, *Entrepreneurship*, 7th Edition, McGraw-Hill, International Education, 2008.

Robert S. Pindyck, and Daniel L. Rubinfeld, 2001, *Microeconomics*, 5th Edition, Prentice Hall.

Ronald D. Kay, William M. Edwards and Patricia A. Duffy, *Farm Management*, 9th Edition, McGraw-Hill, Higher Education, 2020.

Sadhu A.N. and Amarjit Signh, 1993, *Fundamentals of Agricultural Economics*,3rd Edition, Himalaya Publishing House.

Saroj Pareek, 2009, *A Text Book of Business Economics*, 1st Edition, Sunrise Publishers & Distributors.

Stephen L. Slavin, *Economics*, 8th Edition, McGraw Hill Irwin.

Stuart R. Lynn, 2003, *Economic Development: Theory and Practice for a Divided World*, Prentice Hall, Pearson Education, Inc.

Thomas H. Naylor, John M. Vernon, and Kenneth L. Wertz, 1983, *Managerial Economics: Corporate Economics and Strategy*, McGraw-Hill.

William G. Tomex and Harry M. Kaiser, *Agricultural Product Prices*, 5th Edition, Cornell University Press, 2014.

Yujiro Haynami and Yoshihisa Godo, 2005, *Development Economics: From the Poverty to the Wealth of Nations*, 3rd Edition, POxford University Press.